ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

GTI GRAND TWINS

# របាយការណ៍ប្រចាំឆ្នាំ

## ក្រុមហ៊ុន ហ្គ្រេន ធ្វីន អ៊ិនធើណេសិនណល (ខេមបូឌា) ភីអិលស៊ី




# ២០១៧

# ទស្សនវិស័យ បេសកកម្ម ភាពខ្លាំង យុទ្ធសាស្ត្រ និងផែនការអនាគត ក្រុមហ៊ុន ប្រហ្គន ធ្វីន

# ក្រុមហ៊ុន ប្រ្លាន ធីន

"ជាក្រុមហ៊ុនឯកជនដំបូងបង្អស់ ដែលចុះបញ្ជីលក់មូលបត្រ
នៅ ផ.ម.ក ក្នុងព្រះរាជាណាចក្រកម្ពុជា"

## ពាក្យស្លោក

*"អ្នកស្លៀកពាក់ ក្រុមហ៊ុនយកចិត្តទុកដាក់"*

*" You Wear, We Care"*

## ទស្សនៈវិស័យ

- ការធ្វើអោយប្រសើរឡើងនូវប្រតិបត្តិការរបស់ក្រុមហ៊ុន
- ការកែលំអគុណភាព
- ការតម្លើងបច្ចេកវិទ្យាថ្មីៗ

## បេសកកម្ម

បំពេញឲ្យបានតាមការរំពឹងទុករបស់អតិថិជនទៅលើគុណភាព ការចែកចាយ និងតម្លៃ តាមរយៈការកែលំអជាលំដាប់ និងអន្តរកម្មដោយផ្ទាល់ជាមួយអតិថិជន។

# ក្រុមហ៊ុន ហ្វ្រេន ធ្វីន

" ជាពោធចក្រផលិតសំលៀកបំពាក់ ឈានមុខគេ

នៅព្រះរាជាណាចក្រកម្ពុជា"

## ភាពខ្លាំងរបស់ក្រុមហ៊ុន ហ្វ្រេន ធ្វីន

- ក្រុមហ៊ុន ហ្វ្រេន ធ្វីន ទទួលបានអត្ថប្រយោជន៍ពីទំនាក់ទំនងយ៉ាងស្អិតរមួតជាមួយនឹងក្រុមហ៊ុន QMI Industrial Co., Ltd ("QMI តៃវ៉ាន់") ។
- ក្រុមហ៊ុន ហ្វ្រេន ធ្វីន ផលិតម៉ាកសំលៀកបំពាក់កីឡាដែលមានកេរ្តិ៍ឈ្មោះល្បីល្បាញទូទាំងពិភពលោក គឺ ម៉ាក Adidas។
- ក្រុមហ៊ុន ហ្វ្រេន ធ្វីន ទទួលបានការអនុគ្រោះពន្ធពីប្រទេសកាណាដា និងសហគមន៍អឺរ៉ុប។
- ក្រុមហ៊ុន ហ្វ្រេន ធ្វីន ទទួលបានទំនុកចិត្តល្អពីបុគ្គលិក។
- ក្រុមហ៊ុន ហ្វ្រេន ធ្វីន មានគណៈគ្រប់គ្រងដែលមានបទពិសោធន៍ខ្ពស់។
- ក្រុមហ៊ុន ហ្វ្រេន ធ្វីន មានពិពិធកម្មទីផ្សារជាលក្ខណៈភូមិសាស្ត្រសម្រាប់ផលិតផលរបស់ខ្លួន
- ក្រុមហ៊ុន ហ្វ្រេន ធ្វីន បានបញ្ចូលបច្ចេកវិទ្យាថ្មីសម្រាប់ផលិតផលរបស់ខ្លួន។

## យុទ្ធសាស្ត្រ និងផែនការអនាគត

- ក្រុមហ៊ុន ហ្វ្រេន ធ្វីន បានវិនិយោគលើបច្ចេកវិទ្យាថ្មីៗ ដែលអនុញ្ញាតឲ្យក្រុមហ៊ុនអាចបន្តផ្គត់ផ្គង់នូវផលិតផលថ្មី និងផលិតផលច្នៃប្រឌិតថ្មី។
- ក្រុមហ៊ុន ហ្វ្រេន ធ្វីន ធានាបាននូវការឆ្លើយតបយ៉ាងឆាប់រហ័សតាមតម្រូវការរបស់អតិថិជន។
- ក្រុមហ៊ុន ហ្វ្រេន ធ្វីន ធានានូវប្រសិទ្ធភាពក្នុងផលិតកម្ម និងចែកចាយ។
- ក្រុមហ៊ុន ហ្វ្រេន ធ្វីន ធានាបាននូវគុណភាពល្អឥតខ្ចោះ។

# ទិន្នន័យ និងសូចនាករសំខាន់ៗ សម្រាប់ ឆ្នាំ២០១៧





# ព័ត៌មានហិរញ្ញវត្ថុសង្ខេបសម្រាប់ ឆ្នាំ២០១៧ និងក្នុងបណ្តាឆ្នាំកន្លងទៅ

| **បរិយាយ** | | **ឆ្នាំ២០១៧** | **ឆ្នាំ២០១៦** | **ឆ្នាំ២០១៥** |
|---|---|---|---|---|
| | | **រៀល '០០០'** | **រៀល '០០០'** | **រៀល '០០០'** |
| **ស្ថានភាពហិរញ្ញវត្ថុ** | | | | |
| ទ្រព្យសកម្មសរុប | | ៣៣៣.១៤០.៤៨០ | ៣៣៣.៣២៨.៣៨៩ | ៣០៤.៨៥០.៩៥២ |
| បំណុលសរុប | | ៥៩.៧៧៦.៥២០ | ៥៩.១៣២.៨០៦ | ៤៨.៨១៦.២០១ |
| មូលធនសរុប | | ២៧៣.៣៦៣.៩៦០ | ២៧៤.១៩៥.៥៨៣ | ២៥៦.០៣៤.៧៥១ |
| | | | | |
| ចំណូលសរុប | | ៣២៣.៩៨៧.៤១៤ | ៣៣១.៤០៧.៣០៥ | ២២៩.៩៣៩.០៦៦ |
| ចំណេញមុនបង់ពន្ធ | | ៤.៧២៩.៥៤៤ | ១៥.៥៥៥.៨២៨ | ៣.១៨៥.១៨៧ |
| ចំណេញសុទ្ធក្រោយបង់ពន្ធ | | ២.៦៧០.០១២ | ២១.១៦២.៦៥២ | ៤.៣២០.៩៩៥ |
| **អនុបាតហិរញ្ញវត្ថុ** | | | | |
| អនុបាតសាធនភាព | | ៨២,០៦% | ៨២,២៦% | ៨៣,៩៩% |
| អនុបាត សន្ទនីយភាព | អនុបាតចរន្ត | ៧,១១ | ៥,៤៨ | ៥,៤៨ |
| | អនុបាតចរន្តលឿន | ៥,៦៥ | ៤,៧៧ | ៤,៥៤ |
| អនុបាត ចំណេញភាព | ផលចំណេញក្នុងមួយឯកតាទ្រព្យសកម្ម | ០,៨០% | ៦,៣៥% | ១,៤២% |
| | ផលចំណេញក្នុងមួយឯកតាមូលធន | ០,៩៨% | ៧,៧២% | ១,៦៩% |
| | គំលាតចំណេញដុល | ៨,៣៨% | ១២,៥០% | ១១,៤១% |
| | គំលាតចំណេញភាព | ០,៨២% | ៦,៣៩% | ១,៨៨% |
| | ចំណេញក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ | ០,០៧ | ០,៥៣ | ០,១១ |
| ភាគលាភក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ (ប្រសិនមាន) | | - | ០,១០ | ០,០៥ |

# ក្រាហ្វិកអំពីលទ្ធផលហិរញ្ញវត្ថុ ឆ្នាំ២០១៧ និងបណ្តាឆ្នាំកន្លងទៅ

**គិតជា ពាន់ រៀល**




**គិតជា ពាន់ រៀល**



## បម្រែបម្រួលតម្លៃ និងទំហំជួញដូរមូលបត្រ នៅត្រីមាសទី១ ឆ្នាំ២០១៧




## បម្រែបម្រួលតម្លៃ និងទំហំជួញដូរមូលបត្រ នៅ ផ.ម.ក នៅត្រីមាសទី២ ឆ្នាំ២០១៧



## បម្រែបម្រួលតម្លៃ និងទំហំជួញដូរមូលបត្រ នៅត្រីមាសទី៣ ឆ្នាំ២០១៧




## បម្រែបម្រួលតម្លៃ និងទំហំជួញដូរមូលបត្រ នៅត្រីមាសទី៤ ឆ្នាំ២០១៧



# ព្រឹត្តិការណ៍សំខាន់ៗ ក្នុងបណ្ដាឆ្នាំកន្លងទៅរបស់ ក្រុមហ៊ុន ប្រហ្តន ធ្វីន

# ឆ្នាំ២០១៥

សិក្ខាសាលា "**សារៈសំខាន់នៃការផ្តល់ព័ត៌មាន និងវេទិកាជួបជាមួយក្រុមហ៊ុនចុះបញ្ជី**" រៀបចំឡើងដោយ ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៥។



**"មហាសន្និបាតភាគហ៊ុនិក លើកទី១ របស់ក្រុមហ៊ុន គ្រេន ធ្វីន"**

បានប្រារព្ធនៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៥។









## "ការបែងចែកភាគលាភជូនភាគហ៊ុនិក របស់ក្រុមហ៊ុន ហ្គ្រេន ធ្វីន"

ក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុនបានសម្រេច និងអនុម័តលើការបែងចែកភាគលាភដល់ភាគហ៊ុនិកដែលកាន់មូលបត្រកម្មសិទ្ធិមានសិទ្ធិបោះឆ្នោតក្នុងក្រុមហ៊ុន **លើកទី១** តាមរយៈសេចក្តី សម្រេច ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៥។ ភាគហ៊ុនិក ទទួលបាន ៖

**១៧៧ រៀល** ក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ

| | |
|---|---|
| ប្រភេទភាគលាភដែលបែងចែក | ជាសាច់ប្រាក់ |
| រយៈពេលភាគលាភ | ប្រចាំឆ្នាំ២០១៤ |
| អនុបាតនៃការបែងចែកភាគលាភ | ៥០% |
| ភាគលាភសរុបដែលបែងចែក | ៧.០៨០.០០០.០០០ រៀល |
| ភាគលាភក្នុងមួយឯកតាមូលបត្រកម្មសិទ្ធ | ១៧៧ រៀល |
| កាលបរិច្ឆេទប្រកាសបញ្ជីឈ្មោះភាគហ៊ុនិកត្រូវទទួលបានភាគលាភ | ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៥ |
| កាលបរិច្ឆេទចាប់ផ្តើមទូទាត់ភាគលាភ | ថ្ងៃទី២២ ខែមិថុនា ឆ្នាំ ២០១៥ |
| បញ្ជីឈ្មោះភាគហ៊ុនិកផ្លូវការដែលទទួលបានភាគលាភ | ថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៥ |
| ការគាំក្នុងការទូទាត់ភាគលាភសម្រាប់ភាគហ៊ុនិក | ថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៥ ដល់ ថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០១៥ |
| ចំនួនភាគហ៊ុនិកសរុបដែលទទួលបានភាគលាភ | ២៥២ នាក់ |
| - ភាគហ៊ុនិក ជានិវាសនជន | ១៤៨ នាក់ |
| - ភាគហ៊ុនិក អនិវាសនជន | ១០៤ នាក់ |

# ឆ្នាំ២០១៦

**"ការបែងចែកភាគលាភជូនភាគហ៊ុនិក របស់ក្រុមហ៊ុន ហ្គ្រេន ធ្វីន"**

ក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុនបានសម្រេច និងអនុម័តលើការបែងចែកភាគលាភដល់ភាគហ៊ុនិកដែលកាន់មូលបត្រកម្មសិទ្ធិមានសិទ្ធិបោះឆ្នោតក្នុងក្រុមហ៊ុន **លើកទី២** តាមរយៈសេចក្តី សម្រេច ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៦។ ភាគហ៊ុនិកម្នាក់ៗ ទទួលបាន ៖

**៥៤ រៀល** ក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ

| | |
|---|---|
| ប្រភេទភាគលាភដែលបែងចែក | ជាសាច់ប្រាក់ |
| រយៈពេលភាគលាភ | ប្រចាំឆ្នាំ២០១៥ |
| អនុបាតនៃការបែងចែកភាគលាភ | ៤៩,៩៩% |
| ភាគលាភសរុបដែលបែងចែក | ២.១៦០.០០០.០០០ រៀល |
| ភាគលាភក្នុងមួយឯកតាមូលបត្រកម្មសិទ្ធ | ៥៤ រៀល |
| កាលបរិច្ឆេទប្រកាសបញ្ជីឈ្មោះភាគហ៊ុនិកត្រូវទទួលបានភាគលាភ | ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៦ |
| កាលបរិច្ឆេទចាប់ផ្តើមទូទាត់ភាគលាភ | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ ២០១៦ |
| បញ្ជីឈ្មោះភាគហ៊ុនិកផ្លូវការដែលទទួលបានភាគលាភ | ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៦ |
| ការគាំក្នុងការទូទាត់ភាគលាភសម្រាប់ភាគហ៊ុនិក | ថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០១៦ ដល់<br>ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៦ |
| ចំនួនភាគហ៊ុនិកសរុបដែលទទួលបានភាគលាភ | ២៩៤ នាក់ |
| ភាគហ៊ុនិក ជានិវាសនជន | ១៣២ នាក់ |
| ភាគហ៊ុនិក អនិវាសនជន | ១៦២នាក់ |

## ថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៦
## ពិព័រណ៍ភាគហ៊ុនកម្ពុជា រៀបចំដោយក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា។









## ថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៦
## "មហាសន្និបាតភាគហ៊ុនិក លើកទី២ របស់ក្រុមហ៊ុន ហ្គ្រេន ធ្វីន"









# ឆ្នាំ២០១៧

## ពិព័រណ៍ភាគហ៊ុនកម្ពុជាដែលរៀបចំឡើងដោយផ្សារមូលបត្រកម្ពុជា










## ខែមិថុនា

ក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុនបានសម្រេច និងអនុម័តលើការបែងចែកភាគលាភដល់ភាគហ៊ុនិកដែលកាន់មូលបត្រកម្មសិទ្ធិមានសិទ្ធិបោះឆ្នោតក្នុងក្រុមហ៊ុន **លើកទី៣** តាមរយៈសេចក្តី សម្រេច ចុះកាលបរិច្ឆេទថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៧។ ភាគហ៊ុនិកម្នាក់ៗ ទទួលបាន ៖

**១០០ រៀល** ក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ

| | |
|---|---|
| ប្រភេទភាគលាភដែលបែងចែក | ជាសាច់ប្រាក់ |
| រយៈពេលភាគលាភ | ប្រចាំឆ្នាំ២០១៦ |
| អនុបាតនៃការបែងចែកភាគលាភ | ១៨,៩០% |
| ភាគលាភសរុបដែលបែងចែក | ៤.០០០.០០០.០០០ រៀល |
| ភាគលាភក្នុងមួយឯកតាមូលបត្រកម្មសិទ្ធ | ១០០ រៀល |
| កាលបរិច្ឆេទប្រកាសបញ្ជីឈ្មោះភាគហ៊ុនិកត្រូវទទួលបានភាគលាភ | ថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០១៧ |
| កាលបរិច្ឆេទចាប់ផ្តើមទូទាត់ភាគលាភ | ថ្ងៃទី១៤ ខែកក្កដា ឆ្នាំ ២០១៧ |
| បញ្ជីឈ្មោះភាគហ៊ុនិកផ្លូវការដែលទទួលបានភាគលាភ | ថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៧ |
| ការតវ៉ាក្នុងការទូទាត់ភាគលាភសម្រាប់ភាគហ៊ុនិក | ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៧ ដល់<br>ថ្ងៃទី០២ ខែសីហា ឆ្នាំ២០១៧ |
| ចំនួនភាគហ៊ុនិកសរុបដែលទទួលបានភាគលាភ | ២៨០ នាក់ |
| - ភាគហ៊ុនិក និវាសនជន | ៩៨ នាក់ |
| - ភាគហ៊ុនិក អនិវាសនជន | ១៨២ នាក់ |

## ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៧

## ការចុះត្រួតពិនិត្យអភិបាលកិច្ចសាជីវកម្មរបស់ក្រុមហ៊ុន ហ្គ្រេន ធ្វីន ដោយគណៈកម្មការមូលបត្រកម្ពុជា នៅរោងចក្រផ្ទាល់









# មហាសន្និបាតភាគហ៊ុនិក លើកទី ៣
# ប្រព្រឹត្តិទៅកាលពី ថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ២០១៧











# ក្រុមហ៊ុន គ្រេន្ត ធ្វីន ទទួលបាន
# វិញ្ញាបនបត្រអនុលោមភាពសារពើពន្ធកម្រិត

# មាស

## កាលពី ថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០១៧
## ពី អគ្គនាយកដ្ឋានពន្ធដារ


ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA
ជាតិ សាសនា ព្រះមហាក្សត្រ
NATION RELIGION KING

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
MINISTRY OF ECONOMY AND FINANCE
អគ្គនាយកដ្ឋានពន្ធដារ
GENERAL DEPARTMENT OF TAXATION

Phnom Penh, 18 November 2017

អគ្គនាយកដ្ឋានពន្ធដារ
GENERAL DEPARTMENT OF TAXATION
វិញ្ញាបនបត្រ
អនុលោមភាពសារពើពន្ធ

CERTIFICATE OF TAX COMPLIANCE
(Prakas No 1536 MEF/PK dated 23rd December 2016)

GENERAL DEPARTMENT OF TAXATION certifies that :
Company's name : GRAND TWINS INTERNATIONAL (CAMBODIA) PLC.
Tax Identification Number (TIN) : L001-100133479
Under : Department of large Taxpayers
Date of Information Update : 04 December 2015
Business activity(ies) : Garment factory
Tax Compliance Type awarded : GOLD
Validity period of **2 years** from the tax year **2017** to tax year **2018**

... Government in charge as Director
... General Department of Taxation

# ក្រុមហ៊ុន ប្រេនែន ធ្វីន
# អ៊ិនធើណេសិនណល (ខេមបូឌា)
# ភីអិលស៊ី










ឈ្មោះ **យ៉ាង សាវស៊ីន**

**ប្រធានក្រុមប្រឹក្សាភិបាល**



ឈ្មោះ Liao Chung-Te

តំណែង **អភិបាលប្រតិបត្តិ**



ឈ្មោះ **លី យុនថៃ**

តំណែង **អភិបាលឯករាជ្យ**



ឈ្មោះ Chen Tsung-Chi

តំណែង **អភិបាលមិនប្រតិបត្តិ**



ឈ្មោះ Wang Yi Ting

តំណែង **អភិបាលមិនប្រតិបត្តិ**

# សេចក្តីថ្លែងរបស់ ប្រធានក្រុមប្រឹក្សាភិបាល និង របាយការណ៍ អភិបាល ស្តីពីការវាយតម្លៃស្ថានភាព ក្រុមហ៊ុន ហ្គ្រេន ធ្វីន

# សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាអភិបាល



លោក **យ៉ាង សាវស៊ីន**
ប្រធានក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន ប្រេ្គន ធ្វីន មានសេចក្តីសោមនស្ស សូមបង្ហាញជូនរបាយការណ៍ហិរញ្ញវត្ថុសម្រាប់ដំណាច់ការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ ដែលបានធ្វើសវនកម្មរួចរបស់ក្រុមហ៊ុន ប្រេ្គន ធ្វីន អ៊ិនធើណេសិនណល (ខេមបូឌា) ភីអិលស៊ី (ហៅកាត់ថា "ក្រុមហ៊ុន **ប្រេ្គន ធ្វីន**")។ ក្រុមហ៊ុន ប្រេ្គន ធ្វីន ទទួលបានចំណូលសរុបចំនួន ៣២៣.៩៨៧ លាន រៀល (៨០,០៩៦ លាន ដុល្លារអាមេរិក) ចំណេញមុនបង់ពន្ធលើប្រាក់ចំណេញចំនួន ៤.៧៣០ លាន រៀល (១,១៦៩ លាន ដុល្លារអាមេរិក) និងប្រាក់ចំណេញក្នុងការិយបរិច្ឆេទ ចំនួន ២.៦៧០ លាន រៀល (៦៦០.០៧៧ ដុល្លារ អាមេរិក។

## ប្រសិទ្ធភាពក្នុងការផ្តល់សេវាកម្មជូនអតិថិជន

ចាប់តាំងពីបង្កើតក្រុមហ៊ុននៅឆ្នាំ២០០៧ ក្រុមហ៊ុន ប្រេ្គន ធ្វីន អ៊ិនធើណេសិនណល ភីអិលស៊ី បានបង្កើត និងពង្រីកផលិតផលរបស់ខ្លួនតាមតម្រូវការរបស់អតិថិជន ហើយដែលអាចចាត់ទុកថា ជារោងចក្រកាត់ដេរមួយដែលឈានមុខគេនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ក្រុមហ៊ុន ប្រេ្គន ធ្វីន ជឿជាក់ ទៅលើសមត្ថភាពក្នុងការបង្កើត អភិវឌ្ឍ និងចែកចាយផលិតផលទៅអតិថិជនរបស់ខ្លួននៅជុំវិញពិភពលោក។

ក្រុមប្រឹក្សាភិបាលនៅតែខិតខំប្រឹងប្រែងរក្សាទំនាក់ទំនងយ៉ាងល្អជាមួយអតិថិជនរបស់ខ្លួន ជាពិសេស អតិថិជនចម្បង គឺ Adidas ក្នុងគោលបំណងទទួលបានការកើនឡើងនៃការបញ្ជាទិញសម្រាប់ ឆ្នាំ២០១៧ និងព្យាយាមក្នុងការសហការជាមួយដៃគូនានា ដើម្បីទទួលបានចំណូលផ្សេងៗទៀត ដូចជា តាមរយៈការទទួលដេរបន្ត ការកាត់ ដេរ និងវេចខ្ចប់ ដើម្បីរក្សាស្ថេរភាព និងបង្កើនចំណូលឲ្យបានច្រើនជាងបណ្តាឆ្នាំកន្លងទៅសម្រាប់ក្រុមហ៊ុន។

## សន្ទុះហិរញ្ញវត្ថុសម្រាប់ឆ្នាំ២០១៧

ក្នុងឆ្នាំ២០១៧ ក្រុមហ៊ុន ប្រេ្គន ធ្វីន ទទួលបានចំណូលសរុបចំនួន ៣២៣.៩៨៧ លាន រៀល (៨០,០៩៦ លាន ដុល្លារអាមេរិក) ចំណេញមុនបង់ពន្ធលើប្រាក់ចំណេញចំនួន ៤.៧៣០ លាន រៀល (១,១៦៩ លាន ដុល្លារអាមេរិក) និងប្រាក់ចំណេញក្នុងការិយបរិច្ឆេទ ចំនួន ២.៦៧០ លាន រៀល (៦៦០.០៧៧ ដុល្លារអាមេរិក)។ សម្រាប់ឆ្នាំ២០១៧ នេះ ក្រុមហ៊ុន ប្រេ្គន ធ្វីន ទទួលបានចំណូលសរុប ចំនួន ៣២៣.៩៨៧ លាន រៀល (៨០,០៩៦ លាន ដុល្លារអាមេរិក) ដែលក្នុងនោះចំណូលបានពីការលក់ទំនិញ ទទួលបានចំនួន ៣៣៨.៥៨៥ លាន រៀល (៨៣,៧០៥ លាន ដុល្លារអាមេរិក) និងចំណូលបានពីការកាត់ ដេរ និងវេចខ្ចប់ ទទួលបានចំនួន ៦.២១២ លាន រៀល (១,៥៣៦ លាន ដុល្លារអាមេរិក)។ ដោយឡែក ក្រុមហ៊ុនមិនមានចំណូលទទួលបានពីការម៉ៅការឡើយ។

ចំណូលសរុបនៅឆ្នាំ២០១៧ មានការថយចុះតិចតួចជាងបណ្តាឆ្នាំកន្លងទៅ ពោលគឺ ឆ្នាំ២០១៥ និង២០១៦ ទោះបីជាប្រាក់បៀវត្សរ៍ជាមធ្យមរបស់ពលកររោងចក្រកាត់ដេរបានកើនឡើងជាលំដាប់ក្នុងវិស័យកាត់ដេរ និងការលក់បញ្ចុះ

តម្លៃទំនិញជូនអតិថិជន ប្រមាណ ២០.៨០៩ លាន រៀល (៥,១៤៤ លាន ដុល្លារអាមេរិក) ដែលបានប៉ះពាល់ដល់ចំណូលរបស់ក្រុមហ៊ុន ហ្គ្រេន ធ្វីន។ ជាក់ស្តែងចំណូលសរុប គិតត្រឹមការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ ចំណូលមានការកើនឡើង ដែលអត្រាកើនឡើង គឺ ៤៤,១៣% ធៀបនឹងចំណូលសរុបឆ្នាំ២០១៥ ដែលលនេះជាសញ្ញាណវិជ្ជមានមួយសម្រាប់ក្រុមហ៊ុន។ ដោយឡែកសម្រាប់ឆ្នាំ២០១៧ នេះ ចំណូលមានការថយចុះ ដែលអត្រាថយចុះ គឺ ២,២៤% ធៀបនឹងចំណូលសរុបឆ្នាំ២០១៦ ដែលការថយចុះនេះគឺតិចតួច តែក្រុមប្រឹក្សាភិបាលនៅតែខិតខំប្រឹងប្រែងរក្សាទំនាក់ទំនង យ៉ាងល្អជាមួយអតិថិជនរបស់ខ្លួន ជាពិសេស អតិថិជនចម្បង គឺ Adidas ក្នុងគោលបំណងទទួលបានការកើនឡើងនៃការបញ្ជាទិញសម្រាប់ឆ្នាំ២០១៨ និងឆ្នាំបន្ទាប់ និងព្យាយាមក្នុងការសហការជាមួយដៃគូនានាដើម្បីទទួលបានចំណូល ផ្សេងៗទៀត ដូចជា តាមរយៈការទទួលដេរបន្ត ការកាត់ ដេរ និង វេចខ្ចប់ ដើម្បីរក្សាស្ថេរភាព និងបង្កើនចំណូលឲ្យបានច្រើនជាងបណ្តាឆ្នាំកន្លងទៅសម្រាប់ក្រុមហ៊ុន។

## សមិទ្ធិផលសម្រេចបានសម្រាប់ឆ្នាំ២០១៧

ក្រុមហ៊ុន ហ្គ្រេន ធ្វីន បានដាក់ឲ្យប្រើប្រាស់អគារនោះនៅត្រីមាសទី៣ ឆ្នាំ២០១៥ ដែលមានកម្ពស់ ៣ជាន់ នៅក្នុងបរិវេណរោងចក្រ ដែលចំណាយទឹកប្រាក់ប្រមាណ ១៩.០០០ លាន រៀល (៤.៧៥០ លាន ដុល្លារអាមេរិក)។ ដើម្បីឆ្លើយតបទៅនឹងការពង្រីកខ្សែសង្វាក់ផលិតកម្ម និងការរីកចំរើនធុរកិច្ចរបស់ក្រុមហ៊ុន ហ្គ្រេន ធ្វីន។ អគារថ្មីនេះ បានប្រើប្រាស់សម្រាប់រក្សាទុកវត្ថុធាតុដើមសម្រាប់ផលិតសំលៀកបំពាក់។ លើសពីនេះ ក្រុមហ៊ុន ហ្គ្រេន ធ្វីន ប្រើប្រាស់សាច់ប្រាក់មួយចំនួនសម្រាប់ពង្រីកសមត្ថភាពផលិតកម្ម ជាពិសេសការតម្លើងខ្សែសង្វាក់ផលិតកម្មចំនួន ២០ខ្សែ បន្ថែមសម្រាប់ផលិតសំលៀកបំពាក់ និងគ្រោងនឹងជ្រើសរើស បុគ្គលិកបន្ថែមប្រមាណ ៨០០ នាក់ នៅក្រោយពេលដាក់ឲ្យប្រើប្រាស់អគារថ្មីនេះ។ ទឹកប្រាក់ដែលទទួលបានពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិលើកដំបូងជាសាធារណៈ ត្រូវបានយកមកប្រើប្រាស់សម្រាប់គោលបំណងខាងលើនេះ។ ជាក់ស្តែង ក្រុមហ៊ុនទទួលបានផលជាវិជ្ជមានពីការពង្រីកខ្សែសង្វាក់ផលិតកម្មនេះ តាមរយៈកំណើននៃចំណូលសរុបឆ្នាំ២០១៧ នេះ។

ក្រុមហ៊ុន ហ្គ្រេន ធ្វីន នៅតែបន្តកិច្ចប្រឹងប្រែងរៀបចំ និងកែលម្អអគារដែលមានស្រាប់ និងអគារថ្មី ដើម្បីឆ្លើយតបតាមស្តង់ដារអន្តរជាតិ ក្នុងគោលបំណងពង្រីកខ្សែសង្វាក់ផលិតកម្ម និងការរីកចំរើនធុរកិច្ចរបស់ក្រុមហ៊ុន ហ្គ្រេន ធ្វីន និងដើម្បីទទួលបានការបញ្ជាទិញបន្ថែមទៀតពីអតិថិជន។

លើសពីនេះទៅទៀត នៅខែវិច្ឆិកា ឆ្នាំ២០១៦ ក្រុមហ៊ុន ហ្គ្រេន ធ្វីន ទទួលបានសមិទ្ធិផលសម្រេចប្រកបដោយប្រសិទ្ធិភាពខ្ពស់ ដែលក្រុមហ៊ុនបានរំពឹងទុកសម្រាប់ប្រតិបត្តិការរបស់ខ្លួន តាមរយៈការទទួលបានការវាយតម្លៃជាវិជ្ជមានលើការបំពេញកាតព្វកិច្ចត្រឹមត្រូវតាមច្បាប់សម្រាប់សង្គម (Social Compliance: Key Performance Indicators "KPI") ពីអតិថិជនចម្បងរបស់ ក្រុមហ៊ុន គឺ Adidas Group ពោលគឺ ទទួលបានពិន្ទុចំនួន ៧២,៦៣% ប្រសើរជាងឆ្នាំកន្លងទៅទទួលបានត្រឹមតែចំនួន ៥៧,៤២% ប៉ុណ្ណោះ។ ការវាយតម្លៃនេះ រួមមាន ការវាយតម្លៃលើការគ្រប់គ្រង និងទំនួលខុសត្រូវរបស់គណៈគ្រប់គ្រង ប្រព័ន្ធគ្រប់គ្រងក្រុមហ៊ុន ទំនាក់ទំនង និងកិច្ចសហការល្អប្រសើរជាមួយអតិថិជន ការបំពេញកាតព្វកិច្ចត្រឹមត្រូវក្នុងការផ្តល់វគ្គបណ្តុះបណ្តាល និងគ្រប់គ្រង ទំនាក់ទនង និងការបង្ហាញព័ត៌មានប្រកបដោយតម្លាភាព និងប្រសិទ្ធិភាព និងភាពជាអ្នកដឹកនាំ ជាដើម។

ដោយឡែក នៅឆ្នាំ២០១៧ កន្លងទៅ ក្រុមហ៊ុន ហ្គ្រេន ធ្វីន បានបែងចែកភាគលាភដល់ភាគហ៊ុនិករបស់ខ្លួន ជា

លើកទី៣ បន្ទាប់ពីក្រុមហ៊ុនបានបោះផ្សាយ និងចុះបញ្ជីលក់មូលបត្រជាផ្លូវការនៅ ផ.ម.ក។ ទឹកប្រាក់ ១៨,៩០% នៃប្រាក់ចំណេញក្រោយបង់ពន្ធនៅដំណាច់ការិយបរិច្ឆេទឆ្នាំ២០១៦ ត្រូវបានយកមកបែងចែកជាភាគលាភដល់ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតរបស់ក្រុមហ៊ុន ដែលភាគហ៊ុនិកម្នាក់ៗទទួលបាន ១០០ រៀល ក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ។ សម្រាប់ឆ្នាំ២០១៧ នេះ ទោះបីជាក្រុមហ៊ុន ហ្គ្រេន ធ្វីន ទទួលបានលទ្ធផលជាវិជ្ជមានតិចតួចពីប្រតិបត្តិការធុរកិច្ចរបស់ខ្លួនក្តី ក៏ក្រុមហ៊ុនគ្រោងនឹងបែងចែកភាគលាភជូនភាគហ៊ុនិក អាចជាសាច់ប្រាក់ ឬ/និងជាមូលបត្រ។ ក្រុមហ៊ុននឹងធ្វើការជូនដំណឹងពីការបែងចែកភាគលាភ បន្ទាប់ពីក្រុមប្រឹក្សាភិបាលសម្រេច និងអនុម័តលើការបែងចែកនេះ។

គិតត្រឹមការិយបរិច្ឆេទឆ្នាំ២០១៧ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ ក្រុមហ៊ុន ហ្គ្រេន ធ្វីន បានរៀបចំមហាសន្និបាតភាគហ៊ុនិក លើកទី៣ ដែលប្រព្រឹត្តិទៅកាលពីថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៧ កន្លងទៅ បន្ទាប់ពីក្រុមហ៊ុនបានបោះផ្សាយ និងចុះបញ្ជីលក់មូលបត្រជាផ្លូវការនៅ ផ.ម.ក។ ក្រុមប្រឹក្សាភិបាលថ្មី អាណត្តិទី៣ នឹងត្រូវបោះឆ្នោត និងជ្រើសតាំង ដោយភាគហ៊ុនិក សម្រាប់អាណត្តិ ៣ ឆ្នាំ ហើយអភិបាលទាំងអស់ រួមមាន ប្រធានក្រុមប្រឹក្សាភិបាល អភិបាលឯករាជ្យ អភិបាលប្រតិបត្តិ/មិនប្រតិបត្តិ។ ក្រុមហ៊ុន នឹងធ្វើការជូនដំណឹងបន្ទាប់ពីក្រុមប្រឹក្សាភិបាលសម្រេច និងអនុម័តលើកាលបរិច្ឆេទនេះ រួមទាំង កាលបរិច្ឆេទនៃមហាសន្និបាតភាគហ៊ុនិក លើកទី៤ ផងដែរ។

លើសពីនេះ នៅចុងត្រីមាសទី ៤ ឆ្នាំ២០១៧ នេះ ក្រុមហ៊ុនបាន ចំណាយមូលធនប្រមាណ ៤.៩០៩.៧៨០ ដុល្លារអាមេរិក សម្រាប់ការសាងសង់ការិយាល័យស្រាវជ្រាវ និងមជ្ឈមណ្ឌល ទទួលបញ្ជាទិញពីអតិថិជនដោយផ្ទាល់ ផងដែរ។

## ការរំពឹងទុកសម្រាប់ត្រីមាសនានា ឆ្នាំ២០១៨

ចំពោះត្រីមាសបន្ទាប់ ឆ្នាំ២០១៨ ក្រុមហ៊ុន ហ្គ្រេន ធ្វីន នឹងខិតខំប្រឹងប្រែងបន្ថែមទៀត ដើម្បីធ្វើឲ្យកាន់តែប្រសើរឡើង ក្នុងពង្រឹងអភិបាលកិច្ចសាជីវកម្មល្អរបស់ក្រុមហ៊ុន ហើយនៅតែប្រកាន់ខ្ជាប់នូវទស្សនវិស័យ និងបេសកកម្មដែលបានកំណត់ពីឆ្នាំមុនៗ។ ជាទិសដៅសម្រាប់ត្រីមាសបន្ទាប់ ឆ្នាំ២០១៨ ក្រុមហ៊ុន ហ្គ្រេន ធ្វីន អ៊ិនធើណេសិនណល (ខេមបូឌា) ភីអិលស៊ី សង្ឃឹមថានឹងទទួលបានប្រាក់ចំណេញល្អប្រសើរជាង ឆ្នាំ២០១៧ កន្លងទៅ។

## សេចក្តីថ្លែងអំណរគុណ

ជាថ្មីម្តងទៀត ក្រុមហ៊ុន ហ្គ្រេន ធ្វីន មានសេចក្តីសោមនស្សរីករាយ សូមសម្តែងការអរគុណដល់ក្រុមប្រឹក្សាភិបាល គណៈគ្រប់គ្រង បុគ្គលិកគ្រប់ជាន់ថ្នាក់ កម្មករនិយោជិក ចំពោះការគាំទ្រ និងការដឹកនាំល្អសម្រាប់ប្រតិបត្តិការនាត្រីមាសកន្លងទៅ និងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការគាំទ្រពីអតិថិជនទាំងអស់ ជាពិសេសអតិថិជនចម្បងរបស់ក្រុមហ៊ុន ដែលបន្ត និងបន្ថែមការបញ្ជាទិញផលិតផល ដែលធ្វើឲ្យក្រុមហ៊ុន ហ្គ្រេន ធ្វីន បានទទួលបានជោគជ័យរហូតមកដល់សព្វថ្ងៃនេះ។

រាជធានីភ្នំពេញ កាលបរិច្ឆេទ : ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៨

ហត្ថលេខា ត្រា និងឈ្មោះប្រធានក្រុមប្រឹក្សាភិបាល



លោក **យ៉ាង សាវស៊ីន**

# របាយការណ៍របស់អភិបាលស្តីពីការវាយតម្លៃស្ថានភាពរបស់ក្រុមហ៊ុន ហ្គ្រេន ធ្វីន

ក្រុមប្រឹក្សាភិបាល សូមដាក់ជូននូវរបាយការណ៍ប្រចាំឆ្នាំរបស់ខ្លួន ព្រមទាំងរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួចរបស់ក្រុមហ៊ុន ហ្គ្រេន ធ្វីន អ៊ិនធើណេសិនណល (ខេមបូឌា) ភីអិលស៊ី ហៅកាត់ថា ("ក្រុមហ៊ុន") សម្រាប់ការិយបរិច្ឆេទគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧។

## ក្រុមហ៊ុន

ក្រុមហ៊ុន ហ្គ្រេន ធ្វីន អ៊ិនធើណេសិនណល (ខេមបូឌា) ភីអិលស៊ី ហៅកាត់ថា ("ក្រុមហ៊ុន") បានចុះបញ្ជីពាណិជ្ជកម្មនៅថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៧ ជាក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

នៅថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១៣ ក្រុមហ៊ុនបានធ្វើវិសោធនកម្មទៅលើការចុះបញ្ជីពាណិជ្ជកម្ម ដើម្បីផ្លាស់ប្តូរទៅជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត។ ដូច្នេះក្រុមហ៊ុនត្រូវបានចុះបញ្ជីនៅលើផ្សារមូលប័ត្រកម្ពុជានៅថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៤។

ទីស្នាក់ការ និងទីតាំងអាជីវកម្មរបស់ក្រុមហ៊ុនស្ថិតនៅ ភូមិត្រពាំងពោធិ៍ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

ក្រុមហ៊ុន មានក្រុមហ៊ុនមេសម្ព័ន្ធអន្តរការី គឺ ហ្គ្រេន ធ្វីន អ៊ិនធើណេសិនណល អិលធីឌី ជាក្រុមហ៊ុនបានចុះបញ្ជីពាណិជ្ជកម្មនៅ British Virgin Islands ខណៈដែលក្រុមហ៊ុនមេសម្ព័ន្ធគឺ យូអឹមអាយ អ៊ីនដាស្ទ្រៀល ខូអិលធីឌី ជា ក្រុមហ៊ុនបានចុះបញ្ជីពាណិជ្ជកម្មនៅតៃវ៉ាន់។

## សកម្មភាពចម្បង

សកម្មភាពចម្បងរបស់ក្រុមហ៊ុន គឺ ការផលិតសំលៀកបំពាក់។ ពុំមានការផ្លាស់ប្តូរជាសារវន្តសម្រាប់សកម្មភាពចម្បងរបស់ក្រុមហ៊ុនក្នុងការិយបរិច្ឆេទនេះទេ។

## លទ្ធផលនៃប្រតិបត្តិការ

លទ្ធផលនៃប្រតិបត្តិការ និងស្ថានភាព របស់ក្រុមហ៊ុន សម្រាប់ចុងការិយបរិច្ឆេទត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ ត្រូវបានកំណត់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុអមនៅលើទំព័រ ១១ ទៅ ៤៣។

## ភាគលាភ

នៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៧ ក្រុមប្រឹក្សាភិបាលបានអនុម័តការប្រកាសភាគលាភ សម្រាប់ការិយបរិច្ឆេទ ៣១ ធ្នូ ២០១៦ ដែលមានចំនួន ១០០ រៀល ក្នុងមួយហ៊ុន ដែលស្មើនឹងភាគលាភសរុបចំនួន ៤.០០០ លាន រៀល។ ភាគលាភត្រូវបានទូទាត់ជាបន្តបន្ទាប់នៅថ្ងៃទី១៤ ខែកក្កដា ឆ្នាំ ២០១៧ ។

នាកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំទាន់បានធ្វើសេចក្ដីសម្រេចលើការទូទាត់ភាគលាភ សម្រាប់ចុងការិយបរិច្ឆេទ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ នៅឡើយទេ។

## សមាជិកក្រុមប្រឹក្សាភិបាល

សមាជិកនៃក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុននៅក្នុងឆ្នាំ និងនាកាលបរិច្ឆេទនៃការរបាយការណ៍នេះ មានដូចខាងក្រោម៖

| **ឈ្មោះ** | **មុខតំណែង** |
|---|---|
| លោក យ៉ាង សាវស៊ីន | ប្រធានក្រុមប្រឹក្សាភិបាល |
| ឧកញ៉ា លី យុនថៃ | អភិបាលឯករាជ្យ |
| លោក Liao Chung-Te | អភិបាលប្រតិបត្តិ/ នាយកប្រតិបត្តិ |
| លោកស្រី Wang Yi Ting | អភិបាលមិនប្រតិបត្តិ |
| លោក Chen Tsung-Chi | អភិបាលមិនប្រតិបត្តិ |

## សវនករ

របាយការណ៍ហិរញ្ញវត្ថុសម្រាប់ចុងការិយបរិច្ឆេទត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ បានធ្វើសវនកម្មដោយក្រុមហ៊ុន ប្រូ្គន សនថុន ខេមបូឌា លីមីតធីត។

## ភាគកម្មរបស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាល ដែលបម្រើការនាកាលបរិច្ឆេទ និងមានភាគហ៊ុននៅក្នុងក្រុមហ៊ុនមានដូចខាងក្រោម៖

| | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ | |
|---|---|---|---|---|
| | ចំនួនភាគហ៊ុន | ភាគរយកាន់កាប់ | ចំនួនភាគហ៊ុន | ភាគរយកាន់កាប់ |
| លោក យ៉ាង សាវស៊ីន | ១.៥៦០.០០០ | ៣.៩០% | ១.៥៦០.០០០ | ៣.៩០% |
| ឧកញ៉ា លី យុនថៃ | ២៨០.០០០ | ០.៧០% | ២៨០.០០០ | ០.៧០% |
| លោក Liao Chung-Te | ៣១៥.៦១៦ | ០.៧៩% | ២៤០.០០០ | ០.៦០% |
| លោក Chen Tsung-Chi | ១២០.០០០ | ០.៣០% | ១២០.០០០ | ០.៣០% |

## ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាល មានការទទួលខុសត្រូវក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុទាំងនេះដើម្បីបង្ហាញពីទិដ្ឋភាពពិត និងត្រឹមត្រូវសម្រាប់ការិយបរិច្ឆេទគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ ព្រមទាំងលទ្ធផលនៃប្រតិបត្តិការអាជីវកម្ម និងស្ថានភាពលំហូរសាច់ប្រាក់របស់ក្រុមហ៊ុន សម្រាប់ការិយបរិច្ឆេទនេះ។ ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះក្រុមប្រឹក្សាភិបាលតម្រូវអោយ៖

ក. ជ្រើសរើសគោលនយោបាយគណនេយ្យ ក្នុងការអនុលោមតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ("CIFRSs") ឲ្យបានសមស្រប ដោយផ្អែកលើការវិនិច្ឆ័យ និងការប៉ាន់ស្មានសមហេតុផល និងប្រុងប្រយ័ត្ន ហើយបន្ទាប់មកធ្វើការអនុវត្តគោលនយោបាយទាំងនេះអោយមានសង្គតិភាព។

ខ. អនុលោមតាមគោលការណ៍ស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ហើយប្រសិនបើមានការប្រាសចាកណាមួយពីស្តង់ដារទាំងនេះក្នុងការបង្ហាញនូវទិដ្ឋភាពពិត និងត្រឹមត្រូវ ក្រុមប្រឹក្សាភិបាល ត្រូវប្រាកដថាការប្រាសចាកទាំងនេះត្រូវបានលាតត្រដាង ពន្យល់ និងកំណត់បរិមាណអោយបានត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

គ. ធានាអោយបាននូវភាពគ្រប់គ្រាន់នៃការកត់ត្រាគណនេយ្យ និងប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងអោយមានប្រសិទ្ធិភាព។

ឃ. រៀបចំរបាយការណ៍ហិរញ្ញវត្ថុ ដោយផ្អែកលើមូលដ្ឋាននិរន្តរភាពនៃដំណើរការអាជីវកម្ម លើកលែងតែក្នុងករណីមិនសមរម្យក្នុងការសន្មតថា ក្រុមហ៊ុននឹងបន្តធ្វើប្រតិបត្តិការអាជីវកម្មរបស់ខ្លួននាពេលអនាគត និង

ង. ត្រួតពិនិត្យ និងដឹកនាំក្រុមហ៊ុនអោយមានប្រសិទ្ធិភាពលើរាល់សេចក្តីសម្រេចចិត្តសំខាន់ៗដែលប៉ះពាល់ដល់ប្រតិបត្តិការ និងដំណើរការរបស់ក្រុមហ៊ុន ហើយត្រូវប្រាកដថាកិច្ចការទាំងនេះត្រូវបានបង្ហាញត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

ក្រុមប្រឹក្សាភិបាល ក៏ជាអ្នកទទួលខុសត្រូវក្នុងការថែរក្សាទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន ហើយក៏ត្រូវចាត់វិធានការឲ្យសមស្របដើម្បីទប់ស្កាត់ និងរកឲ្យឃើញការក្លែងបន្លំ និងភាពមិនប្រក្រតីផ្សេងៗ។

ក្រុមប្រឹក្សាភិបាលអះអាងថាក្រុមហ៊ុន បានអនុវត្តតាមរាល់តម្រូវការខាងលើក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ។

## របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

តាមមតិយោបល់របស់ក្រុមប្រឹក្សាភិបាល របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ អមដោយរបាយការណ៍ចំណូលពេញលេញ របាយការណ៍បម្រែបម្រួលមូលធន និងរបាយការណ៍លំហូរសាច់ប្រាក់ និងការភ្ជាប់ជាមួយកំណត់សម្គាល់នានា ត្រូវបានផ្តល់នូវទិដ្ឋភាពពិត និងត្រឹមត្រូវ ពីស្ថានភាពហិរញ្ញវត្ថុ ប្រតិបត្តិការអាជីវកម្ម និងស្ថានភាពលំហូរសាច់ប្រាក់របស់ក្រុមហ៊ុន នាកាលបរិច្ឆេទត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ ដោយអនុលោមតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា។

ចុះហត្ថលេខាក្នុងនាមក្រុមប្រឹក្សាភិបាល

KINGDOM OF CAMBODIA
GRAND TWINS INTERNATIONAL (CAMBODIA) PLC.

លោក Liao Chung-Te
នាយកប្រតិបត្តិ

លោក Chen Tsung-Chi
អភិបាល និងនាយកផ្នែកហិរញ្ញវត្ថុ

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៨

# សេចក្តីថ្លែងរបស់នាយកប្រតិបត្តិ ក្រុមហ៊ុន ប្រេ្តាន ធ្វីន

# សេចក្តីថ្លែងរបស់នាយកប្រតិបត្តិ ក្រុមហ៊ុន ហ្គ្រេន ធ្វីន



លោក **Liao Chung-Te**
នាយកប្រតិបត្តិ

តាងនាម ក្រុមហ៊ុន ហ្គ្រេន ធ្វីន អ៊ិនធើណេសិនណល (ខេមបូឌា) ភីអិលស៊ី (ក្រុមហ៊ុន **ហ្គ្រេន ធ្វីន**) ខ្ញុំមានកិត្តិយស និងក្តីសោមនស្សរីករាយក្នុងការបង្ហាញជូនរបាយការណ៍ហិរញ្ញវត្ថុ សម្រាប់ដំណាច់ការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ ដែលបានធ្វើសវនកម្មរួច របស់ក្រុមហ៊ុន ហ្គ្រេន ធ្វីន អ៊ិនធើណេសិនណល (ខេមបូឌា) ភីអិលស៊ី។ ក្រុមហ៊ុន ហ្គ្រេន ធ្វីន ទទួលបានចំណូលសរុបចំនួន ចំនួន ៣២៣.៩៨៧ លាន រៀល (៨០,០៩៦ លាន ដុល្លារអាមេរិក) ចំណេញមុនបង់ពន្ធលើប្រាក់ចំណេញ ចំនួន ៤.៧៣០ លាន រៀល (១,១៦៩ លាន ដុល្លារអាមេរិក) និងប្រាក់ចំណេញក្នុងការិយបរិច្ឆេទ ចំនួន ២.៦៧០ លាន រៀល (៦៦០.០៧៧ ដុល្លារ អាមេរិក។

## សកម្មភាពសំខាន់ៗក្នុងឆ្នាំ២០១៧ និង ក្នុងបណ្តាឆ្នាំកន្លងទៅ




## សមិទ្ធិផលសំខាន់ៗក្នុងឆ្នាំ២០១៧

សម្រាប់ឆ្នាំ២០១៧ នេះ ក្រុមហ៊ុន ហ្គ្រេន ធ្វីន ទទួលបានចំណូលសរុប ចំនួន ៣២៣.៩៨៧ លាន រៀល (៨០,០៩៦ លាន ដុល្លារអាមេរិក) ដែលក្នុងនោះចំណូលបានពីការលក់ទំនិញ ទទួលបានចំនួន ៣៣៨.៥៨៥ លាន រៀល

(៨៣,៧០៥ លាន ដុល្លារអាមេរិក) និងចំណូលបានពីការកាត់ ដេរ និងវេចខ្ចប់ ទទួលបានចំនួន ៦.២១២ លាន រៀល (១,៥៣៦ លាន ដុល្លារអាមេរិក)។ ដោយឡែក ក្រុមហ៊ុនមិនមានចំណូលបានពីការម៉ៅការឡើយ នៅឆ្នាំ២០១៧ នេះ។

លើសពីនេះ ក្រុមហ៊ុន ហ្គ្រេន ធ្វីន ទទួលបានកំណើននៃចំណូលសរុបពីប្រតិបត្តិការ បន្ទាប់ពី ការដាក់ឲ្យប្រើប្រាស់អគារថ្មីដែលមានកម្ពស់ ៣ជាន់ នៅក្នុងបរិវេណរោងចក្រ ដែលចំណាយទឹកប្រាក់ប្រមាណ ១៩.០០០ លាន រៀល (៤.៧៥០ លាន ដុល្លារអាមេរិក) នៅចុងឆ្នាំ២០១៥ ដើម្បីឆ្លើយតបទៅនឹងការពង្រីកខ្សែសង្វាក់ផលិតកម្ម និងការរីកចំរើនធុរកិច្ចរបស់ក្រុមហ៊ុន ហ្គ្រេន ធ្វីន។ អគារថ្មីនេះ បានប្រើប្រាស់សម្រាប់រក្សាទុកវត្ថុធាតុដើមសម្រាប់ផលិតសំលៀកបំពាក់។ លើសពីនេះ ក្រុមហ៊ុន ហ្គ្រេន ធ្វីន ប្រើប្រាស់សាច់ប្រាក់មួយចំនួន សម្រាប់ពង្រីកសមត្ថភាពផលិតកម្ម ជាពិសេសការតម្លើងខ្សែសង្វាក់ផលិតកម្មចំនួន ២០ខ្សែ បន្ថែមសម្រាប់ផលិតសំលៀកបំពាក់ និងគ្រោងនឹងជ្រើសរើសបុគ្គលិកបន្ថែមប្រមាណ ៨០០ នាក់ នៅក្រោយពេលដាក់ឲ្យប្រើប្រាស់អគារថ្មីនេះ។

នៅចុងត្រីមាសទី ៤ ឆ្នាំ២០១៧ នេះ ក្រុមហ៊ុនបានកិច្ចសន្យាមូលធន ប្រមាណ ៤.៩០៩.៧៨០ ដុល្លារអាមេរិក សម្រាប់ការសាងសង់ការិយាល័យស្រាវជ្រាវ និងមជ្ឈមណ្ឌលទទួលបញ្ជាទិញពីអតិថិជនដោយផ្ទាល់ ផងដែរ។ ក្រុមហ៊ុន ហ្គ្រេន ធ្វីន រំពឹងថា ការិយាល័យស្រាវជ្រាវ និងមជ្ឈមណ្ឌលទទួលបញ្ជាទិញពីអតិថិជននេះ នឹងដាក់ឲ្យប្រើប្រាស់ក្នុងពេលឆាប់ៗនេះ។

## ការរំពឹងទុកសម្រាប់ត្រីមាសនានា ឆ្នាំ២០១៨

ចំពោះត្រីមាសនានា ឆ្នាំ២០១៨ ក្រុមហ៊ុន ហ្គ្រេន ធ្វីន នឹងខិតខំប្រឹងប្រែងបន្ថែមទៀត ដើម្បីធ្វើឲ្យកាន់តែប្រសើរឡើង ក្នុងពង្រឹងអភិបាលកិច្ចសាជីវកម្មល្អរបស់ក្រុមហ៊ុន ហើយនៅតែប្រកាន់ខ្ជាប់នូវទស្សនវិស័យ និងបេសកកម្មដែលបានកំណត់ពីឆ្នាំមុនៗ។ ជាទិសដៅសម្រាប់ត្រីមាសបន្ទាប់ ឆ្នាំ២០១៨ ក្រុមហ៊ុន ហ្គ្រេន ធ្វីន អ៊ិនធើណេសិនណល (ខេមបូឌា) ភីអិលស៊ី សង្ឃឹមថានឹងទទួលបានប្រាក់ចំណេញល្អប្រសើរជាងឆ្នាំ ២០១៧។

## សេចក្តីថ្លែងអំណរគុណ

ជាថ្មីម្តងទៀត ក្រុមហ៊ុន ហ្គ្រេន ធ្វីន មានសេចក្តីសោមនស្សរីករាយ សូមសម្តែងការអរគុណដល់ក្រុមប្រឹក្សាភិបាល គណៈគ្រប់គ្រង បុគ្គលិកគ្រប់ជាន់ថ្នាក់ កម្មករនិយោជិក ចំពោះការគាំទ្រ និងការដឹកនាំល្អសម្រាប់ប្រតិបត្តិការឆ្នាំ២០១៧ និងបណ្តាឆ្នាំកន្លងទៅ និងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះការគាំទ្រពីអតិថិជនរបស់ក្រុមហ៊ុនទាំងអស់ ជាពិសេស អតិថិជនចម្បងរបស់ក្រុមហ៊ុន ដែលបន្ត និងបានបង្កើនការបញ្ជាទិញ ពីមួយឆ្នាំទៅមួយឆ្នាំ ដែលធ្វើឲ្យក្រុមហ៊ុន ហ្គ្រេន ធ្វីន បានទទួលបានជោគជ័យរហូតមកដល់សព្វថ្ងៃនេះ។

រាជធានីភ្នំពេញ កាលបរិច្ឆេទ: ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៨

ហត្ថលេខា ត្រា និងឈ្មោះនាយកប្រតិបត្តិ



លោក Liao Chung Te

# មាតិកា


ទស្សនវិស័យ បេសកកម្ម ភាពខ្លាំង យុទ្ធសាស្ត្រ និងផែនការអនាគតរបស់ក្រុមហ៊ុន ហ្រ្គេន ធ្វីន
ទិន្នន័យ និងសូយចនករសំខាន់ៗសម្រាប់ឆ្នាំ២០១៧ និងបណ្តាឆ្នាំកន្លងទៅ
ព័ត៌មានហិរញ្ញវត្ថុសង្ខេប ក្រាហ្វិកអំពីព័ត៌មានហិរញ្ញវត្ថុសង្ខេប
សមាសភាពក្រុមប្រឹក្សាភិបាល របស់ក្រុមហ៊ុន ហ្រ្គេន ធ្វីន
សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន ហ្រ្គេន ធ្វីន
សេចក្តីថ្លែងរបស់នាយកប្រតិបត្តិ ក្រុមហ៊ុន ហ្រ្គេន ធ្វីន

**ផ្នែកទី ១ ៖ ព័ត៌មានពាក់ព័ន្ធនឹងក្រុមហ៊ុន ហ្រ្គេន ធ្វីន** **១**

១. ព័ត៌មានទូទៅរបស់ក្រុមហ៊ុន ហ្រ្គេន ធ្វីន ២
២. ដំណើរការធុរកិច្ចសង្ខេប ៥
៣. ស្ថានភាពទីផ្សារ ១៤
៤. ស្ថានភាពប្រកួតប្រជែង ១៦

**ផ្នែកទី ២ ៖ ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច** **២០**

១. លទ្ធផលប្រតិបត្តិការធុរកិច្ច ដោយរួមបញ្ចូលព័ត៌មានធុរកិច្ចតាមផ្នែក ២១
២. ការប្រែប្រួលសំខាន់ៗពាក់ព័ន្ធនឹងប្រតិបត្តិការធុរកិច្ច ២៥
៣. រចនាសម្ព័ន្ធចំណូល ៣០

**ផ្នែកទី ៣ ៖ អភិបាលកិច្ចសាជីវកម្ម** **៣១**

១. ភាគហ៊ុនិក ៣២
២. រចនាសម្ព័ន្ធក្រុមហ៊ុន ៣៨
៣. ក្រុមប្រឹក្សាភិបាល និងគណៈកម្មាធិការនានា ៤០
៤. បុគ្គលិកជាន់ខ្ពស់ ៤៩
៥. ការជាប់ពាក់ព័ន្ធរបស់អភិបាល និងបុគ្គលិកជាន់ខ្ពស់ក្នុងដំណើរការផ្លូវច្បាប់ ៥៥
៦. លាភការ និងប្រាក់បំណាច់សម្រាប់អភិបាល និងបុគ្គលិកជាន់ខ្ពស់ ៥៦
៧. ក្រមសីលធម៌សម្រាប់អភិបាល និងបុគ្គលិកជាន់ខ្ពស់ ៥៧
៨. សិទ្ធភាគីពាក់ព័ន្ធ ៥៨

**ផ្នែកទី ៤ ៖ បញ្ជីរាយនាមភាគហ៊ុនិកកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួន ច្រើនលើសលុប និងភាគហ៊ុនិកកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើន** **៥៩**

១. ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលុប ៦០
២. ភាគហ៊ុនិកកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើន ៦១

| | | |
|---|---|---|
| **ផ្នែកទី ៥ ៖** | **ព័ត៌មានអំពីការជួញដូរមូលបត្ររបស់ក្រុមហ៊ុន ហ្រ្គេន ធ្វីន** | **៦២** |
| | ១. ព័ត៌មានអំពីមូលបត្រកម្មសិទ្ធិ | ៦៣ |
| | ២. ថ្លៃ និងបរិមាណជួញដូរ | ៦៤ |
| **ផ្នែកទី ៦ ៖** | **របាយការណ៍សវនកម្មរបស់សវនករផ្ទៃក្នុង លើការត្រួតពិនិត្យផ្ទៃក្នុង** | **៦៧** |
| **ផ្នែកទី ៧ ៖** | **របាយការណ៍ហិរញ្ញវត្ថុដែលពិនិត្យឡើងវិញដោយសវនករឯករាជ្យ** | **៧០** |
| **ផ្នែកទី ៨ ៖** | **ព័ត៌មានអំពីប្រតិបត្តិការជាមួយភាគីពាក់ព័ន្ធ** | **១០៨** |
| | ១. ប្រតិបត្តិការជាមួយភាគហ៊ុនិក | ១០៩ |
| | ២. ប្រតិបត្តិការសំខាន់ៗជាមួយអភិបាល ឬបុគ្គលិកជាន់ខ្ពស់ ឬប្រតិបត្តិការសំខាន់ៗ ជាមួយបុគ្គលដែលអភិបាល ឬបុគ្គលិកជាន់ខ្ពស់មានផលប្រយោជន៍ | ១១០ |
| | ៣. ប្រតិបត្តិការសំខាន់ៗជាមួយសមាជិកគ្រួសារភផ្ទាល់របស់អភិបាល និងបុគ្គលិកជាន់ខ្ពស់ | ១១០ |
| | ៤. ប្រតិបត្តិការសំខាន់ៗជាមួយបុគ្គល ដែលមានទំនាក់ទំនងជាមួយអភិបាលរបស់ក្រុមហ៊ុន ក្រុមហ៊ុនបុត្រសម្ព័ន្ធ ឬក្រុមហ៊ុនហូលឌីងរបស់ក្រុមហ៊ុន ដែលទំនាក់ទំនងបុគ្គលទាំងនោះ កើតមាននៅក្នុងប្រតិបត្តិការ ឬការចាត់ចែងណាមួយដែលបានធ្វើឡើងដោយក្រុមហ៊ុន | ១១០ |
| | ៥. ប្រតិបត្តិការសំខាន់ៗជាមួយបុគ្គលធ្លាប់ជាអភិបាល ឬបុគ្គលជាប់ពាក់ព័ន្ធជាមួយបុគ្គលធ្លាប់ ជាអភិបាលក្នុងរយៈពេល ០២ (ពីរ) ឆ្នាំចុងក្រោយ | ១១១ |
| | ៦. ប្រតិបត្តិការសំខាន់ៗជាមួយអភិបាលដែលទទួលបានផលប្រយោជន៍ ឬកម្រៃវិជ្ជាជីវៈ សម្រាប់ សេវាដែលខ្លួនបានផ្តល់តាមរយៈក្រុមហ៊ុនណាមួយដល់ក្រុមហ៊ុន | ១១១ |
| | ៧. ប្រតិបត្តិការសំខាន់ៗជាមួយភាគីពាក់ព័ន្ធផ្សេងទៀត | ១១១ |
| **ផ្នែកទី ៩ ៖** | **ការពិភាក្សា និងវិភាគរបស់គណៈគ្រប់គ្រង** | **១១២** |
| | ១. ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ | ១១៣ |
| | ២. កត្តាសំខាន់ៗដែលប៉ះពាល់លើផលចំណេញ | ១២៤ |
| | ៣. ការប្រែប្រួលសំខាន់ៗលើការលក់ និងចំណូល | ១២៦ |
| | ៤. ផលប៉ះពាល់នៃការប្តូររូបិយបណ្ណ អត្រាការប្រាក់ និងថ្លៃទំនិញ | ១២៧ |
| | ៥. ផលប៉ះពាល់នៃអតិផរណា | ១២៨ |
| | ៦. គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុ របស់រដ្ឋាភិបាល | ១២៨ |
| **ផ្នែកទី ១០ ៖** | **ព័ត៌មានចាំបាច់ផ្សេងទៀតសម្រាប់ការពារវិនិយោគិន (ប្រសិនមាន)** | **១៣០** |
| **ហត្ថលេខារបស់អភិបាល ក្រុមហ៊ុន ហ្រ្គេន ធ្វីន** | | **១៣២** |

# ១. ព័ត៌មានពាក់ព័ន្ធ ក្រុមហ៊ុន ប្រេ្អន ធ្វីន



ឈ្មោះក្រុមហ៊ុន : **ក្រុមហ៊ុន ហ្គ្រេន ធ្វីន អ៊ិនធើណេសិនណាល(ខេមបូឌា) ភីអិលស៊ី**
ឈ្មោះក្រុមហ៊ុន ជាអក្សរឡាតាំង : GRAND TWINS INTERNAIONAL (CAMBODIA) Plc.
លេខកូដមូលបត្រ : KH១០០០០២០០០៣
អាសយដ្ឋាន: ភូមិត្រពាំងពោធិ៍ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
លេខទូរស័ព្ទ : (៨៥៥)២៣ ៨៩០ ៣២៥ លេខទូរសារ : (៨៥៥)២៣ ៨៩០ ៣២៦
គេហទំព័រ : www.Grandtwins.com.kh អ៊ីម៉ែល :vuthy.phuong@qmico.com
លេខវិញ្ញាបនប័ត្រចុះបញ្ជីពាណិជ្ជកម្ម: ០០០១២៣៤៧ កាលបរិច្ឆេទ: ១៥-វិច្ឆិកា-២០០៧
លេខអាជ្ញាបណ្ណអាជីវកម្ម : ០០០១២៣៤៧ កាលបរិច្ឆេទ: ១៥-វិច្ឆិកា-២០០៧

ឈ្មោះបុគ្គលតំណាងក្រុមហ៊ុនបោះផ្សាយ : លោក LIAO CHUNG-TE
តួនាទី : នាយកប្រតិបត្តិ របស់ក្រុមហ៊ុន ហ្គ្រេន ធ្វីន

# វឌ្ឍនភាពរបស់ក្រុមហ៊ុន ហ្គ្រេន ធ្វីន

**ឆ្នាំ២០០៧**

ក្រុមហ៊ុន បានបង្កើតឡើងក្រោមឈ្មោះ ហ្គ្រេន ធ្វីន អ៊ិនធើណេសិនណល (ខេមបូឌា) អិលធីឌី។

**ឆ្នាំ២០០៨**

ក្រុមហ៊ុន ហ្គ្រេន ធ្វីន បានទិញក្រុមហ៊ុន QMI Industrial Co.,Ltd ដែលជារោងចក្រផលិត សំលៀកបំពាក់ឈានមុខមួយ ហើយដែលបាន ដំណើរការនៅក្នុងព្រះរាជាណាចក្រកម្ពុជា តាំងពីទសវត្សរ៍ឆ្នាំ៩០ ។

១

២

៣

**ឆ្នាំ២០១៣**

ក្រុមហ៊ុន បានប្តូរទម្រង់ទៅជាក្រុមហ៊ុន ហ្គ្រេន ធ្វីន អ៊ិនធើណេសិនណល (ខេមបូឌា) ភីអិលស៊ី និងក្រុមហ៊ុន បានបង្កើនដើមទុនរហូតដល់ ៨ លាន ដុល្លារអាមេរិក សម្រាប់បំពេញលក្ខខណ្ឌ តម្រូវការបោះផ្សាយ និងចុះបញ្ជីលក់មូលបត្រ





**ឆ្នាំ២០១៤**

ក្រុមហ៊ុន បានបោះផ្សាយ និងចុះបញ្ជីលក់មូលបត្រជាផ្លូវការនៅក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (ផ.ម.ក) នៅថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៤

**ឆ្នាំ២០១៥**

ក្រុមហ៊ុន បានធ្វើការបែងចែកភាគលាភដល់ភាគហ៊ុនិក និងរៀបចំមហាសន្និបាតភាគហ៊ុនិក លើកទី១ ជាលើកដំបូង បន្ទាប់ពីក្រុមហ៊ុនបាន បោះផ្សាយ និង ចុះបញ្ជីលក់មូលបត្រជាផ្លូវការនៅ ផ.ម.ក។

៤ ៥ ៦

**ឆ្នាំ២០១៦**

ក្រុមប្រឹក្សាភិបាលអាណត្តិទី២ បានធ្វើការសម្រេច និងអនុម័តបែងចែកភាគលាភ ដល់ភាគហ៊ុនិក ជាលើកទី២ កាលពី ខែមិថុនា និង រៀបចំមហាសន្និបាតភាគហ៊ុនិក លើកទី២ របស់ក្រុមហ៊ុន នៅខែកញ្ញា

**ឆ្នាំ២០១៧**

ក្រុមប្រឹក្សាភិបាលអាណត្តិទី២ បានធ្វើការសម្រេច និងអនុម័តបែងចែកភាគលាភដល់ភាគហ៊ុនិក ជាលើកទី៣ កាលពីខែមិថុនា និង រៀបចំមហាសន្និបាតភាគហ៊ុនិក លើកទី៣ របស់ក្រុមហ៊ុន នៅខែវិច្ឆិកា កន្លងទៅ ។

ក្រុមហ៊ុន ហ្គ្រេន ធ្វីន បានបង្កើតឡើងក្រោមច្បាប់ និងបទប្បញ្ញត្តិនៃព្រះរាជាណាចក្រកម្ពុជា នាថ្ងៃទី១៥ ខែ វិច្ឆិកា ឆ្នាំ២០០៧ មានឈ្មោះថា ហ្គ្រេន ធ្វីន អ៊ិនធើណេសិនណល (ខេមបូឌា) អិលធីឌី។ នៅថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១៣ ក្រុមហ៊ុន ហ្គ្រេន ធ្វីន អ៊ិនធើណេសិនណល (ខេមបូឌា) អិលធីឌី ត្រូវបានប្តូរទម្រង់ទៅជាក្រុមហ៊ុន ហ្គ្រេន ធ្វីន អ៊ិនធើណេសិនណល (ខេមបូឌា) ភីអិលស៊ីវិញ។ ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០៨ ក្រុមហ៊ុន ហ្គ្រេន ធ្វីន បានទិញក្រុមហ៊ុន QMI Industrial Co.,Ltd ដែលជារោងចក្រផលិតសំលៀកបំពាក់ឈានមុខមួយ ហើយដែលបានដំណើរការនៅក្នុង ព្រះរាជាណាចក្រកម្ពុជា តាំងពីទសវត្សរ៍ឆ្នាំ ៩០។ នាថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៤ ក្រុមហ៊ុន ហ្គ្រេន ធ្វីន បានចុះបញ្ជីលក់មូលបត្រជាផ្លូវការនៅផ្សារមូលបត្រកម្ពុជា និងបានក្លាយជាក្រុមហ៊ុនឯកជនដំបូងបង្អស់ ដែលបានបោះផ្សាយលក់មូលបត្រលើកដំបូងជាសាធារណៈនៅព្រះរាជាណាចក្រកម្ពុជា។

ក្រុមហ៊ុន ហ្គ្រេន ធ្វីន ជាក្រុមហ៊ុនម៉ៅការផលិតសំលៀកបំពាក់បន្តផង និងជាអ្នកផលិតសំលៀកបំពាក់សម្រាប់នាំចេញផង និងជារោងចក្រច្នៃម៉ូដប្រភពដើម (ODM"original design manufacturer") នៃសំលៀកបំពាក់កីឡា។ បច្ចុប្បន្នផលិតផលចម្បងរបស់ក្រុមហ៊ុន ហ្គ្រេន ធ្វីន រួមមាន ម៉ាកសំលៀកបំពាក់កីឡាល្បីក្នុងពិភពលោក ដូចជា "Adidas", "Reebok", "Taylor Made", "Salomon", "New Balance (NB)", "Kohl's", "Nautica", "NorthFace", "Russell Athletic" និងម៉ាកផ្សេងៗទៀត។

**AdidasGroup** គឺជាក្រុមហ៊ុនមួយក្នុងចំណោមក្រុមហ៊ុននាំមុខគេក្នុងសកលលោក នៅក្នុងវិស័យឧស្សាហកម្មសំលៀកបំពាក់កីឡា និងមានលក់សំលៀកបំពាក់ម៉ាកល្បីៗដូចជា៖ "Adidas" "Reebok" "TaylorMade" "Rockport" "Reebok-CCMHockey"។ ក្រុមហ៊ុន Adidas មានទីស្នាក់ការកណ្តាលនៅក្នុងទីក្រុង Herzogenaurach ប្រទេសអាល្លឺម៉ង់។

ក្រុមហ៊ុន ហ្គ្រេន ធ្វីន បានផលិតសំលៀកបំពាក់កីឡាជាច្រើន ប្រភេទសម្រាប់ក្រុមហ៊ុន Adidas Group។ ដោយឡែក គិតត្រឹមឆ្នាំ២០១៧ នេះ ក្រុមហ៊ុន Adidas នៅតែជាអតិថិជនចម្បងរបស់ ក្រុមហ៊ុន ហ្គ្រេន ធ្វីន ដដែល។

ក្រុមហ៊ុន ហ្គ្រេន ធ្វីន ទិញវត្ថុធាតុដើមពី តៃវ៉ាន់ សាធារណរដ្ឋប្រជាមានិតចិន ប្រទេសថៃ និងប្រទេសវៀតណាម។ ប្រទេសគោលដៅនាំចេញរបស់ក្រុមហ៊ុន ហ្គ្រេន ធ្វីន នៅឆ្នាំ២០១៧ រួមមាន បណ្តាប្រទេសនៅអឺរ៉ុប ៥០% សហរដ្ឋអាមេរិក ២១% និងបណ្តាប្រទេសនៅអាស៊ី និងប្រទេសដទៃទៀត ២៩% នៃចំណូលសរុបនៅឆ្នាំ២០១៧។ គិតត្រឹមឆ្នាំ២០១៧ ទីផ្សារអឺរ៉ុប នៅតែជាទីផ្សារចម្បងក្នុងការនាំចេញផលិតផលរបស់ ក្រុមហ៊ុន ហ្គ្រេន ធ្វីន ដដែល។

ក្រុមហ៊ុន ហ្គ្រេន ធ្វីន មានគណៈគ្រប់គ្រងដែលមានជំនាញ និងបទពិសោធន៏ក្នុងវិស័យសំលៀកបំពាក់ជាច្រើនឆ្នាំ ព្រមទាំងមានបច្ចេកវិទ្យាផលិតយ៉ាងទំនើបដើម្បីធានានូវប្រសិទ្ធភាពផលិតកម្មរបស់ខ្លួន។ ក្រុមហ៊ុនមានបុគ្គលិកសរុប ចំនួន ៥.៧៧៣ នាក់ គិតត្រឹមឆ្នាំ២០១៧។ ដីរោងចក្រដែលប្រើប្រាស់សម្រាប់ខ្សែសង្វាក់ផលិតកម្ម មានទំហំសរុប ប្រមាណ ៣២.៣៤១ ម៉ែត្រការ៉េ (ក្នុងនោះមានអគារ ២ជាន់ ចំនួន ២ ដែលគិតជាទំហំសរុប ២១.៦២០ ម៉ែត្រការ៉េ)។ អគារថ្មីមួយទៀត ដែលមានកម្ពស់ ៣ជាន់ ត្រូវបានសាងសង់បន្ថែមសម្រាប់រក្សាទុកវត្ថុធាតុដើម សម្រាប់ផលិតសំលៀកបំពាក់ និងបានដាក់ឲ្យប្រើប្រាស់ចុងឆ្នាំ២០១៥ កន្លងទៅនេះ។ នៅឆ្នាំ២០១៧ ក្រុមហ៊ុនបានចំណាយមូលធនប្រមាណជិត ៥ លាន ដុល្លារអាមេរិក សម្រាប់ការសាងសង់ការិយាល័យស្រាវជ្រាវ និងមជ្ឈមណ្ឌលទទួលបញ្ជាទិញពីអតិថិជនដោយផ្ទាល់ផងដែរ។

ក្រុមហ៊ុន ហ្វ្រេន ធ្វីន រំពឹងថា ការិយាល័យស្រាវជ្រាវ និងមជ្ឈមណ្ឌលទទួលបញ្ជាទិញពីអតិថិជននេះ នឹងដាក់ឲ្យប្រើប្រាស់ក្នុងពេល ឆាប់ៗនេះ។

## អតិថិជនចម្បង

ក្រុមហ៊ុន ហ្វ្រេន ធ្វីន បានផលិតសំលៀកបំពាក់កីឡាជាច្រើន ប្រភេទសម្រាប់ក្រុមហ៊ុន Adidas Group។ ដោយឡែក គិតត្រឹមឆ្នាំ២០១៧ ក្រុមហ៊ុន Adidas នៅតែជាអតិថិជនចម្បង របស់ក្រុមហ៊ុន ហ្វ្រេន ធ្វីន ដដែល។ កំណើននៃចំណូលសរុបពីការលក់ផលិតផលរបស់ ក្រុមហ៊ុន Adidas នៅត្រីមាសទី២ ឆ្នាំ២០១៧ នេះ គឺកើនឡើងចំនួន ១៦% បន្ទាប់ពីសម្រេចបានកំណើននៃការលក់ខ្ពស់ជាងការរំពឹងទុកខ្លាំង ធៀបនឹងត្រីមាសទី១ ឆ្នាំ២០១៦ កន្លង ទៅនេះ ដោយសារតែសន្ទុះម៉ាកយីហោខ្លាំងដែលត្រូវបានឆ្លុះបញ្ចាំងតាមលទ្ធផលនៅត្រីមាសទី១ ដែលមានស្ថាន ភាពល្អប្រសើរជាងការរំពឹងទុកនោះ ក្រុមហ៊ុនបានបង្កើនចក្ខុវិស័យប្រចាំឆ្នាំ ២០១៧ របស់ខ្លួន។ ដោយឡែក ក្រុមហ៊ុន Adidas ទទួលបានចំណេញសុទ្ធពីប្រតិបត្តិការរបស់ខ្លួនប្រមាណ ២២៦ ពាន់លាន អឺរ៉ូ នៅត្រីមាសទី១ ឆ្នាំ២០១៧ ដែលអត្រា កំណើនប្រមាណ ២៩% ធៀបនឹងត្រីមាសទី១ ឆ្នាំ២០១៦ កន្លងទៅនេះ។

ប្រភព៖ របាយការណ៍ប្រចាំត្រីមាសទី២ ឆ្នាំ២០១៧ និង Press Release ថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៧។



## ផលិតផលចម្បង

### សំលៀកបំពាក់កីឡា

ក្រុមហ៊ុន ហ្គ្រន ធ្វីន បានផលិតផលិតផលថ្មីជាច្រើនប្រភេទដែលបានផលិតចេញពីវត្ថុធាតុដើមអាចកែច្នៃឡើងវិញបាន (ដូចជា ប្លាស្ទិកបានពីសំបកដប ជាដើម) ដើម្បីជាការរួមចំណែកក្នុងការការពារបរិស្ថាន។សំលៀកបំពាក់កីឡា បានប្រើប្រាស់វត្ថុធាតុ ដើមដែលធ្វើឲ្យឆាប់ស្ងួត មានគុណភាពខ្ពស់ អាចស្រូបសំណើមប្រឆាំងនឹងបាក់តេរី និងការប្រឡាក់។







### សំលៀកបំពាក់មិនជ្រាបទឹក

ក្រុមហ៊ុន បានផ្តល់នូវជម្រើសជាច្រើនប្រភេទដល់អតិថិជនដើម្បីពង្រីកសមត្ថភាពអោយបានជាអតិបរមា ក្នុងការឆ្លើយតបទៅនឹងនិន្នាការម៉ូដដែលកំពុងពេញនិយម ដើម្បីបំពេញតាមចំណង់ចំណូលចិត្តរបស់ អតិថិជន និងដើម្បីកាត់បន្ថយការពឹងផ្អែកតែទៅលើ ម៉ូដជាក់លាក់ណាមួយ។ ដូច្នេះ ក្រុមហ៊ុនបានផលិតផងដែរ នូវសំលៀកបំពាក់មិនជ្រាបទឹកដើម្បីបំពេញតម្រូវការ អតិថិជន។

### សំលៀកបំពាក់ខាងក្រៅ

សំលៀកបំពាក់ខាងក្រៅ ដែលផលិតដោយក្រុមហ៊ុន ហ្គ្រន ធ្វីន ត្រូវបានទទួលស្គាល់ថា បានច្នៃម៉ូដប្រកបដោយវិជ្ជាជីវៈ និងមានបច្ចេកទេសបោះពុម្ពខ្ពស់ ដែលអាចកាត់បន្ថយញើស ដែលអាចបង្កឲ្យរលាកស្បែកសម្រាប់អ្នកប្រើប្រាស់។







### សំលៀកបំពាក់មានមុខងារពិសេស

សំលៀកបំពាក់ មានមុខងារពិសេស ជាប្រភេទផលិតផលដ៏សំខាន់មួយ ក្នុងចំណោមផលិតផលរបស់ក្រុមហ៊ុន ហ្គ្រន ធ្វីន សម្រាប់ទីផ្សារសហរដ្ឋអាមេរិក និងកាណាដា។

## ការលក់ផលិតផលចម្រុះ ឆ្នាំ២០១៧ ឆ្នាំ២០១៦ និងឆ្នាំ២០១៥









## ទីផ្សារសម្រាប់ចែកចាយផលិតផល

ក្រុមហ៊ុន ហ្វ្រេន ធ្វីន ផលិតសំលៀកបំពាក់សម្រាប់តែការនាំចេញតែប៉ុណ្ណោះ។ ថ្មីៗនេះ ក្រុមហ៊ុន ហ្វ្រេន ធ្វីន បាននាំចេញផលិតផលទៅឲ្យអតិថិជននៅសហភាពអឺរ៉ុប សហរដ្ឋអាមេរិក បណ្តាប្រទេសនៅតំបន់អាស៊ី និងប្រទេសដទៃទៀត។ សហភាពអឺរ៉ុប គឺ ជាទីផ្សារចម្បងរបស់ក្រុមហ៊ុនក្នុងការនាំចេញផលិតផល បើធៀបនឹងទីផ្សារនៅតាមបណ្តាប្រទេសផ្សេងទៀត។







អាស៊ី
ព្រះរាជាណាចក្រកម្ពុជា
GTI
GRAND TWINS

### ចំនួនបុគ្គលិកសរុប និងបុគ្គលិកធ្វើការងារពេញម៉ោង

គិតត្រឹមឆ្នាំ២០១៧ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ ក្រុមហ៊ុន ហ្គ្រេន ធ្វីន មានបុគ្គលិកធ្វើការពេញម៉ោងចំនួន ៥.៧៧៣ នាក់។ បុគ្គលិកផ្នែកលក់ ត្រូវបានផ្តល់ប្រាក់បៀវត្សជាប្រាក់ម៉ោង រួមជាមួយកម្រៃជើងសា។ លាភការ ត្រូវបានផ្តល់ជូនបុគ្គលិកជារៀងរាល់ឆ្នាំដើម្បីលើកទឹកចិត្ត។ ចំនួននៃលាភការត្រូវបានវិនិច្ឆ័យតាមរយៈកត្តាផ្សេងៗ ដូចជា បទពិសោធន៍នៅក្នុងការងារ តំណែង ឬតួនាទីដែលបានបំពេញ ឬការដឹកនាំនៅក្នុងក្រុមហ៊ុន។ ប្រព័ន្ធគ្រប់គ្រងធនធានមនុស្សដើរតួនាទីយ៉ាងសំខាន់ ក្នុងការវាស់វែងផលិតភាពដែលផ្តល់ឱកាសដល់បុគ្គលិកក្នុងការអភិវឌ្ឍន៍ជំនាញ និងបទពិសោធន៍ផ្តោតការយកចិត្តទុកដាក់លើលទ្ធផល និងការធ្វើឲ្យប្រសើរឡើងនូវផលិតភាព ការជ្រើសរើសបុគ្គលិកប្រកបដោយភាពយុត្តិធម៌ ប្រសិទ្ធភាពនៃការប្រកាន់ខ្ជាប់វិន័យ ការផ្តោតការយកចិត្តទុកដាក់លើលាភការ ឬប្រាក់បំណាច់របស់បុគ្គលិក ការវាយតម្លៃទៅលើសមត្ថភាពការងារ ការបណ្តុះបណ្តាលជំនាញដល់បុគ្គលិកការគ្រប់គ្រង អត្រាផ្លាស់ចេញ ព្រមទាំងការគ្រប់គ្រងទំនាក់ទំនងរវាងបុគ្គលិក និងនិយោជក។ ក្រុមហ៊ុននេះ ទទួលបាននូវភាពស្មោះត្រង់ពីនិយោជិត ហើយច្រើនជាង ៣៥% នៃនិយោជិតសរុបបានបន្តធ្វើការងារជាមួយក្រុមហ៊ុននេះលើសពី ៥ ឆ្នាំ។

តារាងខាងក្រោមនេះ បង្ហាញពីការបែងចែកមុខងាររបស់បុគ្គលិកធ្វើការពេញម៉ោង សម្រាប់ ឆ្នាំ២០១៧ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ ឆ្នាំ២០១៦ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ និងឆ្នាំ២០១៥ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥៖

| បរិយាយ | ឆ្នាំ២០១៧ | ឆ្នាំ២០១៦ | ឆ្នាំ២០១៥ |
|---|---:|---:|---:|
| គណៈគ្រប់គ្រង/រដ្ឋបាល | ៩ | ១០ | ៨ |
| អ្នកបច្ចេកទេស | ២២ | ១៩ | ២០ |
| ប្រធានក្រុម | ៣១៤ | ២៣៨ | ៤៤៣ |
| បុគ្គលិកជំនាញ | ៣.៨៣៧ | ៣.៧២៥ | ៣.២៨១ |
| បុគ្គលិកគ្មានជំនាញ | ១.៥៩១ | ១.៥២២ | ១.៤៦១ |
| **សរុប** | **៥.៧៧៣** | **៥.៥១៤** | **៥.២១៣** |



## កំណើនសេដ្ឋកិច្ចនៅព្រះរាជាណាចក្រកម្ពុជា

តាមរបាយការណ៍សហគមន៍អឺរ៉ុប ផលិតផលក្នុងស្រុកសរុប (GDP) របស់សហគមន៍អឺរ៉ុប ប្រមាណ ១,៧% នៅឆ្នាំ២០១៦ កន្លងទៅ។ ផលិតផលក្នុងស្រុកសរុប (GDP) របស់សហគមន៍អឺរ៉ុប រំពឹងថា នឹងទទួលបានប្រមាណ ១,៦% នៅឆ្នាំ២០១៧ និង ចំនួន ១,៨% នៅឆ្នាំ ២០១៨ ខាងមុខនេះ។ ដោយឡែក ផលិតផលក្នុងស្រុកសរុប (GDP) របស់សហរដ្ឋអាមេរិក មានចំនួន ០,៧% គិតត្រឹមត្រីមាសទី១ ឆ្នាំ២០១៧ បានថយចុះប្រមាណ ០,១% បើធៀបនឹង ចំនួន ០,៨% នៅត្រីមាសទី១ ឆ្នាំ២០១៦ កន្លងទៅ។ ។ ដោយឡែក ផលិតផលក្នុងស្រុកសរុបរបស់ពិភពលោក រំពឹងថា នឹងទទួលបានប្រមាណ ៣,៥% នៅឆ្នាំ២០១៨ ដែលផលិតផលក្នុងស្រុកសរុបរបស់ពិភពលោក នៅឆ្នាំ២០១៦ មានត្រឹមតែ ៣,៥% ប៉ុណ្ណោះ។ ផលិតផលក្នុងស្រុកសរុបនៅតំបន់ទាំងពីរ គិតត្រឹមត្រីមាសទី១ ឆ្នាំ២០១៧ មានការថយចុះបើធៀបនឹងត្រីមាសទី១ នាបណ្ដាឆ្នាំកន្លងទៅ។ តំបន់ទាំងពីរដែលបានរៀបរាប់ខាងលើនេះ គឺជាតំបន់លក់ចម្បងបំផុតរបស់ ក្រុមហ៊ុន ហ្វ្រេន ធ្វីន ជាពិសេស ឥទ្ធិពលពីការថយនៃភាគរយ GDP អាចនឹងជះឥទ្ធិពលដល់ចំណូលរបស់ក្រុមហ៊ុន ហ្វ្រេន ធ្វីន នៅក្នុងឆ្នាំ២០១៧ ផងដែរ។

( ប្រភព៖ របាយការណ៍ European Economic Forecast Winter 2017 dated 13 February 2017 & https://ec.europa.eu/info/publications/economy-finance/european-economic-forecast-winter-2017_en http://www.oecd.org/eco/outlook/)

### ក្រាហ្វិកអំពីកំណើនផលិតផលក្នុងស្រុកសរុប (GDP) របស់អឺរ៉ុប សហរដ្ឋអាមេរិក និងតំបន់អាស៊ី




( ប្រភព៖ របាយការណ៍Adidas Group ឆ្នាំ២០១៧)

សេដ្ឋកិច្ចនៅព្រះរាជាណាចក្រកម្ពុជា បានកើនឡើងគួរឲ្យកត់សំគាល់នៅឆ្នាំ២០១៥ ដែលផលិតផលក្នុងស្រុកសរុប (GDP) មានចំនួន ប្រមាណ ១៨.០៥ ពាន់លានដុល្លារអាមេរិក នៅឆ្នាំ២០១៥ តំណាងអោយ ០,០៣ ភាគរយនៃសេដ្ឋកិច្ចពិភពលោក។ ផលិតផលក្នុងស្រុកសរុប នៅព្រះរាជាណាចក្រកម្ពុជា គិតជាមធ្យម មានចំនួន ៤.៩៣ ពាន់លានដុល្លារអាមេរិក គិតចាប់ពីឆ្នាំ ១៩៦០ ដល់ ឆ្នាំ ២០១៥ ដែលក្នុងនោះ គឺមានកំណើនខ្ពស់នៅឆ្នាំ២០១៥ ពោលគឺ ១៨.០៥ ពាន់លាន ដុល្លារអាមេរិក និងទាបបំផុតនៅ ឆ្នាំ១៩៧២ ពោលគឺត្រឹមតែ ០,៥១ ពាន់លាន ដុល្លារអាមេរិក ប៉ុណ្ណោះ (យោងតាមរបាយកាណ៍ធនាគារពិភពលោក)។ នៅឆ្នាំ២០១៦ កន្លងទៅ ផលិតផលក្នុងស្រុក សរុប (GDP) មានចំនួន ៧% និងរំពឹងថា នឹងកើនឡើង ចំនួន ៧,១% នៅឆ្នាំ២០១៧ និង៧,១% នៅឆ្នាំ២០១៨។

( ប្រភព៖ របាយការណ៍ធនាគារពិភពលោក និងhttps://www.adb.org/countries/cambodia/economy)

**ក្រាហ្វិកអំពីកំណើនផលិតផលក្នុងស្រុកសរុប (GDP) របស់ព្រះរាជាណាចក្រកម្ពុជា**




https://www.adb.org/countries/cambodia/economy

សម្រាប់ទស្សនវិស័យនាពេលអនាគត កំណើនសេដ្ឋកិច្ចនៅព្រះរាជាណាចក្រកម្ពុជា នឹងអាចកើនឡើងតាមការរំពឹងទុក តាមរយៈការសហការជាមួយដៃគូពាណិជ្ជកម្ម ដូចជា សហរដ្ឋអាមេរិក និងប្រទេសថៃ ដែលបច្ចុប្បន្នវិសាលភាពនៃការនាំចេញតិចជាងសហភាពអឺរ៉ុប និងផ្សារភ្ជាប់ជាមួយស្ថេរភាពនយោបាយក្នុងស្រុក និងប្រេងដែលមានតម្លៃទាប។ ផលិតផលក្នុងស្រុកសរុប ត្រូវបានព្យាករណ៍ថា នឹងកើនឡើង ៧,១% នៅ ឆ្នាំ២០១៧ និងឆ្នាំ២០១៨។ ក្នុងរយៈខ្លីនេះ អាចនឹងត្រូវបានជំរុញដោយការធ្វើពិពិធកម្មនៃផលិតកម្ម និងការធ្វើសមាហរណកម្មបន្ថែមទៀត ក្នុងការផ្គត់ផ្គង់នៅក្នុងតំបន់ និងជាលក្ខណៈសកល *(ប្រភព http://www.adb.org/countries/cambodia/economy)។*

នៅឆ្នាំ២០១៧ នេះ ផលិតផលក្នុងស្រុកសរុបមានចំនួន ៧,១% សម្រាប់ការព្យាករណ៍ក្នុងឆ្នាំ២០១៨ នេះ ផលិតផលក្នុងស្រុកសរុប ត្រូវបានព្យាករណ៍ថា មានចំនួន ៧,១% និងព្យាករណ៍ថានឹងកើនឡើងរហូតដល់ ៧,៨៣% នៅឆ្នាំ២០២០ យោងតាមក្រុមអ្នកវិភាគម៉ាក្រូសេដ្ឋកិច្ចសកល (*http://www.tradingeconomics.com/cambodia/gdp-growth-annual/forecast)* និង *Asian Development Outlook 2016 Update។*

## ការនាំចេញរបស់ព្រះរាជាណាចក្រកម្ពុជា នៅឆ្នាំ២០១៦

ការនាំចេញសម្លៀកបំពាក់ និងវាយនភណ្ឌពីព្រះរាជាណាចក្រកម្ពុជា គិតត្រឹម ៦ខែ ដើមឆ្នាំ២០១៦ នេះ គឺ មានចំនួន ៩,៤% បើយោងតាមរបាយការណ៍ធនាគារពិភពលោក។ តាមតួលេខនៃការនាំចេញសម្លៀកបំពាក់ និងវាយនភ័ណ្ឌ ក្នុងរបាយការណ៍សមាគមកាត់ដេរនៃព្រះរាជាណាចក្រកម្ពុជា (GMAC) ការនាំចេញរបស់ព្រះរាជាណាចក្រកម្ពុជា មានចំនួនសរុបប្រមាណ ៥៦៤ លាន ដុល្លារអាមេរិក ខណៈដែលការនាំចេញមានកម្រិតទាបបំផុតនៅឆ្នាំ២០១៤ ដែលការនាំចេញមានត្រឹមតែ ២៣៤ លាន ដុល្លារអាមេរិក ប៉ុណ្ណោះ។ ការថយចុះនៅក្នុងរយៈពេលប៉ុន្មានខែចុងក្រោយ នៅឆ្នាំ២០១៤ ភាគច្រើន គឺបណ្តាលមកពីការកើនឡើងនៃប្រាក់បៀវត្សរ៍សម្រាប់កម្មករនិយោជិក ដែលជាមូលហេតុចម្បង បណ្តាលឲ្យការចំណាយ បានកើនឡើងសម្រាប់រោងចក្រកាត់ដេរមួយចំនួនធំនៅកម្ពុជា។ ប្រាក់ឈ្នួល អប្បបរមា បានកើន ឡើងទ្វេដងនៅឆ្នាំ២០១៤។ ប្រាក់ឈ្នួលអប្បបរមាបច្ចុប្បន្នចំនួន ១៧៣ ដុល្លារអាមេរិក សម្រាប់បុគ្គលិកនិយោជិករោងចក្រកាត់ដេរ ត្រូវបានដាក់អនុវត្តនៅដើម ឆ្នាំ២០១៧ កន្លងទៅ។

ព្រះរាជាណាចក្រកម្ពុជានៅតែរក្សាបានកំណើន ១៥% នៅក្នុងការនាំចេញសម្លៀកបំពាក់ទៅសហភាពអឺរ៉ុប គឺដោយសារតែ ព្រះរាជាណាចក្រកម្ពុជា ទទួលបានការអនុគ្រោះ *«អ្វីៗគ្រប់យ៉ាងលើកលែងតែអាវុធ»* ។ ប៉ុន្តែ តាមការព្យាករណ៍ អត្ថប្រយោជន៍នេះនឹងត្រូវធ្លាក់ចុះបន្ទាប់ពីកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីរវាងសហភាពអឺរ៉ុប និងវៀតណាម បានចូលជាធរមាន។ ប្រាក់ឈ្នួលអប្បបរមារបស់ពលករ គឺខ្ពស់ខណៈផលប៉ះពាល់នៃកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីចាប់ផ្តើមដោយសារវៀតណាម ទទួលបានការអនុគ្រោះពាណិជ្ជកម្ម និងភាពប្រកួតប្រជែងលើតម្លៃ ដោយសារតែផលិតភាពកម្លាំងពលកម្មកាន់តែខ្ពស់របស់ខ្លួន។

## ការប្រកួតប្រជែងរបស់ព្រះរាជាណាចក្រកម្ពុជា និងប្រទេសជិតខាងក្នុងវិស័យកាត់ដេរ

យោងតាមរបាយការណ៍ GMAC បង្ហាញថា ព្រះរាជាណាចក្រកម្ពុជាកំពុងជម្នះទល់នឹងការប្រកួតប្រជែងជាមួយប្រទេសជិតខាង ដោយសារ ផលិតភាពទាប ការកើនឡើងនៃប្រាក់ឈ្នួលអប្បរមា និងកូដកម្មពីសំណាក់សហជីពកម្មករជាដើម។ វិស័យកាត់ដេរកម្ពុជា ផលិតភាពតិចជាងគេទីពីរនៅក្នុងតំបន់ ដែលអត្រាមានត្រឹមតែ ៦០% ប៉ុណ្ណោះ ធៀបនឹងវិស័យកាត់ដេររបស់ប្រទេសចិន។ សម្រាប់ផលិតភាពរបស់ប្រទេសវៀតណាម និងឥណ្ឌូនេស៊ី គឺមានចំនួន ៨០% ខណៈដែលប្រទេសបង់ក្លាដែស មានត្រឹមតែ ៥០% ប៉ុណ្ណោះ ដែលអត្រាទាបជាងព្រះរាជាណាចក្រកម្ពុជាកម្ពុជា។ ផលិតភាពទាប និងប្រាក់ឈ្នួលគោលកាន់តែខ្ពស់ នឹងជាបញ្ហាប្រឈមពិតប្រាកដមួយចំពោះឧស្សាហកម្មនៅកម្ពុជា ដោយសារអតិថិជននៅក្រៅប្រទេស វិនិច្ឆ័យជាចម្បងទៅលើផលិតភាព និងសមត្ថភាពប្រកួតប្រជែង នៅពេលដែលពួកគេជ្រើសរើសដៃគូសម្រាប់ផ្គត់ផ្គង់ផលិតផលរបស់ខ្លួន។ ផលិតភាពទាប គឺដោយសារតែសហជីពច្រើននៅកម្ពុជា។

## ការប្រកួតប្រជែងរបស់ព្រះរាជាណាចក្រកម្ពុជា និងប្រទេសជិតខាងក្នុងវិស័យកាត់ដេរ

យោងតាមរបាយការណ៍ GMAC បង្ហាញថា ព្រះរាជាណាចក្រកម្ពុជាកំពុងជម្នះទល់នឹងការប្រកួតប្រជែងជាមួយប្រទេសជិតខាង ដោយសារ ផលិតភាពទាប ការកើនឡើងនៃប្រាក់ឈ្នួលអប្បរមា និងកូដកម្មពីសំណាក់សហជីពកម្មករជាដើម។ វិស័យកាត់ដេរកម្ពុជា ផលិតភាពតិចជាងគេទីពីរនៅក្នុងតំបន់ ដែលអត្រាមានត្រឹមតែ ៦០% ប៉ុណ្ណោះ ធៀបនឹងវិស័យកាត់ដេររបស់ប្រទេសចិន។ សម្រាប់ផលិតភាពរបស់ប្រទេសវៀតណាម និងឥណ្ឌូនេស៊ី គឺមានចំនួន ៨០% ខណៈដែលប្រទេសបង់ក្លាដែស មានត្រឹមតែ ៥០% ប៉ុណ្ណោះ ដែលអត្រាទាបជាងព្រះរាជាណាចក្រកម្ពុជាកម្ពុជា។ ផលិតភាពទាប និងប្រាក់ឈ្នួលគោលកាន់តែខ្ពស់ នឹងជាបញ្ហាប្រឈមពិតប្រាកដមួយចំពោះឧស្សាហកម្មនៅកម្ពុជា ដោយសារអតិថិជននៅក្រៅប្រទេស វិនិច្ឆ័យជាចម្បងទៅលើផលិតភាព និងសមត្ថភាពប្រកួតប្រជែង នៅពេលដែលពួកគេជ្រើសរើសដៃគូ សម្រាប់ផ្គត់ផ្គង់ផលិតផលរបស់ខ្លួន។ ផលិតភាពទាប គឺដោយសារតែសហជីពច្រើននៅកម្ពុជា។

## ក្រាហ្វិកអំពីការនាំចេញសំលៀកបំពាក់ និងវាយនភ័ណ្ឌរបស់ព្រះរាជាណាចក្រកម្ពុជា




## ក្រាហ្វិកអំពីកំណើនប្រាក់បៀវត្សរ៍ជាមធ្យមរបស់ពលករក្នុងឧស្សាហកម្មកាត់ដេរនៅកម្ពុជា



អតិថិជនរបស់ក្រុមហ៊ុន ហ្គ្រេន ធ្វីន ធ្វើប្រតិបត្តិការនៅក្នុងទីផ្សារដែលមានការប្រកួតប្រជែង រួមជាមួយការកើនឡើងនៃម៉ាកផលិតផលក្នុងស្រុក និងអន្តរជាតិ។ ទោះបីជា មានម៉ាកខុសគ្នាច្រើននៅក្នុងទីផ្សារម៉ូដសំលៀកបំពាក់ក៏ដោយ ក៏មិនមែនម៉ាកផលិតផលទាំងអស់សុទ្ធតែធ្វើការប្រកួតប្រជែងដោយផ្ទាល់ដែរ ដោយសារតែបំណែងចែកទីផ្សារខុសៗគ្នា។ ក្រុមហ៊ុន ហ្គ្រេន ធ្វីន ជឿជាក់ថា អតិថិជនរបស់ក្រុមហ៊ុន និងដៃគូប្រកួតប្រជែងរបស់ពួកគាត់ មានបំណែងចែកទីផ្សារចាប់ពីថ្នាក់កណ្តាលរហូតដល់ថ្នាក់ខ្ពស់។

នៅព្រះរាជាណាចក្រកម្ពុជា មានឧស្សាហករកិច្ចសន្យាដែលដូចនឹងក្រុមហ៊ុន ហ្គ្រេន ធ្វីន ជាច្រើនដែលអាចផលិតសម្រាប់អតិថិជន OEM (Original Equipment Manufacturer) និង ODM (Original Design Manufacturer) ដោយរាប់បញ្ចូលទាំងឧស្សាហករ ដែលបច្ចុប្បន្នធ្វើការជាមួយអតិថជនចម្បងៗរបស់ក្រុមហ៊ុន ហ្គ្រេន ធ្វីន។ ពួកគេ មានសមត្ថភាពប្រកួតប្រជែងជាមួយនឹងក្រុមហ៊ុន ហ្គ្រេន ធ្វីន នៅលើកត្តាសំខាន់ៗ ដែលមានការយកចិត្តទុកដាក់ពីអតិថិជន OEM និង ODM ក្នុងពេលធ្វើការជ្រើសរើសឧស្សាហករកិច្ចសន្យាក្នុងនោះមាន កត្តាគុណភាព ពេលវេលាប្រគល់ទំនិញ ការទទួលខុសត្រូវក្នុងសង្គម និងតម្លៃ។ ទោះបីជាយ៉ាងនេះក្តី ក្រុមហ៊ុន ហ្គ្រេន ធ្វីន ជឿជាក់ថា សមត្ថភាពនៃការប្រកួតប្រជែងរបស់ក្រុមហ៊ុន ហ្គ្រេន ធ្វីន បានបែងចែកក្រុមហ៊ុនពីដៃគូប្រកួតប្រជែងរបស់ខ្លួន។

បេសកកម្មជាចម្បងរបស់ក្រុមហ៊ុន ហ្គ្រេន ធ្វីន គឺ ធ្វើអោយអតិថិជនមានការពេញចិត្ត តាមរយៈការបន្តធ្វើឲ្យប្រសើរឡើងនូវគុណភាព ការប្រគល់ទំនិញទាន់ពេល និងតម្លៃ។

### ភាពខ្លាំងរបស់ក្រុមហ៊ុន ហ្គ្រេន ធ្វីន ក្នុងការប្រកួតប្រជែង

#### ក.អត្ថប្រយោជន៍របស់ក្រុមហ៊ុនបានមកពីទំនាក់ទំនងយ៉ាងស្អិតរមួតជាមួយក្រុមហ៊ុន QMI តៃវ៉ាន់

ក្រុមហ៊ុន QMI តៃវ៉ាន់ជាក្រុមហ៊ុនមួយ ក្នុងចំណោមក្រុមហ៊ុននាំមុខគេក្នុងវិស័យកាត់ដេរនៅតៃវ៉ាន់ និងមានក្រុមហ៊ុនបុត្រសម្ព័ន្ធជាច្រើន នៅក្នុងតំបន់អាស៊ីអាគ្នេយ៍ និងសាធារណរដ្ឋប្រជាមានិតចិន។ ក្នុងនាមជាអ្នកផ្គត់ផ្គង់ផលិតផលសម្រាប់ម៉ាកសំលៀកបំពាក់ល្បីៗក្នុងសកលលោក ក្រុមហ៊ុន ហ្គ្រេន ធ្វីន ត្រូវបានតម្រូវឲ្យគោរពតាមគោលការណ៍ណែនាំជាច្រើនដែលក្នុងនោះរួមមាន វិធីសាស្រ្តទូទាត់ និងការទិញវត្ថុធាតុដើម ដែលជាកត្តាសំខាន់។ Adidas បានស្នើឲ្យក្រុមហ៊ុន ហ្គ្រេន ធ្វីន ទិញវត្ថុធាតុដើមពីអ្នកផ្គត់ផ្គង់ជាក់លាក់នៅជុំវិញសកលលោក។ ជាលទ្ធផល ដើម្បីពង្រឹងនូវអំណាចចរចាជាមួយអ្នកផ្គត់ផ្គង់ក្រុមហ៊ុន ហ្គ្រេន ធ្វីន បានចងសម្ព័ន្ធភាពជាមួយក្រុមហ៊ុន QMI នៅតៃវ៉ាន់ដើម្បីទិញវត្ថុធាតុដើម។ សម្ព័ន្ធភាពនេះ បានអនុញ្ញាតឲ្យក្រុមហ៊ុន ហ្គ្រេន ធ្វីន ទិញវត្ថុធាតុដើមនៅក្នុងតម្លៃមួយទាប ដោយសារការបញ្ជាទិញនៃក្រុមហ៊ុន QMI និងក្រុមហ៊ុន ហ្គ្រេន ធ្វីន មានទំហំធំ។ បន្ថែមពីនេះ Adidas បានធ្វើការទូទាត់តាមរយៈធនាគារពីរនៅទីក្រុងហុងកុង គឺ Standard Charter Bank ឬ HSBC Bank។ ដោយសារធនាគារទាំងពីរនេះមិនមានសាខានៅក្នុងព្រះរាជាណាចក្រកម្ពុជា ដូចនេះក្រុមហ៊ុន QMI នៅតៃវ៉ាន់បានជួយសម្រួលដល់ការទូទាត់របស់ក្រុមហ៊ុន ហ្គ្រេន ធ្វីន ដោយក្រុមហ៊ុន QMI បានយកកម្រៃសេវា ២០ ភាគរយ នៃការបញ្ជាទិញសរុប។

#### ខ. ក្រុមហ៊ុន ហ្គ្រេន ធ្វីន ជាអ្នកផ្គត់ផ្គង់សំលៀកបំពាក់អោយក្រុមហ៊ុនម៉ាកល្បីៗ ដូចជា Adidas

អតិថិជនធំបំផុតរបស់ក្រុមហ៊ុន ហ្គ្រេន ធ្វីន គឺ AdidasGroup ដែលបានទិញយក Reebok ក្នុងខែសីហា ឆ្នាំ២០០៥។ ជារៀងរាល់ឆ្នាំ ក្រុមហ៊ុន ហ្គ្រេន ធ្វីន បានបង្ហាត់បុគ្គលិកជំនាញ ទិញសំភារៈបរិក្ខារ និងអភិវឌ្ឍខ្សែសង្វាក់ផលិតកម្មដើម្បីឆ្លើយតបទៅនឹងស្តង់ដាររបស់ Adidas Group។

### គ. ក្រុមហ៊ុន ប្រេ្គន ធ្វីន ទទួលបានការលើកលែងពន្ធពីប្រទេសកាណាដា និងសហភាពអឺរ៉ុប

ទំនិញដែលនាំចេញពីព្រះរាជាណាចក្រកម្ពុជា មានការលើកលែងពន្ធលើការនាំចូលពី ប្រទេសកាណាដា និង សហភាពអឺរ៉ុប ពីព្រោះ ព្រះរាជាណាចក្រកម្ពុជាស្ថិតក្នុង "ប្រទេសដែលមានការអភិវឌ្ឍន៍តិចតួច (LCD)"។ សហភាពអឺរ៉ុប បានផ្តល់ការអនុគ្រោះជាច្រើនដល់ប្រទេសដែលមានការអភិវឌ្ឍន៍តិចតួច បើធៀបនឹងប្រទេសកំពុងអភិវឌ្ឍន៍។ នៅខែកុម្ភៈ ឆ្នាំ២០០១ សហភាពអឺរ៉ុបបានអនុម័តបទប្បញ្ញត្តិ (EC)៤១៦/២០០១ ស្តីពី "*ទំនិញគ្រប់មុខលើកលែងអាវុធ EBA*" ដែល អនុញ្ញាតឲ្យនាំចូលដោយរួចពន្ធ សម្រាប់ផលិតផលគ្រប់ប្រភេទលើកលែងតែអាវុធយុទ្ធភ័ណ្ឌពីប្រទេសដែលមានការ អភិវឌ្ឍន៍តិចតួច ដោយគ្មានការកំហិតពីបរិមាណ (លើកលែងផលិត ផលដូចជា ចេក ស្ករ និងស្រូវ ដែលមានរយៈពេល កំណត់)។ ក្រោយមកបទប្បញ្ញត្តិ EBA ត្រូវបានដាក់បញ្ចូលទៅក្នុងបទប្បញ្ញត្តិស្តីពីប្រព័ន្ធអនុគ្រោះទូទៅ (GSP Council Regulation) (EC) លេខ ២៥០១/២០០១។ បទប្បញ្ញត្តិនេះ រំពឹងថា កិច្ចព្រមព្រៀងពិសេសៗសម្រាប់ប្រទេសដែលមាន ការអភិវឌ្ឍន៍តិចតួច ត្រូវតែមានរយៈពេលមិនកំណត់ និងមិនត្រូវប្រឈមនឹងការបន្តតាមដំណាក់កាលនៃគំរោងអនុគ្រោះ ទូទៅរបស់សហភាពអឺរ៉ុបឡើយ។ ប្រទេសកាណាដា ក៏បានផ្តល់ការអនុគ្រោះពន្ធនាំចូលដល់ប្រទេសដែលមានការ អភិវឌ្ឍន៍តិចតួចដែរ តាមរយៈការកំណត់ពន្ធនាំចូលលំអៀងទូទៅ និងការកំណត់ពន្ធនាំចូលលំអៀងសម្រាប់ប្រទេសដែល មានការអភិវឌ្ឍន៍តិចតួច។

### ឃ. ក្រុមហ៊ុន ប្រេ្គន ធ្វីន មាននិយោជិតដែលអាចទុកចិត្ត និងជឿជាក់បាន

ក្រុមហ៊ុន ប្រេ្គន ធ្វីន ជាអ្នកផ្គត់ផ្គង់សំលៀកបំពាក់សម្រាប់ម៉ាកសំលៀកបំពាក់កីឡាល្បីៗមួយចំនួន និងប្រតិបត្តិ តាមស្តង់ដារអន្តរជាតិ។ ក្រុមហ៊ុននេះ ទទួលបាននូវភាពស្មោះត្រង់ពីនិយោជិត ហើយច្រើនជាង ៣៥% នៃនិយោជិត សរុបបានបន្តធ្វើការងារជាមួយក្រុមហ៊ុននេះលើសពី ៥ឆ្នាំ។

### ង.គណៈគ្រប់គ្រងនៃក្រុមហ៊ុន ប្រេ្គន ធ្វីន មានបទពិសោធន៍ខ្ពស់

គណៈគ្រប់គ្រងនៃក្រុមហ៊ុន ប្រេ្គន ធ្វីន មានបទពិសោធន៍ខ្ពស់ផ្នែកផលិតកម្មសំលៀកបំពាក់ខាងក្រៅ (outdoor clothing) ដែលមានដូចជា លោកនាយកប្រតិបត្តិ Liao Chung Te លោកនាយកហិរញ្ញវត្ថុ និងជាប្រធានផ្នែកប្រតិបត្តិការ លោក Hsienh Chung Nan។ អ្នកគ្រប់គ្រងទាំងនេះ មានបទពិសោធន៍ជាង ១០ឆ្នាំ មកហើយ នៅក្នុងវិស័យកាត់ដេរ។ គណៈគ្រប់គ្រងរបស់ក្រុមហ៊ុន ប្រេ្គន ធ្វីន ផ្តោតសំខាន់ទៅលើទិសដៅ និងការអនុវត្តយុទ្ធសាស្ត្ររបស់ក្រុមហ៊ុនដែលបាន ដាក់ចេញ។ ក្រុមហ៊ុន ប្រេ្គន ធ្វីន ជឿជាក់ថា គណៈគ្រប់គ្រងរបស់ខ្លួនមានសមត្ថភាពគ្រប់គ្រាន់ និង អាចសម្របតាមការ ប្រែប្រួលនៃទីផ្សារបានយ៉ាងឆាប់រហ័ស។

### ច.ភូមិសាស្ត្រចំរុះនៃទីផ្សារផលិតផល

ទីផ្សាររបស់អតិថិជននៃក្រុមហ៊ុន ប្រេ្គន ធ្វីន មាននៅគ្រប់ទីកន្លែងក្នុងសកលលោក ដូចជា សហរដ្ឋអាមេរិក អឺរ៉ុប និងអាស៊ី ដែលផ្តល់ឲ្យក្រុមហ៊ុនជាមួយនឹងភូមិសាស្ត្រចំរុះនៃទីផ្សារផលិតផល។

### ឆ.ក្រុមហ៊ុន ប្រេ្គន ធ្វីន បាននាំចូលនូវបច្ចេកវិទ្យា "Down"

ក្រុមហ៊ុន ប្រេ្គន ធ្វីន បាននាំចូលនូវបច្ចេកវិទ្យា "Down" សម្រាប់ផលិតអាវរងានៅក្នុងរោងចក្ររបស់ខ្លួន។ បច្ចេក វិទ្យានេះ ជួយបង្កើនគុណភាពអាវរងាឲ្យបានប្រសើរជាងមុន ដោយជួយបង្ខាប់ថ្នេរខោអាវរងាជំនួសដោយការប្រើអំបោះដេរ ភ្ជាប់ថ្នេរខោអាវ។ សាច់ក្រណាត់ខាងក្រៅនៃអាវរងា ជាធម្មតាផលិតពីអំបោះនីឡុងដែលមាំនិងមិនជ្រាបទឹក។ ការបង្ខាប់ ថ្នេរខោអាវបៀបនេះ ដើម្បីធានាថា ទឹកមិនអាចជ្រាបចូលខាងក្នុងតាមរយៈថ្នេរខោអាវ។ ដោយសារគុណភាពនៃ ផលិតផល

ដែលប្រើប្រាស់ដោយបច្ចេកវិទ្យា "Down" ក្រុមហ៊ុន មានភាពប្រកួតប្រជែងខ្ពស់ជាងដៃគូប្រកួតប្រជែងផ្សេងទៀត នៅក្នុងទីផ្សារអាវរងា។

## យុទ្ធសាស្ត្រធុរកិច្ចរបស់ក្រុមហ៊ុន

### ក. ក្រុមហ៊ុន ហ្វ្រេន ធ្វីន បន្តវិនិយោគក្នុងបច្ចេកវិទ្យាថ្មីៗ ដែលអាចអនុញ្ញាតឲ្យក្រុមហ៊ុនបន្តផ្តល់ជូននូវផលិតផលថ្មីៗ

ក្រុមហ៊ុន ហ្វ្រេន ធ្វីន បន្តបញ្ចូលបច្ចេកវិទ្យាថ្មីៗទៅក្នុងប្រតិបត្តិការរបស់ខ្លួន។ ទន្ទឹមនឹងនេះក្រុមហ៊ុន នឹងបន្តស្វែងរកនូវកាលានុវត្តភាព ដោយធ្វើកិច្ចសហប្រតិបត្តិការជាមួយក្រុមហ៊ុនម៉ាកអន្តរជាតិល្បីៗ និងបន្តពង្រីកទីផ្សារ និងអភិវឌ្ឍជំនាញបច្ចេកទេសដើម្បីបង្កើនសមត្ថភាពភាពប្រកួតប្រជែងជាសកល។

### ខ. ក្រុមហ៊ុន ហ្វ្រេន ធ្វីន ធានាថា នឹងឆ្លើយតបតាមតម្រូវការរបស់អតិថិជន

គណៈគ្រប់គ្រង និងក្រុមការងារផ្នែកផលិតផលរបស់ក្រុមហ៊ុន ហ្វ្រេន ធ្វីន បន្តធ្វើឲ្យផលិតផល និងសេវាកម្មសម្រាប់អតិថិជនប្រសើរឡើង ព្រមទាំងបង្កើតផលិតផលថ្មីដើម្បីឆ្លើយតបនឹងតម្រូវការអតិថិជន។

### គ. ក្រុមហ៊ុន ហ្វ្រេន ធ្វីន ធានានូវប្រសិទ្ធភាពក្នុងផលិតកម្ម និងការប្រគល់ទំនិញ

ក្រុមហ៊ុន ហ្វ្រេន ធ្វីន បានធ្វើកំណែទម្រង់ផលិតកម្មសំលៀកបំពាក់តាមរយៈការបន្សំសាច់ក្រណាត់កប្បាស និងទៀនប្រភេទថ្មីដែលមានគុណភាពល្អជាងមុន ការប្រើប្រាស់វិធីសាស្ត្រផ្សេងៗសម្រាប់ការជ្រលក់ពណ៌ ចាក់ ដេរ និងប៉ាក់ និងការប្រើប្រាស់វិធីសាស្ត្រផ្សេងៗសម្រាប់កាត់ ដាក់ស្រទាប់ រចនាម៉ូដ និងរបៀបខ្ចប់ថ្មីៗ។ ក្នុងដំណាក់កាលផលិតកម្មនីមួយៗ វិធីសាស្ត្រល្អថ្មីៗ ត្រូវបានប្រើប្រាស់សម្រាប់បង្កើនប្រសិទ្ធភាព។ ដោយសារក្រុមហ៊ុន ហ្វ្រេន ធ្វីន ស្ថិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលមានភូមិសាស្ត្រនៅជិតអ្នកផ្គត់ផ្គង់វត្ថុធាតុដើមធ្វើអោយការដឹកជញ្ជូនទំនិញមានភាពឆាប់រហ័ស។ ជាលទ្ធផល ក្រុមហ៊ុន ហ្វ្រេន ធ្វីន អាចកាត់បន្ថយរយៈពេលដឹកជញ្ជូនទំនិញ បង្កើនប្រសិទ្ធភាពក្នុងការគ្រប់គ្រងសន្និធិ និងបង្កលក្ខណៈឲ្យក្រុមហ៊ុនអាចប្រគល់ទំនិញទៅឲ្យអតិថិជនទាន់ពេល។ ក្រុមហ៊ុន ហ្វ្រេន ធ្វីន បានប្រើប្រាស់នូវប្រព័ន្ធកំណត់តាមពេលពិត ដើម្បីកត់ត្រានូវការបញ្ជាទិញ និងការបញ្ជូនទំនិញរបស់ក្រុមហ៊ុន ហ្វ្រេន ធ្វីន។

ដើម្បីបង្កើនប្រសិទ្ធភាពផលិតកម្ម ក្រុមហ៊ុន ហ្វ្រេន ធ្វីន បានបំពាក់នូវម៉ាស៊ីនទំនើបៗ និងកម្មវិធីព័ត៌មានវិទ្យាថ្មីៗនៅក្នុងរោងចក្រ ដូចជា កម្មវិធីគូរគំរូដែលអាចគូរគំរូខោអាវ សម្រាប់កាត់អោយបានត្រឹមត្រូវ និងឆាប់រហ័ស។ កម្មវិធី នេះជួយសន្សំពេលវេលា និងពលកម្មជាច្រើននៅក្នុងរោងចក្រ។ បន្ថែមពីកម្មវិធីនេះ ក្រុមហ៊ុនបានប្រើប្រាស់នូវបច្ចេកវិទ្យា "Down" ដែលអាចឲ្យក្រុមហ៊ុនផលិតបាននូវខោអាវរងាដែលមានគុណភាពខ្ពស់។ ក្រុមហ៊ុន ក៏បានតម្លើងកម្មវិធីដែល តម្រូវដោយក្រុមហ៊ុន Adidas សម្រាប់ចុះបញ្ជីលេខកូដដោយផ្ទាល់ និងដោយស្វ័យប្រវត្តិទៅលើផលិតផលសម្រេច នីមួយៗ។

### ឃ. ក្រុមហ៊ុន ហ្វ្រេន ធ្វីន ធានាធ្វើឲ្យផលិតផលមានគុណភាពល្អឥតខ្ចោះ

ភាពជោគជ័យរបស់ក្រុមហ៊ុន គឺពឹងផ្អែកសំខាន់ទៅលើសមត្ថភាពក្នុងការផ្គត់ផ្គង់ទំនិញ ដែលមានគុណភាពខ្ពស់ដល់អតិថិជន។ ដើម្បីសម្រេចបាននូវឆន្ទៈនេះ រាល់បុគ្គលិកក្រុមហ៊ុនម្នាក់ៗ ត្រូវដឹងពីទំនួលខុសត្រូវរបស់ខ្លួនដើម្បីធានាថា ផលិតផល គឺមានគុណភាពល្អបំផុតតាមដែលអាចធ្វើទៅបាន។ ក្រុមហ៊ុន ក៏បានផ្តល់នូវសៀវភៅដែលបង្ហាញពីរបៀបប្រើដល់បុគ្គលិកដើម្បីធានាថា ពួកគាត់បានយល់ច្បាស់អំពីនីតិវិធីការងារ។ ក្រុមត្រួតពិនិត្យគុណភាពជាអ្នកអនុវត្ត និងត្រួតពិនិត្យគោលការណ៍ "គ្មានខុស" ឬ "គោលនយោបាយជោគជ័យ ១០០%" លើផលិតផលគ្រប់ប្រភេទទៅតាមដំណាក់កាលនីមួយៗក្នុងដំណើរការផលិតកម្ម។ គោលការណ៍នេះ ក៏អនុវត្តទៅលើការទិញវត្ថុធាតុដើមនិងគ្រឿងបន្ទាប់បន្សំផងដែរ។ វត្ថុ

ធាតុដើម និងគ្រឿងបន្ទាប់បន្សំត្រូវបានទិញពីអ្នកផ្គត់ផ្គង់ដែលត្រូវបានជ្រើសរើស និងយល់ព្រមដោយ Adidas។ គ្រប់វត្ថុធាតុដើម និងគ្រឿងបន្ទាប់បន្សំ ត្រូវបានត្រួតពិនិត្យបន្ថែមមុនពេលប្រើប្រាស់ក្នុងផលិតកម្មដើម្បីធានាថា វត្ថុធាតុទាំងនោះត្រឹមត្រូវតាមការកំណត់ជាក់លាក់ និងមិនមានភាពខ្វះចន្លោះ។ គ្រប់ផលិតផលសម្រេចទាំងអស់ត្រូវបានត្រួតពិនិត្យជាលើកចុងក្រោយមុនពេលប្រគល់ទំនិញជូនអតិថិជន។

ដោយសារវិស័យកាត់ដេរ នៅតែជាវិស័យដែលប្រើប្រាស់កម្លាំងពលកម្មច្រើនវាមានសារៈសំខាន់ណាស់ដែលបុគ្គលិកមានការពេញចិត្តពីតួនាទីការងាររបស់ខ្លួន ការចូលរួមចំណែក និងការយល់ច្បាស់ពីគំនិតនៃការគ្រប់គ្រងគុណភាពទាំងមូល។ បុគ្គលិកគ្រប់ផ្នែកទាំងអស់ ត្រូវបានហ្វឹកហ្វឺនក្នុងការស្វែងរកកំហុសដែលអាចកើតមានឡើងនៅគ្រប់ដំណាក់កាលក្នុងដំណើរការផលិតកម្ម។ ដំណាក់កាលនីមួយៗក្នុងដំណើរការផលិតកម្ម ត្រូវបានបង្ហាញយ៉ាងល្អិតល្អន់ដល់បុគ្គលិក ដូច្នេះ ពួកគេអាចយល់ថាតើការងាររបស់ខ្លួនមានឥទ្ធិពលទៅលើផលិតកម្មទាំងមូលយ៉ាងដូចម្តេច។

# ២. ព័ត៌មានអំពី លទ្ធផលប្រតិបត្តិការធុរកិច្ច ក្រុមហ៊ុន ប្រេក្តន ធ្វីន

គណនីទាំងអស់ដែលមានក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ត្រូវបានវាស់វែងដោយប្រើប្រាស់រូបិយបណ្ណនៃបរិយាកាសសេដ្ឋកិច្ចចម្បងដែលក្រុមហ៊ុនធ្វើប្រតិបត្តិការ (ហៅកាត់ថា "រូបិយបណ្ណគោល")។ រូបិយបណ្ណជាតិ របស់ព្រះរាជាណាចក្រកម្ពុជាគឺ ប្រាក់រៀលខ្មែរ ("រៀល")។ យ៉ាងណាមិញដោយសារ ក្រុមហ៊ុនធ្វើប្រតិបត្តិការអាជីវកម្ម និងរក្សានូវកំណត់ត្រាគណនេយ្យចម្បងជាប្រាក់ដុល្លារអាមេរិក ថ្នាក់ដឹកនាំក្រុមហ៊ុនកំណត់យក ប្រាក់ដុល្លារអាមេរិក ជារូបិយបណ្ណគោល និងរូបិយបណ្ណបង្ហាញដោយសារវាឆ្លុះបញ្ចាំងពីសារធាតុសេដ្ឋកិច្ចនៃព្រឹត្តិការណ៍និងកាលៈទេសៈរបស់ក្រុមហ៊ុន។

ការបកប្រែពីប្រាក់រៀល ទៅប្រាក់ដុល្លារអាមេរិក ត្រូវបានបង្ហាញក្នុងរបាយការណ៍ហិរញ្ញវត្ថុសម្រាប់ឆ្នាំ២០១៦ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ ឆ្នាំ២០១៥ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ និងឆ្នាំ២០១៤ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ដោយប្រើប្រាស់អត្រាប្តូរប្រាក់ផ្លូវការរបស់ធនាគារជាតិនៃកម្ពុជា ក្នុងតារាងខាងក្រោម៖

| ឆ្នាំ | ប្រាក់រៀល/ដុល្លារអាមេរិក ត្រឹមថ្ងៃទី៣១ ខែធ្នូ | អត្រាប្តូរប្រាក់ជាមធ្យមប្រចាំឆ្នាំ |
|---|---|---|
| ២០១៧ | ៤.០៥៣ | ៤.០៥៣ |
| ២០១៦ | ៤.០៣៧ | ៤.០០០ |
| ២០១៥ | ៤.០៥០ | ៤.០៦០ |

*ប្រភព: ធនាគារជាតិនៃកម្ពុជា*

ប្រតិបត្តិការជារូបិយបណ្ណផ្សេងៗក្រៅពីរូបិយបណ្ណគោលរបស់ក្រុមហ៊ុន (ហៅថា "រូបិយបណ្ណបរទេស") ត្រូវបានប្តូរទៅជាប្រាក់ដុល្លារអាមេរិក ដោយប្រើអត្រាប្តូរប្រាក់នៅថ្ងៃប្រតិបត្តិការនោះ។ ទ្រព្យសកម្ម និងបំណុលជារូបិយបណ្ណបរទេសត្រូវប្តូរទៅជាប្រាក់ដុល្លារអាមេរិក ដោយប្រើអត្រាប្តូរប្រាក់នាថ្ងៃតារាងតុល្យការ លើកលែងតែត្រូវបានទ្រទ្រង់ដោយប្រើប្រាស់កិច្ចសន្យាអត្រាប្តូរប្រាក់បរទេសនាពេលអនាគត ក្នុងករណីបែបនេះអត្រាដែលបានកំណត់នៅក្នុងកិច្ចសន្យានេះនឹងត្រូវប្រើប្រាស់។ អត្រាប្តូរប្រាក់ផ្សេងគ្នាដែលកើតឡើងពីការទូទាត់ និងការកែសម្រួលទ្រព្យសកម្ម និងបំណុលជាទឹក ប្រាក់ជារូបិយបណ្ណបរទេស ត្រូវកត់ត្រាក្នុងរបាយការណ៍លទ្ធផលនៅក្នុងការិយបរិច្ឆេទដែលកើតឡើង។ ទ្រព្យសកម្ម និង បំណុលដែលមិនមែនជាទឹកប្រាក់ដែលកត់ត្រាដំបូងជា រូបិយបណ្ណបរទេស ហើយយោងជាតម្លៃដើមត្រូវបានប្រែសម្រួល ដោយប្រើអត្រាដើមនៅថ្ងៃទិញ ហើយចំពោះទ្រព្យសកម្ម និងបំណុលមិនមែនជាសាច់ប្រាក់ដែលយោងជាតម្លៃទីផ្សារ ត្រូវបានប្រែសម្រួលដោយប្រើអត្រាប្តូរប្រាក់ដែលកើតឡើងនៅពេលដែលតម្លៃនៃទ្រព្យសកម្ម និងបំណុលទាំងនោះត្រូវបានកំណត់ក្នុងគោលបំណងសម្រាប់បង្ហាញ។

ចំណូលរបស់ក្រុមហ៊ុន ហ្ក្រេន ធ្វីន រួមមាន ចំណូលពីការលក់ទំនិញ ចំណូលពីការម៉ៅការ និងចំណូលពីកាត់ ដេរ និងវេចខ្ចប់ ។ សម្រាប់ ឆ្នាំ២០១៧ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ នេះ ចំណូលពីការលក់ទំនិញ មានចំនួនមិនតិចជាង ៩៩% នៃចំណូលសរុប។ ចំណូលពីការម៉ៅការ និងចំណូលពី កាត់ ដេរ និងវេចខ្ចប់ មានចំនួនតិចតួចបើប្រៀបធៀបនឹងចំណូលសរុប។ ហេតុដូច្នេះ រាល់ការប្រែប្រួលជាចំបងនៃការលក់ និងចំណូលសរុប គឺបណ្តាលមកពីការប្រែប្រួលចំណូលពីការលក់ទំនិញ។ ចំណូលពីការលក់ទំនិញ ពឹងផ្អែកទៅលើចំនួនសំលៀកបំពាក់ ដែលក្រុមហ៊ុនផលិត និងលក់ទៅឲ្យ

អតិថិជន។ ចំណូលតាមផ្នែករបស់ក្រុមហ៊ុន ហ្គ្រេន ធ្វីន សម្រាប់ដំណាច់ការិយបរិច្ឆេទ ឆ្នាំ២០១៧ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ ឆ្នាំ២០១៦ និងឆ្នាំ២០១៥ បង្ហាញដូចខាងក្រោម៖

ចំណូលសរុប សម្រាប់ដំណាច់ការិយបរិច្ឆេទ ឆ្នាំ២០១៧ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧

# ៣២៣.៩៨៧.៤១៤.000 រៀល

ស្មើនឹងប្រមាណ **៨0.0៩៥.៧៧៦.000** ដុល្លារអាមេរិក




**ចំណូលបានពីការលក់ទំនិញ**

៣៣៨.៥៨៥.២៤៥.000 រៀល ប្រមាណជា ៨៣.៧0៤.៦៣៤ ដុល្លារអាមេរិក

ស្មើនឹង **៩៨,២0%** នៃចំណូលសរុប

**ចំណូលពីកាត់ ដេរ និងវេចខ្ចប់**

៦.២១១.៥៩៥.000 រៀល ប្រមាណជា ១.៥៣៥.៦២៣ ដុល្លារអាមេរិក

ស្មើនឹង **១,៨0%** នៃចំណូលសរុប

(ការលក់បញ្ចុះតម្លៃ ចំនួន ៥.១៤៤.៤៨១ ដុល្លារអាមេរិក)

ចំណូលសរុប សម្រាប់ដំណាច់ការិយបរិច្ឆេទ ឆ្នាំ២០១៦ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦

# ៣៣១.៤០៧.៣០៥.០០០ រៀល

## ស្មើនឹងប្រមាណ ៨២.០៩២.៤៧១ ដុល្លារអាមេរិក




**ចំណូលបានពីការលក់ទំនិញ**

៣៣០.១០៦.១៨៨.០០០ រៀល ប្រមាណជា ៨១.៧៧០.១៧៣ ដុល្លារអាមេរិក

ស្មើនឹង ៩៩,៦១% នៃចំណូលសរុប

**ចំណូលបានពីការម៉ៅការ**

២៣៣.៥៣៦.០០០ រៀល ប្រមាណជា ៥៧.៨៤៩ ដុល្លារអាមេរិក

ស្មើនឹង 0,0៧% នៃចំណូលសរុប

**ចំណូលពីកាត់ ដេរ និងវេចខ្ចប់**

១.០៦៧.៥៨១.០០០ រៀល ប្រមាណជា ២៦៤.៤៤៩ ដុល្លារអាមេរិក

ស្មើនឹង 0,៣២% នៃចំណូលសរុប

ចំណូលសរុប សម្រាប់ដំណាច់ការិយបរិច្ឆេទ ឆ្នាំ២០១៥ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥

# ២២៩.៩៣៩.០៦៦.០០០ រៀល

ស្មើនឹងប្រមាណ **៥៦.៧៧៥.០៧៨** ដុល្លារអាមេរិក




**ចំណូលបានពីការលក់ទំនិញ**

២២០.៥៤៧.៨៣៦.០០០ រៀល ប្រមាណជា ៥៤.៤៥៦.០០៩ ដុល្លារអាមេរិក

ស្មើនឹង **៩៥,៩២%** នៃចំណូលសរុប

**ចំណូលបានពីការម៉ៅការ**

៤.៤៦៨.៨៤៣.០០០ រៀល ប្រមាណជា ១.១០៣.៤១៨ ដុល្លារអាមេរិក

ស្មើនឹង **១,៩៤%** នៃចំណូលសរុប

**ចំណូលពីកាត់ ដេរ និងវេចខ្ចប់**

៤.៩២៣.៣៨៧.០០០ រៀល ប្រមាណជា ១.២១៥.៦៥១ ដុល្លារអាមេរិក

ស្មើនឹង **២,១៤%** នៃចំណូលសរុប

**ក. ការប្រែប្រួលសំខាន់នៃប្រាក់ចំណូល ថ្លៃដើមលក់ ចំណាយប្រតិបត្តិការផ្សេងៗ និងចំណេញសុទ្ធ**

ក្រុមហ៊ុន ហ្គ្រេន ធ្វីន មានគម្រោងប្រើប្រាស់សាច់ប្រាក់បន្ថែមរបស់ក្រុមហ៊ុន ហ្គ្រេន ធ្វីន ទៅលើខ្សែសង្វាក់ផលិតកម្មថ្មីចំនួន ២០ នៅឆ្នាំ២០១៥ សម្រាប់ផលិតផលិតផលអាវរងា។ ក្រុមហ៊ុន ហ្គ្រេន ធ្វីន រំពឹងទុកថា ខ្សែសង្វាក់ផលិតកម្មទាំងនេះ នឹងបង្កើនប្រាក់ចំណូលរបស់ក្រុមហ៊ុន ហ្គ្រេន ធ្វីន។

ក្រុមហ៊ុន ហ្គ្រេន ធ្វីន រំពឹងទុកថា ថ្លៃឈ្នួលពលកម្មនឹងកើនឡើង ដោយមូលហេតុលក្ខខណ្ឌពលកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ក្រុមហ៊ុន ហ្គ្រេន ធ្វីន ក៏រំពឹងដែរថា តម្លៃវត្ថុធាតុដើម (ពិសេសតម្លៃវត្ថុធាតុដើមដែលក្រុមហ៊ុន ហ្គ្រេន ធ្វីន ត្រូវការសម្រាប់ផលិតផលអាវរងា (down products) នឹងមានការកើនឡើង។ ជាលទ្ធផល ថ្លៃលក់នឹងត្រូវកើនឡើង។ ក្រុមហ៊ុន ហ្គ្រេន ធ្វីន មិនរំពឹងថា នឹងមានការកើនឡើងខ្ពស់លើការចំណាយប្រតិបត្តិការឡើយ។ ជារួម ក្រុមហ៊ុន ហ្គ្រេន ធ្វីន រំពឹងថា ប្រាក់ចំណេញសុទ្ធ នឹងមានការកើនឡើង។

**ទិដ្ឋភាពតាមរដូវកាលនៃធុរកិច្ច**

ប្រាក់ចំណូលដុល ជាទូទៅ មានការប្រែប្រួលតាមរដូវកាល ពីព្រោះ ផលិតផលផ្លាស់ប្តូរទៅតាមបំរែបំរួលអាកាសធាតុ និងស្ថានភាពទីផ្សាររបស់អតិថិជន។ ប្រាក់ចំណូល ជាទូទៅកើនឡើងខ្ពស់បំផុតចាប់ពី ខែកក្កដា ដល់ខែធ្នូ ដែលជារដូវកាលលក់ដាច់ជាងគេបំផុត។ នៅក្នុងរយៈពេលនេះ ផលិតផលដែលផ្តល់ប្រាក់ចំណេញខ្ពស់ ដូចជា សំលៀកបំពាក់សរទរដូវ និងសិសិររដូវ លក់ដាច់ខ្លាំងជាងគេ។ ចាប់ពីខែមករា ដល់ ខែមិថុនា ក្រុមហ៊ុន ហ្គ្រេន ធ្វីន លក់សំលៀកបំពាក់សម្រាប់និទាឃរដូវ និងរដូវក្តៅ។

**និន្នាការ ព្រឹត្តិការណ៍ ឬភាពមិនប្រក្រតី**

ក្រុមហ៊ុន ហ្គ្រេន ធ្វីន រំពឹងថា នឹងមានការប្រែប្រួលខ្លាំងចំពោះតម្លៃលក់ផលិតផល ដោយសារនាពេលបច្ចុប្បន្នមាននិន្នាការកំណើនថ្លៃ។ ថ្លៃដើមដែលរួមមាន ថ្លៃវត្ថុធាតុដើម និងសម្ភារៈសម្រាប់វេចខ្ចប់ ថ្លៃឈ្នួលពលកម្ម និងចំណាយផ្សេង គឺមានការកើនឡើងក្នុងរយៈពេល ៣ឆ្នាំ ចុងក្រោយ គិតចាប់ពីឆ្នាំ២០១៤ ដល់ ឆ្នាំ២០១៦។ ផ្អែកលើនិន្នាការបច្ចុប្បន្ន និងពេលកន្លងមកព្រមទាំងហេតុការណ៍ជាយថាហេតុ ក្រុមហ៊ុន ហ្គ្រេន ធ្វីន មិនរំពឹងថា នឹងមានអ្វីផ្លាស់ប្តូរជាពីនិន្នាការនេះ នៅឆ្នាំ២០១៥ ឡើយ ហើយក្រុមហ៊ុន ហ្គ្រេន ធ្វីន រំពឹងថា សន្និធិរបស់ក្រុមហ៊ុនមានកំរិតស្ថេរភាពដោយសារ ក្រុមហ៊ុន ហ្គ្រេន ធ្វីន គ្រប់គ្រងសន្និធិដោយឈរលើមូលដ្ឋានទាន់ពេល (just-in time basis)។

ក្រុមហ៊ុន ហ្គ្រេន ធ្វីន ជឿជាក់ថា នឹងពុំមាននិន្នាការផ្សេងទៀត ស្តីពីផលិតកម្ម ការលក់សន្និធិ ថ្លៃចំណាយ ថ្លៃលក់ផលិតផល និងសេវាកម្ម ឬនិន្នាការផ្សេងទៀត ភាពមិនច្បាស់លាស់ តម្រូវការ ការប្តេជ្ញាចិត្ត ឬព្រឹត្តិការណ៍ដែលអាចធ្វើឲ្យមានផលប៉ះពាល់ធ្ងន់ធ្ងរដល់ប្រាក់ចំណូល ចំណាយមូលធនសំខាន់ៗចំណេញភាពសន្ទនីយភាព ប្រភពទុន ព្រឹត្តិការណ៍ ឬប្រតិបត្តិការមិនប្រក្រតី ឬកើតឡើងដោយចៃដន្យណាមួយ ឬការប្រែប្រួលសេដ្ឋកិច្ចសំខាន់ណាមួយ ដែលនឹងជះឥទ្ធិពលធ្ងន់ធ្ងរដល់ចំណេញប្រតិបត្តិការ ឬដែលអាចបណ្តាលឲ្យព័ត៌មានហិរញ្ញវត្ថុ ដែលផ្សព្វផ្សាយក្នុងរបាយការណ៍ប្រចាំឆ្នាំឆ្នាំ២០១៦ នេះ ពុំអាចឆ្លុះបញ្ចាំងបាននូវលទ្ធផលអាជីវកម្មនាពេលអនាគត ឬលក្ខខណ្ឌហិរញ្ញវត្ថុឡើយ។

**ខ. ការប្រែប្រួលចំពោះទ្រព្យសកម្មប្រើប្រាស់សម្រាប់ទូទាត់បំណុល**

ក្រុមហ៊ុន ហ្គ្រេន ធ្វីន មិនមានការប្រែប្រួលចំពោះទ្រព្យសកម្មដែលប្រើប្រាស់សម្រាប់ទូទាត់បំណុលទេ។

**កម្ចីសំខាន់ៗរវាងក្រុមហ៊ុនហូលឌីង និងក្រុមហ៊ុនបុត្រសម្ព័ន្ធ**

គិតត្រឹមការិយបរិច្ឆេទឆ្នាំ២០១៧ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ ក្រុមហ៊ុន ហ្គ្រេន ធ្វីន ពុំមានកម្ចីសំខាន់ៗពីក្រុមហ៊ុនហូលឌីង និងក្រុមហ៊ុនបុត្រសម្ព័ន្ធទេ។

**កិច្ចសន្យាបំណុល និងបំណុលជាយថាហេតុនាពេលអនាគត**

គិតត្រឹមការិយបរិច្ឆេទឆ្នាំ២០១៧ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ ក្រុមហ៊ុន ហ្គ្រេន ធ្វីន គ្មានកិច្ចសន្យាបំណុល និងបំណុលជាយថាហេតុនាពេលអនាគតក្រៅពីកិច្ចសន្យាដែលបានរៀបរាប់ ក្នុងរបាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍សវនករឯករាជ្យ សម្រាប់ដំណាច់ការិយបរិច្ឆេទឆ្នាំ២០១៧ នេះ ឡើយ។

**គ. អាករលើតម្លៃបន្ថែមពន្ធលើប្រាក់ចំណេញ ពន្ធគយ ឬចំណុលពន្ធផ្សេងៗ រួមទាំងបំណុលជាយថាហេតុ**

**អាករលើតម្លៃបន្ថែម**

គិតត្រឹមការិយបរិច្ឆេទឆ្នាំ២០១៧ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ ក្រុមហ៊ុន ហ្គ្រេន ធ្វីន គ្មានបំណុលពន្ធលើអាករតម្លៃបន្ថែមដែលត្រូវបង់ជូនអគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុឡើយ។

**ពន្ធលើប្រាក់ចំណូល**

ចាប់ពីឆ្នាំ២០០៧ រហូតដល់ឆ្នាំ២០១១ ក្រុមហ៊ុន ហ្គ្រេន ធ្វីន ទទួលបានការលើកលែងពន្ធពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដូចជា ការលើកលែងពន្ធ ១០០% លើការនាំចូលម៉ាស៊ីន និងសម្ភារៈបរិក្ខាររបស់រោងចក្រ ព្រមទាំងវត្ថុធាតុដើមបើសិនជា ៨០% នៃផលិតផល គឺជាទំនិញនាំចេញ។ យោងទៅខាងមុខនូវខាតសារពើពន្ធ រយៈពេល ៥ឆ្នាំ ដើម្បីកាត់កងនឹងចំណេញនាពេលអនាគត។ ការលើកលែងពន្ធលើប្រាក់ចំណេញដែលរួមមាន រយៈពេលគន្លឹះបូកនឹងរយៈពេល ៣ឆ្នាំបូកនឹងរយៈពេលអាទិភាពចំនួន ១ ឆ្នាំ ចាប់ពីថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០០៧ ដោយទទួលបានការអនុមត័ពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

នៅឆ្នាំ២០១២ ការលើកលែងពន្ធត្រូវបានបញ្ចប់ ក្រុមហ៊ុន ហ្គ្រេន ធ្វីន មានកាតព្វកិច្ចបង់ពន្ធលើប្រាក់ចំណេញ ២០% ពន្ធលើប្រាក់ចំណេញ។ ដោយឡែក កាតព្វកិច្ចបង់ពន្ធលើប្រាក់ចំណេញសម្រាប់ឆ្នាំ២០១៤ ក្រុមហ៊ុន ទទួលបានការលើកទឹកចិត្តពន្ធ ដោយកាត់បន្ថយ ៥០ ភាគរយ នៃពន្ធលើប្រាក់ចំណេញត្រូវបង់ សម្រាប់ឆ្នាំ២០១៤ ឆ្នាំ២០១៥ និងឆ្នាំ២០១៦ ដោយសារ ក្រុមហ៊ុន ហ្គ្រេន ធ្វីន បានបោះផ្សាយ និងចុះបញ្ជីលក់មូលបត្រជាផ្លូវការនៅ ផ.ម.ក នៅអំឡុងពេល ៦ខែ ដើមឆ្នាំជាប់ពន្ធ ពោលគឺ នៅថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៤។ ដោយឡែកសម្រាប់ឆ្នាំ២០១៧ នេះ ក្រុមហ៊ុន ហ្គ្រេន ធ្វីន មិនទទួលបានការលើកទឹកចិត្តពន្ធលើប្រាក់ចំណេញដែលត្រូវបង់ ដូចឆ្នាំ២០១៤ ឆ្នាំ២០១៥ និងឆ្នាំ២០១៦ កន្លងទៅទេ។

**ពន្ធគយ**

គិតត្រឹមការិយបរិច្ឆេទឆ្នាំ២០១៧ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ នេះ ក្រុមហ៊ុន ហ្គ្រេន ធ្វីន មិនមានពន្ធគយដល់ពេលត្រូវបង់ទេ។

**បំណុលពន្ធមិនទាន់ទូទាត់ផ្សេងទៀត រួមទាំងបំណុលកើតឡើងនាពេលអនាគត**

ក្រុមហ៊ុន ហ្គ្រេន ធ្វីន មានកាតព្វកិច្ចបង់ពន្ធ ដូចដែលមានចែងក្នុងច្បាប់សារពើពន្ធនៃព្រះរាជាណាចក្រកម្ពុជា។ គិតត្រឹមការិយបរិច្ឆេទឆ្នាំ២០១៧ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ ក្រុមហ៊ុន ហ្គ្រេន ធ្វីន មានបំណុលពន្ធលើប្រាក់ចំណេញដែលក្រុមហ៊ុនមិនទាន់បានទទូទាត់ មានចំនួន ៥.៦៧០ លាន រៀល (១,៤០២ លាន ដុល្លារអាមេរិក)។

### ឃ. បញ្ញត្តិនានាពាក់ព័ន្ធនឹងបុគ្គលិក រួមទាំង ផលប្រយោជន៍ចូលនិវត្តន៍ដែលមិនពាក់ព័ន្ធ

ដើម្បីបំពេញតាមតម្រូវការរបស់អតិថិជនទៅលើសុខុមាលភាពរបស់បុគ្គលិក និងចក្ខុវិស័យក្នុងការក្លាយខ្លួនជារោងចក្រកាត់ដេរគំរូ ក្រុមហ៊ុន ហ្រ្គេន ធ្វីន បានគោរពយ៉ាងម៉ឺងម៉ាត់នូវច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា ជាពិសេស ច្បាប់ការងារ។

ដោយយោងទៅតាមបទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន ហ្រ្គេន ធ្វីន កម្មករនិយោជិតទាំងអស់មានសិទ្ធិទទួលបានប្រាក់កម្រៃធ្វើការងារបន្ថែមម៉ោង។ សម្រាប់និយោជិតដែលធ្វើការបន្ថែមម៉ោងនៅក្នុងថ្ងៃធ្វើការនិយោជិតនោះត្រូវទទួលបានប្រាក់កម្រៃបន្ថែមចំនួន ១,៥ ដង នៃប្រាក់ខែមូលដ្ឋាន។ សម្រាប់និយោជិតដែលធ្វើការបន្ថែមម៉ោងនៅក្នុងចុងសប្តាហ៍ និងថ្ងៃឈប់សម្រាក និយោជិតនោះត្រូវទទួលបានប្រាក់កម្រៃ ២ដង នៃប្រាក់ខែមូលដ្ឋាន។

និយោជិតរបស់ក្រុមហ៊ុន ហ្រ្គេន ធ្វីន ក៏ទទួលបានប្រាក់បន្ថែមសម្រាប់ថ្ងៃមិនបានឈប់សម្រាក ចំនួន ២០.០០០ រៀល (៥ ដុល្លារអាមេរិក) ក្នុង ១ សប្តាហ៍និងប្រាក់សោហ៊ុយធ្វើដំណើរចំនួន ២៨.០០០ រៀល (៧ ដុល្លារអាមេរិក) ព្រម ទាំងប្រាក់អតីតភាពការងារចាប់ពី ៨.០០០ រៀល (២ ដុល្លារអាមេរិក) ទៅ ៤៤.០០០ រៀល (១១ ដុល្លារអាមេរិក) ដោយ ផ្អែកទៅលើរយៈពេលនៃបទពិសោធន៍ក្នុងការងារ។ បន្ថែមលើផលប្រយោជន៍ទាំងនេះ និយោជិតក៏ត្រូវទទួលបានប្រាក់ថ្លៃបាយបន្ថែមចំនួន ៤.០០០ រៀល (១ ដុល្លារអាមេរិក) សម្រាប់ការងារបន្ថែមម៉ោង ចាប់ពីម៉ោង ៤:០០ ទៅ ៦:០០ ល្ងាច។

ក្រុមហ៊ុន ហ្រ្គេន ធ្វីន ក៏ផ្តល់អត្ថប្រយោជន៍ផ្សេងទៀតដល់និយោជិត យោងទៅតាមច្បាប់ការងារនៃព្រះរាជាណាចក្រកម្ពុជា ដូចជា ថ្ងៃឈប់សម្រាកប្រចាំឆ្នាំចំនួន ១៨ ទៅ ៣០ ថ្ងៃ ដោយផ្អែកទៅលើរយៈពេលនៃបទពិសោធន៍ការងារ ឈប់សម្រាកមាតុភាព ចំនួន ៩០ ថ្ងៃ ឈប់សម្រាកពិសេស (អនុញ្ញាតរហូតដល់អតិបរមាចំនួន ៧ ថ្ងៃ ក្នុងករណីមានព្រឹត្តិការណ៍ណាមួយកើតឡើងដល់គ្រួសារនិយោជិត) និងឈប់សម្រាកពេលមានជម្ងឺ ជាដើម។

ទោះបីជាក្រុមហ៊ុន ហ្រ្គេន ធ្វីន បានប្តេជ្ញាក្នុងការឆ្លើយតបទៅនឹងបទប្បញ្ញត្តិពាក់ព័ន្ធនានា ជាពិសេសគឺ ការកំណត់ប្រាក់បៀវត្សរ៍ជាមធ្យមរបស់ពលករោងចក្រកាត់ដេរ ដែលកំណត់ដោយរាជរដ្ឋាភិបាលកម្ពុជា ក៏ប៉ុន្តែកូដកម្មពីសំណាក់សហជីពកម្មករករតាមបណ្តារោងចក្រនានា នៅតែបន្តកើតឡើង។ ជាក់ស្តែង ការធ្វើកូដកម្មទូទាំងប្រទេសពីសំណាក់សហជីពកម្មករតាមបណ្តារោងចក្រនានា ក្នុងទាមទារតម្លើងប្រាក់បៀវត្សរ៍ជាមធ្យមរបស់ពលកររោងចក្រកាត់ដេរនៅដើមឆ្នាំ២០១៤ បានធ្វើឲ្យខ្សែសង្វាក់ផលិតកម្មរបស់ក្រុមហ៊ុនត្រូវបានផ្អាកមួយរយៈ។ ចំណាយប្រតិបត្តិការ និងសម្រាប់ការដោះស្រាយវិវាទមានការកើនឡើង ដែលបណ្តាលឲ្យចំណូលមានការធ្លាក់ចុះជាង ៥០% នៅឆ្នាំ២០១៤ បើធៀបនឹងចំណូលទទួលបាននៅ ឆ្នាំ២០១៣ ។ ស្ថានការណ៍នេះ នៅតែបន្តប៉ះពាល់ដល់លទ្ធផលអាជីវកម្មរបស់ក្រុមហ៊ុន ឆ្នាំ២០១៥ ផងដែរ ដោយសារកំណើននៃការចំណាយខ្ពស់លើប្រាក់បៀវត្សរ៍ជាមធ្យមរបស់ពលកររោងចក្រកាត់ដេរ ដែលធ្វើឲ្យចំណូលសរុប មានការធ្លាក់ចុះគួរឲ្យកត់សម្គាល់។ ដោយឡែក ប្រាក់បៀវត្សរ៍ជាមធ្យមរបស់ពលកររោងចក្រកាត់ដេរ ចំនួន ១៥៣ ដុល្លារអាមេរិក ត្រូវបានដាក់ឲ្យអនុវត្តនៅដើមឆ្នាំ២០១៧ កន្លងទៅ កំណើននៃការចំណាយខ្ពស់លើប្រាក់បៀវត្សរ៍ជាមធ្យមរបស់ពលកររោងចក្រកាត់ដេរ បានប៉ះពាល់ដល់លទ្ធផលអាជីវកម្មរបស់ក្រុមហ៊ុន នៅឆ្នាំ២០១៧ នេះ។ ប្រាក់បៀវត្សរ៍ជាមធ្យមរបស់ពលកររោងចក្រកាត់ដេរនៅតែបន្តកើនឡើងនៅឆ្នាំ២០១៨ ខាងមុខនេះ។

# រចនាសម្ព័ន្ធចំណូល របស់ក្រុមហ៊ុន ហ្គ្រេន ធ្វីន

| បរិយាយ | ឆ្នាំ២០១៧<br>ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ | | ឆ្នាំ២០១៦<br>ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ | | ឆ្នាំ២០១៥<br>ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ | |
|---|---|---|---|---|---|---|
| | រៀល"០០០" | ដុល្លារអាមេរិក | រៀល"០០០" | ដុល្លារអាមេរិក | រៀល"០០០" | ដុល្លារអាមេរិក |
| ចំណូលពីការលក់ទំនិញ | ៣៣៨.៥៨៥.២៤៥ | ៨៣.៧០៤.៦៣៤ | ៣៣០.១០៦.១៨៨ | ៨១.៧៧០.១៧៣ | ២២០.៥៤៦.៨៣៦ | ៥៤.៤៥៦.០០៩ |
| ចំណូលពីការម៉ៅការ | - | - | ២៣៣.៥៣៦ | ៥៧.៨៤៩ | ៤.៤៦៨.៨៤៣ | ១.១០៣.៤១៨ |
| ចំណូលពីកាត់ ដេរ និងវេចខ្ចប់ | ៦.២១១.៥៩៥ | ១.៥៣៥.៦២៣ | ១.០៦៧.៥៨១ | ២៦៤.៤៤៩ | ៤.៩២៣.៣៨៧ | ១.២១៥.៦៥១ |
| **ចំណូលសរុប** | **៣២៣.៩៨៧.៤១៤*** | **៨០.០៩៥.៧៧៦** | **៣៣១.៤០៧.៣០៥** | **៨២.០៩២.៤៧១** | **២២៩.៩៣៩.០៦៦** | **៥៦.៧៧៥.០៧៨** |

*បានដកចេញអប្បហាររលក់ចំនួន ២០.៨០៩.៤២៦.០០០ រៀល ( ៥.១៤៤.៤៨១ ដុល្លារអាមេរិក)









# ៣. អភិបាលកិច្ចសាជីវកម្ម
# ក្រុមហ៊ុន ប្រេហ្គន ធ្វីន



# ភាគហ៊ុនិក របស់ក្រុមហ៊ុន ហ្ក្រេន ធ្វីន

| | |
|---|---|
| ចំណាត់ថ្នាក់មូលបត្រកម្មសិទ្ធិដែលបោះផ្សាយ | : មូលបត្រកម្មសិទ្ធិមានសិទ្ធិបោះឆ្នោត |
| ចំនួនមូលបត្រកម្មសិទ្ធិសរុប | : ៤០.០០០.០០០ មូលបត្រកម្មសិទ្ធិ |
| ចំនួនមូលបត្រកម្មសិទ្ធិដែលបោះផ្សាយ | : ៨.០០០.០០០ មូលបត្រកម្មសិទ្ធិថ្មី |
| តម្លៃចារឹកក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ | : ១.០០០ រៀល (០,២៥ ដុល្លារអាមេរិក) |
| ថ្លៃលក់ក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ | : ៩.៦៤០ រៀល (២,៤១ ដុល្លារអាមេរិក) |
| ចំនួនទឹកប្រាក់សរុបបោះផ្សាយលក់លើកដំបូង | : ៧៧.១២០ លាន រៀល (១៩,២៨០ លាន ដុល្លារអាមេរិក) |
| អក្សរកូដ (ជាភាសាខ្មែរ និងអង់គ្លេស) | : ហ.ធ.អ (GTI) |
| លេខកូដមូលបត្រកម្មសិទ្ធិ | : KH១០០០០២០០០៣ |
| លេខកូដក្រុមហ៊ុនចុះបញ្ជី | : ០០០០២ |

គិតត្រឹមការិយបរិច្ឆេទឆ្នាំ២០១៧ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ នេះ ភាគហ៊ុនិកសរុបរបស់ក្រុមហ៊ុន ហ្ក្រេន ធ្វីន មានចំនួន ៣២៣ រូប ដែលក្នុង នោះ ភាគហ៊ុនិកនីតិបុគ្គល មានចំនួន ១១ និង ៣១២ ទៀត ជារូបវន្តបុគ្គល។ មូលបត្រកម្មសិទ្ធិមានសិទ្ធិបោះឆ្នោតសរុប របស់ក្រុមហ៊ុន ត្រូវបានកាន់កាប់ដោយភាគហ៊ុនិកជនជាតិខ្មែរ ចំនួន ១២៧ នាក់ និង ភាគហ៊ុនិកមិនមែនជនជាតិខ្មែរ ចំនួន ១៩៦ នាក់។

ក្រុមហ៊ុន Grand Twins International Ltd នៅតែជាភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតច្រើនលើសលុបរបស់ក្រុមហ៊ុន ហ្ក្រេន ធ្វីន។ ដោយឡែក រយៈពេលឡុកអាប់មូលបត្រសម្រាប់ក្រុមហ៊ុន Grand Twins International Ltd និងក្រុមហ៊ុន HOPE RIDGE LIMITED ដែលជាភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតច្រើនលើសលុបរបស់ក្រុមហ៊ុន ហ្ក្រេន ធ្វីន បានបញ្ចប់នៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៥ កន្លងទៅនេះ។ ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតច្រើនលើសលុបរបស់ក្រុមហ៊ុន មានសិទ្ធិជួញដូរមូលបត្រនៅ ផ.ម.ក បន្ទាប់ពីរយៈពេល ឡុកអាប់ត្រូវបានបញ្ចប់ ដោយអនុលោមតាមច្បាប់ នឹងបទប្បញ្ញត្តិពាក់ព័ន្ធ។



### ក. ការការពារសិទ្ធិភាគហ៊ុនិក

បន្ទាប់ពីក្រុមហ៊ុន ហ្គ្រេន ធ្វីន បានបោះផ្សាយ និងចុះបញ្ជីលក់មូលបត្រជាផ្លូវការនៅ ផ.ម.ក ដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធ រួមមាន ប្រកាសស្តីពីការបង្ហាញព័ត៌មានសាជីវកម្ម ភាគហ៊ុនិក និងសាធារណជន អាចទទួលបានទាន់ពេល នូវព័ត៌មានប្រតិបត្តិការធុរកិច្ចសំខាន់ៗ ការប្រែប្រួលសំខាន់ៗដែលប៉ះពាល់ដល់ធុរកិច្ច និងខ្សែសង្វាក់ផលិតកម្ម របាយការណ៍ហិរញ្ញវត្ថុក្នុងគ្រាសង្ខេបប្រចាំត្រីមាស ប្រចាំឆមាស និងរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួច លទ្ធផលប្រតិបត្តិ ព័ត៌មានអំពីបម្រែបម្រួលថ្លៃ និងការជួញដូរមូលបត្ររបស់ក្រុមហ៊ុន នៅ ផ.ម.ក សេចក្តីជូនដំណឹងស្តីពីការបែងចែកភាគលាភជូនភាគហ៊ុនិក និងព័ត៌មានសំខាន់ៗផ្សេងៗទៀត រួមមាន សេចក្តីជូនដំណឹងនានា តាមរយៈគេហទំព័ររបស់គណៈកម្មការមូលបត្រកម្ពុជា ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា និងគេហទំព័ររបស់ក្រុមហ៊ុនផ្ទាល់តែម្តង។ ក្រុមហ៊ុន នៅតែបន្តផ្តល់ជូនព័ត៌មានទាន់ពេល ព័ត៌មានសំខាន់ៗផ្សេងទៀត ដែលអាចប៉ះពាល់ដល់ផលប្រយោជន៍ភាគហ៊ុនិក ជូនភាគហ៊ុនិករបស់ក្រុមហ៊ុន និងសាធារណជន ឲ្យកាន់តែទូលំទូលាយជាងបណ្តាឆ្នាំកន្លងទៅ។

អនុលោមតាមច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម និងលក្ខន្តិកៈក្រុមហ៊ុន ហ្គ្រេន ធ្វីន មានតែភាគហ៊ុនិកដែលកាន់កាប់មូលបត្រកម្មសិទ្ធិមានសិទ្ធិបោះឆ្នោត ហើយមានឈ្មោះក្នុងបញ្ជីស្តីពីកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិក ដែលរៀបចំដោយក្រុមប្រឹក្សាភិបាលទេ ដែលអាចចូលរួមប្រជុំ បោះឆ្នោត និងទទួលបានព័ត៌មាននោះបាន។

**សិទ្ធិចូលរួមមហាសន្និបាតភាគហ៊ុនិក សិទ្ធិបោះឆ្នោត និងជ្រើសតាំង ដកហូតសមាជិកក្រុមប្រឹក្សាភិបាល**

ក្នុងគោលបំណងកំណត់ចំនួនភាគហ៊ុនិកដែលមានបំណងចូលរួម និងបោះឆ្នោតក្នុងមហាសន្និបាតភាគហ៊ុនិក ក្រុមប្រឹក្សាភិបាល នឹងធ្វើការកំណត់កាលបរិច្ឆេទកំណត់ទុកដើម្បីកំណត់ចំនួនភាគហ៊ុនិក។ បញ្ជីឈ្មោះភាគហ៊ុនិកដែលបានកំណត់នៅក្នុងកាលបរិច្ឆេទកំណត់ទុក ត្រូវបានរៀបចំឡើងតាមលំដាប់អក្ខរក្រម និងបញ្ជាក់នូវចំនួនមូលបត្រកម្មសិទ្ធិដែលកាន់កាប់។ ភាគហ៊ុនិកដែលមានឈ្មោះក្នុងបញ្ជី នឹងទទួលបានសេចក្តីជូនដំណឹងអំពីកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិក មិនតិចជាងពី ២០ ថ្ងៃ និងច្រើនជាង ៥០ ថ្ងៃ មុនកាលបរិច្ឆេទនៃកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិក។ សេចក្តីជូនដំណឹងស្តីពីកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិក នឹងបង្ហាញនូវកាលបរិច្ឆេទ ពេលវេលា ទីកន្លែង និងរបៀបវារៈនៃកិច្ចប្រជុំ។

ពេលអនុវត្តសិទ្ធិបោះឆ្នោតក្នុងកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិក ការបោះឆ្នោត គឺឈរលើគោលការណ៍ "**មួយភាគហ៊ុន-មួយសម្លេង**"។ យោងតាមប្រការ ៣៦ នៃលក្ខន្តិកៈក្រុមហ៊ុន ភាគហ៊ុនិកអាចបោះឆ្នោតដោយផ្ទាល់ក៏បាន ឬដោយអាណត្តិគាហកៈតាមរយៈលិខិតផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរ ដោយមានចុះហត្ថលេខា កាលបរិច្ឆេទ ចំនួនមូលបត្រកម្មសិទ្ធិដែលកាន់កាប់ដោយភាគហ៊ុនិក ឈ្មោះ និងអាសយដ្ឋានរបស់អណត្តិគាហកៈ និងរយៈពេលនៃការតែងតាំងអណត្តិគាហកៈ។ លិខិតផ្ទេរសិទ្ធិជូនអណត្តិគាហកៈ ត្រូវបញ្ជូនឲ្យបុគ្គលិកទទួលបន្ទុករៀបចំមហាសន្និបាតភាគហ៊ុនិកឲ្យបានមុន ឬ នៅថ្ងៃចាប់ផ្តើមកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិក។

ដូចបានចែងក្នុងប្រការ ៧ នៃលក្ខន្តិកៈក្រុមហ៊ុន មូលបត្រកម្មសិទ្ធិដែលមានសិទ្ធិបោះឆ្នោត មានសិទ្ធិបោះឆ្នោតមួយសម្លេង និងមានសិទ្ធិទទួលបានទ្រព្យសកម្មសុទ្ធ (មូលធន) របស់ក្រុមហ៊ុននៅពេលដែលមានការ រំលាយក្រុមហ៊ុន តាមចំណែកមូលបត្រកម្មសិទ្ធិដែលបានកាន់កាប់។ អភិបាលត្រូវតែជ្រើសតាំងតាមរយៈការបោះឆ្នោតរបស់ភាគហ៊ុនិកអនុលោមតាមច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម។ ភាគហ៊ុនិក ឬអាណត្តិគាហកៈមានសិទ្ធិជ្រើសរើស ផ្លាស់ប្តូរ និងជំនួសអភិបាល និងបោះឆ្នោតសម្រេចលើបញ្ញត្តិសាជីវកម្មមួយចំនួនតាមរយៈកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិក។

គិតត្រឹមដំណាច់ការិយបរិច្ឆេទឆ្នាំ២០១៧ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ នេះ គិតចាប់ពីក្រុមហ៊ុនបានបោះផ្សាយ និងចុះបញ្ជីលក់មូលបត្រនៅ ផ.ម.ក ក្រុមហ៊ុន ហ្គ្រេន ធ្វីន បានកោះប្រជុំមហាសន្និបាតភាគហ៊ុនិក លើកទី១ ដែលប្រព្រឹត្តិទៅ

កាលពីថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៥ មហាសន្និបាតភាគហ៊ុនិក លើកទី២ ប្រព្រឹត្តិទៅកាលពីថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៦ និងមហាសន្និបាតភាគហ៊ុនិក លើកទី៣ កាលពីថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៧ កន្លងទៅ។

**សិទ្ធិទទួលព័ត៌មាន**

ភាគហ៊ុនិករបស់ក្រុមហ៊ុន ហ្គ្រេន ធ្វីន មានសិទ្ធិទទួលបានព័ត៌មានគ្រប់ប្រភេទ រួមទាំង ព័ត៌មានអំពីធុរកិច្ចក្រុមហ៊ុន និងកំណត់ត្រាប្រឹក្សាយោបល់ដូចចែងក្នុងប្រការ ១៨ វាក្យខណ្ឌទី ១ នៃលក្ខន្តិកៈក្រុមហ៊ុន។

អនុលោមតាមប្រការ ៧ នៃប្រកាសស្តីពី អភិបាលកិច្ចសាជីវកម្មសម្រាប់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ ដែលបានចែងអំពីសិទ្ធិក្នុងការទទួលបានព័ត៌មានរបស់ភាគហ៊ុនិក ភាគហ៊ុនិកម្នាក់ៗ អាចពិនិត្យបញ្ជីឈ្មោះរបស់ភាគហ៊ុនិកទាំងឡាយបាននៅទីស្នាក់ការចុះបញ្ជីរបស់ក្រុមហ៊ុន ឬនៅទីកន្លែងរក្សាទុកបញ្ជីមូលបត្រនោះនៅក្នុងម៉ោងធ្វើការ ឬពេលប្រជុំមហាសន្និបាតភាគហ៊ុនិកដែលបញ្ជីឈ្មោះត្រូវបានរៀបចំ។

ក្រុមហ៊ុន មានគេហទំព័រមួយដែលអាចអោយភាគហ៊ុនិក និងសាធារណជនអាចទទួលបានព័ត៌មាន។ ភាគហ៊ុនិកអាចទទួលបាន លទ្ធផលប្រតិបត្តិការ របាយការណ៍ហិរញ្ញវត្ថុក្នុងគ្រាសង្ខេបប្រចាំត្រីមាស របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំដែលបានធ្វើសវនកម្មរួច របាយការណ៍ប្រចាំត្រីមាស ព្រមទាំងព័ត៌មានរបស់អភិបាល និងបុគ្គលិកជាន់ខ្ពស់តាមរយៈគេហទំព័ររបស់ក្រុមហ៊ុន និងព័ត៌មានផ្សេងទៀតអំពីក្រុមហ៊ុន។ ភាគហ៊ុនិកមានសិទ្ធិទទួលបានទាន់ពេល អំពីព័ត៌មានដែលបានរៀបរាប់ខាងលើតាមរយៈគេហទំព័ររបស់ក្រុមហ៊ុនគឺ www.Grandtwins.com.kh។ ដោយឡែក សិទ្ធិរបស់ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនភាគតិច ត្រូវបានការពារដូចមានចែងក្នុងប្រការ ៩ នៃ ប្រកាសស្តីពីអភិបាលកិច្ចសាជីវកម្មសម្រាប់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ។

**សិទ្ធិទទួលបានភាគលាភ**

យោងតាមប្រការ ៤៩ និង ៥១ នៃលក្ខន្តិកៈក្រុមហ៊ុន ស្តីពីការបែងចែកភាគលាភ ជារៀងរាល់ឆ្នាំ ភាគហ៊ុនិកអាចទទួលបានភាគលាភ យោងតាមការសម្រេចរបស់ក្រុមប្រឹក្សាភិបាល។ ភាគលាភ អាចចែកជូនជា សាច់ប្រាក់ទាំងស្រុង ឬមួយភាគ ឬតម្លៃតបស្នងដែលមិនមែនជាសាច់ប្រាក់ តែជាមូលបត្រ។ ប្រាក់ចំណេញរក្សាទុក អាចបញ្ចូលជាមួយប្រាក់ចំណេញនៃឆ្នាំសារពើពន្ធ ដើម្បីបែងចែកជាភាគលាភ។ ដោយឡែក ក្រុមប្រឹក្សាភិបាល មានសិទ្ធសម្រេចក្នុងការមិនបែងចែកភាគលាភជូនភាគហ៊ុនិក ប្រសិនបើ ក្រុមហ៊ុន រងនូវការខាតបង់ ហើយពុំមានលទ្ធភាពក្នុងការបែងចែកភាគលាភ ឬក្រុមប្រឹក្សាភិបាលមានបំណងរក្សាទុកប្រាក់ចំណេញ សម្រាប់ប្រើប្រាស់ក្នុងគម្រោងវិនិយោគណាមួយ ឬសម្រាប់គោលបំណងណាមួយផ្សេងទៀត។

គិតត្រឹមការិយបរិច្ឆេទឆ្នាំ២០១៧ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ នេះ ក្រុមហ៊ុន ហ្គ្រេន ធ្វីន បានធ្វើបែងចែកភាគលាភដល់ភាគហ៊ុនិកចំនួន ៣ លើក បន្ទាប់ពីក្រុមហ៊ុនបានបោះផ្សាយ និងចុះបញ្ជីលក់មូលបត្រជាផ្លូវការនៅ ផ.ម.ក។ តាមរយៈសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៥ ក្រុមប្រឹក្សាភិបាលបានសម្រេច និងអនុម័តការបែងចែកភាគលាភដល់ភាគហ៊ុនិកជាលើកដំបូង ដោយ ៥០% នៃចំណេញក្រោយបង់ពន្ធឆ្នាំ២០១៤ ត្រូវបានយកមកបែងចែកជូនភាគហ៊ុនិកសមាមាត្រនឹងចំនួនមូលបត្រដែលភាគហ៊ុនិកម្នាក់ៗកាន់កាប់។ ជាលទ្ធផល ភាគហ៊ុនិកម្នាក់ៗទទួលបាន ១៧៧ រៀល ក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ។ ក្រុមហ៊ុនបានធ្វើបែងចែកភាគលាភជាលើកទី២ តាមរយៈសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៦ ចំនួន ៤៩,៩៩% នៃចំណេញក្រោយបង់ពន្ធឆ្នាំ២០១៥ ភាគហ៊ុនិកម្នាក់ៗទទួលបាន ៥៤ រៀល ក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ។ ក្រុមហ៊ុនបានធ្វើបែងចែកភាគលាភជាលើកទី៣ តាមរយៈសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៧ ដោយ ១៨,៩០% នៃចំណេញក្រោយបង់ពន្ធឆ្នាំ២០១៦ ភាគហ៊ុនិកម្នាក់ៗទទួលបាន ១០០ រៀល ក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ។

## ខ. ការបែងចែកប្រភេទភាគហ៊ុនិក




តារាងខាងក្រោមនេះ គឺ ចំនួនភាគហ៊ុនិកដែលកាន់កាប់មូលបត្រកម្មសិទ្ធិមានសិទ្ធិបោះឆ្នោតសរុប របស់ក្រុមហ៊ុន ហ្ប្រេន ធ្វីន គិតត្រឹមដំណាច់ការិយបរិច្ឆេទឆ្នាំ២០១៧ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ ៖

| បរិយាយ | សញ្ជាតិ | ប្រភេទភាគហ៊ុនិក | ចំនួនភាគហ៊ុនិក | ចំនួនមូលបត្រ | ភាគរយ |
|---|---|---|---|---|---|
| តិចជាង ០៥% | សញ្ជាតិខ្មែរ | រូបវន្តបុគ្គល | ១២៥ | ២.៧៩៥.២៦២ | ៦,៩៩% |
| | | នីតិបុគ្គល | ២ | ២០៧.៦៤០ | ០,៥២% |
| | មិនមែនសញ្ជាតិខ្មែរ | រូបវន្តបុគ្គល | ១៨៧ | ១៣.៧០៩.៤៤០ | ៣៤,២៧% |
| | | នីតិបុគ្គល | ៧ | ៣.០៤៧.៦៥៨ | ៧,៦២% |
| ចាប់ពី ០៥% តិចជាង ៣០% | សញ្ជាតិខ្មែរ | រូបវន្តបុគ្គល | - | - | - |
| | | នីតិបុគ្គល | - | - | - |
| | មិនមែនសញ្ជាតិខ្មែរ | រូបវន្តបុគ្គល | - | - | - |
| | | នីតិបុគ្គល | ១ | ៣.៨៤០.០០០ | ៩,៦០% |
| ចាប់ពី ៣០% | សញ្ជាតិខ្មែរ | រូបវន្តបុគ្គល | - | - | - |
| | | នីតិបុគ្គល | - | - | - |
| | មិនមែនសញ្ជាតិខ្មែរ | រូបវន្តបុគ្គល | - | - | - |
| | | នីតិបុគ្គល | ១ | ១៦.៤០០.០០០ | ៤១,០០% |
| សរុប | | | ៣០០ | ៤០.០០០.០០០ | ៣២៣ |

### គ. អភិបាល បុគ្គលិកជាន់ខ្ពស់ និងបុគ្គលិក ដែលកាន់កាប់មូលបត្រកម្មសិទ្ធិរបស់ក្រុមហ៊ុន ហ្គ្រេន ធ្វីន

| ភាគហ៊ុនិក | ចំនួនភាគហ៊ុនិក | ចំនួនមូលបត្រ | ភាគរយ |
|---|---|---|---|
| អភិបាល | ៤ | ២.២៧៥.៦១៦ | ៥,៦៩% |
| បុគ្គលិកជាន់ខ្ពស់ | - | - | - |
| និយោជិក | - | - | - |
| **សរុប** | **៤** | **២.២៧៥.៦១៦** | **៥,៦៩%** |

គិតត្រឹមការិយបរិច្ឆេទឆ្នាំ២០១៧ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ ក្រុមហ៊ុន ហ្គ្រេន ធ្វីន មិនមានបុគ្គលិកជាន់ខ្ពស់ និងនិយោជិកផ្សេងទៀត ដែលកាន់កាប់មូលបត្រកម្មសិទ្ធិរបស់ខ្លួននោះទេ។

### ឃ. ការផ្លាស់ប្តូរភាគហ៊ុនិកកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើន និងភាគហ៊ុនិកកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់ ដោយបញ្ជាក់អំពីអត្តសញ្ញាណ

គិតត្រឹមការិយបរិច្ឆេទឆ្នាំ២០១៧ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ ក្រុមហ៊ុន ហ្គ្រេន ធ្វីន មិនមានការផ្លាស់ប្តូរភាគហ៊ុនិកកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើន និង ភាគហ៊ុនិកកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់នោះទេ។

### ង. អត្តសញ្ញាណភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនចាប់ពី ០៥ (ប្រាំ) ភាគរយឡើងទៅ ស្ថិតក្នុងស្ថានភាពអសាធនភាព

គិតត្រឹមការិយបរិច្ឆេទឆ្នាំ២០១៧ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ ក្រុមហ៊ុន ហ្គ្រេន ធ្វីន មិនមានភាគហ៊ុនិកណាម្នាក់ដែលកាន់កាប់ភាគហ៊ុនចាប់ពី ០៥ % ឡើងទៅ ហើយមានអសោធនភាពនោះទេ។

### ច. កិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិក

គិតត្រឹមការិយបរិច្ឆេទឆ្នាំ២០១៧ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ ក្រុមហ៊ុន ហ្គ្រេន ធ្វីន បានរៀបចំកិច្ចមហាសន្និបាតភាគហ៊ុនិកលើកទី១ ដែលប្រព្រឹត្តិទៅកាលពីថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៥ មហាសន្និបាតភាគហ៊ុនិកលើកទី២ ប្រព្រឹត្តិទៅកាលពីថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៦ និងមហាសន្និបាតភាគហ៊ុនិកលើកទី៣ ដែលប្រព្រឹត្តិទៅកាលពីថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៧ កន្លងទៅ បន្ទាប់ពីក្រុមហ៊ុនបានបោះផ្សាយ និងចុះបញ្ជីលក់មូលបត្រជាផ្លូវការនៅ ផ.ម.ក។

### ឆ. គោលនយោបាយភាគលាភ

### ឆ.១. គោលនយោបាយភាគលាភរបស់ក្រុមហ៊ុន ហ្គ្រេន ធ្វីន

គិតត្រឹមការិយបរិច្ឆេទឆ្នាំ២០១៧ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ ក្រុមហ៊ុន ហ្គ្រេន ធ្វីន មិនមានគោលការណ៍ក្នុងការបង្កើនប្រាក់បំណាច់ ឬលាភការសរុបក្នុងចំនួនច្រើនដល់អភិបាល ឬបុគ្គលិករបស់ខ្លួននោះទេ។

ជាគោលការណ៍ គោលនយោបាយ ភាគលាភត្រូវបានកំណត់ដូចខាងក្រោម៖

ក. ប្រាក់ចំណេញសុទ្ធក្រោយបង់ពន្ធ ត្រូវទូទាត់សម្រាប់ការខាតបង់ដែលបានកើតឡើងកាលពីឆ្នាំមុន។

ខ. ចំពោះចំណែកនៅសល់ក្រោយការបែងចែក ចំនួន ១០ (ដប់) ភាគរយ នៃប្រាក់ចំណេញក្រោយបង់ពន្ធ ត្រូវបានរក្សាទុកសម្រាប់ការខាតបង់នៅពេលអនាគត។

គ. ក្រោយការទូទាត់សម្រាប់ការខាតបង់ និងការរក្សាទុកប្រាក់ចំណេញសុទ្ធដែលនៅសល់ នឹងត្រូវធ្វើការបែងចែក ដូចខាងក្រោម៖

គ.១.មិនលើសពី ០៣ (បី) ភាគយ នៃប្រាក់ចំណេញសុទ្ធក្រោយបង់ពន្ធ នឹងក្លាយជាលាភការ ឬប្រាក់បំណាច់សម្រាប់ក្រុមប្រឹក្សាភិបាល។

គ.២.មិនលើសពី ០៥ (ប្រាំ) ភាគរយ នៃប្រាក់ចំណេញសុទ្ធក្រោយបង់ពន្ធ នឹងក្លាយជាលាភការ ឬប្រាក់បំណាច់សម្រាប់បុគ្គលិក។

សម្រាប់ឆ្នាំ២០១៥ ក្រុមប្រឹក្សាភិបាល បានសម្រេច និងអនុម័ត ដោយយកទឹកប្រាក់ ៥០% នៃប្រាក់ចំណេញក្រោយបង់ពន្ធនៅដំណាច់ការិយបរិច្ឆេទឆ្នាំ២០១៤ មកបែងចែកជាភាគលាភដល់ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតរបស់ក្រុមហ៊ុន ជាលើកដំបូង បន្ទាប់ពីក្រុមហ៊ុនបានចុះបញ្ជីលក់មូលបត្រនៅ ផ.ម.ក។ នៅឆ្នាំ ២០១៦ ទឹកប្រាក់ចំនួន ៤៩,៩៩% នៃប្រាក់ចំណេញក្រោយបង់ពន្ធនៅដំណាច់ការិយបរិច្ឆេទឆ្នាំ ២០១៥ មកបែងចែកជាភាគលាភជាលើកទី២។ ដោយឡែកនៅត្រីមាសទី២ ឆ្នាំ២០១៧ កន្លងទៅ ក្រុមប្រឹក្សាភិបាលបានសម្រេច និងអនុម័តដោយយកទឹកប្រាក់ ១៨,៩០% នៃប្រាក់ចំណេញក្រោយបង់ពន្ធនៅដំណាច់ការិយបរិច្ឆេទឆ្នាំ២០១៦ មកបែងចែកជាភាគលាភដល់ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតរបស់ក្រុមហ៊ុន។

## ឆ.២. ព័ត៌មានប្រវត្តិសាស្ត្រពីគោលនយោបាយភាគលាភរបស់ក្រុមហ៊ុន ហ្គ្រេន ធ្វីន ក្នុងរយៈពេល ០៣ (បី) ឆ្នាំចុងក្រោយ

គិតត្រឹមការិយបរិច្ឆេទឆ្នាំ២០១៧ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ ក្រុមហ៊ុន ហ្គ្រេន ធ្វីន បានបែងចែកភាគលាភដល់ភាគហ៊ុនិករបស់ខ្លួនជាលើកទី៣។ ទឹកប្រាក់ ១៨,៩០% នៃប្រាក់ចំណេញក្រោយបង់ពន្ធនៅដំណាច់ការិយបរិច្ឆេទឆ្នាំ ២០១៦ ត្រូវបានយកមកបែងចែកជាភាគលាភ ដល់ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតរបស់ក្រុមហ៊ុន ដែលភាគហ៊ុនិកម្នាក់ៗទទួលបាន ១០០ រៀល ក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ។

ដោយឡែក ក្រុមហ៊ុន ហ្គ្រេន ធ្វីន មិនមានគោលការណ៍បែងចែកភាគលាភដល់ភាគហ៊ុនិក ជារៀងរាល់ត្រីមាសឡើយ។ ការបែងចែកភាគលាភ នឹងត្រូវបែងចែកនៅដំណាច់ការិយបរិច្ឆេទនៃឆ្នាំនីមួយៗ និងយោងតាមការសម្រេចរបស់ក្រុមប្រឹក្សាភិបាល។ សម្រាប់ការបែកចែកភាគលាភសម្រាប់ការិយបរិច្ឆេទឆ្នាំ២០១៧ ក្រុមហ៊ុន ហ្គ្រេន ធ្វីន នឹងជូនដំណឹងដល់ភាគហ៊ុនិក បន្ទាប់ពីក្រុមប្រឹក្សាភិបាលសម្រេច និងអនុម័តលើការបែងចែកភាគលាភនេះ។

| ពិពណ៌នាលម្អិតអំពីការបែងចែងភាគលាភ | ឆ្នាំ២០១៧ | ឆ្នាំ២០១៦ | ឆ្នាំ២០១៥ |
|---|---|---|---|
| | រៀល "០០០" | រៀល "០០០" | រៀល "០០០" |
| ចំណេញសុទ្ធ | ២.៦៧០.០១២ | ២១.១៦២.៦៥២ | ៤.៣២០.៩៩៥ |
| ភាគលាភជាសាច់ប្រាក់សរុប | - | - | ២.១៦០.០០០ |
| ភាគលាភជាមូលបត្រកម្មសិទ្ធិសរុប | - | - | - |
| ភាគលាភផ្សេងទៀត | - | - | - |
| អនុបាតនៃការបែងចែកភាគលាភ (%) | - | ១៨,៩០% | ៤៩,៩៩% |
| ទិន្នផលភាគលាភ (%) | - | ១៨,៩០% | ៤៩,៩៩% |
| ភាគលាភក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិសរុប | - | ១០០ | ៥៤ |

## រចនាសម្ព័ន្ធចាត់តាំង របស់ក្រុមហ៊ុន ហ្គ្រេន ធីន



## រចនាសម្ព័ន្ធផ្នែកលក់របស់ក្រុមហ៊ុន ប្រេហ្គន ធ្វីន នៅទីក្រុងសៀងហៃ សាធារណរដ្ឋប្រជាមានិតចិន



# ក្រុមប្រឹក្សាភិបាល

ក្រុមហ៊ុន ហ្គ្រេន ធ្វីន ត្រូវបានដឹកនាំដោយក្រុមប្រឹក្សាភិបាលដែលមានសមាជិក ០៥ រូប ក្នុងនោះមាន ប្រធានក្រុមប្រឹក្សាភិបាល ០១ រូប អភិបាលមិនប្រតិបត្តិ ០២ រូប នាយកប្រតិបត្តិ ០១ រូប និងអភិបាលឯករាជ្យ ០១ រូប។ រាល់ការជ្រើសតាំង និងបញ្ឈប់តំណែងអភិបាលរបស់ក្រុមហ៊ុន ហ្គ្រេន ធ្វីន ត្រូវតែធ្វើឡើងតាមរយៈការបោះឆ្នោតដោយភាគហ៊ុនិកក្នុងមហាសន្និបាតភាគហ៊ុនិក។ អភិបាលរបស់ក្រុមហ៊ុន ហ្គ្រេន ធ្វីន ត្រូវមានអាណត្តិ ០៣ ឆ្នាំ ហើយអាណត្តិនេះ អាចបន្តទៀតបាន ដោយការបោះឆ្នោតជ្រើសតាំងដោយភាគហ៊ុនិកក្នុងមហាសន្និបាតភាគហ៊ុនិក។ ករណីក្រុមប្រឹក្សាភិបាល បានបញ្ចប់តួនាទី និងភារកិច្ចរបស់ខ្លួន តែក្រុមប្រឹក្សាភិបាលនៅតែបន្តបំពេញតួនាទី និងភារកិច្ចរបស់ខ្លួនដូច ដែលមានចែងក្នុងច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម រហូតដល់មានការបោះឆ្នោតជ្រើសតាំងបន្តអាណត្តិ ឬផ្លាស់ប្តូរសមាសភាពអភិបាលថ្មី។ តាមរយៈការបោះឆ្នោតដោយភាគហ៊ុនិកក្នុងមហាសន្និបាតភាគហ៊ុនិក លើកទី១ ដែលប្រព្រឹត្តិទៅកាលពីថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៥ អភិបាលដែលមានរាយនាមដូចខាងក្រោម ត្រូវបានបោះឆ្នោត និងជ្រើសតាំង ដោយសម្លេងភាគច្រើនរបស់ភាគហ៊ុនិកសម្រាប់អាណត្តិ ៣ ឆ្នាំ សម្រាប់ក្រុមប្រឹក្សាភិបាល អាណត្តិទី២ ៖

| ល.រ | ឈ្មោះអភិបាល | តំណែង | អាណត្តិ | កាលបរិច្ឆេទ ក្លាយជាអភិបាល |
|---|---|---|---|---|
| ១ | លោក យ៉ាង សាវស៊ីន | ប្រធានក្រុមប្រឹក្សាភិបាល | ៣ ឆ្នាំ | ២៣/វិច្ឆិកា/២០១៥ |
| ២ | លោក Liao Chung-Te | អភិបាលប្រតិបត្តិ | ៣ ឆ្នាំ | ២៣/វិច្ឆិកា/២០១៥ |
| ៣ | ឧកញ៉ា លី យុនថៃ | អភិបាលឯករាជ្យ | ៣ ឆ្នាំ | ២៣/វិច្ឆិកា/២០១៥ |
| ៤ | លោក Chen, Tsung-Chi | អភិបាលមិនប្រតិបត្តិ | ៣ ឆ្នាំ | ២៣/វិច្ឆិកា/២០១៥ |
| ៥ | លោកស្រី Wang Yi Ting | អភិបាលមិនប្រតិបត្តិ | ៣ ឆ្នាំ | ២៣/វិច្ឆិកា/២០១៥ |

ប្រធានក្រុមប្រឹក្សាភិបាល លោក **យ៉ាង សាវស៊ីន** ត្រូវបានតែងតាំងដោយ សមាជិកក្រុមប្រឹក្សាភិបាល នៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាល លើកទី០៩ កាលពីថ្ងៃទី០៥ ខែមករា ឆ្នាំ២០១៦។ ឧកញ៉ា **លី យុនថៃ** ត្រូវបានតែងតាំងជាអភិបាលឯករាជ្យ ដែលលោកមិនមានទំនាក់ទំនងជាមួយអតិថិជន ឬអ្នកផ្គត់ផ្គង់សំខាន់ៗរបស់ក្រុមហ៊ុន មិនធ្លាប់ធ្វើជាសវនករឲ្យក្រុមហ៊ុន មិនមានកិច្ចសន្យាផ្ទាល់ខ្លួនជាមួយក្រុមហ៊ុន ឬជាមួយបុគ្គលិកជាន់ខ្ពស់ ឬភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើន ឬភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់នោះទេ។ លើសពីនេះ លោកមិនមានផលប្រយោជន៍សំខាន់ណាមួយនៅក្នុងក្រុមហ៊ុនផងដែរ។ លោក Liao Chung-Te ត្រូវបានតែងតាំងជានាយកប្រតិបត្តិរបស់ក្រុមហ៊ុន ដែលលោកមានតួនាទីគន្លឹះក្នុងការអនុវត្តការងារស្របតាមការកំណត់ទិសដៅយុទ្ធសាស្ត្ររបស់ក្រុមប្រឹក្សាភិបាល។ ក្រុមហ៊ុន ហ្គ្រេន ធ្វីន ដឹកនាំដោយក្រុមប្រឹក្សាភិបាល ដែលមានអភិបាលជាបុគ្គលមានគុណវុឌ្ឍិ និងមានបទពិសោធន៍គ្រប់គ្រាន់ក្នុងវិស័យកាត់ដេរ ដែលធានាដល់ភាពជោគជ័យរយៈពេលវែងរបស់ក្រុមហ៊ុន ព្រមទាំងចីរភាពនៃការប្រកួតប្រជែងប្រកបដោយតម្លាភាព គណនេយ្យភាព និងប្រសិទ្ធភាពខ្ពស់។

លើសពីនេះ ក្រុមហ៊ុន ហ្គ្រេន ធ្វីន មានអភិបាលឯករាជ្យ ដែលមានឯករាជ្យភាពពិតប្រាកដ និងការដឹកនាំកម្រិតក្រុមប្រឹក្សាភិបាលមិនបានប្រមូលអំណាច ដោយបានធ្វើការផ្តាច់ចេញពីគ្នានូវបុគ្គល ដែលមានតំណែងជា ប្រធានក្រុមប្រឹក្សាភិបាល និងនាយកប្រតិបត្តិ ដែលការណ៍នេះជាការអនុវត្តក្របខណ្ឌអភិបាលកិច្ចសាជីវកម្មល្អ។

## សមាសភាពក្រុមប្រឹក្សាភិបាល

| ល.រ | ឈ្មោះអភិបាល | មុខតំណែង | គុណវុឌ្ឍិ | បទពិសោធន៍ |
|---|---|---|---|---|
| ១ |  លោក **យ៉ាង សាវស៊ីន** | ប្រធានក្រុមប្រឹក្សាភិបាល និងជា អភិបាលមិនប្រតិបត្តិ | ទទួលការសិក្សា ផ្នែកកាយវប្បកម្ម (ជំនាញផ្នែកអត្តពលកម្ម) នៅមហាវិទ្យាល័យតៃប៉ិ នាកំឡុងទស្សវត្ស ឆ្នាំ១៩៨០ និងត្រូវបានតែងតាំងជាប្រធានសមាគមនិស្សិត សម្រាប់អាណត្តិទីបួននៅឆ្នាំ២០០៦ និងអាណត្តិទីប្រាំ នៅឆ្នាំ២០០៩។ | មានបទពិសោធន៍ជាង ២០ ឆ្នាំនៅក្នុងវិស័យសំលៀកបំពាក់កីឡា រួមមាន ៖<br>• ជាអភិបាល នៃក្រុមហ៊ុនQi Cang industrial Co.,Ltd តាំងពីឆ្នាំ១៩៨២<br>• ជាប្រធានក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុន QMI Industrial Co., Ltd តាំងពីឆ្នាំ២០០១<br>• ជាអភិបាលនៃក្រុមហ៊ុនសំណង់ Kun Yu Construction Co., Ltd តាំងពីឆ្នាំ២០០៦ |
| ២ |  លោក Liao Chung-Te | អភិបាលប្រតិបត្តិ និងជា នាយកប្រតិបត្តិ | បានបញ្ចប់បរិញ្ញាបត្រ ផ្នែកការរៀបចំធុរកិច្ចនៅសាកលវិទ្យាល័យChristian Chuang Yuan។ | មានបទពិសោធន៍ជាង ២០ ឆ្នាំនៅក្នុងវិស័យសំលៀកបំពាក់កីឡា រួមមាន ៖<br>• ជានាយករងទូទៅទទួលបន្ទុកផ្នែកផលិតកម្មនៅក្រុមហ៊ុន QMI Industrial Co., Ltd. (តៃវ៉ាន់) ក្នុងឆ្នាំ១៩៩៤<br>• នៅក្នុងឆ្នាំ២០០៥ ក្រោយពីក្រុមហ៊ុន QMI Industrial Co., Ltd. (Taiwan) បង្កើតក្រុមហ៊ុនបុត្រសម្ព័ន្ធQMI Industrial (Shanghai) Ltd. លោកបានទទួលឋានៈជានាយកគ្រប់គ្រង ទូទៅទទួលបន្ទុកផ្នែកផលិតកម្ម<br>• នៅឆ្នាំ២០០៧ លោកត្រូវបានផ្លាស់មកក្រុមហ៊ុន Quint Major Industrial Co., Ltdនៅប្រទេសនៅកម្ពុជា ដោយមានតំណែងជានាយករងគ្រប់គ្រងទូទៅ<br>• នៅឆ្នាំ ២០១០លោកត្រូវបានតែងតាំងជា នាយករងគ្រប់គ្រងទូទៅនៅក្រុមហ៊ុន ហ្គ្រេន ធ្វីន និងត្រូវបានតម្លើងឋានៈ ជា នាយកប្រតិបត្តិរបស់ក្រុមហ៊ុននៅឆ្នាំដដែល។ |

| | | | | |
|---|---|---|---|---|
| ៣ | <br>ឧកញ៉ា<br>**លី យុនថៃ** | អភិបាលឯករាជ្យ | ទទួលការសិក្សាផ្នែកគ្រប់គ្រងធុរកិច្ច នៅសាកលវិទ្យាល័យ អាស៊ី អឺរ៉ុប។ | • ជានាយកប្រតិបត្តិនៃក្រុមហ៊ុនសាជីវកម្ម May Wa ពីឆ្នាំ១៩៩៧ ដល់ឆ្នាំ២០០៥<br>• ជានាយកប្រតិបត្តិ និងប្រធានផ្នែកហិរញ្ញវត្ថុនៃក្រុមហ៊ុន Alpha Construction Trade International Co. Ltd ពីឆ្នាំ២០០៥-២០០៨<br>• ជាអគ្គនាយក និងប្រធានក្រុមប្រឹក្សាភិបាល នៃក្រុមហ៊ុន Alpha Property Construction Co., Ltd ចាប់ពីឆ្នាំ ២០០៨ |
| ៤ | <br>លោកស្រី<br>Wang Yi Ting | អភិបាលមិនប្រតិបត្តិ | បានបញ្ចប់ការសិក្សា និង ទទួលបាន វិញ្ញាបនប័ត្រជំនាញផ្នែកដែនសមុទ្រពីសាលា បណ្តុះបណ្តាលជាតិ KEELUNG នៅឆ្នាំ២០០០ និងបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាប័ត្រផ្នែកគណនេយ្យ ពីសាកលវិទ្យាល័យបច្ចេកវិទ្យានៃប្រទេសចិន។ | មានបទពិសោធន៍ជាង ១០ឆ្នាំ ក្នុងផ្នែកគណនេយ្យ និងហិរញ្ញវត្ថុ រួមមាន ៖<br>• ជាសមាជិក នៃសមាគមរោងចក្រកាត់ដេរ នៅកោះតៃវ៉ាន់។<br>• ជាគណនេយ្យករ-ហិរញ្ញិកនៅក្រុមហ៊ុន QMI Industrial Co., Ltd។<br>• ជាសវនករ នៅក្រុមហ៊ុនសវនកម្ម នៅតៃវ៉ាន់។<br>• ជាគណនេយ្យករ នៅក្រុមហ៊ុន B & T Technology Corporation។ |
| ៥ | <br>លោក<br>Chen,<br>Tsung-Chi | អភិបាលមិនប្រតិបត្តិ | បានបញ្ចប់ការសិក្សាជំនាញពាណិជ្ជកម្ម គណិតសាស្ត្រ ពីសាលាពាណិជ្ជសាស្ត្រ នៃសាកលវិទ្យាល័យ Soochow កោះតៃវ៉ាន់។ | • មានបទពិសោធន៍ផ្នែកហិរញ្ញវត្ថុលើសពី ៣០ឆ្នាំ ជាមួយក្រុមហ៊ុនបោះផ្សាយ និងក្រុមហ៊ុនឯកជន ក្នុងការរៀបចំដំណើរការបោះផ្សាយ<br>• ចាប់ផ្តើមការងារជាបេឡាក្នុងធនាគារ អ្នកវិភាគឥណទានអតិថិជន ក្នុងធនាគារ China Trust Commercial Bank បន្ទាប់មកក្លាយជាប្រធានគ្រប់គ្រង និងត្រួតពិនិត្យផ្នែកហិរញ្ញវត្ថុ<br>• ជាប្រធានគ្រប់គ្រងនិងត្រួតពិនិត្យផ្នែកហិរញ្ញវត្ថុនៃសម្ព័ន្ធក្រុមហ៊ុន Smart Home International Ltd<br>• មានចំណេះដឹងនិងបទពិសោធន៍ក្នុងវិស័យកាត់ដេរសំលៀក បំពាក់កីឡា និងគណនេយ្យថ្លៃដើមនៅក្នុងវិស័យផលិតកម្ម<br>• ជាប្រធានគ្រប់គ្រង និងត្រួតពិនិត្យផ្នែកហិរញ្ញវត្ថុនៃក្រុមហ៊ុន QMI Industrial Co., Ltd. (តៃវ៉ាន់) តាំងពីឆ្នាំ ១៩៨២ |

## តួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាល

តួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន ហ្គ្រេន ធ្វីន ត្រូវបានកំណត់នៅក្នុងក្រមសីលធម៌សម្រាប់អភិបាល និងអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត។ តួនាទី ភារកិច្ច រួមមាន៖

- អនុម័តលើគោលនយោបាយ និងនីតិវិធីអនុវត្តសម្រាប់ក្រុមហ៊ុន
- ចូលរួមចំណែក និងអនុម័តលើផែនការយុទ្ធសាស្ត្រ
- តាមដាននូវការអនុវត្តគោលនយោបាយ
- ធានាការអនុវត្តតាមច្បាប់ និងបទប្បញ្ញត្តិផ្សេងៗ និងទទួលខុសត្រូវចំពោះក្រុមហ៊ុន
- ធានាសាធនភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន តាមរយៈការគ្រប់គ្រង និងត្រួតពិនិត្យហិរញ្ញវត្ថុបានត្រឹមត្រូវ និងការការពារទ្រព្យសកម្មរបស់ភាគហ៊ុនិក
- ផ្តល់នូវភាពជាអ្នកដឹកនាំ ជួយគាំទ្រ និងលើកទឹកចិត្តដល់និយោជិត
- ធានាថា ក្រុមប្រឹក្សាភិបាលមានប្រសិទ្ធភាពក្នុងការដឹកនាំក្រុមហ៊ុន
- ធានានូវការសម្រេចបានគោលដៅរបស់ក្រុមហ៊ុន
- អនុម័តគម្រោងថវិកាប្រចាំឆ្នាំ កម្មវិធីវិនិយោគ ព្រមទាំងហិរញ្ញប្បទានបម្រុងសម្រាប់កម្មវិធីវិនិយោគ
- អនុម័តលើរបាយការណ៍គណនេយ្យ (តារាងតុល្យការ និងគណនីលទ្ធផល)
- អនុម័តនូវរចនាសម្ព័ន្ធចាត់តាំង ការបែងចែកមុខងារទូទៅ និងប្រាក់បៀវត្សរបស់និយោជិតតាមសំណើរបស់អគ្គនាយក
- ជ្រើសរើសក្រុមហ៊ុនគណនេយ្យជំនាញ និងកំណត់សេវាសវនកម្មជូនក្រុមហ៊ុនគណនេយ្យជំនាញ
- លើកសំណើសុំកែប្រែលក្ខន្តិកៈក្រុមហ៊ុន ជាដើម។

## ព័ត៌មានរបស់អភិបាល ជាភាគហ៊ុនិក កម្មសិទ្ធិករ ឬសហកម្មសិទ្ធិកររបស់ក្រុមហ៊ុន ឬរបស់សហគ្រាសផ្សេងទៀត

តារាងខាងក្រោមនេះ គឺបញ្ជីរាយនាមអភិបាលរបស់ក្រុមហ៊ុន ហ្គ្រេន ធ្វីន ដែលជាអភិបាល ឬជាភាគហ៊ុនិក ជាកម្មសិទ្ធិករ ឬជាសហកម្មសិទ្ធិកររបស់ក្រុមហ៊ុន ឬរបស់សហគ្រាសផ្សេងទៀត គិតត្រឹមការិយបរិច្ឆេទឆ្នាំ២០១៧ ៖

| ឈ្មោះអភិបាល | ឈ្មោះក្រុមហ៊ុនពាក់ព័ន្ធ | អភិបាល ឬភាគហ៊ុនិក ឬកម្មសិទ្ធិករ ឬជាសហកម្មសិទ្ធិករ |
|---|---|---|
| លោក យ៉ាង សាវស៊ីន | ១-ក្រុមហ៊ុន Qi Cang industrial Co.,Ltd<br>២-ក្រុមហ៊ុន QMI Industrial Co., Ltd<br>៣-ក្រុមហ៊ុនសំណង់ Kun Yu Construction Co., Ltd | ១-ជាអភិបាល តាំងពីឆ្នាំ១៩៨២<br>២-ជាប្រធានក្រុមប្រឹក្សាភិបាល តាំងពីឆ្នាំ២០០១<br>៣-ជាអភិបាល តាំងពីឆ្នាំ២០០៦ |
| លោក Liao Chung-Te | គ្មាន | គ្មាន |
| ឧកញ៉ា លី យុនថៃ | ក្រុមហ៊ុន Alpha Property Construction Co., Ltd | ជាប្រធានក្រុមប្រឹក្សាភិបាល |
| លោក Chen, Tsung-Chi | គ្មាន | គ្មាន |
| លោកស្រី Wang Yi Ting | គ្មាន | គ្មាន |

## សេចក្តីសម្រេចរបស់អភិបាល និងលទ្ធផលសម្រេច

កិច្ចប្រជុំក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន ហ្គ្រេន ធ្វីន ត្រូវធ្វើឡើងយ៉ាងទៀងទាត់ ០១ ដង ក្នុងរយៈពេល ០៣ ខែ។ កិច្ចប្រជុំប្រឹក្សាភិបាលវិសាមញ្ញអាចប្រព្រឹត្តទៅបាន តាមសំណើរបស់ប្រធានក្រុមប្រឹក្សាភិបាល ឬតាមសំណើរបស់សមាជិកក្រុមប្រឹក្សាភិបាលដែលមានសម្លេងស្មើនឹង ១/៣ នៃសមាជិកក្រុមប្រឹក្សាភិបាលសរុប។

កិច្ចប្រជុំក្រុមប្រឹក្សាភិបាលត្រូវមានវត្តមាននៃអភិបាលភាគច្រើន និងវត្តមានរបស់អភិបាលឯករាជ្យ ដែលកិច្ចប្រជុំក្រុមប្រឹក្សាភិបាលអាចប្រព្រឹត្តទៅនៅក្នុងការិយាល័យរបស់ក្រុមហ៊ុន ហ្គ្រេន ធ្វីន នៅព្រះរាជាណាចក្រកម្ពុជា តាមការសម្រេចរបស់ប្រធានក្រុមប្រឹក្សាភិបាល។ កំណត់ហេតុនៃកិច្ចប្រជុំក្រុមប្រឹក្សាភិបាល ត្រូវចុះហត្ថលេខា ដោយលេខាធិការក្រុមហ៊ុន និងប្រធានក្រុមប្រឹក្សាភិបាល។

សម្រាប់ការិយបរិច្ឆេទឆ្នាំ២០១៧ នេះ ក្រុមប្រឹក្សាភិបាល បានអនុម័តចំនុចចម្បងមួយចំនួន មានដូចជា (១) ផ្លាស់ប្តូរក្រុមហ៊ុន ប៊ីឌីអូ និងជ្រើសរើសក្រុមហ៊ុនសវនកម្មថ្មី ជាសវនករឯករាជ្យដើម្បីពិនិត្យ និងធ្វើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុក្នុងគ្រាសង្ខេបសម្រាប់ត្រីមាសនានា ឆ្នាំ២០១៧ និងសម្រាប់ការិយបរិច្ឆេទដំណាច់ឆ្នាំ២០១៧ និងឆ្នាំបន្ទាប់ (២) កំណត់យុទ្ធសាស្រ្ត និងផែនការសម្រាប់ត្រីមាសបន្ទាប់ឆ្នាំ ២០១៨ (៣) ការរៀបចំមហាសន្និបាតភាគហ៊ុនិក លើកទី៣ (៤) កិច្ចពិភាក្សាលើការបែងចែកភាគលាភជាមូលបត្រជូនភាគហ៊ុនិក សម្រាប់ឆ្នាំ២០១៦ និងឆ្នាំបន្ទាប់ (៥) កិច្ចពិភាក្សាលើតម្លៃមូលបត្ររបស់ក្រុមហ៊ុន ដែលជួញដូរនៅលើទីផ្សារនាពេល បច្ចុប្បន្ន និង (៧) បញ្ហាផ្សេងៗទៀត។

## វគ្គបណ្តុះបណ្តាលសម្រាប់អភិបាល

បន្ទាប់ពីក្រុមហ៊ុន ហ្គ្រេន ធ្វីន បានបោះផ្សាយ និងចុះបញ្ជីលក់មូលបត្រជាផ្លូវការ នៅ ផ.ម.ក ក្រុមប្រឹក្សាភិបាលអាណត្តិទី២ បានទទួលការបណ្តុះបណ្តាលដែលរៀបចំដោយគណៈកម្មការមូលបត្រកម្ពុជា (គ.ម.ក) លើការគ្រប់គ្រងអភិបាលកិច្ចសាជីវកម្ម និងការបង្ហាញព័ត៌មានសាជីវកម្ម បន្ទាប់ពីក្រុមហ៊ុនបានក្លាយជាក្រុមហ៊ុនឯកជនដំបូងបង្អស់ ដែលបានបោះផ្សាយ និងចុះបញ្ជីលក់មូលបត្រនៅព្រះរាជាណាចក្រកម្ពុជា។

ការចែកចាយចំណេះដឹង និងបទពិសោធន៍តាមរយៈការបណ្តុះបណ្តាលនេះ គឺមានសារៈសំខាន់ណាស់សម្រាប់ក្រុមហ៊ុនក្នុងការគ្រប់គ្រង និងបង្ហាញព័ត៌មានសាជីវកម្មក្រុមហ៊ុនជូនភាគហ៊ុនិករបស់ក្រុមហ៊ុន បុគ្គលពាក់ព័ន្ធ វិនិយោគិនសាធារណៈ ប្រកបដោយតម្លាភាព និងបានទាន់ពេលវេលា។ ទន្ទឹមនឹងនេះ ក្រុមប្រឹក្សាភិបាលបានចែករំលែកចំណេះដឹងនេះ ទៅគណៈគ្រប់គ្រង និងបុគ្គលិកពាក់ព័ន្ធផ្សេងទៀត ដែលទទួលខុសត្រូវក្នុងការបង្ហាញព័ត៌មានសាជីវកម្ម និងបានប្រឹងប្រែង និងធានាបាននូវការអនុវត្តប្រកបដោយប្រសិទ្ធិភាពខ្ពស់ក្នុងការបង្ហាញព័ត៌មានទាន់ពេល និងព័ត៌មានចាំបាច់ផ្សេងទៀត ដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធ។

កាលពីត្រីមាសទី២ ឆ្នាំ២០១៧ កន្លងទៅ គណៈកម្មាការមូលបត្រកម្ពុជា និងសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពីការរៀបចំផែនការសម្រាប់អនុវត្តអភិបាលកិច្ចសាជីវកម្ម កាលពីថ្ងៃទី១៤ និង ១៥ ខែមីនា ឆ្នាំ២០១៧ កន្លងទៅ សម្រាប់ក្រុមហ៊ុនបោះផ្សាយ ក្រុមប្រឹក្សាភិបាល អាណត្តិទី២ (អាណត្តិថ្មី) បានចាត់តាំងអ្នកតំណាងទៅចូលរួមវគ្គបណ្តុះបណ្តាលក្នុងគោលបំណងពង្រឹងការគ្រប់គ្រង និងធ្វើអោយមានភាពប្រសើរឡើងនៃអភិបាលកិច្ចសាជីវកម្មរបស់ក្រុមហ៊ុនបន្ថែមទៀត។ ដោយឡែក ត្រីមាសទី៣ ឆ្នាំ២០១៧ នេះ ក្រុមការងាររបស់គណៈកម្មការមូលបត្រកម្ពុជា បានចុះត្រួតពិនិត្យអភិបាលកិច្ចសាជីវកម្ម ក្រុមហ៊ុន ហ្គ្រេន ធ្វីន នៅរោងចក្រផ្ទាល់ កាលពីថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៧ កន្លងទៅ។

# លេខាធិការក្រុមហ៊ុន



**លោក ភួង វុធ្ធី**
**លេខាធិការក្រុមហ៊ុន**

ជនជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ លេខ ០១០៣៦២០៦៧ ចុះកាលបរិច្ឆេទថ្ងៃទី០៩ ខែមេសា ឆ្នាំ២០១២។ លោក មានបទពិសោធន៍ជាង ២០ឆ្នាំ ក្នុងផ្នែករដ្ឋបាល និងការគ្រប់គ្រងធនធានមនុស្ស។ លោក ធ្លាប់បម្រើការងារជាប្រធានផ្នែករដ្ឋបាលនៅក្រុមហ៊ុនជាច្រើន ដូចជា ពីឆ្នាំ១៩៩៤ ដល់ ឆ្នាំ១៩៩៦ ជាប្រធានផ្នែករដ្ឋបាល គ្រប់គ្រងលើផ្នែករដ្ឋបាល និងធនធានមនុស្ស នៃក្រុមហ៊ុន PPS Co., Ltd ។ ពីឆ្នាំ១៩៩៧ ដល់ ឆ្នាំ១៩៩៨ ជាប្រធានផ្នែករដ្ឋបាល គ្រប់គ្រងលើផ្នែករដ្ឋបាល និងធនធានមនុស្ស នៃរោងចក្រកាត់ដេរ Milling។ ពីឆ្នាំ១៩៩៩ ដល់ ឆ្នាំ២០០៨ ជាប្រធានផ្នែករដ្ឋបាល គ្រប់គ្រងលើផ្នែករដ្ឋបាល និងធនធានមនុស្ស នៃរោងចក្រកាត់ដេរ QMI Industrial (Cambodia) Co., Ltd ។ ពីឆ្នាំ២០០៨ ដល់ បច្ចុប្បន្ន លោក ជាប្រធានផ្នែករដ្ឋបាល គ្រប់គ្រងលើផ្នែករដ្ឋបាល និងត្រូវបានតែងតាំងជា លេខាធិការក្រុមហ៊ុន នៃក្រុមហ៊ុន ហ្គ្រេន ធ្វីន នៅឆ្នាំ២០១៣។

ដើម្បីជាជំនួយការក្នុងការអនុវត្តការងារ ក្រុមប្រឹក្សាភិបាលបានតែងតាំង លោក **ភួង វុធ្ធី** ប្រធានផ្នែកធនធានមនុស្ស ជាលេខាធិការក្រុមហ៊ុន ដែលជាបុគ្គលមានគុណវុឌ្ឍិ និងបទពិសោធន៍គ្រប់គ្រាន់ ជាប់ពាក់ព័ន្ធនឹងការងារលេខាធិការក្រុមហ៊ុននេះ។ តួនាទី ភារកិច្ច និងការទទួលខុសត្រូវ ត្រូវបានកំណត់ ដូចខាងក្រោមនេះ៖

- បង្កើតទំនាក់ទំនងការងារប្រកបដោយប្រសិទ្ធភាពជាមួយក្រុមប្រឹក្សាភិបាល និងបុគ្គលិកជាន់ខ្ពស់នានាក្នុងក្រុមហ៊ុន។
- គាំទ្រដល់កិច្ចដំណើរការងាររបស់ក្រុមប្រឹក្សាភិបាល និងគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សាភិបាល។
- ធ្វើបច្ចុប្បន្នកម្មនូវរាល់ការវិវត្តនៃច្បាប់ និងបទប្បញ្ញត្តិ ដែលអាចមានផលប៉ះពាល់ដល់ក្រុមប្រឹក្សាភិបាល និងប្រតិបត្តិការរបស់ក្រុមហ៊ុន។
- ធ្វើបច្ចុប្បន្នកម្មអំពីអភិបាលកិច្ចសាជីវកម្ម។
- ចាត់ចែង រៀបចំនីតិវិធី និងរក្សាទុកកំណត់ហេតុនៃកិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាល និងភារកិច្ចចាំបាច់ផ្សេងទៀត។

# គណៈកម្មាធិការនានា

គិតត្រឹមការិយបរិច្ឆេទឆ្នាំ២០១៧ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ ក្រុមហ៊ុន ហ្វ្រេន ធ្វីន មិនមានគណៈកម្មាធិការគ្រប់គ្រងហានិភ័យ និងគណៈកម្មាធិការតែងតាំងឡើយ។ ក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន បានបង្កើតគណៈកម្មាធិការសវនកម្មមួយគត់ នៅឆ្នាំ២០១៣។ គណៈកម្មាធិការសវនកម្ម ដែលមានសមាជិកចំនួន ៣ រូប រួមមាន ឧកញ៉ា **លី យុនថៃ** អភិបាលឯករាជ្យ ជាប្រធាន និងសមាជិក ០២ រូប ផ្សេងទៀត គឺលោក Chen Tsung-Chi អភិបាលមិនប្រតិបត្តិ និងលោក Liao Chung-Te អភិបាលប្រតិបត្តិ ជាសមាជិក។ គណៈកម្មាធិការសវនកម្ម មានតួនាទីពិនិត្យរបាយការណ៍ហិរញ្ញវត្ថុ ពិនិត្យការត្រួតពិនិត្យផ្ទៃក្នុងពិនិត្យការធ្វើសវនកម្មផ្ទៃក្នុង និងពិនិត្យការធ្វើសវនកម្មខាងក្រៅ។ ក្រុមប្រឹក្សាភិបាលក្រុមហ៊ុន ហ្វ្រេន ធ្វីន មិនទាន់បង្កើតគណៈកម្មាធិការគ្រប់គ្រងហានិភ័យនៅឡើយទេ ហេតុនេះ ការងារជាប់ពាក់ព័ន្ធនឹងហានិភ័យរបស់ក្រុមហ៊ុន ហ្វ្រេន ធ្វីន រួមមាន ការវិភាគហានិភ័យ ការវាយតម្លៃអំពីហានិភ័យ ការលើកវិធានការទប់ទល់ហានិភ័យ និងការតាមដានអំពីហានិភ័យ ត្រូវអនុវត្តដោយគណៈកម្មាធិការសវនកម្ម។



## តួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់គណៈកម្មាធិការសវនកម្ម

គណៈកម្មាធិការសវនកម្មមានតួនាទី ភារកិច្ច និងការទទួលខុសត្រូវ ដូចខាងក្រោមៈ

- ត្រួតពិនិត្យគម្រោងសវនកម្មរបស់សវនករផ្ទៃក្នុង និងសវករឯករាជ្យ រួមទាំង លទ្ធផលនៃការពិនិត្យ និងការវាយតម្លៃរបស់សវនករសម្រាប់ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង (រួមមាន ការពិនិត្យឡើងវិញនូវលិខិតរបស់គណៈគ្រប់គ្រង និងការឆ្លើយតបរបស់គណៈគ្រប់គ្រង)។
- ត្រួតពិនិត្យលទ្ធផល និងភាពសមស្របរបស់ក្រុមហ៊ុនគណនេយ្យជំនាញក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួន ដោយយោងទៅលើភាពគ្រប់គ្រាន់នៃធនធាន និងបទពិសោធន៍របស់ក្រុមហ៊ុនគណនេយ្យករជំនាញ និងបុគ្គល ដែលធ្វើសវនកម្ម។
- ធ្វើការត្រួតពិនិត្យឡើងវិញជាប្រចាំដើម្បីធានាថា មានគោលការណ៍ពិនិត្យ និងថ្លឹងថ្លែងនៅក្នុងក្រុមហ៊ុន ហ្គ្រេន ធ្វីន ដើម្បីបង្កាទំនាស់ផលប្រយោជន៍ និងភាពអន់ថយនៃការអនុវត្តគោលការណ៍គ្រប់គ្រងផ្ទៃក្នុង។
- ត្រួតពិនិត្យដំណើរការការអនុវត្តគោលការណ៍គ្រប់គ្រងផ្ទៃក្នុង ដោយធានានូវប្រសិទ្ធភាពការងាររវាងសវនករឯករាជ្យ សវនករផ្ទៃក្នុង និងបុគ្គលិកជាន់ខ្ពស់។
- ត្រួតពិនិត្យរបាយការណ៍របស់សវនករឯករាជ្យ។
- ត្រួតពិនិត្យឡើងវិញនូវរបាយការណ៍ហិរញ្ញវត្ថុប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ មុននឹងដាក់ការពិនិត្យ និងសម្រេចពីក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន។
- ដាក់សំណើដើម្បីជ្រើសរើសក្រុមហ៊ុនគណនេយ្យជំនាញ។
- ផ្តល់ការយល់ព្រមអំពីកម្រិតហានិភ័យនៃទំនាស់ផលប្រយោជន៍ រាល់សេវាសវនកម្ម និងសេវាមិនមែនសវនកម្ម និងកម្រៃដែលត្រូវបង់ទៅឲ្យសវនករឯករាជ្យសម្រាប់សេវាសវនកម្ម និងសេវាមិនមែនសវនកម្ម។
- ត្រួតពិនិត្យឡើងវិញនូវកត្តាដែលអាចបង្កឲ្យមានទំនាស់ផលប្រយោជន៍។
- ត្រួតពិនិត្យឡើងវិញ អំពីសមត្ថភាពប្រតិបត្តិការការងាររបស់នាយកហិរញ្ញវត្ថុ និងតាមដានការអនុវត្តរបស់ នាយកហិរញ្ញវត្ថុ។
- ត្រួតពិនិត្យអំពីប្រសិទ្ធភាពដំណើរការនៃការអនុវត្តយន្តការត្រួតពិនិត្យផ្ទៃក្នុង។
- ត្រួតពិនិត្យឡើងវិញហានិភ័យហិរញ្ញវត្ថុ និងត្រូវបញ្ជាក់នៅក្នុងរបាយការណ៍ប្រចាំឆ្នាំ។
- អនុវត្តតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ព្រមទាំងធ្វើរបាយការណ៍ជូនក្រុមប្រឹក្សាភិបាលអំពីការរកឃើញនូវបញ្ហាដែលអាចមានឡើងនូវទំនាស់ផលប្រយោជន៍។

គណៈកម្មាធិការសវនកម្ម បានពិនិត្យទៅលើគុណវុឌ្ឍិ លោក Lin Te Chang ដែលជាបុគ្គលិកដែលមានគុណវុឌ្ឍិ និងបទពិសោធន៍គ្រប់គ្រាន់ក្នុងការអនុវត្តការងារជាប្រធានផ្នែកគណនេយ្យ និងហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ហ្គ្រេន ធ្វីន និងបានប្រគល់ការទទួលខុសត្រូវ ដោយមិនត្រូវអនុវត្តការងារដែលបង្កើតឲ្យមានទំនាស់ផលប្រយោជន៍ ដោយត្រូវបញ្ជូនរបាយការណ៍សវនកម្មដែលធ្វើដោយសវនករផ្ទៃក្នុងទៅឲ្យគណៈកម្មាធិការសវនកម្ម និងបុគ្គលិកជាន់ខ្ពស់ដទៃទៀត ដែលទទួលខុសត្រូវក្នុងផ្នែកដែលត្រូវបានធ្វើសវនកម្ម ព្រមទាំងត្រូវបញ្ជូនទៅឲ្យគណៈកម្មាធិការសវនកម្មនូវរាល់ការរកឃើញនានា ដែលអាចមានផលប៉ះពាល់ដល់ដំណើរការរបស់ក្រុមហ៊ុន ហ្គ្រេន ធ្វីន ។ លោក Hsieh Chung Nan អាយុ ៥៣ ឆ្នាំ ជនជាតិតៃវ៉ាន់ លោកបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាប័ត្រ ផ្នែកគណនេយ្យ និងហិរញ្ញវត្ថុ និងមានបទពិសោធន៍ជាច្រើនឆ្នាំ ពាក់ព័ន្ធនឹងផ្នែកនេះ។ លោក បានបម្រើការងារជា ប្រធានផ្នែកគណនេយ្យ និងហិរញ្ញវត្ថុ នៅក្រុមហ៊ុន ហ្គ្រេន ធ្វីន ជំនួសលោក Lin Te Chang កាលពីខែមិថុនា ឆ្នាំ២០១៧ កន្លងទៅ។

## សកម្មភាពការងារសម្រាប់ឆ្នាំ២០១៧

សម្រាប់ដំណាច់ការិយបរិច្ឆេទឆ្នាំ២០១៧ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ នេះ គណៈកម្មាធិការសវនកម្មបាន ពិនិត្យលទ្ធផល និងវាយតម្លៃលទ្ធផលការងាររបស់អង្គភាពសវនករផ្ទៃក្នុង និងការងារចម្បងមួយចំនួន មានដូចជា (១) ដាក់សំណើទៅក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន ដើម្បីជ្រើសរើសក្រុមហ៊ុនគណនេយ្យជំនាញ Grant Thornton (Cambodia) Limited ជាសវនករឯករាជ្យ (២) ត្រួតពិនិត្យរបាយការណ៍ហិរញ្ញវត្ថុក្នុងគ្រាសង្ខេប និងរបាយការណ៍ហិរញ្ញវត្ថុសម្រាប់ ដំណាច់ការិយបរិច្ឆេទឆ្នាំ២០១៧ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ ដែលរៀបចំដោយសវនករផ្ទៃក្នុង (៣) ត្រួតពិនិត្យឡើងវិញនូវរបាយការណ៍ហិរញ្ញវត្ថុសង្ខេបក្នុងគ្រាសង្ខេបត្រីមាសនានា និងរបាយការណ៍ហិរញ្ញវត្ថុដែលពិនិត្យ និងធ្វើសវនកម្មរួចដោយ ក្រុមហ៊ុន Grant Thornton ជាសវនករឯករាជ្យ មុននឹងដាក់ការពិនិត្យ និងសម្រេចពីក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន ដោយធានានូវប្រសិទ្ធភាពការងាររវាង សវនករឯករាជ្យ និងសវនករផ្ទៃក្នុង (៤) កិច្ចពិភាក្សាលើផែនការបែងចែកភាគលាភ ជាមូលបត្រ ជូនភាគហ៊ុនិកសម្រាប់ឆ្នាំ បន្ទាប់ និង (៥) បញ្ហាផ្សេងៗ ទៀត។

## បញ្ហាប្រឈម

សម្រាប់ដំណាច់ការិយបច្ឆេទឆ្នាំ២០១៧ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ គណៈកម្មាធិការសវនកម្ម ពុំមានបញ្ហាប្រឈមណាមួយដែលបានប៉ះពាល់ដល់ប្រតិបត្តិការ និងស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុននះទេ។ ការត្រួតពិនិត្យ និងវាយតម្លៃលទ្ធផលការងាររបស់អង្គភាពសវនករផ្ទៃក្នុង និងក្រុមហ៊ុនគណនេយ្យជំនាញ ដែលជាជាសវនករឯករាជ្យ គឺទទួលបានលទ្ធផលជាវិជ្ជមាន ទោះជាមានភាពយឺតយ៉ាវខ្លះៗ ក្នុងការផ្តល់ព័ត៌មានទាន់ពេល រួមមាន លទ្ធផលប្រតិបត្តិការក្រុមហ៊ុន របាយការណ៍ហិរញ្ញវត្ថុក្នុងគ្រាសង្ខេប ជូន គ.ម.ក និង ផ.ម.ក និងវិនិយោគិនសាធារណៈ ក៏ដោយ។

សម្រាប់លទ្ធផលឆ្នាំ២០១៧ កន្លងទៅ ប្រតិបត្តិការ និងស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ប្រាក់ចំណេញសុទ្ធក្រោយបង់ពន្ធមានការថយចុះ បើធៀបនឹងឆ្នាំ២០១៥ និងឆ្នាំ២០១៦ កន្លងទៅ ដោយសារ នៅឆ្នាំ២០១៧ ប្រាក់បៀវត្សរ៍ជាមធ្យមរបស់ពលកររោងចក្រកាត់ដេរបានកើនឡើងជាបន្តបន្ទាប់ និងការលក់បញ្ចុះតម្លៃទំនិញ ដែលជាបញ្ហាប្រឈម និងបានប៉ះពាល់ដល់ប្រតិបត្តិការក្រុមហ៊ុននោះឡើយ។ សម្រាប់លទ្ធផលដំណាច់ការិយបច្ឆេទឆ្នាំ២០១៧ ប្រតិបត្តិការ និងស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុនមានលក្ខណៈល្អប្រសើរ។ គណៈកម្មាធិការសវនកម្ម គណៈគ្រប់គ្រងក្រុមហ៊ុន និងបុគ្គលិកពាក់ព័ន្ធ បានចាត់វិធានការត្រៀមជាស្រេច ក្នុងការទប់ស្កាត់ការណ៍ដែលអាចកើតឡើងជាយថាហេតុសម្រាប់ឆ្នាំបន្ទាប់ៗ។

សម្រាប់ត្រីមាសបន្ទាប់ ឆ្នាំ២០១៨ គណៈកម្មាធិការសវនកម្ម នៅតែបន្តកិច្ចប្រឹងប្រែង និងប្រកាន់ជាប់តួនាទីភារកិច្ចរបស់ខ្លួន ដើម្បីធានានូវប្រសិទ្ធភាពការងាររវាងសវនករឯករាជ្យ និងសវនករផ្ទៃក្នុង និងត្រួតពិនិត្យអំពីប្រសិទ្ធភាពដំណើរការនៃការអនុវត្តយន្តការត្រួតពិនិត្យផ្ទៃក្នុង។

# បុគ្គលិកជាន់ខ្ពស់

## សមាសភាព និងតួនាទី ភារកិច្ច ការទទួលខុសត្រូវរបស់បុគ្គលិកជាន់ខ្ពស់



លោក Liao Chung-Te
អភិបាលប្រតិបត្តិ និង
នាយកប្រតិបត្តិ

លោក Liao Chung-Te អភិបាលប្រតិបត្តិ និងជានាយកប្រតិបត្តិ ទទួលបន្ទុកអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ហើយធ្វើឲ្យសម្រេចនូវគោលនយោបាយដែលកំណត់ដោយក្រុមប្រឹក្សាភិបាល។ លោក ចូលរួមរៀបចំគម្រោងការងាររបស់ក្រុមហ៊ុន ហើយដាក់ជូនក្រុមប្រឹក្សាភិបាលអនុម័ត រៀបចំគម្រោងថវិកាប្រចាំឆ្នាំរបស់ក្រុមហ៊ុន និង ដាក់ជូនក្រុមប្រឹក្សាភិបាលអនុម័ត រៀបចំរបាយការណ៍ប្រចាំឆ្នាំអំពីសកម្មភាព ធ្វើតុល្យការហិរញ្ញវត្ថុប្រចាំឆ្នាំ និង ដាក់ជូនក្រុមប្រឹក្សាភិបាលអនុម័ត ប្រើប្រាស់ និងចាត់ចែងនិយោជិតរបស់ក្រុមហ៊ុនក្នុងកម្រិតក្របខណ្ឌដែលបានកំណត់ដោយក្រុមប្រឹក្សាភិបាល និង ស្របតាមបទប្បញ្ញត្តិ ដែលមានចែងក្នុងលក្ខន្តិកៈបុគ្គលិករបស់ក្រុមហ៊ុន។ នាយកប្រតិបត្តិ ត្រូវបានផ្តល់សិទ្ធិអំណាចក្នុងការជ្រើសរើស តែងតាំង ដកហូតមុខងារ ឬបណ្តេញចោលនូវបុគ្គលិក និងអនុវត្តសិទ្ធិអំណាចតាមឋានានុក្រម។ ជារួមអគ្គនាយកមានមុខងារដឹកនាំ និងគ្រប់គ្រងរាល់ការងារចាំបាច់ ទាំងអស់ដើម្បីធានាដំណើការជាប្រក្រតីរបស់ក្រុមហ៊ុន។



លោក Hsieh Chung Nan
ប្រធានផ្នែកគណនេយ្យ និងហិរញ្ញវត្ថុ

ជនជាតិតៃវ៉ាន់ កើតនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៦៤ កាន់លិខិតឆ្លងដែនចិនលេខ ៣០៦០៧៧០៤០ ចុះកាលបរិច្ឆេទថ្ងៃទី២៨ ខែសីហា ឆ្នាំ ២០១២។ លោកបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាប័ត្រ ផ្នែកគណនេយ្យ និង គ្រប់គ្រង ពី National Defense Management College ក្នុងឆ្នាំ១៩៨៦ និង បានបន្តការសិក្សាថ្នាក់បរិញ្ញាប័ត្រ ផ្នែកគ្រប់គ្រងធុរកិច្ច ពីសាកលវិទ្យាល័យ Cheng-Kung University College of Further Education នៅឆ្នាំ១៩៩១។ លោកធ្លាប់ជា ប្រធានផ្នែកគ្រប់គ្រង នៅក្រុមហ៊ុន Tai Yang Enterprise Co., Ltd (កម្ពុជា) ពីឆ្នាំ២០១០ ដល់ឆ្នាំ២០១៦។ ពីឆ្នាំ២០០៦ ដល់ ឆ្នាំ២០០៧ លោកជា ជំនួយការប្រធានចាត់ការទូទៅ នៅក្រុមហ៊ុន Formosa Enterprise Co., Ltd (Honduras)។ លោកក៏ធ្លាប់ជា ប្រធានផ្នែកគណនេយ្យ នៅក្រុម ហ៊ុន Tainan Enterprise Co., Ltd (ឥណ្ឌូណេស៊ី) ពីឆ្នាំ២០០៤ ដល់ ឆ្នាំ ២០០៥ និងនៅក្រុមហ៊ុន Jordan Dragon Enterprise Co., Ltd (ហ្សកដង់) ពីឆ្នាំ២០០៣ ដល់ឆ្នាំ២០០៤។ ឆ្នាំ១៩៩៩ ដល់ ឆ្នាំ២០០៣ លោកជា ប្រធានផ្នែកគណនេយ្យ នៅក្រុមហ៊ុន Tai Yang Enterprise Co., Ltd (កម្ពុជា)។ ពីឆ្នាំ១៩៩៦ ដល់ ឆ្នាំ១៩៩៩ លោកជា ប្រធានផ្នែករដ្ឋបាល នៅក្រុមហ៊ុន Zheng-He Industrial Co (ចិន)។ លោកបានបម្រើការងារជា ប្រធានផ្នែកគណនេយ្យ និងហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ហ្គ្រេន ធ្វីន កាលពីខែមិថុនា។



លោក Jin Meng
ប្រធានផ្នែកបច្ចេកទេសព័ត៌មានវិទ្យា

ជនជាតិតៃវ៉ាន់ កើតនៅថ្ងៃទី២១ ខែមិថុនា ឆ្នាំ១៩៧៨ កាន់លិខិតឆ្លងដែនចិនលេខ G២៩៩៦២៣៨៤ ចុះកាលបរិច្ឆេទ ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ ២០០៨។ លោក បានបញ្ចប់ការសិក្សា នៅវិទ្យាស្ថានបច្ចេកវិទ្យា Nanchang នៃសាធារណៈ រដ្ឋប្រជាមានិតចិន ក្នុងឆ្នាំ១៩៩៧។ លោក បានបំពេញការងារ ជាប្រធានផ្នែកព័ត៌មានវិទ្យា នៅក្រុមហ៊ុន Ford Glory (Cambodia) Co., Ltd ពីឆ្នាំ២០១១ ដល់ ឆ្នាំ២០១២។ ពីឆ្នាំ២០១២ ដល់ ឆ្នាំ២០១៣ លោក បានបម្រើារងារ ជាប្រធានផ្នែកព័ត៌មានវិទ្យា នៅក្រុមហ៊ុន TY Fashion Cambodia lc។ លោក បានចាប់ផ្តើមបម្រើការ នៅក្រុមហ៊ុន ហ្វ្រេន ធ្វីន មានឋានៈ ជា្រធានផ្នែកបច្ចេកទេសព័ត៌មានវិទ្យា ជំនួសលោក Zhang Wei នៅ ឆ្នាំ២០១៤។ លោក Jin Meng ប្រធានផ្នែកបច្ចេកទេស ព័ត៌មានវិទ្យា មានតួនាទីយ៉ាងសំខាន់ ក្នុងការថែរក្សានូវ ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់ក្រុមហ៊ុន និងទទួលបន្ទុក លើការងារបច្ចេកទេស ដោយលោក ជាប្រធានផ្នែកព័ត៌មានវិទ្យាផង និងជាវិស្វករបណ្តាញព័ត៌មានវិទ្យាផង។



លោកស្រី Cheng Yi Shan
ប្រធានផ្នែកបង្កើតថ្មី និង
ផ្នែកទំនួលខុសត្រូវសង្គម

ជនជាតិតៃវ៉ាន់ កើតនៅថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ១៩៩០ កាន់ លិខិតឆ្លងដែនចិនលេខ ៣០៥៦៥៣៩៥១ ចុះកាល បរិច្ឆេទថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១២។ លោកស្រី បានបញ្ចប់ការសិក្សាពីមហាវិទ្យាល័យ Wenzao Ursuline University of Languages សាធារណៈរដ្ឋប្រជាមានិតចិន ផ្នែកអក្សរសាស្ត្រអង់គ្លេស ក្នុងឆ្នាំ២០១៤។ លោកស្រី ធ្លាប់បម្រើការងារជា អ្នកតំណាងផ្នែកលក់ នៅក្រុមហ៊ុន Synclink Transportation Co., Ltd. ពី ឆ្នាំ២០១៤ ដល់ឆ្នាំ២០១៥។ លោកស្រី បានចូលបម្រើការងារនៅ ក្រុមហ៊ុន ហ្វ្រេន ធ្វីន កាលពីខែមិថុនា ឆ្នាំ២០១៧ កន្លងទៅ ក្នុងតួនាទីជា ប្រធានផ្នែកបង្កើតថ្មី និងផ្នែកទំនួលខុសត្រូវសង្គម ជំនួស លោកស្រី Qu Ning។ លោកស្រី ទទួលខុសត្រូវលើផ្នែកទំនាក់ទំនងអតិថិជន និងធ្វើការសម្របសម្រួលជាមួយអតិថិជន លើផ្នែកសុវត្ថិភាព រោងចក្រ និងគោលការណ៍ ទំនួលខុសត្រូវសង្គមទទួលខុសត្រូវចំពោះបរិស្ថាន ការងារក្នុងរោងចក្រ ពិនិត្យ និងធ្វើបច្ចុប្បន្នកម្មលើគោលការណ៍ សុវត្ថិភាពផលិតកម្ម ដឹកជញ្ជូន និងប្រឆាំងភេរវកម្ម តម្រូវអោយនិយោជិតទាំងអស់ គោរពតាមគោលការណ៍ស្តង់ដា សុវត្ថិភាព និងធានាថា ស្តង់ដានេះបានធ្វើបច្ចុប្បន្នកម្ម។



លោក Hsieh Chung Nan
ប្រធានផ្នែកស្រាវជ្រាវ ការអភិវឌ្ឍន៍
និងផ្នែកប្រតិបត្តិការ

លោក Hsieh Chung Nan ជាប្រធានផ្នែកគណនេយ្យ និងហិរញ្ញវត្ថុ របស់ក្រុមហ៊ុន ប្រ្គេន ធ្វីន កាលពីខែមិថុនា ឆ្នាំ២០១៧។ លោក ក៏ត្រូវបានតែងតាំងជាប្រធានផ្នែកស្រាវជ្រាវ ការអភិវឌ្ឍន៍ និងផ្នែកប្រតិបត្តិការ ជំនួស លោក Chang Yuan Jong។ លោក មានតួនាទីក្នុងការមើលការខុសត្រូវ គម្រោង និងសកម្មភាពស្រាវជ្រាវអភិវឌ្ឍន៍ ទទួលខុសត្រូវទៅលើរាល់ប្រតិបត្តិការ ទាំងអស់របស់រោងចក្រ ដូចជា ផលិតកម្ម ការដឹកជញ្ជូន និងគុណភាពផលិតផលមុនពេលបញ្ជូន ទៅផ្នែកត្រួតពិនិត្យគុណភាព រៀបចំ ដំណើរការផលិតកម្ម និងធានាថា ប្រតិបត្តិការរបស់រោងចក្រមានភាពរលូន ធ្វើទំនាក់ទំនងយ៉ាងជិតស្និតជាមួយអតិថិជន ដើម្បីពិភាក្សាពីម៉ូដែល និងសំលៀកបំពាក់ច្នៃម៉ូដថ្មី តម្រូវអោយគុណភាព នៃផលិតផលមានការប្រសើរឡើងជាបន្តបន្ទាប់ តម្រូវអោយមានការបណ្តុះបណ្តាលដល់និយោជិត លើផ្នែកគុណភាព និងដំណើរការផលិតកម្ម និងត្រួតពិនិត្យគុណភាពផលិតផល ដែលគោរពតាមតម្រូវការរបស់អតិថិជន។



លោក **លឹម យុនហួត**
ប្រធានផ្នែកត្រួតពិនិត្យគុណភាព

ជនជាតិខ្មែរ កើតនៅថ្ងៃទី០២ ខែកញ្ញា ឆ្នាំ១៩៧៩ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ លេខ ០១០០៤៥១២០ ចុះកាលបរិច្ឆេទថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១១។ លោក បានបញ្ចប់មធ្យមសិក្សាទុតិយភូមិ ពីវិទ្យាល័យបាក់ទូក ក្នុង ឆ្នាំ១៩៩៧។ ពីឆ្នាំ២០១១ ដល់បច្ចុប្បន្ន លោកកំពុងសិក្សាថ្នាក់បរិញ្ញាប័ត្រផ្នែកគ្រប់គ្រង នៅសាកលវិទ្យាល័យ បៀលប្រាយ។ ពីឆ្នាំ២០០១ ដល់ឆ្នាំ២០០៣ លោក ជាគ្រូបង្រៀនភាសាចិន នៅសាលា Chhong Cheng។ ពីឆ្នាំ២០០៣ ដល់ ឆ្នាំ២០០៨ លោកបម្រើការងារជា ប្រធានផ្នែកកាត់ និងត្រួតពិនិត្យគុណភាព នៅក្រុមហ៊ុន QMI Industrial (Cambodia) Co., Ltd។ ឆ្នាំ២០០៨ លោក បានចូលបម្រើការងារនៅក្រុមហ៊ុន ប្រ្គេន ធ្វីន ដោយ មានឋានៈជាជំនួយការប្រធានផ្នែកត្រួតពិនិត្យគុណភាព។ នៅចុងឆ្នាំ២០១៤ ត្រូវបានតែងតាំងជាប្រធានផ្នែក ត្រួតពិនិត្យគុណភាព ជំនួស លោក Zhang Yao Jun ។ លោក មានតួនាទីក្នុងការត្រួតពិនិត្យគុណភាព ទំនិញ មុន នឹងធ្វើការ វេច ខ្ចប់ និងបញ្ជូនទៅអតិថិជន។ ផលិតផល ទាំងអស់ ត្រូវ ធានាថា គោរពតាមតម្រូវការអតិថិជន។



លោក **ភួង វុធ្វី**
ប្រធានផ្នែកធនធានមនុស្ស និង
លេខាធិការ

ជនជាតិខ្មែរ កើតនៅថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ១៩៤៩ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ លេខ ០១០៣៦២០៦៧ ចុះកាលបរិច្ឆេទថ្ងៃទី០៩ ខែមេសា ឆ្នាំ២០១២។ លោក បានបញ្ចប់មធ្យមសិក្សាទុតិយភូមិ ពីវិទ្យាល័យខេត្តស្វាយរៀង នៅឆ្នាំ១៩៧៥។ លោកមានបទពិសោធន៍ជាង ២០ឆ្នាំ ក្នុងផ្នែករដ្ឋបាល និងការគ្រប់គ្រងធនធានមនុស្ស។ លោក ធ្លាប់បម្រើការងារជាប្រធានផ្នែករដ្ឋបាលនៅក្រុមហ៊ុនជាច្រើន ដូចជា ពីឆ្នាំ១៩៩៤ ដល់ឆ្នាំ១៩៩៦ លោក ជាប្រធានផ្នែករដ្ឋបាល គ្រប់គ្រងផ្នែករដ្ឋបាល និងធនធានមនុស្ស នៃក្រុមហ៊ុន PPS Co., Ltd។ ពី ឆ្នាំ១៩៩៧ ដល់ ១៩៩៨ លោក ជាប្រធានផ្នែករដ្ឋបាល និងគ្រប់គ្រងធនធានមនុស្សនៃរោងចក្រកាត់ដេរ Milling។ ពី ឆ្នាំ១៩៩៩ ដល់ ឆ្នាំ២០០៨ លោក ជាប្រធាន ផ្នែករដ្ឋបាល និងគ្រប់គ្រងធនធានមនុស្សនៃរោងចក្រកាត់ដេរ QMI Industrial (Cambo dia) Co., Ltd ។ ពីឆ្នាំ២០០៨ ដល់ បច្ចុប្បន្ន លោកជា ប្រធានផ្នែកគ្រប់គ្រងធនធានមនុស្ស នៃក្រុមហ៊ុន ហ្រ្គេន ធ្វីន។



លោក **លី ផុង**
ប្រធានផ្នែករដ្ឋបាល

ជនជាតិខ្មែរកើតនៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ១៩៤៤ កាន់ អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ លេខ ១១០០៨១៩៩៤ ចុះកាលបរិច្ឆេទថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១១។ លោក បានបញ្ចប់មធ្យមសិក្សាបឋមភូមិ ពីសាលាភាសាចិន Jue Ming ខេត្តកំពត នាឆ្នាំ១៩៦១។ ពីឆ្នាំ១៩៩២ ដល់ ឆ្នាំ១៩៩៣ លោកបម្រើការងារជា អនុប្រធានផ្នែកហិរញ្ញវត្ថុនៃក្រុមហ៊ុនស្រាបៀរFoster។ លោក ក៏ធ្លាប់បម្រើការងារ នៅក្រុមហ៊ុនសំយាបផ្ទះ Jing Shan ក្នុងតំណែង ជានាយករងគ្រប់គ្រងទូទៅ ពីឆ្នាំ១៩៩៦ ដល់ ឆ្នាំ ១៩៩៧។ ពីឆ្នាំ២០០៨ ដល់បច្ចុប្បន្ន លោក ជាប្រធាន ផ្នែករដ្ឋបាលនៃក្រុមហ៊ុន ហ្រ្គេន ធ្វីន។ លោក លី ផុង ទទួលខុសត្រូវលើគ្រប់ផ្នែក ដែលទាក់ទងនឹងការងារទូទៅរបស់រោងចក្រ ដូចជាអនាម័យអាហារ ការគ្រប់គ្រងរថយន្ត ក្រុមហ៊ុន អន្តេវាសិនដ្ឋានរបស់កម្មករ អគ្គីសនីបំភ្លើរោងចក្រ និងសំភារៈផ្គត់ផ្គង់ការិយាល័យ និងការងាររដ្ឋបាលមួយចំនួនទៀត។

## លទ្ធផលការងាររបស់បុគ្គលិកជាន់ខ្ពស់

គណៈគ្រប់គ្រងនៃក្រុមហ៊ុន ហ្រ្គេន ធ្វីន មានបទពិសោធន៍ខ្ពស់ផ្នែកផលិតកម្មសំលៀកបំពាក់ ជាពិសេស សំលៀកបំពាក់កីឡា។ គណៈគ្រប់គ្រងរបស់ក្រុមហ៊ុន ហ្រ្គេន ធ្វីន ផ្តោតសំខាន់ទៅលើទិសដៅ និងការអនុវត្តយុទ្ធសាស្រ្តរបស់ក្រុមហ៊ុនដែលបានដាក់ចេញ។ ក្រុមហ៊ុន ហ្រ្គេន ធ្វីន ជឿជាក់ថា គណៈគ្រប់គ្រងរបស់ខ្លួនមានសមត្ថភាពគ្រប់គ្រាន់ និងអាចសម្របតាមការប្រែប្រួលនៃទីផ្សារបានយ៉ាងឆាប់រហ័ស។ ភាពជោគជ័យរបស់ក្រុមហ៊ុន គឺ ពឹងផ្អែកសំខាន់ទៅលើសមត្ថភាពក្នុងការផ្គត់ផ្គង់ទំនិញ ដែលមានគុណភាពខ្ពស់ដល់អតិថិជន។ ដើម្បីសម្រេចបាននូវឆន្ទៈនេះ រាល់បុគ្គលិកក្រុមហ៊ុនម្នាក់ៗ ត្រូវដឹងពីទំនួលខុសត្រូវរបស់ខ្លួនដើម្បីធានាថា ផលិតផល គឺមានគុណភាពល្អបំផុតតាមដែលអាចធ្វើទៅបាន។ ក្រុមហ៊ុន ក៏បានផ្តល់នូវសៀវភៅដែលបង្ហាញពីរបៀបប្រើដល់បុគ្គលិកដើម្បីធានាថា ពួកគាត់បានយល់ច្បាស់អំពីនីតិវិធីការងារ។ ក្រុមត្រួតពិនិត្យគុណភាពជាអ្នកអនុវត្ត និងត្រួតពិនិត្យគោលការណ៍ "គ្មានខុស" ឬ "គោលនយោបាយជោគជ័យ ១០០%" លើផលិតផលគ្រប់ប្រភេទទៅតាមដំណាក់កាលនីមួយៗក្នុងដំណើរការផលិតកម្ម។ គោលការណ៍នេះ ក៏អនុវត្តទៅលើការទិញវត្ថុធាតុដើមនិងគ្រឿងបន្ទាប់បន្សំផងដែរ។ វត្ថុធាតុដើម និងគ្រឿងបន្ទាប់បន្សំត្រូវបានទិញពីអ្នកផ្គត់ផ្គង់ដែលត្រូវបានជ្រើសរើស និងយល់ព្រមដោយ Adidas។ គ្រប់វត្ថុធាតុដើម និងគ្រឿងបន្ទាប់បន្សំ ត្រូវបានត្រួតពិនិត្យបន្ថែមមុនពេលប្រើប្រាស់ក្នុងផលិតកម្មដើម្បីធានាថា វត្ថុធាតុទាំងនោះត្រឹមត្រូវតាមការកំណត់ជាក់លាក់ និងមិនមានភាពខ្វះចន្លោះ។ គ្រប់ផលិតផលសម្រេចទាំងអស់ត្រូវបានត្រួតពិនិត្យជាលើកចុងក្រោយមុនពេលប្រគល់ទំនិញជូនអតិថិជន។

សម្រាប់ឆ្នាំ២០១៧ គណៈគ្រប់គ្រងគ្រប់ផ្នែករបស់ក្រុមហ៊ុន គោរព និងអនុវត្តបានតាមផែនការដែលបានកំណត់ ដែលជាលទ្ធផល ក្រុមហ៊ុនទទួលបានលទ្ធផលដ៏ល្អប្រសើរពីប្រតិបត្តិការរបស់ខ្លួន។ គណៈគ្រប់គ្រងគ្រប់ផ្នែក នៅតែបន្តកិច្ចប្រឹងប្រែងនេះ សម្រាប់ឆ្នាំបន្ទាប់។

## ការបណ្តុះបណ្តាលបន្តសម្រាប់បុគ្គលិកជាន់ខ្ពស់

ការបណ្តុះបណ្តាលបុគ្គលិក គឺរៀបចំឡើងដោយក្រុមហ៊ុន ហ្រ្គេន ធ្វីន។ ការបណ្តុះបណ្តាលផ្ទៃក្នុងសម្រាប់បុគ្គលិកមានដូចជា ការណែនាំលើកដំបូងសម្រាប់បុគ្គលិកថ្មី ដើម្បីអោយពួកគេស្គាល់ច្បាស់ពីស្ថានភាពការងារទូទៅ ផលិតផល ការគ្រប់គ្រងគុណភាព និងនីតិវិធីសម្រាប់សុវត្ថិភាពក្នុងរោងចក្រ។ បន្ថែមពីនេះអតិថិជនធ្លាប់បានបញ្ជូនបុគ្គលិករបស់ពួកគេ ដើម្បីបង្ហាត់ពីការគ្រប់គ្រងគុណភាពដល់បុគ្គលិករបស់ក្រុមហ៊ុនដល់កន្លែងធ្វើការ។ ពេលខ្លះ អតិថិជនបានឧបត្ថម្ភដល់បុគ្គលិករបស់ក្រុមហ៊ុន ហ្រ្គេន ធ្វីន ទៅបណ្តុះបណ្តាលនៅបរទេស។ ការបណ្តុះបណ្តាលដល់ទីកន្លែងបំពេញការងារជាកត្តាចម្បងដែលជួយអោយបុគ្គលិកទទួលបានបទពិសោធន៍ និងការអនុវត្តជាក់ស្តែងក្នុងពេលតែមួយ។ ក្រុមហ៊ុន ហ្រ្គេន ធ្វីន ជឿជាក់ថា កម្មវិធីបណ្តុះបណ្តាលរបស់ក្រុមហ៊ុន ហ្រ្គេន ធ្វីន បានផ្តល់នូវជំនាញគ្រប់គ្រាន់ចាំបាច់សម្រាប់ការអនុវត្តការងារអោយបានសម្រេចជោគជ័យ និងមានប្រសិទ្ធភាព។

ក្រុមហ៊ុន ហ្រ្គេន ធ្វីន ក៏បានផ្តល់ការហ្វឹកហ្វឺនដល់បុគ្គលិកជាន់ខ្ពស់ពាក់ព័ន្ធនឹងការទទួលខុសត្រូវក្នុងសង្គមការបង្កើនប្រសិទ្ធភាពនៅក្នុងដំណើរការផលិតកម្ម និងវិធានការប្រឆាំងភេរវកម្ម។

ក្រុមហ៊ុន បានផ្តល់វគ្គបណ្តុះបណ្តាលក្រោមប្រធានបទផ្សេងៗ និងបានបង្កើតក្លឹបសិក្សាសម្រាប់បុគ្គលិករបស់ក្រុមហ៊ុនផងដែរ។ គោលបំណងនៃការផ្តួចផ្តើមបង្កើតក្លឹបសិក្សាសម្រាប់បុគ្គលិកនេះ គឺដើម្បីពង្រីកការយល់ដឹងការផ្លាស់ប្តូរ និងការទទួលបានព័ត៌មាន និងដើម្បីលើកកម្ពស់គុណភាពនៃការធ្វើការ។ សមាជិកទាំងអស់ ត្រូវបានទទួលការបណ្តុះបណ្តាល ដើម្បីឱ្យមានសមត្ថកិច្ចក្នុងការបង្ហាញការគិតរបស់ពួកគេ នៅក្នុងបែបបទដែលបានកំណត់ ។ ក្រុមហ៊ុន រំពឹងថា ការបណ្តុះបណ្តាលនេះ បានពង្រីកចំណេះដឹងរបស់បុគ្គលិក តាមរយៈការធ្វើការងារជាក្រុម និងផ្លាស់ប្តូរមតិយោបល់គ្នាក្នុងក្រុម ក្នុងការដោះស្រាយបញ្ហាអ្វីមួយ និងចែករំលែកគ្នានូវដំណោះស្រាយទាំងនោះ។

ក្លឹបសិក្សា គឺជាសកម្មភាពផ្លាស់ប្តូរបទពិសោធន៍រវាងបុគ្គលិក។ បុគ្គលិកទាំងអស់ មានតម្រូវការស្រដៀងគ្នា សម្រាប់ការអនុវត្តការងារ ការប្រមូលផ្តុំគ្នាដើម្បីចែករំលែកបទពិសោធន៍ទៅវិញទៅមក ទស្សនៈនៃគំនិតរបស់ពួកគេ និងវិធីនៃការគិត។ ដោយការរួមបញ្ចូលគ្នា រវាងការគ្រប់គ្រងចំណេះដឹង ចំណេះដឹងទូទៅទាំងអស់ អាចត្រូវបានចែករំលែក ក្នុងការអភិវឌ្ឍប្រាជ្ញា។ ការចែករំលែកនេះ អនុញ្ញាតឱ្យសម្រាប់ទាំងការងារ និងជីវិតឯកជន នឹងត្រូវបានគេយកមកចែករំលែក ក្នុងគោលបំណងដើម្បីលើកកំពស់ និងការផ្តោតភក្តីភាព ដូច្នេះ នាំឱ្យទំនាក់ទនងរវាងបុគ្គលិកក្នុងក្រុមហ៊ុនមានភាពជិតស្និទ និងរឹងមាំ។ ក្លឹបសិក្សា គឺមិនមែនគ្រាន់តែជាវិធីថ្មីនៃការរៀននៅក្នុងសតវត្សទី២១ នោះទេ ប៉ុន្តែ គឺជាវិធីសាស្រ្ត ដែលត្រូវបានប្រើប្រាស់។

ក្រៅពីវគ្គបណ្តុះបណ្តាលដែលផ្តល់ដោយក្រុមហ៊ុនផ្ទាល់ គណៈគ្រប់គ្រង និងបុគ្គលិកគ្រប់ជាប់ថ្នាក់របស់ក្រុម ហ៊ុនក៏បានទទួលវគ្គបណ្តុះបណ្តាលផងដែរ ដែលផ្តល់ឲ្យដោយ អតិថិជនចម្បងរបស់ក្រុមហ៊ុន ដូចជា ក្រុមហ៊ុន Adidas សមាគម GMAC និង Better Factories ដែលវគ្គបណ្តុះបណ្តាលនោះ ត្រូវបានបែងចែកទៅតាមប្រភេទនៃវគ្គបណ្តុះបណ្តាលនោះ។ វគ្គបណ្តុះបណ្តាល អាចត្រូវបានរៀបចំនៅក្រុមហ៊ុន ហ្វ្រេន ធ្វីន ឬ នៅសមាគម GMAC និង Better Factories ឬ នៅក្រុមហ៊ុន Adidas ដែលជាអតិថិជនចម្បង ដែលមានទីតាំងនៅក្រៅប្រទេស។ ដោយឡែក ក្រុមហ៊ុនតែងតែផ្តល់ឪកាសដល់គណៈគ្រប់គ្រង និងបុគ្គលិកគ្រប់ជាប់ថ្នាក់ ក្នុងការចូលរួមវគ្គបណ្តុះបណ្តាលទាំងនោះ ដើម្បីទទួលបានចំណេះដឹង និងអាចយកមកប្រើប្រាស់ក្នុងការងាររបស់ខ្លួន។ ជាក់ស្តែង ក្រុមហ៊ុន បានចាត់តាំងបុគ្គលិកតាម ផ្នែកដែលពាក់ព័ន្ធ ដើម្បីចូលរួមក្នុងវគ្គបណ្តុះបណ្តាលនោះផងដែរ។ សម្រាប់ឆ្នាំ២០១៧ គណៈគ្រប់គ្រង និងបុគ្គលិករបស់ក្រុមហ៊ុនបានចូលរួមវគ្គបណ្តុះបណ្តាល មួយចំនួន រួមមាន ៖

- វគ្គបណ្តុះបណ្តាលស្តីពី ភពជាដៃគូរវាងគយ និងពាណិជ្ជកម្ម ប្រឆាំងនឹងអំពើភេរវកម្ម
- បណ្តុះបណ្តាលអាហារូបត្ថម្ភ
- វគ្គបណ្តុះបណ្តាលស្តីពី ការប្រើប្រាស់ឧបករណ៍ការពារខ្លួន
- វគ្គបណ្តុះបណ្តាលស្តីពីនិតិវិធីក្នុងការរត់ជំលៀស និង ពន្លត់អគ្គីភ័យ
- វគ្គបណ្តុះបណ្តាលស្តីពី សុខភាព សុវត្ថិភាព និងបរិស្ថានការងារ
- វគ្គបណ្តុះបណ្តាលស្តីពី ប្រាក់ខែនិងអត្ថប្រយោជន៍ផ្សេងៗ
- វគ្គបណ្តុះបណ្តាលស្តីពី ការប្រើប្រាស់ឧបករណ៍ការពារខ្លួន
- វគ្គបណ្តុះបណ្តាលស្តីពី ៦S
- វគ្គបណ្តុះបណ្តាលស្តីពី សុខភាព សុវត្ថិភាព និងបរិស្ថានការងារ
- វគ្គបណ្តុះបណ្តាលស្តីពី ប្រាក់ខែនិងអត្ថប្រយោជន៍ផ្សេងៗ
- វគ្គបណ្តុះបណ្តាលស្តីពីបរិស្ថាន
- វគ្គបណ្តុះបណ្តាលស្តីពីការមិនរើសអើង និងការមិនបៀតបៀនផ្លូវភេទ
- វគ្គបណ្តុះបណ្តាលផ្សេងៗ

វគ្គបណ្តុះបណ្តាលខាងលើនេះ មានការចូលរួមពី ផ្នែកបង្កើតថ្មី និងផ្នែកទំនួលខុសត្រូវសង្គម និងផ្នែករដ្ឋបាលរបស់ក្រុមហ៊ុន ហ្វ្រេន ធ្វីន។ ប្រធានផ្នែក ឬបុគ្គលដែលទទួលខុសត្រូវក្នុងការងារនេះ មានតួនាទីក្នុងការចែកចាយបន្ត និងផ្តល់ជាវគ្គបណ្តុះបណ្តាល ដល់បុគ្គលិកគ្រប់ជាប់ថ្នាក់របស់ក្រុមហ៊ុនដើម្បីទទួលបាននូវចំណេះដឹងនេះ បន្ទាប់ពីវគ្គបណ្តុះបណ្តាល។

**ក. បណ្តឹងពាក់ព័ន្ធនឹងក្ស័យធនធ្វើឡើងចំពោះក្រុមហ៊ុនដែលបុគ្គលិកជាន់ខ្ពស់ ឬអភិបាលរបស់ក្រុមហ៊ុន ហ្គ្រេន ធ្វីន ធ្លាប់ជាអភិបាលបុគ្គលិក ឬជាសហកម្មសិទ្ធិករ**

គិតត្រឹមថ្ងៃដាក់របាយការណ៍ប្រចាំឆ្នាំ២០១៧ នេះ ក្រុមហ៊ុន ហ្គ្រេន ធ្វីន មិនមានអភិបាល ឬបុគ្គលិកជាន់ខ្ពស់ណាម្នាក់ ធ្លាប់មានការពាក់ព័ន្ធនឹងបណ្តឹងក្ស័យធនធ្វើឡើងចំពោះក្រុមហ៊ុនដែលអភិបាល ឬបុគ្គលិកជាន់ខ្ពស់ របស់ក្រុមហ៊ុន ហ្គ្រេន ធ្វីន ធ្លាប់ជាអភិបាល ឬជាសហកម្មសិទ្ធិករក្នុងរយៈពេល ២ឆ្នាំ ចុងក្រោយនោះទេ។

**ខ. ការផ្តន្ទាទោសពីបទឧក្រិដ្ឋ ឬកំពុងស្ថិតនៅក្នុងនីតិវិធីតុលាការចំពោះអភិបាល ឬបុគ្គលិកជាន់ខ្ពស់**

គិតត្រឹមថ្ងៃដាក់របាយការណ៍ប្រចាំឆ្នាំ២០១៧ នេះ ក្រុមហ៊ុន ហ្គ្រេន ធ្វីន មិនមានអភិបាល ឬបុគ្គលិកជាន់ខ្ពស់ណាម្នាក់ ធ្លាប់ត្រូវបានផ្តន្ទាទោសពីបទឧក្រិដ្ឋ ឬកំពុងស្ថិតនៅក្នុងនីតិវិធីតុលាការក្នុងរយៈពេល ២ឆ្នាំចុងក្រោយនោះទេ។

**គ. ការសម្រេចជាស្ថាពរឬជាបណ្តោះអាសន្នរបស់តុលាការមានសមត្ថកិច្ចចំពោះអភិបាល ឬបុគ្គលិកជាន់ខ្ពស់ដោយហាមខាត់មិនឲ្យចូលរួម ឬដោយរារាំង ឬដោយព្យួរ ឬដោយដាក់កំហិតទៅលើអភិបាល ឬបុគ្គលិកជាន់ខ្ពស់នោះ ក្នុងសកម្មភាពមូលបត្រ ឬសកម្មភាពធុរកិច្ចណាមួយ**

គិតត្រឹមថ្ងៃដាក់របាយការណ៍ប្រចាំឆ្នាំ២០១៧ នេះ ក្រុមហ៊ុន ហ្គ្រេន ធ្វីន មិនមានអភិបាល ឬបុគ្គលិក ជាន់ខ្ពស់ណាម្នាក់ទទួលការសម្រេចជាស្ថាពរ ឬជាបណ្តោះអាសន្នរបស់តុលាការមានសមត្ថកិច្ច ដោយហាមឃាត់មិនឲ្យចូលរួម ឬដោយរារាំង ឬដោយព្យួរ ឬដោយដាក់កំហិតទៅលើ អភិបាល ឬបុគ្គលិកជាន់ខ្ពស់នោះនៅក្នុងសកម្មភាពមូលបត្រ ឬសកម្មភាពធុរកិច្ចណាមួយក្នុងរយៈពេល ២ឆ្នាំ ចុងក្រោយនោះទេ។

**ឃ. ការសម្រេចរបស់គណៈកម្មការមូលបត្រកម្ពុជា ឬគណៈកម្មការមូលបត្របរទេស ឬនិយ័តករនៃវិស័យផ្សេងទៀតដោយហាមឃាត់មិនឲ្យចូលរួម ឬដោយរារាំង ឬដោយព្យួរ ឬដោយដាក់កំហិតទៅលើអភិបាល ឬបុគ្គលិកជាន់ខ្ពស់ នៅក្នុងសកម្មភាពមូលបត្រឬសកម្មភាពធុរកិច្ចណាមួយ**

គិតត្រឹមថ្ងៃដាក់របាយការណ៍ប្រចាំឆ្នាំ២០១៧ នេះ ក្រុមហ៊ុន ហ្គ្រេន ធ្វីន មិនមានអភិបាល ឬបុគ្គលិកជាន់ខ្ពស់ណាម្នាក់ទទួលការសម្រេចពីគណៈកម្មការមូលបត្រកម្ពុជា ឬគណៈកម្មការមូលបត្របរទេស ឬនិយ័តករនៃវិស័យផ្សេងទៀតដោយហាមឃាត់មិនឲ្យចូលរួម ឬដោយរារាំង ឬដោយព្យួរ ឬដោយដាក់កំហិតនៅក្នុងសកម្មភាពមូលបត្រ ឬសកម្មភាពធុរកិច្ចណាមួយក្នុងរយៈពេល ២ឆ្នាំ ចុងក្រោយនោះទេ។

**ក. ចំនួនប្រាក់បំណាច់ ឬលាភការជាកញ្ចប់ដែលបានបើកឲ្យអភិបាល និងបុគ្គលិកជាន់ខ្ពស់**

ក្រុមហ៊ុន ហ្គ្រេន ធ្វីន មានអភិបាលសរុបទាំងអស់ចំនួន ០៥ រូប ដែលក្នុងនោះ មានអភិបាលមិនប្រតិបត្តិចំនួន ០៤ រូប ដែលជាសមាជិកក្រុមប្រឹក្សាភិបាល ដែលមិនប្រតិបត្តិការងារប្រចាំថ្ងៃនៅក្នុងក្រុមហ៊ុន ហ្គ្រេន ធ្វីន និងបុគ្គលិកជាន់ខ្ពស់ចំនួន ០៧ រូប។

| មុខតំណែង | ចំនួនសរុប (ប្រាក់បៀវត្សរ៍ និងប្រាក់បំណាច់មិនបូកបញ្ចូលប្រាក់សោធននិវត្តន៍) | | | | | |
|---|---|---|---|---|---|---|
| | ឆ្នាំ២០១៧ | | ឆ្នាំ២០១៦ | | ឆ្នាំ២០១៥ | |
| | រៀល ʹ000ʹ | ដុល្លារអាមេរិក | រៀល ʹ000ʹ | ដុល្លារអាមេរិក | រៀល ʹ000ʹ | ដុល្លារអាមេរិក |
| អភិបាលទាំងអស់ | ២០០.០០០ | ៥០.០០០ | ២០០.០០០ | ៥០.០០០ | ២០០.០០០ | ៥០.០០០ |
| បុគ្គលិកជាន់ខ្ពស់ | ១.០៤២.៥៦០ | ២៦០.៦៤០ | ១.០៤២.៥៦០ | ២៦០.៦៤០ | ១.០៤២.៥៦០ | ១.០៤២.៥៦០ |

**ខ. ការបង្កើនប្រាក់បំណាច់ ឬលាភការសរុបក្នុងចំនួនច្រើន ដល់អភិបាល ឬបុគ្គលិករបស់ក្រុមហ៊ុន ហ្គ្រេន ធ្វីន នៅក្នុងឆ្នាំសារពើពន្ធបច្ចុប្បន្ន ឬអនាគត**

គិតត្រឹមថ្ងៃដាក់របាយការណ៍ប្រចាំឆ្នាំ២០១៧ នេះ ក្រុមហ៊ុន ហ្គ្រេន ធ្វីន មិនមានគោលការណ៍ក្នុងការបង្កើនប្រាក់បំណាច់ ឬលាភការសរុបក្នុងចំនួនច្រើនដល់អភិបាល ឬបុគ្គលិករបស់ខ្លួន នៅឡើយទេ។

**គ. សិទ្ធិទិញមូលបត្រកម្មសិទ្ធិ ដែលបានផ្តល់ទៅឲ្យអភិបាល បុគ្គលិកជាន់ខ្ពស់ និងនិយោជិត (Stock Opotion)**

**សិទ្ធិទិញមូលបត្រកម្មសិទ្ធិផ្តល់ឲ្យអភិបាល**

គិតត្រឹមថ្ងៃដាក់របាយការណ៍ប្រចាំឆ្នាំ២០១៧ នេះ ក្រុមហ៊ុន ហ្គ្រេន ធ្វីន មិនមានគោលការណ៍ក្នុងការផ្តល់សិទ្ធិទិញមូលបត្រកម្មសិទ្ធិ សម្រាប់អភិបាលរបស់ខ្លួននោះទេ។

**សិទ្ធិទិញមូលបត្រកម្មសិទ្ធិផ្តល់ឲ្យបុគ្គលិកជាន់ខ្ពស់**

គិតត្រឹមថ្ងៃដាក់របាយការណ៍ប្រចាំឆ្នាំ២០១៧ នេះ ក្រុមហ៊ុន ហ្គ្រេន ធ្វីន មិនមានគោលការណ៍ក្នុងការផ្តល់សិទ្ធិទិញមូលបត្រកម្មសិទ្ធិសម្រាប់បុគ្គលិកជាន់ខ្ពស់របស់ខ្លួននោះទេ។

**សិទ្ធិទិញមូលបត្រកម្មសិទ្ធិផ្តល់ឲ្យនិយោជិត**

គិតត្រឹមថ្ងៃដាក់របាយការណ៍ប្រចាំឆ្នាំ២០១៧ នេះ ក្រុមហ៊ុន ហ្គ្រេន ធ្វីន មិនមានគោលការណ៍ក្នុងការផ្តល់សិទ្ធិទិញមូលបត្រកម្មសិទ្ធិ សម្រាប់និយោជិតរបស់ខ្លួននោះទេ។

ដើម្បីធានាការដឹកនាំប្រកបដោយប្រសិទ្ធភាពខ្ពស់ ក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន ហ្គ្រេន ធ្វីន បានសម្រេចអនុម័តក្រមសីលធម៌សម្រាប់អភិបាល និងបុគ្គលិកជាន់ខ្ពស់របស់ក្រុមហ៊ុននៅឆ្នាំ២០១៣ ហើយអភិបាល និងបុគ្គលិកជាន់ខ្ពស់ទាំងអស់របស់ក្រុមហ៊ុន ត្រូវតែអនុវត្តក្រមសីលធម៌នេះ។

ក្រមសីលធម៌នេះ ត្រូវបានធ្វើឡើងសម្រាប់សមាជិកនៃក្រុមប្រឹក្សាភិបាល និងបុគ្គលិកជាន់ខ្ពស់របស់ក្រុមហ៊ុន ហ្គ្រេន ធ្វីន ដោយអនុលោមទៅតាមច្បាប់ និងបទប្បញ្ញត្តិដែលមានជាធរមាន ជាពិសេសគឺ បទប្បញ្ញត្តិនៃជំពូក ៦ នៃ ច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការ ជួញដូរមូលបត្រមហាជន ក៏ដូចជា ប្រកាសស្តីពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ។ លើសពីនេះទៅទៀត ក្រមនេះត្រូវបាន រៀបចំតាក់តែងឡើងដើម្បីធានាឲ្យបាននូវការគោរព និងអនុលោមទៅតាមរាល់បទប្បញ្ញត្តិនានាដែលនៅជាធរមាន និងដែលមានចែងក្នុងប្រកាសស្តីពីអភិបាលកិច្ចសាជីវកម្ម សម្រាប់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈផងដែរ។

## ក. គោលការណ៍នៃក្រមសីលធម៌

ក្រមសីលធម៌នេះ មានគោលដៅកំណត់លក្ខខណ្ឌតម្រូវនានាពាក់ព័ន្ធនឹងការអនុវត្តអភិបាលកិច្ចសាជីវកម្មសម្រាប់ក្រុមហ៊ុន កំណត់សិទ្ធិអំណាច និងកាតព្វកិច្ចរបស់ក្រុមប្រឹក្សាភិបាល ការបង្កើតយន្តការដើម្បីការពារសិទ្ធភាគហ៊ុនិក និងភាគីពាក់ព័ន្ធ ការរៀបចំរចនាសម្ព័ន្ធគ្រប់គ្រង និងប្រព័ន្ធត្រួតពិនិត្យ ប្រកបដោយប្រសិទ្ធិភាពខ្ពស់។ ក្រុមប្រឹក្សាភិបាល និងបុគ្គលិកជាន់ខ្ពស់ ត្រូវអនុវត្តការងារក្នុងរង្វង់នៃដែសមត្ថកិច្ច ដែលបានប្រគល់ជូនជាមួយនឹងករណីយកិច្ច ក្នុងការតាមដាននូវព័ត៌មាន បច្ចុប្បន្នភាពពាក់ព័ន្ធទៅនឹងដំណើរការវិវត្តន៍នៃធុរកិច្ច ក្រុមហ៊ុន និងបញ្ហាផ្សេងៗពាក់ព័ន្ធ នឹងកាតព្វកិច្ចផ្នែកច្បាប់នានា ដែលតម្រូវឲ្យក្រុមហ៊ុនត្រូវតែធ្វើការបំពេញ។

ក្រមនេះ ក៏ជាជំនួយក្នុងការណែនាំបញ្ហានានាដែលមានការពាក់ព័ន្ធទៅនឹងបញ្ហាក្រមសីលធម៌ ដោយផ្តល់ជាយន្តការក្នុងការរាយកាណ៍ក្នុងករណីអភិបាល ឬបុគ្គលិកជាន់ខ្ពស់ណាម្នាក់ ប្រព្រឹត្តិផ្ទុយទៅនឹងក្រមសីលធម៌ និងបង្ហាញតម្លាភាពក្នុងការគ្រប់គ្រងប្រតិបត្តិការរបស់ក្រុមហ៊ុន។ ក្រមនេះ មិនត្រឹមតែធានាបាននូវការគោរពច្បាប់ និងបទប្បញ្ញត្តិនានានោះទេ ប៉ុន្តែវាមានគោលដៅដើម្បីធានាឲ្យបាននូវអភិបាលកិច្ចសាជីវកម្មមួយផងដែរ សម្រាប់ក្រុមហ៊ុន។

## ខ. ការអនុវត្តក្រមសីលធម៌

ក្រោយពីក្រមសីលធម៌ត្រូវបានអនុម័ត និងដាក់ឲ្យប្រើប្រាស់ សមាជិកក្រុមប្រឹក្សាភិបាល និងគណៈគ្រប់គ្រង គ្រប់ផ្នែក អនុវត្តបានខ្ជាប់ខ្ជួន នូវកាតព្វកិច្ច និងទទួលខុសត្រូវខ្ពស់នូវភារកិច្ចរបស់ខ្លួន។ តាមបណ្តាឆ្នាំកន្លងទៅ និងគិតត្រឹមថ្ងៃដាក់របាយការណ៍ប្រចាំឆ្នាំ ២០១៧ នេះ ជាលទ្ធផលមិនមានបញ្ហាធ្ងន់ធ្ងរណាមួយដែលប្រព្រឹត្ត ដោយសមាជិកក្រុមប្រឹក្សាភិបាល និងគណៈគ្រប់គ្រងគ្រប់ផ្នែក ផ្ទុយនឹងក្រមសីលធម៌នេះឡើយ។

## ក. យន្តការការពារសិទ្ធិ

ក្រុមហ៊ុន ហ្គ្រេន ធ្វីន តែងតែផ្តោត និងយកចិត្តទុកដាក់យ៉ាងខ្លាំង ក្នុងការការពារសិទ្ធិសម្រាប់ភាគីពាក់ព័ន្ធនានា រួម មាន ឥណទាយក បុគ្គលដែលមានទំនាក់ទំនងផលប្រយោជន៍ និងមានកិច្ចសន្យាជាមួយក្រុមហ៊ុន។ ក្រុមហ៊ុន ហ្គ្រេន ធ្វីន បច្ចុប្បន្នជាក្រុមហ៊ុនចុះបញ្ជីលក់មូលបត្រ ដូច្នេះ ក្រុមហ៊ុន មានកាតព្វកិច្ចក្នុងការបង្ហាញព័ត៌មានទាន់ពេល ប្រកប ដោយតម្លាភាព និងផ្តល់របាយការណ៍ប្រចាំត្រីមាស ឆមាស និងរបាយការណ៍ប្រចាំឆ្នាំ ដែលរួមមាន ព័ត៌មានអំពីបច្ចុប្បន្ន ភាពនៃ ប្រតិបត្តិការក្រុមហ៊ុន ស្ថានភាពហិរញ្ញវត្ថុ និងព័ត៌មានចាំបាច់ផ្សេងទៀត ដែលអាចមានផលប៉ះពាល់ដល់ការ សម្រេចចិត្ត និងផលប្រយោជន៍របស់ភាគីពាក់ព័ន្ធ និងវិនិយោគិនសាធារណៈ។ ព័ត៌មានទាំងនោះ ភាគីពាក់ព័ន្ធ និង វិនិយោគិន សាធារណៈ រួមទាំង ភាគហ៊ុនិករបស់ក្រុមហ៊ុន ហ្គ្រេន ធ្វីន មានសិទ្ធិទទួលបានទាន់ពេល នូវព័ត៌មានដែល បាន រៀបរាប់ខាង លើតាមរយៈគេហទំព័ររបស់ក្រុមហ៊ុនគឺ www.Grandtwins.com.kh គេហទំព័ររបស់គណៈកម្មការមូលបត្រ កម្ពុជា គឺ www.secc.gov.kh និងគេហទំព័ររបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា គឺគឺ www.csx.com.kh។

## ខ. សកម្មភាពនៃការការពារសិទ្ធិ

គិតត្រឹមការិយបរិច្ឆេទឆ្នាំ២០១៧ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ គិតចាប់ពី ក្រុមហ៊ុន ហ្គ្រេន ធ្វីន បានចុះបញ្ជីលក់ មូលបត្រនៅ ផ.ម.ក នៅថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៤ ក្រុមហ៊ុន បានបំពេញកាតព្វកិច្ចក្នុងការបង្ហាញព័ត៌មានទាន់ពេល និងភ្លាមៗ ប្រកបដោយតម្លាភាពនូវរបាយការណ៍ហិរញ្ញវត្ថុក្នុងគ្រាសង្ខេបសម្រាប់ត្រីមាសនានា ឆ្នាំ២០១៥ ឆ្នាំ២០១៦ និងឆ្នាំ២០១៧ និងរបាយការណ៍ហិរញ្ញវត្ថុដែលត្រូតពិនិត្យរួចដោយសវនករឯករាជ្យ សេចក្តីជូនដំណឹងពីការបែងចែកភាគ លាភដល់ភាគហ៊ុនិករបស់ក្រុមហ៊ុន រួមទាំង សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលក្រុមហ៊ុនលើការបែងចែកភាគលាភ សេចក្តីជូនដំណឹងពីមហាសន្និបាតភាគហ៊ុនិកលើកទី៣ និងព័ត៌មានចាំបាច់ផ្សេងទៀត ដែលអាចមានផលប៉ះពាល់ដល់ ការសម្រេចចិត្ត និងផលប្រយោជន៍ភាគីពាក់ព័ន្ធ និងវិនិយោគិនសាធារណៈ។

សម្រាប់ត្រីមាសនានា ឆ្នាំ២០១៨ ក្រុមហ៊ុន ហ្គ្រេន ធ្វីន នឹងខិតខំប្រឹងប្រែងបន្ថែមទៀត ដើម្បីធ្វើឲ្យកាន់តែ ប្រសើរឡើងក្នុងការពង្រឹងអភិបាលកិច្ចសាជីវកម្មល្អរបស់ក្រុមហ៊ុន ហើយនៅតែប្រកាន់ខ្ជាប់នូវទស្សនវិស័យ និងបេសក កម្មដែលបានកំណត់។ ក្រុមហ៊ុន ហ្គ្រេន ធ្វីន នៅតែប្រឹងប្រែងក្នុងការបង្ហាញព័ត៌មានទាន់ពេល និងប្រកបដោយតម្លាភាព។

# ៤.បញ្ជីរាយនាមភាគហ៊ុនិក កាន់កាប់ភាគហ៊ុនមានសិទ្ធបោះឆ្នោតចំនួនច្រើនលើសលប់ និងភាគហ៊ុនមានសិទ្ធ បោះឆ្នោតចំនួនច្រើន ក្រុមហ៊ុន ប្រហ្គន ធ្វីន



## ១.   ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលុប

មុនការបោះផ្សាយ និងចុះបញ្ជីលក់មូលបត្រជាផ្លូវការនៅក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា មូលបត្រកម្មសិទ្ធសរុបរបស់ក្រុមហ៊ុន ហ្គ្រេន ធ្វីន ត្រូវបានកាន់កាប់ដោយភាគហ៊ុនិក ចំនួន ១៥ រូប ដែលក្នុងនោះ ២ ជា នីតិបុគ្គល និង ១៣ រូបទៀត ជារូបវន្តបុគ្គល។ ភាគហ៊ុនិក ដែលជានីតិបុគ្គល រួមមាន៖

- ក្រុមហ៊ុន **Grand Twins International Ltd** ជាក្រុមហ៊ុនចុះបញ្ជីក្រោមច្បាប់ស្តីពី Business Companies Act ឆ្នាំ២០០៤ នៅកោះ BVI ប្រទេសអង់គ្លេស កាលបរិច្ឆេទថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០០៧ មានវិញ្ញាបនប័ត្រចុះបញ្ជីលេខ ១៤០៩២៨១ មានអាសយដ្ឋាន Portcullis TrustNet (BVI) Limited, Portcullis TrustNet Chambers, P.O. Box 3444, Road Town, Tortola, British Virgin Islands និង

-ក្រុមហ៊ុន **HOPE RIDGE LIMITED** ជាក្រុមហ៊ុនចុះបញ្ជីក្រោមច្បាប់ស្តីពីក្រុមហ៊ុនអន្តរជាតិ ឆ្នាំ១៩៨៧ នៃប្រទេស Samoa កាលបរិច្ឆេទថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១១ មានវិញ្ញាបនប័ត្រចុះបញ្ជីលេខ ៥០៤៤៩ មានអាសយដ្ឋាន Portcullis TrustNet Chambers, P.O. Box 1225, Apia, Somoa។

**រចនាសម្ព័ន្ធភាគហ៊ុនិក មុនការបោះផ្សាយ**




**រចនាសម្ព័ន្ធភាគហ៊ុនិក ក្រោយការបោះផ្សាយ (គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧)**



**ភាគហ៊ុនិកដែលត្រូវឡុកអាប់**

អនុលោមតាមច្បាប់ស្តីពីមូលបត្រ នឹងបទប្បញ្ញត្តិពាក់ព័ន្ធនានា ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតច្រើនលើសលុបរបស់ក្រុមហ៊ុន ហ្រ្គេន ធ្វីន ត្រូវបានហាមខាត់ក្នុងការផ្ទេរ ឬលក់មូលបត្ររបស់ខ្លួន ក្នុងរយៈកំណត់ណាមួយ។ ខាងក្រោម គឺជា ភាគហ៊ុនិក ដែលត្រូវឡុកអាប់៖

**ក្រុមហ៊ុន** Grand Twins International Ltd.

ចំនួនមូលបត្រកម្មសិទ្ធិដែលត្រូវឡុកអាប់ : ១៦.៤០០.០០០ មូលបត្រកម្មសិទ្ធិ

មូកហេតុឡុកអាប់ : ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតច្រើនលើសលុប

រយៈពេលឡុកអាប់ : ពីថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៤ ដល់ ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៥

**ក្រុមហ៊ុន** Hope Ridge Limited

ចំនួនមូលបត្រកម្មសិទ្ធិដែលត្រូវឡុកអាប់ : ៣.៨៤០.០០០ មូលបត្រកម្មសិទ្ធិ

មូកហេតុឡុកអាប់ : ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតច្រើនលើសលុប

រយៈពេលឡុកអាប់ : ពីថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៤ ដល់ ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៥

គិតត្រឹមការិយបរិច្ឆេទឆ្នាំ២០១៧ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ ក្រុមហ៊ុន Grand Twins International Ltd នៅតែជាភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតច្រើនលើសលុបរបស់ក្រុមហ៊ុន ហ្រ្គេន ធ្វីន។ ដោយឡែក រយៈពេលឡុកអាប់មូលបត្រសម្រាប់ក្រុមហ៊ុន Grand Twins International Ltd និងក្រុមហ៊ុន HOPE RIDGE LIMITED ដែលជាភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតច្រើនលើសលុបរបស់ក្រុមហ៊ុន ហ្រ្គេន ធ្វីន បានបញ្ចប់នៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៥ កន្លងទៅនេះ។ ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតច្រើនលើសលុបរបស់ក្រុមហ៊ុនមានសិទ្ធិជួញដូរមូលបត្រនៅ ផ.ម.ក បន្ទាប់ពីរយៈពេលឡុកអាប់ត្រូវបានបញ្ចប់ ដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធ។

| ភាគហ៊ុនិក | សញ្ជាតិ | អាសយដ្ឋាន | លេខអត្តសញ្ញាណវិនិយោគិន | បរិមាណ | % |
|---|---|---|---|---|---|
| **ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតច្រើនលើសលុប** | | | | | |
| ក្រុមហ៊ុន Grand Twins International Ltd | BVI | Portcullis TrustNet (BVI) Limited, Portcullis TrustNet Chambers, P.O. Box 3444, Road Town, Tortola, British Virgin Islands | F៨២៨៥៦៦៧៣៧១៥ | ១៦.៤០០.០០០ | ៤១ |
| **ភាគហ៊ុនិកកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើន** | | | | | |
| ក្រុមហ៊ុន HOPE RIDGE LIMITED | Samoa | Portcullis TrustNet Chambers, P.O. Box 1225, Apia, Somoa | F៩១៨៥៥៦៩៦៧៨៤ | ៣.៨៤០.០០០ | ៩,៦០ |

# ៥.ព័ត៌មានអំពីការជួញដូរមូលបត្រ ក្រុមហ៊ុន ហ្គ្រេន ធ្វីន



## ១. ព័ត៌មានអំពីមូលបត្រកម្មសិទ្ធិ

| | |
|---|---|
| ឈ្មោះមូលបត្រកម្មសិទ្ធិ | មូលបត្រកម្មសិទ្ធិដែលមានសិទ្ធិបោះឆ្នោត |
| អក្សរកូដមូលបត្រកម្មសិទ្ធិ | KH១០០០០២០០០៣ |
| ចំណាត់ថ្នាក់នៃមូលបត្រកម្មសិទ្ធិ | មូលបត្រកម្មសិទ្ធិដែលមានសិទ្ធិបោះឆ្នោត |
| តម្លៃចារឹកក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ | ១.០០០ រៀល |
| ថ្លៃបិទក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ (ឆ្នាំ២០១៧) | ៤.៧០០ រៀល |
| បរិមាណមូលបត្រកម្មសិទ្ធិសរុបដែលកំពុងចរាចរលើទីផ្សារ | ៤០.០០០.០០០ ភាគហ៊ុន |
| មូលធនូបនីយកម្មទីផ្សារ (ឆ្នាំ២០១៧) | ១៨៨.០០០ លាន រៀល |
| ឈ្មោះទីផ្សារមូលបត្រប្រតិស្រុត<br>កាលបរិច្ឆេទនៃការចុះបញ្ជីលក់មូលបត្រ | ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា<br>ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៤ |

តម្លៃមូលបត្ររបស់ក្រុមហ៊ុន ហ្រ្គេន ធ្វីន អាចមានការប្រែប្រួលយ៉ាងខ្លាំង អាស្រ័យលើលទ្ធផលរបស់ក្រុមហ៊ុននាពេលបច្ចុប្បន្ន ឬលទ្ធផលប្រចាំត្រីមាស ឬលទ្ធផលហិរញ្ញវត្ថុប្រចាំឆ្នាំរបស់ក្រុមហ៊ុនកន្លងទៅ ឬលទ្ធផលហិរញ្ញវត្ថុរបស់ក្រុមហ៊ុនផ្សេងទៀត ដែលស្ថិតក្នុងវិស័យឧស្សាហកម្មកាត់ដេរ។ ជាទូទៅ នៅទីផ្សារមូលបត្រ តែងតែជួបប្រទះការប្រែប្រួលថ្លៃមូលបត្រ និងទំហំជួញដូរមូលបត្រនៅលើទីផ្សារ ដែលរងផលប៉ះពាល់ពីលទ្ធផលប្រតិបត្តិការ ឬលទ្ធផលហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ដែលជាញឹកញាប់ពលខ្លះ មិនមែនទាក់ទងផ្ទាល់ ឬដោយសារតែលទ្ធផលប្រតិបត្តិរបស់ក្រុមហ៊ុននោះ ឡើយ។ លើសពីនេះទៀត ការប្រែប្រួលនៃតម្លៃមូលបត្ររបស់ក្រុមហ៊ុន ក៏អាចបណ្តាលមកពីក្រុមហ៊ុនបរាជ័យក្នុងការបំពេញកាតព្វកិច្ចតម្រូវជាដើម។ ការជួញដូរនៅក្នុងតម្លៃទាបក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិរបស់ក្រុមហ៊ុន អាចកើតឡើង ក្នុងរយៈពេលមួយប៉ុណ្ណោះ។

ជាក់ស្តែង តម្លៃមូលបត្ររបស់ក្រុមហ៊ុន ហ្រ្គេន ធ្វីន គិតត្រឹមថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៧ ថ្លៃបិទ គឺ ៤.៧០០ រៀល ក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ បានកើនឡើង ៣៨០ រៀល ឬ ៧,៤៦% ធៀបនឹង ថ្លៃបិទ ៤.៣២០ រៀល ក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ គិតត្រឹមថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៦ ដែលក្នុងនោះបរិមាណជួញដូរមូលបត្រសរុបចំនួន ៥.៨៨៨ នៅថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០១៦ បានកើនឡើងចំនួន ៤.៧៣៩ ឬ ៤១២% ធៀបនឹងបរិមាណជួញដូរមូលបត្រសរុបចំនួន ៥.៨៨៨ នៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៦។ គិតត្រឹមថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៦ ថ្លៃបិទ គឺ ៤.៣២០ រៀល ក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ បានកើនឡើង ៣០០ រៀល ឬ ៧,៤៦% ធៀបនឹង ថ្លៃបិទ ៤.០២០ រៀល ក្នុងមួយឯកតា មូលបត្រកម្មសិទ្ធិ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ ដែលក្នុងនោះបរិមាណជួញដូរមូលបត្រសរុបចំនួន ៥.៨៨៨ នៅថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០១៦ បានកើនឡើងចំនួន ៤.៧៣៩ ឬ ៤១២% ធៀបនឹងបរិមាណជួញដូរមូលបត្រសរុបចំនួន ១.១៤៩ នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។

ដោយផ្អែកលើថ្លៃបិទគិតត្រឹមថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៧ ធៀបនឹងចំណូលឆ្នាំ២០១៦ មូលបត្រត្រូវបានជួញដូរក្នុងអនុបាតភីអ៊ី ៣៧,៦៨ ដង ហើយតម្លៃមូលបត្រគិតត្រឹមថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៧ បានធ្លាក់ចុះ ១៣៩,៨០% ធៀបនឹងតម្លៃមូលបត្រនៅពេលបោះផ្សាយ គឺ ៩.៦៤០ រៀល ដែលអនុបាតភីអ៊ី មានត្រឹម ១១ ដង។




## ២. ថ្លៃ និងបរិមាណជួញដូរ

| មូលបត្រកម្មសិទ្ធិ | | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ថ្លៃជួញដូរ | អតិបរិមា | ៥.៤០០ | ៤.៩៨០ | ៤.៩៤០ | ៤.៧០០ | ៤.១០០ | ៤.០០០ | ៤.០៨០ | ៤.២០០ | ៤.០០០ | ៥.៤០០ | ៥.១៤០ | ៤.៧០០ |
| | ជាមធ្យម | ៥.០៣១ | ៤.៣៩៧ | ៤.៥០៥ | ៤.៤១២ | ៤.០២៥ | ៣.៨៥៤ | ៤.០០៤ | ៤.០៤៣ | ៣.៩៥៣ | ៤.៣៧៨ | ៤.២២៣ | ៤.០៨៥ |
| | អប្បរមា | ៤.៥២០ | ៣.៩២០ | ៣.៩២០ | ៤.១០០ | ៤.០០០ | ៣.៦១០ | ៣.៧៩០ | ៣.៩០០ | ៣.៤០ | ៣.៩៧០ | ៣.៨០០ | ៣.៨២០ |
| បរិមាណជួញដូរ | អតិបរិមា | ១៦.១៣២ | ២៤៧ | ៨.៧៤៨ | ១.៣០០ | ៦៥៦ | ២០០ | ១៨០ | ១៩.៧៣៨ | ១១.៦៥០ | ២៥.០០០ | ៤.៣២៧ | ៣០.៩៦០ |
| | ជាមធ្យម | ៣.១១៨ | ៦១ | ៤៧០ | ១៧០ | ១១៤ | ៤៦ | ៣០ | ២០០៥ | ៩៦៤ | ២៤៧៧ | ៦០៩ | ២៤៣១ |
| | អប្បរមា | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |

## ក្រាហ្វិកបង្ហាញបម្រែបម្រួលតម្លៃជួញដូរមូលបត្រ នៅ ផ.ម.ក

(គិតចាប់ពីថ្ងៃទី០១ ខែមករា ដល់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧)



## ក្រាហ្វិកបង្ហាញបម្រែបម្រួលទំហំជួញដូរមូលបត្រ នៅ ផ.ម.ក



# ៦.របាយការណ៍សវនកម្ម
# របស់សវនកម្មផ្ទៃក្នុងលើការ
# ត្រួតពិនិត្យផ្ទៃក្នុង

ហ្គ្រេន ធ្វីន អ៊ិនធើណេសិនណល
(ខេមបូឌា) ភីអិលស៊ី

# របាយការណ៍សវនកម្មរបស់សវនករផ្ទៃក្នុង ស្តីពីការអនុវត្តការត្រួតពិនិត្យផ្ទៃក្នុង ឆ្នាំ២០១៧

ការរីកចំរើន និងការផ្លាស់ប្តូរជាបន្តបន្ទាប់នៃសកម្មភាពអាជីវកម្មរបស់ ក្រុមហ៊ុន ហ្គ្រេន ធ្វីន អ៊ិនធើណេសិនណល (ខេមបូឌា) ភីអិលស៊ី ដែលជាក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ ក៍ទទួលរងនូវហានិភ័យថ្មីៗ ផងដែរ ទន្ទឹមនឹងហានិភ័យដែលកើតឡើងកន្លងមកអាចនឹងត្រូវសាបរលាបទៅវិញ។ ដូច្នេះ ក្រុមហ៊ុន ហ្គ្រេន ធ្វីន ប្រឈមនឹងហានិភ័យជាច្រើន ដែលទាមទារឲ្យមានការគ្រប់គ្រងដែលមានប្រសិទ្ធិភាព និងសមត្ថភាព។ ប្រសិនបើ មិនដូច្នោះ នឹងធ្វើឲ្យក្រុមហ៊ុន ហ្គ្រេន ធ្វីន មិនអាចសម្រេចបានតាមផែនការសកម្មភាពហិរញ្ញវត្ថុ និងគោលដៅអភិវឌ្ឍ។

វិធីសាស្ត្រសម្រាប់គ្រប់គ្រងហានិភ័យរបស់ក្រុមហ៊ុន ហ្គ្រេន ធ្វីន គឺ ត្រូវកំណត់ជាមុនពីប្រភេទនៃហានិភ័យ និងវាយតម្លៃហានិភ័យ ដែលនឹងផ្តល់ផលប៉ះពាល់ដល់ធុរកិច្ចក្រុមហ៊ុន និងការទាក់ទងនៃការកកើតមានជាថ្មីនូវហានិភ័យទាំងនោះ។ ក្រុមហ៊ុន ហ្គ្រេន ធ្វីន ត្រូវរៀបចំវិធីសាស្ត្រដើម្បីទប់ស្កាត់ នឹងបង្ការនានានិងយន្តការក្នុងការតាមដាន និងដោះស្រាយ ហើយបែងចែកភារកិច្ច និងការទទួលខុសត្រូវច្បាស់លាស់សម្រាប់បុគ្គលិកនីមួយៗ សម្រាប់ដោះស្រាយហានិភ័យទាំងនោះ។

ការងារត្រួតពិនិត្យផ្ទៃក្នុងមានសារសំខាន់ណាស់ ក្នុងការសម្រេចបានដោយជោគជ័យនូវប្រតិបត្តិការប្រចាំថ្ងៃរបស់ក្រុមហ៊ុន និងសម្រេចបាននូវគោលដៅតាមរយៈការប្រើប្រាស់វិធីសាស្ត្រវាយតម្លៃដែលត្រឹមត្រូវ និងជាក់លាក់ ក្នុងគោលបំណងបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងហានិភ័យ និងការបង្កើនប្រសិទ្ធិភាពប្រតិបត្តិការធុរកិច្ចរបស់ក្រុមហ៊ុន តាមរយៈការត្រួតពិនិត្យ និងផ្តល់អនុសាសន៍ដោយផ្អែកលើការវិភាគ និងវាយតម្លៃទិន្នន័យ។

ក្រុមហ៊ុន ហ្គ្រេន ធ្វីន បានបង្កើតប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងយ៉ាងរឹងមាំ ដើម្បីការពារសុវត្ថិភាពទ្រព្យសកម្ម និងលើកកម្ពស់សេវាកម្មសម្រាប់អតិថិជនចម្បង និងអតិថិជនផ្សេងទៀត ការពារការកើតមានកំហុសឆ្គងដោយចេតនា និង អចេតនា ដើម្បីធានាថា គណៈគ្រប់គ្រង បុគ្គលិក និយោជិកទាំងអស់របស់ក្រុមហ៊ុន ហ្គ្រេន ធ្វីន គោរព និងអនុវត្តតាមស្តង់ដារបទដ្ឋានការងារ ជំនាញនីមួយៗ និងសេចក្តីណែនាំផ្សេងៗរបស់ក្រុមហ៊ុន។

អង្គភាពសវនកម្មផ្ទៃក្នុងត្រូវបានបង្កើតឡើងនៅដើមឆ្នាំ២០១៣ ហើយបានកំណត់យ៉ាងច្បាស់ពីតួនាទី ភារកិច្ច និងការទទួលខុសត្រូវ ក្នុងការវាយតម្លៃដោយឯករាជ្យ លើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង។ បច្ចុប្បន្ន អង្គភាពសវនកម្មផ្ទៃក្នុង មានសមាជិក ៣ នាក់ ដែលក្នុងនោះ មានជំនាញគណនេយ្យ បច្ចេកទេស និងសវនកម្ម។

ក្នុងឆ្នាំ២០១៧ អង្គភាពសវនកម្មផ្ទៃក្នុងបានចុះត្រួតពិនិត្យ និងវាយតម្លៃការងារតាមផែនការសកម្មភាពឆ្នាំ២០១៨ និងត្រីមាសកន្លងទៅ ឆ្នាំ២០១៨ សម្រាប់ប្រតិបត្តិការធុរកិច្ចរបស់ក្រុមហ៊ុន។

ការត្រួតពិនិត្យ សម្រាប់ឆ្នាំ២០១៧ នេះ បានពិនិត្យលទ្ធផល និងវាយតម្លៃលទ្ធផលការងាររបស់អង្គភាពសវនកម្មផ្ទៃក្នុង និងការងារចម្បងមួយចំនួន មានដូចជា (១) ដាក់សំណើទៅក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន ដើម្បីជ្រើសរើស ក្រុមហ៊ុនគណនេយ្យជំនាញថ្មី ជាសវនករឯករាជ្យ (២) ត្រួតពិនិត្យរបាយការណ៍ហិរញ្ញវត្ថុសង្ខេបដែលរៀបចំដោយសវនករផ្ទៃក្នុង (៣) ត្រួតពិនិត្យឡើងវិញនូវរបាយការណ៍ហិរញ្ញវត្ថុសង្ខេបក្នុងគ្រាសង្ខេបសម្រាប់ត្រីមាសនានា ឆ្នាំ២០១៧ និងរបាយការណ៍ហិរញ្ញវត្ថុសម្រាប់ដំណាច់ការិយបរិច្ឆេទឆ្នាំ២០១៧ គិតត្រឹម ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ ដែលពិនិត្យ និងធ្វើសវនកម្មរួច ដោយក្រុមហ៊ុនសវនករឯករាជ្យ មុននឹងដាក់ការពិនិត្យ និងសម្រេចពីក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន ដោយធានានូវប្រសិទ្ធភាពការងាររវាងសវនករឯករាជ្យ និងសវនករផ្ទៃក្នុង និង (៤) ការងារចម្បងមួយចំនួន ទៀត។

និយោជិក និងគណៈគ្រប់គ្រងតាមផ្នែកនីមួយៗ ប្រកបដោយក្រមសីលធម៌ល្អប្រសើរ មានឆន្ទៈមុះមុត ក្នុងការងារ គោរពវិន័យល្អ រៀបចំចងក្រងឯកសារតាមកាលបរិច្ឆេទបានល្អប្រសើរ និងធ្វើរបាយការណ៍បូកសរុបការងារ ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំបានទៀងទាត់ និងទាន់ពេលវេលា។

ការធ្វើសវនកម្មដែលបានធ្វើឡើងខាងលើ សម្រាប់ឆ្នាំ២០១៧ នេះ បង្ហាញថា ដំណើរការប្រតិបត្តិការខាងលើ អនុវត្តបានល្អប្រសើរដើយអនុលោមតាមសេចក្តីកំណត់ ស្តង់ដារការងារ ព្រមទាំងបទដ្ឋានគតិយុត្តិ។

បានអាន និងយល់ព្រម

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៨
ហត្ថលេខា និងឈ្មោះរបស់គណៈកម្មាធិការសវនកម្ម
ប្រធាន

ឧកញ៉ា **លី យុនថៃ**

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៨
ហត្ថលេខា និងឈ្មោះសវនកម្មផ្ទៃក្នុង
ជ.ប្រធាន

លោក Hsieh Chung Nan

# ៧.របាយការណ៍ហិរញ្ញវត្ថុ
# ដែលធ្វើសវនកម្ម
# ដោយសវនករឯករាជ្យ

# ព័ត៌មានហិរញ្ញវត្ថុក្រុមហ៊ុន ហ្គ្រន ធ្វីន សម្រាប់ដំណាច់ការិយបរិច្ឆេទឆ្នាំ ២០១៧ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧



**ហ្គ្រេន សនថុន (ខេមបូឌា) លីមីតធីត**

ជាន់ទី២០ អាគារកាណាឌីយ៉ា
៣១៥ ផ្លូវព្រះអង្គឌួង
កែងមហាវិថីព្រះមុនីវង្ស
សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ
រាជធានីភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា

លេខទូរស័ព្ទ +៨៥៥ ២៣ ៩៦៦ ៥២០
www.grantthornton.com.kh

## ជូនចំពោះភាគហ៊ុនិករបស់ ក្រុមហ៊ុន ហ្គ្រេន ធ្វីន អ៊ិនធើណេសិនណល (ខេមបូឌា) ភីអិលស៊ី

### មតិយោបល់

យើងខ្ញុំបានធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ហ្គ្រេន ធ្វីន អ៊ិនធើណេសិនណលហៅកាត់ថា ("ក្រុមហ៊ុន") ដែលរួមមានរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុនាកាលបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ ព្រមទាំងរបាយការណ៍ចំណូលពេញលេញ របាយការណ៍បម្រែបម្រួលមូលធន និងរបាយការណ៍លំហូរសាច់ប្រាក់ សម្រាប់ចុងការិយបរិច្ឆេទ សេចក្តីសង្ខេបកំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុផ្សេងៗ រួមទាំងគោលនយោបាយគណនេយ្យសង្ខេបសំខាន់ៗ។

ជាមតិយោបល់របស់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុបានបង្ហាញនូវទិដ្ឋភាពពិត និងត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុ ព្រមទាំងលទ្ធផលនៃប្រតិបត្តិការអាជីវកម្ម និងស្ថានភាពលំហូរសាច់ប្រាក់របស់ក្រុមហ៊ុន នាកាលបរិច្ឆេទ និងចុងការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ ដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងទៅនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា។

### មូលដ្ឋាននៃការបញ្ចេញមតិយោបល់

យើងខ្ញុំបានធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា ("CISAs")។ ការទទួលខុសត្រូវរបស់យើងខ្ញុំស្ថិតក្រោមស្តង់ដារទាំងនោះ ត្រូវបានរៀបរាប់បន្ថែមទៀតនៅក្នុងផ្នែក *ការទទួលខុសត្រូវរបស់សវនករទៅលើការធ្វើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុ*។ យើងមានឯករាជ្យភាពលើក្រុមហ៊ុន ហើយអនុលោមតាមស្តង់ដារនៃវិជ្ជាជីវៈគណនេយ្យអន្តរជាតិ "ក្រមសីលធម៌ របស់គណនេយ្យករជំនាញ ("IESBA")" រួមជាមួយនិងតម្រូវការក្រមសីលធម៌ ដែលពាក់ព័ន្ធទៅនឹងការធ្វើសវនកម្មរបស់យើងខ្ញុំ ទៅលើរបាយការណ៍ហិរញ្ញវត្ថុក្នុងប្រទេសកម្ពុជា ហើយយើងបានបំពេញការទទួលខុសត្រូវទៅតាមតម្រូវការក្រមសីលធម៌ទាំងនោះ និង IESBA Code ។ យើងខ្ញុំជឿជាក់ថា ភស្តុតាងសវនកម្ម ទាំងឡាយដែលយើងទទួលបានគឺគ្រប់គ្រាន់និងសមរម្យដើម្បីផ្តល់ជូនជាមូលដ្ឋានសម្រាប់ការបញ្ចេញមតិរបស់យើង។

## បញ្ហាគន្លឹះសវនកម្ម

តាមវិជ្ជាជីវៈវិនិច្ឆ័យរបស់យើងខ្ញុំ បញ្ហាគន្លឹះសវនកម្មគឺជាបញ្ហាទាំងឡាយណា ដែលមានសារៈសំខាន់បំផុតក្នុងការធ្វើសវនកម្មរបស់យើងខ្ញុំទៅលើរបាយការណ៍ហិរញ្ញវត្ថុពេលបច្ចុប្បន្ន។
បញ្ហាទាំងនេះត្រូវបានបង្ហាញនៅក្នុងបរិបទនៃការធ្វើសវនកម្មរបស់យើងខ្ញុំលើរបាយការណ៍ហិរញ្ញវត្ថុទាំងមូល និងក្នុងការបង្កើតមតិយោបល់របស់យើងខ្ញុំ ហើយយើងខ្ញុំនឹងមិនផ្តល់នូវមតិយោបល់ដាច់ដោយឡែកណាមួយ ទៅលើបញ្ហាទាំងនេះទេ។

### ក. លទ្ធភាពនៃការទទួលមកវិញរបស់គណនីអតិថិជនពាណិជ្ជកម្ម

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ គណនីអតិថិជនពាណិជ្ជកម្មដែលហួសរយៈពេលត្រូវសង ប៉ុន្តែមិនមានឱនភាពមានចំនួន ៣៩.៩១៩.៥០៣ ដុល្លារអាមេរិក (២០១៦: ៣៦.៦៨៤.៨៩១ ដុល្លារអាមេរិក) ដែលជំពាក់ដោយក្រុមហ៊ុនមេសម្ព័ន្ធ។ ព័ត៌មានលម្អិតនៃគណនីអតិថិជនពាណិជ្ជកម្ម និងហានិភ័យឥណទាន ត្រូវបានបង្ហាញនៅក្នុងកំណត់សម្គាល់លេខ ៩ នៃរបាយការណ៍ហិរញ្ញវត្ថុ។

ក្រុមប្រឹក្សាភិបាល បានកំណត់ការខាតបង់ពីឱនភាពនៃគណនីអតិថិជនពាណិជ្ជកម្ម ដោយផ្អែកលើការពិត ឬ កាលៈទេសៈ ឬលទ្ធភាពទូទាត់សងពីអតិថិជន។

ការកំណត់លទ្ធភាពនៃការទទួលមកវិញរបស់គណនីអតិថិជនពាណិជ្ជកម្ម ទាមទារអោយគណៈគ្រប់គ្រងប្រើប្រាស់លក្ខណៈវិនិច្ឆ័យ ដោយសារតែមានការប្រែប្រួលជាប់ជានិច្ច នៅពេលដែលធ្វើការវិនិច្ឆ័យពាក់ព័ន្ធទៅនឹងការប្រឈមហានិភ័យឥណទានរបស់អតិថិជនជាបុគ្គល។

ក្នុងការវាយតម្លៃលក្ខណៈវិនិច្ឆ័យរបស់ក្រុមប្រឹក្សាភិបាល ទៅលើលទ្ធភាពនៃការទទួលមកវិញរបស់គណនីអតិថិជនពាណិជ្ជកម្ម យើងខ្ញុំបានអនុវត្តនូវនីតិវិធីសវនកម្ម ដូចខាងក្រោម៖

- ទទួលបានព័ត៌មានលម្អិត នៃសមតុល្យគណនីអតិថិជនពាណិជ្ជកម្មនាកាលបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧
- បានត្រួតពិនិត្យ និងវាយតម្លៃភស្តុតាងផ្តល់ដោយក្រុមប្រឹក្សាភិបាលថាគ្មានឱនភាព ដោយយើងខ្ញុំធ្វើការវិភាគប្រវត្តិកេរ្តិ៍ឈ្មោះ ប្រវត្តិនៃការទូទាត់សងត្រលប់ និង
- ត្រួតពិនិត្យទឹកប្រាក់ទូទាត់ ក្រោយពីកាលបរិច្ឆេទនៃរបាយការណ៍។

ជាលទ្ធផល យើងខ្ញុំបានសន្និដ្ឋានថា លក្ខណៈវិនិច្ឆ័យរបស់ក្រុមប្រឹក្សាភិបាលទៅលើលទ្ធភាពនៃការទទួលមកវិញរបស់គណនីអតិថិជនពាណិជ្ជកម្ម គឺត្រឹមត្រូវ។

### ខ. ការទទួលស្គាល់ចំណូល

ការរំពឹងទីផ្សារ និងគោលដៅស្វែងរកប្រាក់ចំណេញ អាចដាក់សំពាធដល់គណៈគ្រប់គ្រងលើភាពមិនត្រឹមត្រូវ ចំពោះការទទួលស្គាល់ចំណូល ដូច្នេះហើយវាបង្កើនហានិភ័យចំពោះកំហុសឆ្គងធំដុំទៅលើភាពមានប្រាកដ និងការកើតឡើងនៃចំណូល។
ក្នុងការឆ្លើយតបទៅលើហានិភ័យធំដុំដែលទាក់ទងទៅនឹងការកត់ត្រា និងការទទួលស្គាល់ចំណូល យើងខ្ញុំបានប្រើនូវនីតិវិធីសវនកម្មនានា រួមមាន៖

- ធ្វើការស្វែងយល់អំពីគោលការណ៍គណនេយ្យរបស់ក្រុមហ៊ុន ក្នុងការទទួលស្គាល់ចំណូល និងត្រួតពិនិត្យភាពត្រឹមត្រូវ របស់វា ជាមួយនឹងគោលការណ៍របាយការណ៍ហិរញ្ញវត្ថុដែលមាន
- កំណត់សង្គតិភាព ដែលបានប្រើប្រាស់ ពីមុន និងក្នុងកំឡុងពេលបច្ចុប្បន្ន
- អនុវត្តនីតិវិធីវិភាគ និងកំណត់ពេលវេលាទទួល ស្គាល់នៃចំណូលទៅតាមការរំពឹងទុកដែលបានមកពីចំណេះដឹងខាង វិស័យក្រុមហ៊ុន និងធ្វើការតាមដានភាពមិនស៊ី សង្វាក់ជាមួយនឹងការរំពឹងទុករបស់យើងខ្ញុំ
- តេស្តទិន្នានុប្បវត្តន៍កត់ត្រាចំណូល ដើម្បីកំណត់រកទិន្នានុប្បវត្តន៍ខុសប្រក្រតី
- អនុវត្តនីតិវិធីតេស្តលម្អិតចំពោះចំណូលសំខាន់ៗ និង
- ទទួលបានការបញ្ជាក់អះអាងពីអតិថិជន ចំពោះការលក់ទំនិញ សេវាវេចខ្ចប់ និងការលក់អប្បហារ។

យើងខ្ញុំយល់ថា ការទទួលស្គាល់ចំណូលដែលបានកត់ត្រានៅក្នុងរបាយការណ៍ហិរញ្ញវត្ថុសម្រាប់ឆ្នាំនេះ គឺត្រឹមត្រូវ និងប្រើប្រាស់ដោយសង្គតិភាព អនុលោមតាមស្តង់ដាររបាយការណ៍ទាក់ទងទៅនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា។

### គ. ចំណាយពន្ធលើប្រាក់ចំណូល បំណុលពន្ធពន្យា និងយថាភាពលើពន្ធ

ផ្អែកលើច្បាប់ស្តីពីសារពើពន្ធរបស់ព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុនមានកាតព្វកិច្ចក្នុងការបង់ពន្ធលើប្រាក់ចំណូលក្នុងអត្រា ២០% លើប្រាក់ចំណេញជាប់ពន្ធ ឬពន្ធអប្បបរមាក្នុងអត្រា១% លើផលរបរសរុប ចំពោះជម្រើសណាមួយដែលធំជាង។

នាចុងកាលបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ ក្រុមហ៊ុនបានប៉ាន់ប្រមាណបំណុលពន្ធពន្យា ចំនួន ៣១៨.៥៧៨ ដុល្លារអាមេរិក និងចំណាយពន្ធលើប្រាក់ចំណូល ចំនួន ៥០៩.១៥៥ ដុល្លារអាមេរិក។

យើងបានកំណត់ឃើញថា ការវិនិច្ឆ័យសំខាន់ត្រូវបានប្រើប្រាស់ក្នុងការកំណត់ចំណាយពន្ធលើប្រាក់ចំណូល និងពន្ធពន្យា។ បំណុលដែលជាប់ពន្ធត្រូវបានទទួលស្គាល់ ដោយពឹងទៅលើការប៉ាន់ស្មានបំណុលពន្ធ កំណត់តាមបំណកស្រាយរបស់ក្រុមប្រឹក្សាភិបាល ទៅលើនីតិវិធីពន្ធផ្សេងៗគ្នា។ ដោយសារតែលិខិតប្រកាសបង់ពន្ធរបស់ក្រុមហ៊ុន នឹងត្រូវបានត្រួតពិនិត្យ ដូច្នេះបំណុលពន្ធចុងក្រោយអាចនឹងខុសគ្នាពីចំនួនដែលបានទទួលស្គាល់ពីមុន។ ជាផ្នែកមួយនៃការធ្វើសវនកម្មរបស់យើងខ្ញុំ យើងខ្ញុំបានត្រួតពិនិត្យការគណនាប្រាក់បង់ពន្ធ និងពន្ធពន្យាដែលបានប៉ាន់ស្មានដោយក្រុមហ៊ុនក្នុងការិយបរិច្ឆេទ។

យើងខ្ញុំត្រូវបានជូនដំណឹងថា នាកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមហ៊ុនពុំទាន់ទទួលបានលិខិតជូនដំណឹងពីការកំណត់ពន្ធឡើងវិញ សម្រាប់ការិយបរិច្ឆេទគណនេយ្យពីថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ រហូតដល់ ឆ្នាំ២០១៧។

យើងខ្ញុំបានត្រួតពិនិត្យការបង្ហាញរបស់ក្រុមហ៊ុន (កំណត់សម្គាល់លេខ២០) ចំពោះបញ្ហានេះ ហើយកំណត់ថា វាបានអនុលោមតាមស្តង់ដាររបាយការណ៍ទាក់ទងទៅនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា។

### បញ្ហាផ្សេងៗ

របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុននាចុងការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ បានធ្វើសវនកម្ម ដោយក្រុមហ៊ុនសវនករដ៏ទៃទៀត ហើយបានបញ្ចេញមតិសវនកម្ម នៅថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៧ ថារបាយការណ៍ហិរញ្ញវត្ថុនោះមានភាពត្រឹមត្រូវ។

## ព័ត៌មានផ្សេងៗ

ក្រុមប្រឹក្សាភិបាល ទទួលខុសត្រូវទាំងស្រុងទៅលើព័ត៌មានផ្សេងៗទៀត។ ព័ត៌មានទាំងនេះរួមមាន ព័ត៌មានដែលបានរៀបរាប់ក្នុងរបាយការណ៍ប្រចាំឆ្នាំ ប៉ុន្តែមិនទទួលខុសត្រូវចំពោះរបាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍របស់សវនករយើងខ្ញុំ។ របាយការណ៍ប្រចាំឆ្នាំ រំពឹងថានឹងផ្តល់ឲ្យយើងត្រួតពិនិត្យ បន្ទាប់ពីថ្ងៃចុះហត្ថលេខាលើរបាយការណ៍សវនករ។

មតិយោបល់របស់យើងខ្ញុំទៅលើរបាយការណ៍ហិរញ្ញវត្ថុ មិនបានគ្របដណ្តប់ទៅលើព័ត៌មានផ្សេងៗដែលរៀបចំដោយគណៈគ្រប់គ្រងនោះទេ ហើយយើងក៏មិនបញ្ចេញមតិយោបល់ទៅលើព័ត៌មានទាំងនោះដែរ។

ភ្ជាប់ជាមួយការធ្វើសវនកម្ម របស់យើងខ្ញុំលើរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន យើងខ្ញុំមានទំនួលខុសត្រូវក្នុងការអានព័ត៌មានដែលបានកំណត់ខាងលើ នៅពេលដែលវាត្រូវបានផ្តល់ឲ្យដើម្បីធ្វើការវិនិច្ឆ័យថា តើមានព័ត៌មានណាមួយដែលមិនសង្គតិភាពជាសារវន្តជាមួយរបាយការណ៍ហិរញ្ញវត្ថុ ឬក៏ចំណេះដឹងរបស់យើងខ្ញុំដែលទទួលបានពីសវនកម្ម ឬលេចឡើងមានកំហុសឆ្គងជាសារវន្ត។

នៅពេលដែលយើងរកឃើញភាពខុសគ្នាជាសារវន្តណាមួយនៅពេលអានរបាយការណ៍ប្រចាំឆ្នាំ យើងនឹងធ្វើការប្រាស្រ័យទាក់ទងអំពីបញ្ហាទាំងនេះជាមួយក្រុមប្រឹក្សាភិបាល ដើម្បីធ្វើការកែតម្រូវព័ត៌មានផ្សេងៗទាំងនេះ ដោយអនុលោមទៅតាម CISA ៧២០ (បានកែលម្អរឡើងវិញ)។

## ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលលើរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាលទទួលខុសត្រូវក្នុងការរៀបចំ និងការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុទាំងនេះឲ្យបានត្រឹមត្រូវដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា និងទទួលខុសត្រូវលើការត្រួតពិនិត្យផ្ទៃក្នុងដែលក្រុមប្រឹក្សាភិបាលកំណត់ថា វាមានភាពចាំបាច់ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ មិនឲ្យមានការរាយការណ៍ខុសជាសារវន្ត ដែលបណ្តាលមកពីការក្លែងបន្លំ ឬកំហុសឆ្គងផ្សេងៗ។

ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុក្រុមប្រឹក្សាភិបាលមានទំនួលខុសត្រូវចំពោះការវាយតម្លៃសមត្ថភាពក្រុមហ៊ុនក្នុងការបន្តប្រតិបត្តិការដោយផ្អែកលើមូលដ្ឋាននិរន្តរភាព ភាពលាតត្រដាង (ប្រសិនជាមានការព្រួយបារម្ភនិរន្តភាព) និងប្រើប្រាស់មូលដ្ឋាននិរន្តភាពជាមូលដ្ឋានគណនេយ្យ លុះត្រាណាតែក្រុមប្រឹក្សាភិបាលមានគោលបំណងរំសាយក្រុមហ៊ុន ឬបញ្ឈប់ប្រតិបត្តិការ ឬក៏គ្មានជម្រើសផ្សេងប៉ុន្តែចាំបាច់ត្រូវធ្វើ។

## ការទទួលខុសត្រូវរបស់សវនករនៅលើការធ្វើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុ

គោលបំណងរបស់យើងខ្ញុំ គឺដើម្បីទទួលបាននូវការធានាអះអាងដ៏សមហេតុផល ទៅលើរបាយការណ៍ហិរញ្ញវត្ថុដោយពុំមានលក្ខណៈខុសឆ្គងជាសារវន្ត ដែលបណ្តាលមកពីការក្លែងបន្លំ ឬកំហុសឆ្គង និងការធ្វើរបាយការណ៍សវនកម្មដែលរួមមានមតិយោបល់របស់យើងខ្ញុំផងដែរ។ ការធានាអះអាងដែលសមហេតុផល គឺជាការធានាមួយដ៏ខ្ពស់ ប៉ុន្តែ វាមិនបានធានាថាការធ្វើសវនកម្មដោយផ្អែកទៅលើស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា នឹងតែងតែរកឃើញនូវការរាយការណ៍ខុសជាសារវន្តដែលមានឡើយ។ ការរាយការណ៍ខុសអាចកើតមានឡើងពីការក្លែងបន្លំ ឬកំហុសឆ្គងដែលអាចចាត់ទុកថាជាសារវន្ត នៅ

ពេលដែលកំហុសមួយ ឬកំហុសរួមគ្នាបានធ្វើអោយប៉ះពាល់ដល់សេចក្ដីសម្រេចចិត្តផ្នែកសេដ្ឋកិច្ចរបស់អ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុនេះ។

ជាផ្នែកមួយនៃការធ្វើសវនកម្មដោយយោងទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា យើងអនុវត្តនូវវិជ្ជាជីវៈវិនិច្ឆ័យ និងការសង្ស័យដែលមានវិជ្ជាជីវៈទៅលើការធ្វើសវនកម្ម។ យើងខ្ញុំក៏៖

ក កំណត់អត្តសញ្ញាណ និងវាយតម្លៃនូវហានិភ័យនៃការរាយការណ៍ខុសជាសារវន្តនៃរបាយការណ៍ហិរញ្ញវត្ថុ ថាតើវាកើតឡើងដោយការក្លែងបន្លំ ឬកំហុសឆ្គង រៀបចំនិងអនុវត្តនិតិវិធីសវនកម្មដែលឆ្លើយតបទៅនឹងហានិភ័យទាំងនោះ រួមទាំង ការប្រមូលយកភស្តុតាងសវនកម្មឲ្យបានគ្រប់គ្រាន់ និងសមស្របដើម្បីជាមូលដ្ឋានសម្រាប់បញ្ចេញមតិយោបល់របស់យើងខ្ញុំ។ ហានិភ័យដែលមិនអាចរកឃើញដោយការរាយការណ៍ខុសជាសារវន្តដែលបណ្តាលមកពីការក្លែងបន្លំ គឺធំជាងកំហុសឆ្គងដោយអចេតនាដោយសារតែការក្លែងបន្លំរួមបញ្ចូលទាំងការរួមគំនិត ការក្លែងបន្លំដោយចេតនា ការលុបចោលដោយ ចេតនា ការបង្ហាញខុស ឬការល្មើសទៅលើការត្រួតពិនិត្យផ្ទៃក្នុង។

ខ ធ្វើការស្វែងយល់អំពីការគ្រប់គ្រងផ្ទៃក្នុងដែលទាក់ទងទៅនឹងការធ្វើសវនកម្ម ដើម្បីបង្កើតនូវនិតិវិធីសវនកម្មដែលសមស្របទៅនឹងកាលៈទេសៈ ប៉ុន្តែមិនមែនជាគោលបំណងក្នុងការបង្ហាញនូវមតិយោបល់លើប្រសិទ្ធិភាពនៃការត្រួតពិនិត្យ ផ្ទៃក្នុងរបស់ក្រុមហ៊ុននោះទេ។

គ ធ្វើការវាយតម្លៃភាពសមស្របលើគោលនយោបាយគណនេយ្យដែលបានប្រើប្រាស់ និងភាពសមហេតុផលនៃគណនេយ្យប៉ាន់ស្មាន ក៏ដូចជាការបង្ហាញនានាដែលធ្វើឡើងដោយក្រុមប្រឹក្សាភិបាល។

ឃ សន្និដ្ឋានដ៏សមស្របមួយទៅលើការប្រើប្រាស់របស់ក្រុមប្រឹក្សាភិបាល លើមូលដ្ឋាននិរន្តភាពគណនេយ្យ ផ្អែកទៅលើភស្តុតាងសវនកម្មដែលទទួលបាន ថាតើភាពមិនប្រាកដប្រជាជាសារវន្តបានកើតឡើងទាក់ទិននឹងព្រឹត្តិការណ៍ ឬលក្ខខណ្ឌដែលធ្វើឲ្យមានមន្ទិលសង្ស័យខ្លាំងទៅលើលទ្ធភាពការបន្តនិរន្តភាពរបស់ក្រុមហ៊ុន។ ប្រសិនបើយើងសន្និដ្ឋានថា ភាពមិនប្រាកដប្រជាជាសារវន្តនឹងកើតមានឡើង យើងតម្រូវឲ្យធ្វើការលាតត្រដាងព័ត៌មានចាំបាច់ដើម្បីទាញការយកចិត្តទុកដាក់ នៅក្នុងរបាយការណ៍សវនកម្មរបស់យើងខ្ញុំទៅនឹងការលាតត្រដាងនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ឬក៏ប្រសិនបើការលាតត្រ ដាងនោះមិនគ្រប់គ្រាន់ នោះមតិយោបល់មិនត្រឹមត្រូវ ត្រូវបានផ្តល់។ ការសន្និដ្ឋានរបស់យើងខ្ញុំ គឺផ្អែកទៅលើភស្តុតាងសវន កម្មដែលទទួលបាន គិតត្រឹមថ្ងៃនៃការចេញរបាយការណ៍សវនកម្មរបស់យើងខ្ញុំ។ ទោះបីយ៉ាងណាក៏ដោយ ស្ថានភាព ឬក៏ ព្រឹត្តិការណ៍នាពេលអនាគតអាចបណ្តាលឲ្យក្រុមហ៊ុនមិនអាចបន្តប្រតិបត្តិការជានិរន្តភាពបាន។

ង វាយតម្លៃការបង្ហាញទូទៅ ទម្រង់ និងអត្ថន័យរបស់របាយការណ៍ហិរញ្ញវត្ថុរួមបញ្ចូលទាំងការលាតត្រដាងនានា ថាតើរបាយការណ៍ហិរញ្ញវត្ថុបង្ហាញនូវប្រតិបត្តិការ និងព្រឹត្តិការណ៍នានាដើម្បីបង្ហាញនូវភាពត្រឹមត្រូវសមស្របរបស់វា។

យើងប្រាស្រ័យទាក់ទងជាមួយនឹងក្រុមប្រឹក្សាភិបាលទៅលើបញ្ហាផ្សេងៗ ការរៀបចំដែនកំណត់ និងពេលវេលាក្នុងការធ្វើសវនកម្ម និងរបបគំហើញសវនកម្មសំខាន់ៗ រួមបញ្ចូលទាំងកង្វះខាតធំៗមួយចំនួនទៅលើការគ្រប់គ្រងផ្ទៃក្នុងដែលពួកយើងខ្ញុំរកឃើញកំឡុងពេលធ្វើសវនកម្ម។

យើងខ្ញុំក៏ផ្តល់ជូនក្រុមប្រឹក្សាភិបាល នូវសេចក្តីថ្លែងការណ៍មួយដែលយើងខ្ញុំបានអនុវត្តទៅតាមតម្រូវការក្រមសីលធម៌ដែលទាក់ទងនឹងឯករាជ្យភាព ហើយពួកយើងធ្វើការប្រាស្រ័យទាក់ទងជាមួយនឹងក្រុមប្រឹក្សាភិបាលនូវបញ្ហាទាំងអស់ដែលនឹងគិតថាសមហេតុផលទៅលើឯករាជ្យភាពរបស់យើងខ្ញុំ និង ការការពារដែលអាចមាន។

អំពីបញ្ហាដែលបានប្រាស្រ័យទាក់ទងជាមួយនឹងក្រុមប្រឹក្សាភិបាល យើងខ្ញុំបានកំណត់បញ្ហាសំខាន់ៗ សម្រាប់ការធ្វើសវនកម្មទៅលើរបាយការណ៍ហិរញ្ញវត្ថុនៃឆ្នាំបច្ចុប្បន្ន ដែលបានរួមបញ្ចូលទៅក្នុងបញ្ហាគន្លឹះសវនកម្ម។ យើងខ្ញុំពណ៌នាបញ្ហាទាំងនោះនៅក្នុងរបាយការណ៍សវនកម្មរបស់យើងខ្ញុំ លុះត្រាតែ មានច្បាប់ណាមួយដែលមិនតម្រូវឲ្យយើងធ្វើដូច្នេះ ឬក្នុងកាលៈទេសៈដ៏កម្រណាមួយដែលយើងខ្ញុំកំណត់ថា បញ្ហានោះមិនគួរត្រូវបានប្រាស្រ័យទាក់ទងនៅក្នុងរបាយការណ៍របស់យើងខ្ញុំ ដោយសារតែផលអវិជ្ជមានអាចនឹងមានផលប៉ះពាល់ធំជាងអត្ថប្រយោជន៍ដែលសាធារណៈអាចទទួលបាន។

ហ្គ្រេន សនតុន ខេមបូឌា លីមីធីត
គណនេយ្យករជំនាញ
សវនករប្រតិស្រុតចុះបញ្ជី

Ronald C. Almera
នាយកសវនករជំនាញ

ក្រុងភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៨

| | កំណត់សម្គាល់ | ដុល្លារអាមេរិក | ៣១ ធ្នូ ២០១៧ ពាន់រៀល (កំណត់សម្គាល់៤) | ដុល្លារអាមេរិក | ៣១ ធ្នូ ២០១៦ ពាន់រៀល (កំណត់សម្គាល់៤) |
|---|---|---|---|---|---|
| **ទ្រព្យសកម្ម** | | | | | |
| **ទ្រព្យសកម្មរយៈពេលវែង** | | | | | |
| ទ្រព្យសម្បត្តិ រោងចក្រ និង បរិក្ខារ | ៦ | **១៤.៣២២.៧១១** | **៥៧.៩៣៥.៣៦៦** | ១៤.៨៥១.៦៥៦ | ៥៩.៩៥៦.១៣៥ |
| ទ្រព្យសកម្មអរូបី | ៧ | **១៨.៨៤៨** | **៧៦.២៤០** | ៩.៨៣៩ | ៣៩.៧២០ |
| ទ្រព្យសកម្មរយៈពេលវែងសរុប | | **១៤.៣៤១.៥៥៩** | **៥៨.០១១.៦០៦** | ១៤.៨៦១.៤៩៥ | ៥៩.៩៩៥.៨៥៥ |
| **ទ្រព្យសកម្មរយៈពេលខ្លី** | | | | | |
| សន្និធិ | ៨ | **១៣.៩៥១.៣៥០** | **៥៦.៤៣៣.២១១** | ៨.៧៥១.៣៤៣ | ៣៥.៣២៩.១៧២ |
| គណនីអតិថិជនពាណិជ្ជកម្ម និងគណនីត្រូវទទួលផ្សេងៗ | ៩ | **៥៣.៨៣៧.១៤០** | **២១៧.៧៧១.២៣១** | ៥៧.៦៦៤.២៩២ | ២៣២.៧៩០.៧៤៧ |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូល | ១០ | **២២៨.៥៣៧** | **៩២៤.៤៣២** | ១.២៩១.២១០ | ៥.២១២.៦១៥ |
| ទ្រព្យសកម្មរយៈពេលខ្លីសរុប | | **៦៨.០១៧.០២៧** | **២៧៥.១២៨.៨៧៤** | ៦៧.៧០៦.៨៤៥ | ២៧៣.៣៣២.៥៣៤ |
| **ទ្រព្យសកម្មសរុប** | | **៨២.៣៥៨.៥៨៦** | **៣៣៣.១៤០.៤៨០** | ៨២.៥៦៨.៣៤០ | ៣៣៣.៣២៨.៣៨៩ |
| **មូលធន និងបំណុល** | | | | | |
| **មូលធនភាគហ៊ុននិក** | | | | | |
| ដើមទុន | ១១ | **១០.០០០.០០០** | **៤០.៤៥០.០០០** | ១០.០០០.០០០ | ៤០.៣៧០.០០០ |
| បុព្វលាភភាគហ៊ុន | ១២ | **១៧.២៨០.០០០** | **៦៩.៨៩៧.៦០០** | ១៧.២៨០.០០០ | ៦៩.៧៥៩.៣៦០ |
| ចំណេញរក្សាទុក | | **៤០.៣០០.៧០៧** | **១៦៣.០១៦.៦៣០** | ៤០.៦៤០.៦៣០ | ១៦៤.០៦៦.២២៣ |
| មូលធនភាគហ៊ុននិកសរុប | | **៦៧.៥៨០.៧០៧** | **២៧៣.៣៦៣.៩៦០** | ៦៧.៩២០.៦៣០ | ២៧៤.១៩៥.៥៨៣ |
| **បំណុល** | | | | | |
| **បំណុលរយៈពេលវែង** | | | | | |
| បំណុលពន្ធពន្យារ | ២០.៣ | **៣១៨.៥៧៨** | **១.២៨៨.៦៤៧** | ៤៥.៦៦៤ | ១៨៤.៣៤៦ |
| គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម និងគណនីត្រូវបង់ផ្សេងៗ | ១៣ | **២.២៨៩.៤០០** | **៩.២៦០.៦២៣** | ២.២៥០.០០០ | ៩.០៨៣.២៥០ |
| ប្រាក់កម្ចី | ១៤ | **២.៦០២.២៨៧** | **១០.៥២៦.២៥១** | - | - |
| **បំណុលរយៈពេលវែងសរុប** | | **៥.២១០.២៦៥** | **២១.០៧៥.៥២១** | ២.២៩៥.៦៦៤ | ៩.២៦៧.៥៩៦ |
| **បំណុលរយៈពេលខ្លី** | | | | | |
| គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម និងគណនីត្រូវបង់ផ្សេងៗ | ១៣ | **៣.៨០១.២៩០** | **១៥.៣៧៦.២១៨** | ៣.១៣៩.៥៦៩ | ១២.៦៧៤.៤៤០ |
| ប្រាក់កម្ចី | ១៤ | **៤.៣៦៤.៦១៥** | **១៧.៦៥៤.៨៦៨** | ៦.៤០០.០០០ | ២៥.៨៣៦.៨០០ |
| ពន្ធលើប្រាក់ចំណេញត្រូវបង់ | ២០.២ | **១.៤០១.៧០៩** | **៥.៦៦៩.៩១៣** | ២.៨១២.៤៧៧ | ១១.៣៥៣.៩៧០ |
| **បំណុលរយៈពេលខ្លីសរុប** | | **៩.៥៦៧.៦១៤** | **៣៨.៧០០.៩៩៩** | ១២.៣៥២.០៤៦ | ៤៩.៨៦៥.២១០ |
| **បំណុលសរុប** | | **១៤.៧៧៧.៨៧៩** | **៥៩.៧៧៦.៥២០** | ១៤.៦៤៧.៧១០ | ៥៩.១៣២.៨០៦ |
| **មូលធនភាគហ៊ុននិក និងបំណុលសរុប** | | **៨២.៣៥៨.៥៨៦** | **៣៣៣.១៤០.៤៨០** | ៨២.៥៦៨.៣៤០ | ៣៣៣.៣២៨.៣៨៩ |

# របាយការណ៍ចំណូលពេញលេញ
## សម្រាប់ការិយបរិច្ឆេទគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧

| | កំណត់សម្គាល់ | ដុល្លារអាមេរិក | ៣១ ធ្នូ ២០១៧ ពាន់រៀល (កំណត់សម្គាល់៤) | ដុល្លារអាមេរិក | ៣១ ធ្នូ ២០១៦ ពាន់រៀល (កំណត់សម្គាល់៤) |
|---|---|---|---|---|---|
| ចំណូល | ១៥ | **៨០.០៩៥.៧៧៦** | **៣២៣.៩៨៧.៤១៤** | ៨២.០៩២.៤៧១ | ៣៣១.៤០៧.៣០៥ |
| ថ្លៃដើម | ១៦ | **(៧៣.៣៨២.២៥១)** | **(២៩៦.៨៣១.២០៥)** | (៧១.៨៣៤.៧៤២) | (២៨៩.៩៩៦.៨៥៣) |
| **ចំណេញដុល** | | **៦.៧១៣.៥២៥** | **២៧.១៥៦.២០៩** | ១០.២៥៧.៧២៩ | ៤១.៤១០.៤៥២ |
| ចំណូលផ្សេងៗ | | **៧៤.៨៧៨** | **៣០២.៨៨២** | ៣៩.៨៧០ | ១៦០.៩៥៥ |
| ចំណាយរដ្ឋបាល | ១៧ | **(៣.៦២០.១០០)** | **(១៤.៦៤៣.៣០៥)** | (៣.៨១៦.៩២៥) | (១៥.៤០៨.៩២៦) |
| ចំណាយលើការដឹកជញ្ជូន | ១៨ | **(១.៦៤០.២៩៧)** | **(៦.៦៣៥.០០១)** | (២.៤៨៧.៩១២) | (១០.០៤៣.៧០១) |
| ចំណាយផ្សេងៗ | | **(១៧១.៨៨១)** | **(៦៩៥.២៥៩)** | (២១.២៩៧) | (៨៥.៩៧៦) |
| **ចំណេញលើប្រតិបត្តិការ** | | **១.៣៥៦.១២៥** | **៥.៤៨៥.៥២៦** | ៣.៩៧១.៤៦៥ | ១៦.០៣២.៨០៤ |
| ចំណូលហិរញ្ញប្បទាន | | **២០.១០៥** | **៨១.៣២៥** | ២០.២៤៥ | ៨១.៧២៩ |
| ចំណាយហិរញ្ញប្បទាន | ១៩ | **(២០៦.៩៩៨)** | **(៨៣៧.៣០៧)** | (១៣៨.៣៩៦) | (៥៥៨.៧០៥) |
| **ចំណេញមុនបង់ពន្ធ** | | **១.១៦៩.២៣២** | **៤.៧២៩.៥៤៤** | ៣.៨៥៣.៣១៤ | ១៥.៥៥៥.៨២៨ |
| (ចំណាយ)អត្ថប្រយោជន៍ពន្ធលើប្រាក់ចំណេញ | ២០.១ | **(៥០៩.១៥៥)** | **(២.០៥៩.៥៣២)** | ១.៣៨៨.៨៥៩ | ៥.៦០៦.៨២៤ |
| **ចំណេញក្នុងការិយបរិច្ឆេទ** | | **៦៦០.០៧៧** | **២.៦៧០.០១២** | ៥.២៤២.១៧៣ | ២១.១៦២.៦៥២ |
| ចំណូលលម្អិតផ្សេងៗ | | - | - | - | - |
| **ចំណូលលម្អិតផ្សេងៗក្នុងការិយបរិច្ឆេទសរុប** | | **៦៦០.០៧៧** | **២.៦៧០.០១២** | ៥.២៤២.១៧៣ | ២១.១៦២.៦៥២ |

ប្រាក់ចំណេញក្នុង១ភាគហ៊ុន ដែលអាចបែងចែកទៅភាគហ៊ុននិករបស់ក្រុមហ៊ុន ក្នុងការិយបរិច្ឆេទនេះមានដូចខាងក្រោម៖

| | កំណត់សម្គាល់ | ដុល្លារអាមេរិក | ៣១ ធ្នូ ២០១៧ ពាន់រៀល (កំណត់សម្គាល់៤) | ដុល្លារអាមេរិក | ៣១ ធ្នូ ២០១៦ ពាន់រៀល (កំណត់សម្គាល់៤) |
|---|---|---|---|---|---|
| ចំណេញក្នុងមួយភាគហ៊ុនគោល | ២២ | **០.០២** | **០.០៧** | ០.១៣ | ០.៥៣ |
| ចំណេញក្នុងមួយភាគហ៊ុនថយចុះ | ២២ | **០.០២** | **០.០៧** | ០.១៣ | ០.៥៣ |

# របាយការណ៍បម្រែបម្រួលមូលធន
## សម្រាប់ការិយបរិច្ឆេទបញ្ចប់ត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧

| | កំណត់សម្គាល់ | ដើមទុន ដុល្លារអាមេរិក | បុព្វលាភភាគហ៊ុន ដុល្លារអាមេរិក | ចំណេញរក្សាទុក ដុល្លារអាមេរិក | សរុប ដុល្លារអាមេរិក |
|---|---|---|---|---|---|
| **សមតុល្យគិតត្រឹមថ្ងៃទី១ ខែមករា ឆ្នាំ២០១៧** | ១១ | **១០.០០០.០០០** | **១៧.២៨០.០០០** | **៤០.៦៤០.៦៣០** | **៦៧.៩២០.៦៣០** |
| ចំណេញក្នុងការិយបរិច្ឆេទ | | - | - | **៦៦០.០៧៧** | **៦៦០.០៧៧** |
| ភាគលាភបានទូទាត់ | ២១ | - | - | **(១.០០០.០០០)** | **(១.០០០.០០០)** |
| ចំណូលលម្អិតផ្សេងៗ | | - | - | - | - |
| **សមតុល្យគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧** | | **១០.០០០.០០០** | **១៧.២៨០.០០០** | **៤០.៣០០.៧០៧** | **៦៧.៥៨០.៧០៧** |
| **ពាន់រៀល (កំណត់សម្គាល់៤)** | | **៤០.៤៥០.០០០** | **៦៩.៨៩៧.៦០០** | **១៦៣.០១៦.៣៦០** | **២៧៣.៣៦៣.៩៦០** |
| សមតុល្យគិតត្រឹមថ្ងៃទី១ ខែមករា ឆ្នាំ២០១៦ | ១១ | ១០.០០០.០០០ | ១៧.២៨០.០០០ | ៣៥.៩៣៨.៤៥៧ | ៦៣.២១៨.៤៥៧ |
| ចំណេញក្នុងការិយបរិច្ឆេទ | | - | - | ៥.២៤២.១៧៣ | ៥.២៤២.១៧៣ |
| ភាគលាភ | ២១ | - | - | (៥៤០.០០០) | (៥៤០.០០០) |
| ចំណូលលម្អិតផ្សេងៗ | | - | - | - | - |
| សមតុល្យគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ | | ១០.០០០.០០០ | ១៧.២៨០.០០០ | ៤០.៦៤០.៦៣០ | ៦៧.៩២០.៦៣០ |
| ពាន់រៀល (កំណត់សម្គាល់៤) | | ៤០.៣៧០.០០០ | ៦៩.៧៥៩.៣៦០ | ១៦៤.០៦៦.២២៣ | ២៧៤.១៩៥.៥៨៣ |

# របាយការណ៍លំហូរសាច់ប្រាក់
# សម្រាប់ការិយបរិច្ឆេទបញ្ចប់ត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧

| | កំណត់សម្គាល់ | ៣១ ខែធ្នូ ២០១៧ ដុល្លារអាមេរិក | ៣១ ខែធ្នូ ២០១៧ ពាន់រៀល (កំណត់សម្គាល់៤) | ៣១ ខែធ្នូ ២០១៦ ដុល្លារអាមេរិក | ៣១ ខែធ្នូ ២០១៦ ពាន់រៀល (កំណត់សម្គាល់៤) |
|---|---|---|---|---|---|
| **លំហូរសាច់ប្រាក់ពីសកម្មភាពប្រតិបត្តិការ** | | | | | |
| ចំណេញមុនបង់ពន្ធ | | **១.១៦៩.២៣២** | **៤.៧២៩.៥៤៤** | ៣.៨៩៣.៣១៤ | ១៥.៥៥៥.៨២៨ |
| **និយ័តកម្ម៖** | | | | | |
| រំលស់ទ្រព្យសកម្មអរូបី | ៧ | **១៥.០៩១** | **៦១.០៤៣** | ៥.១៩២ | ២០.៧៥៨ |
| រំលស់ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ | ៦ | **១.៦៥៨.៨១៧** | **៦.៧០៩.៩១៥** | ១.៥៩៧.២៦០ | ៦.២៤៦.២៨៩ |
| ចំណាយហិរញ្ញប្បទាន | ១៩ | **២០៦.៩៩៨** | **៨៣៧.៣០៧** | ១៣៨.៣៩៦ | ៥៥៨.៧០៥ |
| ចំណូលការប្រាក់ | | **(២០.១០៥)** | **(៨១.៣២៥)** | (២០.២៤៤) | (៨១.៧២៥) |
| **ចំណូលប្រតិបត្តិការមុនបម្រែបម្រួលដើមទុនបង្វិល** | | **៣.០៣០.០៣៣** | **១២.២៥៦.៤៨៤** | ៥.៥២៣.៨៦៨ | ២២.២៩៩.៨៥៥ |
| **បម្រែបម្រួលដើមទុនបង្វិល៖** | | | | | |
| បម្រែបម្រួលសន្និធិ | ៨ | **(៥.២០០.០០៧)** | **(២១.០៣៤.០២៨)** | ២៣៧.៧៣២ | ៩៥៩.៧២៤ |
| បម្រែបម្រួលគណនីអតិថិជនពាណិជ្ជកម្ម និងគណនីត្រូវទទួលផ្សេងៗ | ៩ | **(៣.៤៦៧.៧៦២)** | **(១៤.០២៧.០៩៨)** | (៤.២២៧.៦១៩) | (១៧.០៦៦.៨៩៧) |
| បម្រែបម្រួលគណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម និងគណនីត្រូវបង់ផ្សេងៗ | ១៣ | **(៨២៧.៦២៣)** | **(៣.៣៤៧.៧៣៥)** | ២.៨២៧.០៤០ | ១១.៤១២.៧៦៥ |
| **សាច់ប្រាក់បានមកពីសកម្មភាពប្រតិបត្តិការ** | | **(៦.៤៦៥.៣៥៩)** | **(២៦.១៥២.៣៧៧)** | ៤.៣៦១.០២១ | ១៧.៦០៥.៤៤៧ |
| ពន្ធលើការប្រាក់ចំណេញដែលត្រូវបង់ | | **(១.៦៤៧.០០៩)** | **(៦.៦៦២.១៥១)** | (៧៤.០២១) | (២៩៨.៨២៣) |
| ការប្រាក់បានបង់ | ១៩ | **(២០៦.៩៩៨)** | **(៨៣៧.៣០៧)** | (១៣៨.៣៩៦) | (៥៥៨.៧០៥) |
| **សាច់ប្រាក់សុទ្ធបាន(ប្រើ)មកពីសកម្មភាពប្រតិបត្តិការ** | | **(៨.៣១៩.៣៦៦)** | **(៣៣.៦៥១.៨៣៥)** | ៤.១៤៨.៦០៤ | ១៦.៧៤៧.៩១៩ |
| | | | | | |
| **លំហូរសាច់ប្រាក់សុទ្ធពីសកម្មភាពវិនិយោគ** | | | | | |
| បុរេប្រទានពី/(ទូទាត់សងទៅ)ក្រុមហ៊ុនមេសម្ព័ន្ធ | ៩. ១៣ | **៩.៣៥៨.១៥២** | **៣៧.៨៥៣.៧២៥** | (១.១៦៩.៨៣៣) | (៤.៧២២.៦២០) |
| បុរេប្រទានពី/(ទៅ)ក្រុមហ៊ុនសម្ព័ន្ធញាតិនានា | ៩ | **(៥៣៤.៤៩៤)** | **(២.១៦២.០២៨)** | (២២.៨០៧) | (៩២.០៧២) |
| ការទិញទ្រព្យសកម្មអរូបី | ៧ | **(២៤.១០០)** | **(៩៧.៤៨៥)** | (៥.១៣០) | (២០.៧១០) |
| ការទិញទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ | ៦ | **(១.១២៩.៨៧២)** | **(៤.៥៧០.៣៣២)** | (៤.៨០០.៥៥៩) | (១៩.៣៧៩.៨៥៧) |
| ការប្រាក់ទទួលបាន | | **២០.១០៥** | **៨១.៣២៥** | ២០.២៤៤ | ៨១.៧២៥ |
| ភាគលាភបានបង់ | | **(១.០០០.០០០)** | **(៤.០៤៥.០០០)** | (៥៤០.០០០) | (២.១៧៩.៩៨០) |
| **សាច់ប្រាក់សុទ្ធបានមកពី(ប្រើ)ក្នុងសកម្មភាពវិនិយោគ** | | **៦.៦៨៩.៧៩១** | **២៧.០៦០.២០៥** | (៦.៥១៨.០៨៥) | (២៦.៣១៣.៥១៤) |
| **លំហូរសាច់ប្រាក់សុទ្ធពីសកម្មភាពហិរញ្ញប្បទាន** | | | | | |
| ការទូទាត់សងកម្ចីធនាគារ | ១៤ | **(១៣.២៣៣.០៩៨)** | **(៥៣.៥២៧.៨៩១)** | (៤.១០០.០០០) | (១៦.៥៥១.៧០០) |
| ការទទួលយកប្រាក់កម្ចីពីធនាគារ | ១៤ | **១៣.៨០០.០០០** | **៥៥.៨២១.០០០** | ៦.៥០០.០០០ | ២៦.២៤០.៥០០ |
| **សាច់ប្រាក់សុទ្ធបានមកពីសកម្មភាពហិរញ្ញប្បទាន** | | **៥៦៦.៩០២** | **២.២៩៣.១១៩** | ២.៤០០.០០០ | ៩.៦៨៨.៨០០ |
| | | | | | |
| **បម្រែបម្រួលសាច់ប្រាក់ និងសាច់ប្រាក់សមមូលសុទ្ធ** | | **(១.០៦២.៦៧៣)** | **(៤.២៩៨.៥១១)** | ៣០.៥១៩ | ១២៣.២០៥ |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូលនៅដើមការិយបរិច្ឆេទ | | **១.២៩១.២១០** | **៥.២១២.៦១៥** | ១.២៦០.៦៩១ | ៥.០៨៩.៤១០ |
| លម្អៀងពីការបកប្រែរូបិយប័ណ្ណ | | **-** | **១០.៣២៨** | - | - |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលនៅចុងការិយបរិច្ឆេទ** | | **២២៨.៥៣៧** | **៩២៤.៤៣២** | ១.២៩១.២១០ | ៥.២១២.៦១៥ |

## ១. ព័ត៌មានអំពីក្រុមហ៊ុន

ក្រុមហ៊ុន ហ្រ្គេន ធ្វីន អ៊ិនធើណេសិនណល (ខេមបូឌា) ភីអិលស៊ី ហៅកាត់ថា ("ក្រុមហ៊ុន") បានចុះបញ្ជីពាណិជ្ជកម្មនៅថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៧ ជាក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ នៅថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១៣ ក្រុមហ៊ុនបានធ្វើវិសោធនកម្មទៅលើការចុះបញ្ជីពាណិជ្ជកម្ម ដើម្បីផ្លាស់ប្តូរទៅជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត។ដូច្នេះក្រុមហ៊ុនត្រូវបានចុះបញ្ជីនៅលើផ្សារមូលប័ត្រកម្ពុជានៅថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៤។

ក្រុមហ៊ុន មានក្រុមហ៊ុនមេសម្ព័ន្ធអន្តរការី គឺ ហ្រ្គេន ធ្វីន អ៊ិនធើណេសិនណល អិលធីឌី ជាក្រុមហ៊ុនបានចុះបញ្ជីពាណិជ្ជកម្មនៅ British Virgin Islands ខណៈដែលក្រុមហ៊ុនមេសម្ព័ន្ធគឺ យូអឹមអាយ អ៊ីនដាស្ទ្រៀល ខូអិលធីឌី ជាក្រុមហ៊ុនបានចុះបញ្ជីពាណិជ្ជកម្មនៅតៃវ៉ាន់។

ទីស្នាក់ការ និងទីតាំងអាជីវកម្មរបស់ក្រុមហ៊ុនស្ថិតនៅភូមិត្រពាំងពោធិ៍ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

សកម្មភាពចម្បងរបស់ក្រុមហ៊ុនគឺការផលិតសំលៀកបំពាក់។

ពុំមានការផ្លាស់ប្តូរជាសារវ័ន្តសម្រាប់សកម្មភាពចម្បងរបស់ក្រុមហ៊ុនក្នុងកំឡុងការិយបរិច្ឆេទនេះទេ។

## ២ របាយការណ៍អនុលោមតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា

របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ត្រូវបានរៀបចំដោយអនុលោមតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា។

ក្រុមប្រឹក្សាគណនេយ្យជាតិ បានកំណត់ដោយប្រកាស (សារាចរ) លេខ ០៦៨ ថ្ងៃទី៨ ខែមករា ឆ្នាំ២០០៩ ដែលចេញដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៃប្រទេសកម្ពុជា ទៅលើការអនុម័តនៃស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាបានសម្រេចអនុម័តយ៉ាងពេញលេញទៅតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ដែលចេញដោយក្រុមប្រឹក្សាស្តង់ដារគណនេយ្យអន្តរជាតិ ("IASB") ដោយគ្មានការកែប្រែ។ បទដ្ឋានថ្មីត្រូវបានហៅថា "ស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា"។

## ៣ ស្តង់ដារ វិសោធនកម្ម និងការបកស្រាយទៅលើស្តង់ដារមានស្រាប់ដែលមិនទាន់មានប្រសិទ្ធភាពនៅឡើយ និងមិនទាន់ត្រូវបាន អនុវត្តដោយក្រុមហ៊ុន

នាកាលបរិច្ឆេទនៃការអនុម័តរបាយការណ៍ហិរញ្ញវត្ថុនេះ ស្តង់ដារថ្មីមួយចំនួន ការធ្វើវិសោធនកម្ម និងបំណកស្រាយស្តង់ដារដែលមានស្រាប់ ត្រូវបានបោះពុម្ពផ្សាយដោយ IASB តែមិនទាន់មានប្រសិទ្ធភាពនៅឡើយ ព្រមទាំងមិនទាន់ត្រូវបានអនុវត្តដោយក្រុមហ៊ុន។

ក្រុមប្រឹក្សាភិបាលរំពឹងថា សេចក្តីប្រកាសដែលពាក់ព័ន្ធទាំងអស់ នឹងត្រូវបានអនុវត្តនៅក្នុងគោលនយោបាយគណនេយ្យរបស់ក្រុមហ៊ុន សម្រាប់ការិយបរិច្ឆេទដែលចាប់ផ្តើមដំបូង បន្ទាប់ពីប្រកាសនោះមានប្រសិទ្ធភាព។ ស្តង់ដារថ្មី ការធ្វើវិសោធនកម្ម និងបំណកស្រាយ ដែលរំពឹងថាអាចពាក់ព័ន្ធទៅនឹងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន គឺមានដូចខាងក្រោម។ ស្តង់ដារថ្មី និងបំណកស្រាយទាំងនេះ ត្រូវបានចេញផ្សាយ ប៉ុន្តែមិនបានរំពឹងថានឹងមានផលប៉ះពាល់ជាសារវន្តទៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនឡើយ។

**ស្តង់ដារទាក់ទងនឹងរបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិលេខ៩ ស្តីពី "ឧបករណ៍ហិរញ្ញវត្ថុ"**

ស្តង់ដារថ្មីសម្រាប់ឧបករណ៍ហិរញ្ញវត្ថុ ("IFRS ៩") ជំនួសអោយស្តង់ដារគណនេយ្យអន្តរជាតិលេខ៣៩ *"ឧបករណ៍ហិរញ្ញវត្ថុ : ការទទួលស្គាល់ និង ការវាស់វែង"* ។ វាកែប្រែយ៉ាងធំ ទៅលើគោលការណ៍ណែនាំពីមុន ចំពោះការធ្វើចំណាត់ថ្នាក់ និងការវាស់វែង ទៅលើទ្រព្យសកម្មហិរញ្ញវត្ថុ និងណែនាំនូវគំរូ *"ការខាតបង់ឥណទានដែលបានរំពឹងទុក (expected credit loss)"* សម្រាប់ការធ្វើឱនភាពតម្លៃនៃទ្រព្យសកម្មហិរញ្ញវត្ថុ។

IFRS ៩ ក៏មានតម្រូវការថ្មីចំពោះការប្រើប្រាស់គណនេយ្យការពារហានិភ័យផងដែរ។ តម្រូវការថ្មីនេះ តម្រឹមគណនេយ្យការពារហានិភ័យ អោយជិតទៅនឹងសកម្មភាពគ្រប់គ្រងហានិភ័យក្រុមហ៊ុន ដោយបង្កើនសិទ្ធិទទួលបាននៃធាតុការពារហានិភ័យ និងឧបករណ៍ការពារហានិភ័យ និងការណែនាំវិធីសាស្រ្ត ដែលមានមូលដ្ឋានលើគោលការណ៍ដើម្បីវាយតម្លៃលើប្រសិទ្ធិភាពការពារហានិភ័យ។

ក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន ពុំទាន់បានវាយតម្លៃផលប៉ះពាល់នៃ IFRS ៩ ទៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុននោះឡើយ។

IFRS ៩ មានប្រសិទ្ធភាពអនុវត្តទៅលើរបាយការណ៍ប្រចាំឆ្នាំ ដែលផ្តើមនៅថ្ងៃ ឬបន្ទាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០១៨។

**ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិលេខ១៥ ស្តីពី "ចំណូលពីកិច្ចសន្យាជាមួយអតិថិជន" ("IFRS ១៥")**

IFRS ១៥ បង្ហាញនូវតម្រូវការថ្មីសម្រាប់ការទទួលស្គាល់ចំណូល ជំនួស IAS ១៨ ស្តីពី "ចំណូល" IAS ១១ "ស្តីពីកិច្ចសន្យាសាងសង់" និងការបកស្រាយមួយចំនួនដែលពាក់ព័ន្ធនឹងចំណូល។ ស្តង់ដារថ្មីបង្កើតក្នុងបរិបទនៃការទទួលស្គាល់ប្រាក់ចំណូលផ្អែកលើការគ្រប់គ្រងនិងផ្តល់នូវគោលការណ៍ណែនាំលើផ្នែកមួយចំនួនទៀត ដែលមិនត្រូវបានបង្ហាញលម្អិតនៅក្នុងស្តង់ដារទាក់ទងនឹងរបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិដែលមានស្រាប់ ដោយរួមបញ្ចូលពីរបៀបកត់ត្រា ទៅលើកាតព្វកិច្ចអនុវត្តច្រើន តម្លៃអថេរ សិទ្ធក្នុងការសងត្រលប់របស់អតិថិជន ជម្រើសក្នុងការជ្រើសរើសអ្នកផ្គត់ផ្គង់ និងភាពស្មុគស្មាញផ្សេងៗទៀត។

ក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន មិនទាន់ចាប់ផ្តើមធ្វើការវាយតម្លៃពីផលប៉ះពាល់នៃ IFRS ១៥ ទៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុននោះឡើយ។

IFRS ១៥ មានប្រសិទ្ធិភាពអនុវត្តចំពោះរបាយការណ៍ប្រចាំឆ្នាំ ដែលផ្តើមពី ឬបន្ទាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០១៨។

**ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិលេខ១៦ ស្តីពី "ភតិសន្យា" ("IFRS ១៦")**

IFRS ១៦ នឹងជំនួស IAS ១៧ និងបំណកស្រាយបីផ្សេងទៀត។ វាគឺជាការបញ្ចប់គម្រោងដ៏យូររបស់ IASB ដើម្បីធ្វើកំណែទម្រង់គណនេយ្យភតិសន្យា។ ភតិសន្យានឹងត្រូវបានកត់ត្រានៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ ក្នុងទម្រង់សិទ្ធប្រើប្រាស់ទ្រព្យសកម្ម និងបំណុលភតិសន្យា។

ក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន មិនទាន់បានធ្វើការវាយតម្លៃពីផលប៉ះពាលរបស់ស្តង់ដារ IFRS ១៦ ទៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុននោះទេ។

IFRS ១៦ មានប្រសិទ្ធភាពអនុវត្តទៅលើរបាយការណ៍ប្រចាំឆ្នាំ ដែលផ្តើមពី ឬបន្ទាប់ពី ថ្ងៃទី១ ខែមករា ឆ្នាំ២០១៩។

# ៤ សេចក្តីសង្ខេបនៃគោលការណ៍គណនេយ្យសំខាន់ៗ

## ៤.១ ការពិនិត្យពិច័យទូទៅ

គោលការណ៍គណនេយ្យសំខាន់ៗ ដែលបានប្រើនៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុទាំងនេះត្រូវបានសង្ខេបដូចខាងក្រោម។ គោលការណ៍គណនេយ្យទាំងនេះ ត្រូវបានប្រើពេញការិយបរិច្ឆេទនានា ដែលបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ ប្រសិនជាគ្មានការបញ្ជាក់ផ្សេងនោះ។

## ៤.២ រូបិយប័ណ្ណគោល និងរូបិយប័ណ្ណសម្រាប់បង្ហាញ

រូបិយប័ណ្ណជាតិនៃព្រះរាជាណាចក្រកម្ពុជាគឺខ្មែររៀល ("រៀល")។ ប៉ុន្តែដោយសារក្រុមហ៊ុនមានប្រតិបត្តិការអាជីវកម្ម និងការរក្សាកំណត់ត្រាគណនេយ្យបឋមជាដុល្លារសហរដ្ឋអាមេរិក ("ដុល្លារអាមេរិក") ក្រុមប្រឹក្សាភិបាលបានកំណត់ដុល្លារ អាមេរិកជារូបិយប័ណ្ណរបស់ក្រុមហ៊ុនសម្រាប់គោលបំណងនៃការវាស់វែង និងបង្ហាញ ព្រោះវាបានឆ្លុះបញ្ចាំងពីខ្លឹមសារសេដ្ឋកិច្ចនៃព្រឹត្តិការណ៍និងកាលៈទេសៈរបស់ក្រុមហ៊ុន។

ប្រតិបត្តិការជារូបិយប័ណ្ណបរទេសក្រៅពីដុល្លារអាមេរិក ត្រូវបានបកប្រែទៅជាដុល្លារអាមេរិក ដោយប្រើប្រាស់អត្រាប្តូរប្រាក់ទូទៅនៅកាលបរិច្ឆេទនៃប្រតិបត្តិការ។ ទ្រព្យសកម្ម ឬបំណុលដែលកំណត់ជារូបិយប័ណ្ណក្រៅពីដុល្លារអាមេរិកនៅកាលបរិច្ឆេទរបាយការណ៍ត្រូវបានបកប្រែទៅជាដុល្លារអាមេរិកដោយប្រើប្រាស់អត្រាប្តូរប្រាក់ទូទៅនាកាលបរិច្ឆេទនៃប្រតិបត្តិការ ។ ភាពខុសគ្នាពីការប្តូររូបិយប័ណ្ណដែលបានកើតឡើងពីការបកប្រែត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណូលពេញលេញ។ ការបកប្រែចំនួនទឹកប្រាក់ពីដុល្លារអាមេរិក ទៅជារៀល បានបង្ហាញក្នុងរបាយការណ៍ហិរញ្ញវត្ថុគឺ ដើម្បីអនុវត្តតាមតែច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម (ខែមេសា ឆ្នាំ២០១៦) ប៉ុណ្ណោះ ព្រមទាំងត្រូវបានធ្វើឡើង ដោយប្រើប្រាស់អត្រាប្តូរប្រាក់មធ្យមជាផ្លូវការ ១ដុល្លារស្មើនឹង៤.០៤៥រៀល ដែលត្រូវបានចេញផ្សាយដោយអគ្គនាយកដ្ឋានពន្ធដារ នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ (ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦: ៤.០៣៧ រៀល)។

ការបកប្រែនេះ មិនគួរត្រូវបានបកស្រាយជាការតំណាងថា ចំនួនទឹកប្រាក់ដុល្លារអាមេរិកត្រូវបាន ឬអាចត្រូវបាន ឬក៏អាចនៅថ្ងៃអនាគតប្តូរជារៀលក្នុងអត្រានេះ ឬអត្រាផ្សេងទៀតនៃអត្រាប្តូរប្រាក់។

## ៤.៣ ទ្រព្យសម្បត្តិ រោងចក្រ និងគ្រឿងបរិក្ខារ

ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារបានកត់ត្រាដំបូងតាមថ្លៃដើម ។តម្លៃដើមរាប់បញ្ចូលចំណាយទាំងអស់ដែលទាក់ទងផ្ទាល់នឹងការទិញទ្រព្យសកម្មទាំងនោះ។

ការចំណាយបន្តបន្ទាប់ ត្រូវរួមបញ្ចូលទៅក្នុងតម្លៃយោងរបស់ទ្រព្យសកម្មទាំងនោះ ឬទទួលស្គាល់ជាទ្រព្យសកម្មមួយផ្សេងទៀត នៅពេលដែលទ្រព្យសកម្មនោះមានភាពអត្ថប្រយោជន៍សេដ្ឋកិច្ចដែលអាចជឿទុកចិត្តបាន នាពេលអនាគតដល់ក្រុមហ៊ុន ហើយតម្លៃនោះអាចវាស់វែងបានត្រឹមត្រូវ។ តម្លៃយោងរបស់ផ្នែកណាមួយនៃទ្រព្យសកម្មដែលបានផ្លាស់ ប្តូរ នឹងត្រូវបានលុបចេញពីបញ្ជី។ តម្លៃសេវាកម្មប្រចាំថ្ងៃរបស់ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណេញ ឬខាត នៅពេលដែលចំណាយបានកើតឡើង។ ថ្លៃដើមក៏ត្រូវរួមបញ្ចូលទាំងតម្លៃបឋមទៅលើការរុះរើ ការផ្លាស់ទីតាំងទ្រព្យសកម្ម និងការរៀបចំទីតាំងឡើងវិញ ដែលអាចនឹងកើតមានឡើងនាពេលអនាគត នៅពេលទិញទ្រព្យសកម្មទាំងនោះប្រសិនបើចាំបាច់។

ផ្នែកនីមួយៗនៃទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ ដែលមានតម្លៃដើមជាសារវន្ត ធៀបនឹងតម្លៃសរុបនៃទ្រព្យទាំងនោះ និងមានអាយុកាលប្រើប្រាស់ផ្សេងៗ ត្រូវបានរំលស់ដាច់ដោយឡែក។

បន្ទាប់ពីការទទួលស្គាល់ដំបូង ទ្រព្យសម្បត្តិ រោងចក្រ និងគ្រឿងបរិក្ខារ ត្រូវបានកត់ត្រាតាមថ្លៃដើមដករំលស់បង្គរ និងការខាតបង់បង្គរពីឱនភាពផ្សេងៗទៀត។

រំលស់ត្រូវបានគណនា ដើម្បីជម្រះថ្លៃដើមនៃទ្រព្យសម្បត្តិ អោយនៅត្រឹមតម្លៃសំណល់របស់ខ្លួន ដោយប្រើមូលដ្ឋានរំលស់លើអាយុកាលប្រើប្រាស់ប៉ាន់ស្មាន និងវិធីសាស្ត្ររំលស់ដូចខាងក្រោម៖

| | **អាយុកាលប្រើប្រាស់ប៉ាន់ស្មាន** | **វិធីសាស្ត្ររំលស់** |
|---|---:|---:|
| ដីភតិសន្យារយៈពេលវែង | ១០០ឆ្នាំ | វិធីរំលស់ថេរ |
| សំណង់អាគារ | ១២ឆ្នាំ | វិធីរំលស់ថេរ |
| រោងចក្រ និងគ្រឿងយន្ត | ៥ឆ្នាំ | វិធីរំលស់ថយចុះជាលំដាប់ |
| យានយន្ត | ៤ឆ្នាំ | វិធីរំលស់ថយចុះជាលំដាប់ |
| បរិក្ខារ និងកុំព្យូទ័រ | ២ ទៅ ៤ឆ្នាំ | វិធីរំលស់ថយចុះជាលំដាប់ |

នៅចុងការិយបរិច្ឆេទនៃរបាយការណ៍ហិរញ្ញវត្ថុ តម្លៃយោងនៃទ្រព្យសកម្មទាំងអស់ត្រូវបានធ្វើការប៉ាន់ប្រមាណពីឱនភាពតម្លៃនៅពេលដែលព្រឹត្តិការណ៍ ឬបម្រែបម្រួលលក្ខខណ្ឌណាមួយ ដែលបង្ហាញថា តម្លៃយោងនៃទ្រព្យសកម្មនោះមិនអាចស្រង់មកវិញបាន។ ការខាតបង់ពីឱនភាពតម្លៃត្រូវបានទទួលស្គាល់ នៅពេលដែលតម្លៃយោងលើសពីតម្លៃដែលអាចស្រង់មកវិញបាន។

តម្លៃកាកសំណល់ អាយុកាលប្រើប្រាស់ និងមូលដ្ឋានរំលស់ត្រូវបានពិនិត្យឡើងវិញជារៀងរាល់កាលបរិច្ឆេទរាយការណ៍ ដើម្បីធ្វើការអនុវត្តប្រកបដោយសង្គតិភាព។ បើមានភាពខុសគ្នាធៀបនឹងឆ្នាំមុន ការផ្លាស់ប្តូរនេះនឹងកត់ត្រាជាការផ្លាស់ប្តូរនៃការប៉ាន់ស្មានគណនេយ្យ។

តម្លៃយោងរបស់ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ នឹងឈប់កត់ត្រាក្នុងបញ្ជីគណនេយ្យ នៅពេលដែលទ្រព្យសកម្មនោះត្រូវបានលក់ ឬក៏រំពឹងថា នឹងមិនមានអត្ថប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគតពីការប្រើប្រាស់ ឬ លក់។ ប្រសិនជាមាន ភាពខុសគ្នារវាងតម្លៃសុទ្ធពីការលក់ និងតម្លៃយោងគឺត្រូវកត់ត្រាចូលក្នុងចំណែកចំណេញ ឬខាត។

## ៤.៤ ទ្រព្យសកម្មអរូបី

ទ្រព្យសកម្មអរូបីត្រូវបានទទួលស្គាល់នៅពេលដែលលក្ខខណ្ឌដូចជា អត្តសញ្ញាណកម្មសិទ្ធ ការគ្រប់គ្រង និងមានលទ្ធភាព ផ្តល់អត្ថប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគត។ ទ្រព្យសកម្មអរូបី ត្រូវបានវាយតម្លៃដំបូងតាមថ្លៃដើម។

បន្ទាប់ពីការទទួលស្គាល់លើកដំបូង ទ្រព្យសកម្មអរូបីត្រូវបានកត់ត្រាតាមថ្លៃដើម ដករំលស់បង្គរ និងឱនភាពបង្គរប្រសិនបើមាន។ អាយុកាលប្រើប្រាស់របស់ទ្រព្យសកម្មអរូបីត្រូវបានកំណត់ជាអចិន្ត្រៃយ៍ ឬមានកាលកំណត់។ ទ្រព្យសកម្មអរូបីដែលមានអាយុកាលប្រើប្រាស់មានកាលកំណត់ ត្រូវបានធ្វើការរំលស់ដោយប្រើវិធីសាស្ត្ររំលស់ថេរទៅតាមអាយុកាលរបស់ទ្រព្យសកម្មអរូបី ហើយនឹងធ្វើការវាយតម្លៃដើម្បីស្វែងរកកត្តាដែលអាចនាំអោយមានឱនភាពតម្លៃ។ ប្រសិនបើរកឃើញថាមានកត្តាទាំងនោះ ក្រុមហ៊ុន គួរតែធ្វើការប៉ាន់ប្រមាណតម្លៃដែលអាចស្រង់មកវិញបានរបស់ទ្រព្យសកម្មនោះ។ វិធីសាស្ត្រ និងរយៈពេលនៃការធ្វើរំលស់របស់ទ្រព្យសកម្មអរូបី ដែលមានអាយុកាលជាក់លាក់ ឬមានកាលកំណត់ត្រូវបានធ្វើការវាយតម្លៃយ៉ាងតិចបំផុតមួយដង ជារៀងរាល់ឆ្នាំ។ ចំណាយរំលស់លើទ្រព្យសកម្មអរូបី ដែលមានអាយុកាលប្រើប្រាស់ជាក់លាក់ ត្រូវបានកត់ត្រាចំណេញ ឬខាត ផ្នែកចំណាយប្រតិបត្តិការផ្សេងៗ។

ទ្រព្យសកម្មអរូបីត្រូវបានចាត់ទុកថាមានអាយុកាលប្រើប្រាស់អចិន្ត្រៃយ៍ ឬមិនមានកាលកំណត់ នៅពេលដែលទ្រព្យ សកម្មនោះ ត្រូវបានរំពឹងថានឹងបង្កើតលំហូរសាច់ប្រាក់ដល់ក្រុមហ៊ុន ហើយពេលវេលានៃការបង្កើតលំហូរសាច់ប្រាក់នោះមិនអាចប៉ាន់ស្មានបាន។ ទ្រព្យសកម្មអរូបីដែលមានអាយុកាលប្រើប្រាស់មិនកំណត់ ត្រូវបានវាយតម្លៃជារៀងរាល់ឆ្នាំ ឬនៅពេលដែលមានកត្តាសង្ស័យថាទ្រព្យសកម្មអរូបីនោះមានឱនភាពតម្លៃ។ ទ្រព្យសកម្មអរូបីប្រភេទនេះ មិនត្រូវបានធ្វើរំលស់នោះទេ។ អាយុកាលប្រើប្រាស់របស់វា ត្រូវបានពិនិត្យឡើងវិញនៅរៀងរាល់ចុងការិយបរិច្ឆេទនីមួយៗ ដើម្បីឲ្យដឹងថា តើព្រឹត្តិការណ៍ និងបរិយាកាសនានារបស់ទ្រព្យសកម្មទាំងនោះ នៅតែអាចចាត់ទុកថាមានអាយុកាល ប្រើប្រាស់មិនកំណត់ដែរឬទេ។ប្រសិនថាមាននោះ ការផ្លាស់ប្តូរអាយុកាលប្រើប្រាស់របស់ទ្រព្យសកម្មពីអាយុកាលអចិន្ត្រៃយ៍ ទៅជាអាយុកាលមានកំណត់ត្រូវបានចាត់ទុកថា ជាការផ្លាស់ប្តូរការប៉ាន់ស្មានគណនេយ្យដោយអនុលោមទៅ តាម គ.អ.ក ៨ ស្តីពី *"គោលនយោបាយគណនេយ្យ ការផ្លាស់ប្តូរការប៉ាន់ស្មានគណនេយ្យ និងកំហុសឆ្គង"*។

ចំណាយទៅលើទ្រព្យសកម្មអរូបី ដែលបានកត់ត្រាជាចំណាយប្រតិបត្តិការ គឺមិនអាចធ្វើការកត់ត្រាជាថ្លៃដើមរបស់ទ្រព្យសកម្មវិញនៅពេលក្រោយបានទេ។

ទ្រព្យសកម្មអរូបីនឹងត្រូវបានលុបចេញពីបញ្ជី នៅពេលដែលលក់ចេញ ឬ នៅពេលដែលអស់អត្ថប្រយោជន៍សេដ្ឋកិច្ចពីការប្រើប្រាស់។ ចំណេញ ឬខាតដែលកើតឡើងពីការលុបចេញពីបញ្ជីនេះ គឺជាភាពខុសគ្នារវាងតម្លៃសុទ្ធដែលបានមកពីការលក់ប្រសិនបើមាន និងតម្លៃយោងរបស់ទ្រព្យសកម្មនោះ។

### ៤.៥ ឱនភាពតម្លៃនៃទ្រព្យអរូបី និង ទ្រព្យសម្បត្តិ រោងចក្រនិងបរិក្ខារ

ដើម្បីធ្វើការវាយតម្លៃឱនភាពទ្រព្យសកម្ម នឹងត្រូវបានដាក់ជាក្រុមនៅកម្រិតទាបបំផុតដែលមានលំហូរសាច់ប្រាក់ឯករាជ្យមួយផ្នែកធំ។ ជាលទ្ធផល (ការបង្កើតសាច់ប្រាក់) ទ្រព្យសកម្មមួយចំនួនត្រូវបានវាយតម្លៃឱនភាពដាច់ដោយឡែក និងមួយចំនួនទៀតវាយតម្លៃជាក្រុម។

ការខាតបង់លើឱនភាពតម្លៃ នឹងត្រូវបានទទួលស្គាល់ប្រសិនបើតម្លៃយោងនៃទ្រព្យសកម្ម ឬក្រុមទ្រព្យនោះ ធំជាងតម្លៃដែលអាចស្រង់មកវិញបាន។ តម្លៃដែលអាចស្រង់មកវិញ គឺជាតម្លៃមួយណាដែលខ្ពស់ជាង រវាងតម្លៃទីផ្សារសមរម្យ ដកការចំណាយដែលពាក់ព័ន្ធដើម្បីលក់ និងតម្លៃបច្ចុប្បន្ននៃលំហូរសាច់ប្រាក់នាពេលអនាគត។ដើម្បីកំណត់តម្លៃប្រើប្រាស់ ក្រុមប្រឹក្សាភិបាលត្រូវធ្វើការប៉ាន់ប្រមាណតម្លៃបច្ចុប្បន្ននៃលំហូរសាច់ប្រាក់នាពេលអនាគតនៃក្រុមនីមួយៗ ដោយកំណត់

អត្រាការប្រាក់ដ៏សមរម្យ ដើម្បីគណនាតម្លៃបច្ចុប្បន្ននៃលំហូរសាច់ប្រាក់ទាំងនោះ។ ទិន្នន័យប្រើប្រាស់ដើម្បីធ្វើការវាយតម្លៃឱនភាព មានការទាក់ទងដោយផ្ទាល់ទៅនឹងគម្រោងផែនការចុងក្រោយរបស់ក្រុមហ៊ុនដែលបានអនុម័ត នឹងធ្វើនិយ័តកម្មប្រសិនបើចាំបាច់ ដើម្បីដកផលប៉ះពាល់ពីការរៀបចំ នឹងធ្វើឲ្យប្រសើរឡើងវិញនៃទ្រព្យសកម្ម នោះនាពេលអនាគត។ អត្រាអប្បហារ ត្រូវបានកំណត់ឡើងសម្រាប់ក្រុមទ្រព្យសកម្មនីមួយៗ ដើម្បីឆ្លុះបញ្ចាំងពីប្រវត្តិសង្ខេបនៃហានិភ័យរបស់ទ្រព្យសកម្មនីមួយៗដោយក្រុមប្រឹក្សាភិបាល។

## ៤.៦ សន្និធិ

សន្និធិ ត្រូវបានវាស់វែងតាមតម្លៃណាដែលទាបជាង រវាងតម្លៃដើម និងតម្លៃលក់ពិត។

ថ្លៃដើមសន្និធិ ត្រូវបានកំណត់ដោយប្រើប្រាស់មូលដ្ឋានជាមធ្យម។ ថ្លៃដើមសន្និធិ ដែលជាវត្ថុធាតុដើមរួមបញ្ចូល ថ្លៃទិញ បូកបញ្ចូលនឹងចំណាយផ្សេងៗដែលកើតឡើងក្នុងការនាំសន្និធិនោះមកកាន់ទីតាំង និងមានលក្ខណៈបច្ចុប្បន្ន។ ថ្លៃដើមផលិតផលពាក់កណ្តាលសំរេច និងផលិតផលសំរេច រួមបញ្ចូលថ្លៃដើមវត្ថុធាតុដើម ថ្លៃពលកម្មផ្ទាល់ ចំណាយផ្ទាល់ផ្សេងៗ និងចំណាយការបំលែងផលិតផ្សេងៗ។

តម្លៃលក់ពិត គឺជាតម្លៃលក់ប៉ាន់ស្មានតាមប្រតិបត្តិការអាជីវកម្មធម្មតាដក នឹងថ្លៃដើមប៉ាន់ស្មាននៃការសម្រេចអោយបានផលិតផល និងចំណាយប៉ាន់ស្មានចាំបាច់ក្នុងការលក់។

## ៤.៧ ឧបករណ៍ហិរញ្ញវត្ថុ

### ការទទួលស្គាល់ ការវាស់វែងដំបូង និងការឈប់ទទួលស្គាល់

ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ ត្រូវបានទទួលស្គាល់នៅពេលដែលក្រុមហ៊ុន បានក្លាយទៅជាភាគីនៃកិច្ចសន្យាឧបករណ៍ហិរញ្ញវត្ថុ និងត្រូវបានវាស់វែងដំបូងតាមតម្លៃសមរម្យដែលបានដកចំណាយប្រតិបត្តិការ លើកលែងតែ ឧបករណ៍ហិរញ្ញវត្ថុដែលអនុវត្តតាមតម្លៃសមរម្យតាមរយៈការចំណេញ ឬខាតដែលត្រូវវាស់វែងដំបូងតាមតម្លៃសមរម្យ។ ការវាស់វែងជាបន្តបន្ទាប់នៃទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុត្រូវបានរៀបរាប់ ដូចខាងក្រោម៖

ទ្រព្យសកម្មហិរញ្ញវត្ថុ ត្រូវបានឈប់ទទួលស្គាល់នៅពេលដែលសិទ្ធិទទួលបានសាច់ប្រាក់តាមកិច្ចសន្យានៃទ្រព្យសកម្មនោះផុតកំណត់ ឬនៅពេលហានិភ័យ និងតម្លៃតបស្នងពីកម្មសិទ្ធ ភាពជាសារវន្តនៃទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានផ្ទេរចេញ។ បំណុលហិរញ្ញវត្ថុនឹងឈប់ទទួលស្គាល់នៅពេលដែលកាតព្វកិច្ច កិច្ចសន្យាបានបញ្ចប់ លុបចោល ឬ ផុតកាលកំណត់។

### ចំណាត់ថ្នាក់ និងការវាស់វែងជាបន្តបន្ទាប់នៃទ្រព្យសកម្មហិរញ្ញវត្ថុ

ដើម្បីធ្វើការវាស់វែងជាបន្តបន្ទាប់ នៃទ្រព្យសកម្មហិរញ្ញវត្ថុផ្សេងទៀតដែលមិនមែនជា ឧបករណ៍ទប់ស្កាត់ហានិភ័យ ត្រូវបានចាត់ថ្នាក់បន្ទាប់ពីទទួលស្គាល់លើកដំបូងដូចខាងក្រោម៖

- ឥណទាន និងគណនីទទួល
- ទ្រព្យសកម្មហិរញ្ញវត្ថុដែលវាស់វែងតាមតម្លៃទីផ្សារសមរម្យតាមរយៈការចំណេញ ឬខាត (FVTPL)

- ទ្រព្យសកម្មសម្រាប់លក់
- ការវិនិយោគដែលរក្សាទុកដល់ការកំណត់

ទ្រព្យសកម្មហិរញ្ញវត្ថុទាំងអស់លើកលែងតែ FVTPL ត្រូវបានវាយតម្លៃនាកាលបរិច្ឆេទរាយការណ៍នីមួយៗ ដើម្បីកំណត់សញ្ញាណឱនភាពនៃតម្លៃទ្រព្យសកម្ម។ ឱនភាពតម្លៃនៃទ្រព្យសកម្មហិរញ្ញវត្ថុនីមួយៗត្រូវបានកំណត់ផ្សេងៗគ្នា។

ចំណូល និងចំណាយទាំងអស់ ដែលទាក់ទងទៅនឹងទ្រព្យសកម្មហិរញ្ញវត្ថុ ដែលត្រូវបានទទួលស្គាល់នៅក្នុង របាយ ការណ៍ចំណេញ ឬខាតត្រូវបានបង្ហាញនៅក្នុងការចំណាយហិរញ្ញវត្ថុ ចំណូលហិរញ្ញវត្ថុ ឬធាតុហិរញ្ញវត្ថុផ្សេងទៀត លើកលែងតែឱនភាពតម្លៃគណនីអតិថិជនពាណិជ្ជកម្មដែលត្រូវបានបង្ហាញនៅក្នុងការចំណាយផ្សេងទៀត។

ក្រុមហ៊ុនមានប្រភេទនៃទ្រព្យសកម្មហិរញ្ញវត្ថុទាំងនេះ ដូចជា គណនីឥណទាន និងគណនីត្រូវទទួលនៅក្នុងរបាយ ការណ៍ស្ថានភាពហិរញ្ញវត្ថុ។

### *ឥណទាន និងគណនីត្រូវទទួល*

ឥណទាន និងគណនីត្រូវទទួលគឺជាទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុមិននិទស្សន៍ ដែលមានសំណងថេរ ឬអាច កំណត់បាន ហើយមិនត្រូវបានបោះផ្សាយនៅក្នុងទីផ្សារសកម្ម។បន្ទាប់ពីការទទួលស្គាល់ដំបូងត្រូវបានវាស់វែងតាម រំលស់ថ្លៃដើមដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធិភាពដកឱនភាពតម្លៃផ្សេងៗ។ ឥណទាន និងគណនីទទួលទាំងនោះ នឹងមិនធ្វើអប្បហារទេ ប្រសិនបើអប្បហារនោះមិនសារវន្ត។ សាច់ប្រាក់ និងសាច់ប្រាក់សមមូល គណនីអតិថិជន ពាណិជ្ជកម្ម និងគណនីទទួលផ្សេងៗទៀតត្រូវបានចាត់ចំណាត់ថ្នាក់ជាឧបករណ៍ហិរញ្ញវត្ថុ។

គណនីទទួលទោលសំខាន់ៗ ដែលហួសកាលកំណត់ ឬមានភស្តុតាងណាមួយដែលគណនីទទួលមិនអាចស្រង់មកវិញបាន ត្រូវចាត់ទុកថាមានឱនភាពតម្លៃ។ ក្រុមប្រឹក្សាភិបាលត្រូវពិចារណាក្នុងការធ្វើឱនភាពតម្លៃគណនីទទួលទោលនោះ ជាក្រុម ប្រសិនបើគណនីទទួលទោលនោះមិនមានឱនភាពតម្លៃ ដែលកំណត់ទៅតាមលក្ខណសម្បត្តិស្រដៀងគ្នារបស់ដៃគូពាណិជ្ជកម្ម តំបន់ និងហានិភ័យឥណទាន។ ការខាតបង់នៃឱនភាពតម្លៃ ត្រូវបានធ្វើការប៉ាន់ប្រមាណយោងតាមអត្រាគ្មានលទ្ធភាពសងរបស់ដៃគូរពាណិជ្ជកម្មចុងក្រោយបង្អស់ សម្រាប់ក្រុមនីមួយៗដែលបានរកឃើញ។

### ចំណាត់ថ្នាក់ និងការវាស់វែងជាបន្តបន្ទាប់នៃបំណុលហិរញ្ញវត្ថុ

បំណុលហិរញ្ញវត្ថុរបស់ក្រុមហ៊ុន រួមមាន ប្រាក់កម្ចី គណនីអ្នកផ្គត់ផ្គង់ និងគណនីបំណុលផ្សេងៗទៀត។

បន្ទាប់ពីទទួលស្គាល់លើកដំបូង បំណុលហិរញ្ញវត្ថុត្រូវបានវាស់វែងតាមរំលស់ថ្លៃដើម ដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធិភាព លើកលែងតែបំណុលហិរញ្ញវត្ថុដែលធ្វើឡើងសម្រាប់ការធ្វើពាណិជ្ជកម្ម ឬដែលបានកំណត់ជា FVTPL ដែលបន្ទាប់មកទទួលស្គាល់តាមតម្លៃទីផ្សារសមរម្យ ដែលចំណេញ ឬខាតទទួលស្គាល់នៅក្នុងរបាយការណ៍ចំណេញ ឬខាត។ ឧបករណ៍ហិរញ្ញវត្ថុនិទស្សន៍ទាំងអស់ ដែលមិនបានកំណត់ជា ឧបករណ៍ទប់ស្កាត់ហានិភ័យ ត្រូវបានកត់ត្រាជា FVTPL ។

ចំណាយការប្រាក់ទាំងអស់ និងការផ្លាស់ប្តូរតម្លៃទីផ្សារសមរម្យ ដែលរាយការណ៍នៅក្នុងរបាយការណ៍ចំណេញ ឬខាតត្រូវបានរួមបញ្ចូលនៅក្នុងចំណាយ និងចំណូលហិរញ្ញវត្ថុ។

## ៤.៨ សាច់ប្រាក់ និងសាច់ប្រាក់សមមូល

សាច់ប្រាក់និងសាច់ប្រាក់សមមូល រួមមានសាច់ប្រាក់ក្នុងដៃ និងប្រាក់បញ្ញើតាមតម្រូវការ រួមទាំងការវិនិយោគក្នុងរយៈពេលខ្លី ដែលប្តូរជាសាច់ប្រាក់ក្នុងរយៈពេល ៩០ ថ្ងៃ ដោយមានហានិភ័យតិចតួចចំពោះការផ្លាស់ប្តូរតម្លៃ។

### ៤.៩ មូលធន បុព្វលាភភាគហ៊ុន ប្រាក់ចំណេញរក្សាទុក និងការទូទាត់ភាគលាភ

ដើមទុន តំណាងអោយ តម្លៃចារឹក (តម្លៃដើម) របស់ភាគហ៊ុនដែលបានបោះផ្សាយ។

បុព្វលាភភាគហ៊ុន រួមបញ្ចូល ថ្លៃបុព្វលាភទទួលបានពីការបោះពុម្ពផ្សាយភាគហ៊ុន។ ចំណាយប្រតិបត្តិការនានាដែលទាក់ទងនឹងការបោះពុម្ពផ្សាយភាគហ៊ុន ដែលបានកាត់កងជាមួយអត្ថប្រយោជន៍ពន្ធលើប្រាក់ចំណេញត្រូវកាត់ចេញពីបុព្វលាភ។

ប្រាក់ចំណេញរក្សាទុករួមមាន ប្រាក់ចំណេញនាពេលបច្ចុប្បន្ន និងប្រាក់ចំណេញរក្សាទុកពីឆ្នាំមុន។

ភាគលាភបណ្តោះអាសន្ន ផ្តល់អោយភាគទុនិក ត្រូវបានទទួលស្គាល់នៅក្នុងមូលធន នាការិយបរិច្ឆេទដែលបានប្រកាស។ ភាគលាភចុងក្រោយ នឹងត្រូវបានទទួលស្គាល់ បន្ទាប់ពីទទួលបានការអនុម័តពីភាគទុនិក។

### ៤.១០ ពន្ធលើប្រាក់ចំណេញ

ចំណាយពន្ធ រួមមានពន្ធពន្យា និងពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ ដែលមិនបានទទួលស្គាល់នៅក្នុងលទ្ធផលលម្អិតផ្សេងៗ ឬ មូលធន។

ការគណនាពន្ធបច្ចុប្បន្ន ត្រូវបានផ្អែកលើអត្រាពន្ធនិងច្បាប់ពន្ធ ដែលត្រូវបានអនុម័ត ឬអនុម័តជាអាទិ៍ នាកាលបរិច្ឆេទរាយការណ៍។ ពន្ធពន្យាត្រូវបានគណនាដោយប្រើវិធានបំណុល។

ទ្រព្យសកម្មពន្ធពន្យា ត្រូវបានទទួលស្គាល់ តែក្នុងករណី ការខាតពន្ធ រឺការខុសគ្នាបណ្តោះអាសន្នអាចកាត់កងនឹងអាចមានលទ្ធភាពទូទាត់ប្រាក់ចំណេញជាប់ពន្ធនាពេលអនាគត។

វាត្រូវបានវាយតំលៃដោយពឹងផ្អែកលើការព្យាករណ៍លទ្ធផលប្រតិបត្តិនាពេលអនាគត កែសំរួលដោយចំណូលនិងចំណាយដែលមិនត្រូវជាប់ពន្ធសំខាន់ៗ និងការប្រើប្រាស់មានកំរិតនៃការខាតពន្ធ និងឥណទានពន្ធ។

បំណុលពន្ធពន្យា គឺត្រូវបានទទួលស្គាល់ទាំងស្រុង ទោះបីជា IAS ១២ "ពន្ធលើប្រាក់ចំណូល" មានភាពលើកលែងមួយចំនួនក៏ដោយ។

### ៤.១១ ភតិសន្យាប្រតិបត្តិការ

ភតិសន្យាដែលចាត់ទុកជាភតិសន្យាប្រតិបត្តិការ ប្រសិនបើហានិភ័យ និងអត្ថប្រយោជន៍ជាម្ចាស់កម្មសិទ្ធស្របច្បាប់ទាំងស្រុងរក្សាដោយភតិសន្យាបតី។ ការទូទាត់ក្រោមភតិសន្យាប្រតិបត្តិការ (បន្ទាប់ពីការទូទាត់ប្រាក់លើកទឹកចិត្តពី ភតិសន្យាបតី) ត្រូវកត់ត្រាទៅក្នុងគណនីចំណេញ ឬខាតតាមអត្រាស្មើភាគលើរយៈពេលនៃការជួល។

## ៤.១២ ការទទួលស្គាល់ចំណូល

ចំណូល ត្រូវបានវាស់វែងតាមតម្លៃទីផ្សារសមរម្យនៃទឹកប្រាក់ដែលបានទទួល ឬទឹកប្រាក់ដែលនឹងត្រូវទទួល បន្ទាប់ពីការបញ្ចុះតម្លៃនានា និងការទូទាត់សងត្រលប់វិញ។

ប្រាក់ចំណូល ត្រូវបានទទួលស្គាល់នៅពេលដែលអត្ថប្រយោជន៍សេដ្ឋកិច្ច ដែលទាក់ទងនឹងប្រតិបត្តិការនឹងហូរចូលមកក្នុងក្រុមហ៊ុន ហើយចំណូល និងថ្លៃដើមដែលបានកើតឡើង ឬនឹងកើតឡើងទាក់ទងទៅនឹងប្រតិបត្តិការនោះអាចវាស់វែងដែលអាចជឿទុកចិត្តបាន និងស្របតាមលក្ខខណ្ឌការទទួលស្គាល់ចំណូលជាក់លាក់ សម្រាប់សកម្មភាពនីមួយៗរបស់ក្រុមហ៊ុន មានដូចខាងក្រោម៖

### ការលក់ទំនិញ

ចំណូលដែលបានពីការលក់ទំនិញត្រូវបានទទួលស្គាល់នៅពេលហានិភ័យសំខាន់ៗ និងភាពជាម្ចាស់កម្មសិទ្ធិលើទំនិញត្រូវបានផ្ទេរទៅអតិថិជន ហើយនៅពេលណាដែលក្រុមហ៊ុនមិនរក្សាទុក ឬបន្តការគ្រប់គ្រងនៅលើទំនិញ ដែលស្របគ្នាទៅនឹងការដឹកជញ្ជូនទំនិញនិងការទទួលទំនិញដោយអតិថិជន។

### សេវាកម្ម

ចំណូលដែលបានមកពីកិច្ចសន្យាម៉ៅការបន្ត ត្រូវបានទទួលស្គាល់នៅពេលដែលសេវាកម្មនោះបានបំពេញចប់។

ប្រាក់ចំណូលពីសេវាកាត់ ដេរ និងវេចខ្ចប់ ("CMP") ត្រូវបានទទួលស្គាល់ នៅពេលដែលសេវាកម្មនោះបានបញ្ចប់ និងទំនិញត្រូវបានផ្ទេរ និងទទួលដោយអតិថិជន។

### ចំណូលការប្រាក់

ចំណូលការប្រាក់ត្រូវបានទទួលស្គាល់នៅពេលដែលបង្ករដោយប្រើការប្រាក់ដែលមានប្រសិទ្ធិភាព។

## ៤.១៣ អត្ថប្រយោជន៍បុគ្គលិក

### អត្ថប្រយោជន៍បុគ្គលិករយៈពេលខ្លី

ប្រាក់ឈ្នួល ប្រាក់បៀវត្ស វិភាគទានសន្តិសុខសង្គម ប្រាក់ទូទាត់ថ្ងៃសម្រាកប្រចាំឆ្នាំ ប្រាក់ទូទាត់ថ្ងៃសម្រាកឈឺ ប្រាក់រង្វាន់ និងអត្ថប្រយោជន៍មិនមែនជាសាច់ប្រាក់គឺ វាស់វែងដោយមិនបានធ្វើអប្បហារ ត្រូវបានទទួលស្គាល់ជាចំណាយ នៅក្នុងការិយបរិច្ឆេទ ដែលនិយោជិកបានផ្តល់សេវាកម្មទៅឲ្យក្រុមហ៊ុន។

អវត្តមានដែលទទួលសំណងបង្ករយៈពេលខ្លី ដូចជាថ្ងៃសម្រាកប្រចាំឆ្នាំទទួលកម្រៃ ត្រូវបានទទួលស្គាល់ជាចំណាយ នៅពេលដែលនិយោជិកផ្តល់សេវាកម្មដែលបង្កើនសិទ្ធិក្នុងការទទួលបាននូវចំនួនថ្ងៃអវត្តមាន ទទួលកម្រៃនាពេលអនាគត។ ចំនួនថ្ងៃអវត្តមានទទួលកម្រៃរយៈពេលខ្លីមិនបង្ករដូចជាថ្ងៃសំរាកឈឺ ត្រូវទទួលស្គាល់នៅពេលដែលការអវត្តមាននោះកើតឡើង។

ប្រាក់រង្វាន់ ត្រូវបានទទួលស្គាល់ជាចំណាយនៅពេលដែលមានកាតព្វកិច្ចបច្ចុប្បន្នជាផ្លូវច្បាប់ ឬ ជាប្រយោលដើម្បីធ្វើ ការទូទាត់ចំណាយបែបនេះជាលទ្ធផលនៃព្រឹត្តិការណ៍ពីអតីតកាល ហើយការប៉ាន់ស្មានគួរអោយជឿជាក់មួយត្រូវបានធ្វើឡើងលើចំនួននៃកាតព្វកិច្ចនោះ។

**អត្ថប្រយោជន៍ពីការបញ្ឈប់កិច្ចសន្យា**

អត្ថប្រយោជន៍ពីការបញ្ឈប់កិច្ចសន្យាគឺជាចំណាយទៅលើបុគ្គលិក ដែលបណ្តាលមកពីការបញ្ឈប់កុងត្រាការងារមុនចូលនិវត្តន៍ ឬជាការសំរេចចិត្តរបស់បុគ្គលិកសុំឈប់ពីការងារដោយស្ម័គ្រចិត្ត ដើម្បីប្តូរយកអត្ថប្រយោជន៍នោះ។ ចំណាយនឹងត្រូវទទួលស្គាល់ជាបំណុល និងចំណាយនៅពេលដែលក្រុមហ៊ុនមានផែនការលម្អិតសំរាប់ការបញ្ចប់កុង ត្រាដោយគ្មានសក្តានុពលប្រាកដនៃការដកប្រាក់។ ក្នុងករណីសុំឈប់ពីការងារដោយស្ម័គ្រចិត្ត អត្ថប្រយោជន៍នឹងត្រូវ បានកត់ត្រាដោយផ្អែកទៅលើចំនួនបុគ្គលិកដែលរំពឹងទុកនឹងទទួលសំណើ។

នៅពេលអត្ថប្រយោជន៍ពីការបញ្ឈប់ការងារនៅក្រោម១២ខែឡើងទៅបន្ទាប់ពីនាចុងការិយបរិច្ឆេទ គឺត្រូវបានធ្វើអប្បហារមកជាតម្លៃបច្ចុប្បន្នដោយផ្អែកទៅលើទន្និផលទីផ្សារនាចុងការិយបរិច្ឆេទ។

## ៤.១៤ កម្រៃហិរញ្ញប្បទាន

កម្រៃហិរញ្ញប្បទានដែលពាក់ព័ន្ធដោយផ្ទាល់លើការទិញ ការសាងសង់ ឬការផលិតទ្រព្យសកម្ម ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ នឹងត្រូវបានធ្វើមូលធនកម្ម នៅពេលដែលកម្រៃហិរញ្ញប្បទាននោះចាំបាច់ក្នុងការបញ្ចប់ ហើយរៀបចំទ្រព្យសកម្មនោះសម្រាប់ប្រើប្រាស់ ឬ លក់។ កម្រៃហិរញ្ញប្បទានផ្សេងទៀតត្រូវបានទទួលស្គាល់ជាចំណាយ នៅពេលដែលបានកើតឡើង និងបានរាយការណ៍នៅក្នុងការចំណាយហិរញ្ញវត្ថុ។

## ៤.១៥ ចំណាយរដ្ឋបាលនិងចំណាយលើការដឹកជញ្ជូន

ចំណាយរដ្ឋបាល និងចំណាយលើការដឹកជញ្ជូនត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណេញ ឬខាតនៅពេលការប្រើសេវាកម្មបានបញ្ចប់ ឬពេលកើតឡើង។

## ៤.១៦ សំវិធានធន បំណុលយថាភាព និងទ្រព្យសកម្មយថាភាព

សំវិធានធនសម្រាប់ការធានាផលិតផល ជម្លោះផ្លូវច្បាប់កិច្ចសន្យា ឬការទាមទារផ្សេងទៀត ត្រូវបានទទួលស្គាល់នៅ ពេលដែលក្រុមហ៊ុននេះមានកាតព្វកិច្ចស្របច្បាប់ ឬប្រយោល ដែលជាលទ្ធផលនៃព្រឹត្តិការណ៍កន្លងផុតទៅ ហើយមាន លទ្ធភាពដែលតម្រូវអោយមានលំហូរចេញនូវអត្ថប្រយោជន៍សេដ្ឋកិច្ច ក្នុងការបំពេញនូវកាតព្វកិច្ច ហើយតម្លៃនោះអាចប៉ាន់ស្មានដោយជាក់លាក់បាន។ ការកំណត់ពេលវេលា ឬចំនួនទឹកប្រាក់នៃលំហូរនៅតែអាចមានភាពមិនច្បាស់លាស់។

សំវិធានធនដែលរៀបចំឡើងវិញ ត្រូវបានទទួលស្គាល់ប្រសិនបើផែនការលម្អិតក្នុងការរៀបចំឡើងវិញបានកើតឡើង ហើយក្រុមប្រឹក្សាភិបាលបានទាក់ទងជាមួយអ្នករងផលប៉ះពាល់អំពីផែនការចម្បងនោះ ឬក៏ផែនការនោះត្រូវបានអនុវត្ត។ សំវិធានធន មិនត្រូវបានទទួលស្គាល់ចំពោះការខាតបង់ប្រតិបត្តិការនាពេលអនាគត។

សំវិធានធនត្រូវបានវាស់វែងដោយការប៉ាន់ប្រមាណការចំណាយដែលចាំបាច់ក្នុងការបំពេញនូវកាតព្វកិច្ចនោះ ដោយយោងទៅតាមភស្តុតាងដែលអាចជឿទុកចិត្តបាន នៅចុងការិយបរិច្ឆេទរបាយការណ៍រួមទាំងហានិភ័យ និងភាពមិនជាក់លាក់

ដែលទាក់ទងទៅនឹងកាតព្វកិច្ចបច្ចុប្បន្ន។ ប្រសិនបើមានកាតព្វកិច្ចស្រដៀងគ្នា ដែលអាចនឹងតម្រូវអោយមានលំហូរចេញសាច់ប្រាក់ ដើម្បីបំពេញនូវកាតព្វកិច្ច ត្រូវបានកំណត់ដោយពិចារណាទៅលើថ្នាក់នីមួយៗនៃកាតព្វកិច្ចនោះជាក្រុម។ សំវិធានធនត្រូវធ្វើអប្បហារមកជាតម្លៃបច្ចុប្បន្ន ប្រសិនបើតម្លៃនោះមានភាពជាសារវន្ត។

សំណងណាមួយដែលក្រុមហ៊ុន ជឿជាក់ថានឹងអាចមានសិទ្ធប្រមូលបានពីតតិយជន នឹងត្រូវបានគេទទួលស្គាល់ជាទ្រព្យសម្បត្តិដាច់ដោយឡែកមួយ។ ទោះជាយ៉ាងណា ទ្រព្យសម្បត្តិនេះមិនអាចលើសពីចំនួនទឹកប្រាក់ដែលពាក់ព័ន្ធទៅនឹងសំវិធានធននោះទេ។

បំណុលនឹងមិនត្រូវបានទទួលស្គាល់ ប្រសិនបើលំហូរនៃអត្ថប្រយោជន៍សេដ្ឋកិច្ចដែលជាលទ្ធផលនៃកាតព្វកិច្ចបច្ចុប្បន្នមិនមានភាពជាក់លាក់។ ស្ថានភាពបែបនេះ ត្រូវបានបង្ហាញជាបំណុលយថាភាព។ ប្រសិនបើក្រុមប្រឹក្សាភិបាលរំពឹងថានឹងគ្មានលំហូរសាច់ប្រាក់ បំណុលយថាភាពនោះក៏មិនត្រូវបានទទួលស្គាល់ដែរ។

## ៥ ការវិនិច្ឆ័យសំខាន់ៗរបស់ក្រុមប្រឹក្សាភិបាល ក្នុងការអនុវត្តគោលនយោបាយគណនេយ្យ និងភាពមិនប្រាកដប្រជា

ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ក្រុមប្រឹក្សាភិបាលបានធ្វើការវិនិច្ឆ័យ ការប៉ាន់ស្មាន និងការសន្មតមួយចំនួនដើម្បីទទួលស្គាល់ និងវាស់វែងនៃទ្រព្យសកម្ម បំណុល ចំណូល និងចំណាយ ដែលត្រូវបានសង្ខេបដូចខាងក្រោម៖

**ការវិនិច្ឆ័យសំខាន់ៗរបស់ក្រុមប្រឹក្សាភិបាល**

ខាងក្រោមនេះ ជាការវិនិច្ឆ័យរបស់ក្រុមប្រឹក្សាភិបាលសំខាន់ៗ ក្នុងការអនុវត្តគោលនយោបាយគណនេយ្យរបស់ក្រុមហ៊ុន ដែលមានផលប៉ះពាល់ជាសារវន្ត ទៅលើរបាយការណ៍ហិរញ្ញវត្ថុ។

*ការទទួលស្គាល់ទ្រព្យសកម្មពន្ធពន្យា*

ទ្រព្យសកម្មពន្ធពន្យា អាចទទួលស្គាល់បាននៅពេលដែលមានការប៉ាន់ស្មានជាក់លាក់មួយដែលក្រុមហ៊ុន អាចមានប្រាក់ចំណេញជាប់ពន្ធនាពេលអនាគត ដែលអាចកាត់កងជាមួយភាពលម្អៀងជាបណ្តោះអាសន្ន ហើយការខាតពន្ធយោងទៅការិយបរិច្ឆេទបន្ទាប់អាចប្រើប្រាស់បាន។ លើសពីនេះទៀត ការវិនិច្ឆ័យសំខាន់ៗ ត្រូវបានទាមទារអោយមានការវាយតម្លៃពីផលប៉ះពាល់នៃផ្នែកច្បាប់នីមួយៗ ផ្នែកសេដ្ឋកិច្ច និងភាពមិនច្បាស់លាស់នៅក្នុងការកំណត់ពន្ធនានា។

**ការប៉ាន់ស្មានភាពមិនជាក់លាក់**

ព័ត៌មានអំពីការប៉ាន់ប្រមាណ និងការសន្មតដែលមានផលជាសារវន្តនៅលើការទទួលស្គាល់ និងការវាស់វែងនៃទ្រព្យសកម្ម បំណុល ចំណូល និងចំណាយត្រូវបានផ្តល់ជូននៅខាងក្រោម។ លទ្ធផលជាក់ស្តែងអាចនឹងខុសគ្នា។

*ឱនភាពនៃទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ*

ក្នុងការវាយតំលៃឱនភាព ក្រុមប្រឹក្សាភិបាលបានប៉ាន់ប្រមាណពីចំនួនទឹកប្រាក់ដែលអាចស្រង់មកវិញបានរបស់ទ្រព្យសកម្មនីមួយៗ ឬទ្រព្យសកម្មដែលដាក់បញ្ចូលគ្នាជាក្រុម ដោយផ្អែកទៅលើការរំពឹងទុកនៃលំហូរសាច់ប្រាក់នាពេលអនាគត និងការប្រើអត្រាការប្រាក់ដើម្បីធ្វើអប្បហារ។ ការប៉ាន់ប្រមាណដែលមិនជាក់លាក់ មានការទាក់ទងទៅនឹងការប៉ាន់ប្រមាណអំពីលទ្ធផលប្រតិបត្តិការនាពេលអនាគត និងការកំណត់យកអប្បហារដែលសមស្រប។

*អាយុកាលប្រើប្រាស់របស់ទ្រព្យសកម្មដែលអាចធ្វើរំលស់*

ក្រុមប្រឹក្សាភិបាលនឹងធ្វើការពិនិត្យ ការប៉ាន់ប្រមាណនៃអាយុកាលភាពរបស់ទ្រព្យសកម្មដែលអាចធ្វើរំលស់នៅរៀងរាល់កាលបរិច្ឆេទរាយការណ៍ ដោយយោងទៅលើការប្រើប្រាស់ទ្រព្យសកម្មនោះ។ ភាពមិនប្រាកដប្រជាក្នុងការប៉ាន់ស្មានទាំងនេះពាក់ព័ន្ធនឹងភាពហួសសម័យបច្ចេកទេសដែលអាចផ្លាស់ប្ដូរអាយុកាលរបស់ឧបករណ៍បច្ចេកវិទ្យាជាក់លាក់ណាមួយ។

*សន្និធិ*

ក្រុមប្រឹក្សាភិបាលបានប៉ាន់ស្មានតម្លៃលក់ពិតនៃសន្និធិ ដោយប្រើប្រាស់ភស្តុតាងដែលមាន និងគួរឱ្យទុកចិត្ត នៅក្នុងកាលបរិច្ឆេទរបាយការណ៍នីមួយៗ។ តម្លៃលក់ពិតនាពេលអនាគតនៃសន្និធិទាំងនោះ អាចនឹងរងផលប៉ះពាល់ដោយបច្ចេកវិទ្យានាពេលអនាគត ឬការផ្លាស់ប្ដូរនៃកត្តាទីផ្សារផ្សេងៗ ដែលអាចបណ្ដាលអោយធ្លាក់ចុះនូវតម្លៃលក់នាពេលអនាគត។

*ការចំណាយពន្ធលើប្រាក់ចំណូល*

ការប៉ាន់ស្មានសំខាន់ៗ ត្រូវបានប្រើដើម្បីកំណត់សំវិធានធនពន្ធលើប្រាក់ចំណូលរបស់ក្រុមហ៊ុន។ ក្រុមហ៊ុន នឹងទទួលស្គាល់បំណុលសម្រាប់ការចំណាយលើពន្ធ ដោយផ្អែកទៅលើការប៉ាន់ប្រមាណពន្ធ តាមរយៈការបកស្រាយទៅលើច្បាប់ពន្ធនានារបស់ក្រុមប្រឹក្សាភិបាល។ នៅពេលដែលលទ្ធផលពន្ធចុងក្រោយ ខុសគ្នាពីចំនួនដែលបានទទួលស្គាល់ដំបូង ភាពខុសគ្នានោះនឹងមានផលប៉ះពាល់ទៅលើសំវិធានធនពន្ធ នៅក្នុងការិយបរិច្ឆេទរបាយការណ៍ហិរញ្ញវត្ថុដែលការសំរេចចិត្តបានធ្វើឡើង។

*ឱនភាពនៃប្រាក់ទទួល*

ក្រុមហ៊ុនកំណត់ឱនភាពនៃប្រាក់ទទួលសមល្មម ដោយផ្អែកទៅលើការប៉ាន់ស្មានការលើការអាចស្រង់មកវិញនៃប្រាក់ទទួល។ ឱនភាពត្រូវបានអនុវត្តលើប្រាក់ទទួលនៅពេលមានប្រត្តិការ ឬការប្រែប្រួលក្នុងកាលៈទេសៈបង្ហាញឲឃើញថាតម្លៃយោងមិនអាចស្រង់មកវិញបាន។ គណៈគ្រប់គ្រងធ្វើការវិភាគជាក់លាក់ទៅលើប្រវត្តិបំណុលអាក្រក់ បណ្ដុំអតិថិជនឥណទានអតិថិជន និន្នាការសេដ្ឋកិច្ចនាពេលបច្ចុប្បន្ន និងបម្រែបម្រួលក្នុងកិច្ចសន្យាបង់នៃអតិថិជននៅពេលធ្វើការវិនិច្ឆ័យដើម្បីវាយតម្លៃឱនភាពនៃប្រាក់ទទួលសមល្មម។ ពេលមានការរំពឹងទុកខុសពីការប៉ាន់ស្មានពីដើម ភាពខុសគ្នានឹងអាចប៉ះពាល់តម្លៃយោងនៃប្រាក់ទទួល។

*ការវាស់វែងតម្លៃទីផ្សារសមរម្យ*

ក្រុមប្រឹក្សាភិបាល ប្រើបច្ចេកទេសវាយតម្លៃដើម្បីធ្វើការកំណត់តម្លៃទីផ្សារសមរម្យនៃឧបករណ៍ហិរញ្ញវត្ថុ (នៅពេលដែលតម្លៃគ្មាននៅលើទីផ្សារមូលប័ត្រ) និងទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ។ ទាំងនេះរួមបញ្ចូលការអភិវឌ្ឍ ការប៉ាន់ប្រមាណ និងការសន្មតដោយសង្គតិភាពជាមួយនឹងអ្នកចូលរួមទីផ្សារ និងអោយតម្លៃឧបករណ៍នេះ។ ក្រុមប្រឹក្សាភិបាលធ្វើការសន្មតដោយផ្អែកទៅលើស្ថិតិដែលអាចអង្កេតបាន ក៏ប៉ុន្តែស្ថិតិទាំងនេះមិនមាននៅលើទីផ្សារជានិច្ចកាលនោះទេ។ ក្នុងករណីនេះក្រុមប្រឹក្សាភិបាលប្រើស្ថិតិដែលមានល្អបំផុតដើម្បីធ្វើការសន្មត។ ការប៉ាន់ប្រមាណតម្លៃសមរម្យអាចមានភាពលម្អៀងពីតម្លៃជាក់ស្ដែង ដែលតម្លៃនេះអាចទទួលបានពីការធ្វើប្រតិបត្តិការជាធម្មតានាកាលបរិច្ឆេទរបាយការណ៍។

## ៦. ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ

| | ដីភតិសន្យារយៈពេលវែង<br>ដុល្លារអាមេរិក | សំណង់អាគារ<br>ដុល្លារអាមេរិក | រោងចក្រ និងគ្រឿងយន្ត<br>ដុល្លារអាមេរិក | យានយន្ត<br>ដុល្លារអាមេរិក | បរិក្ខារ និងកុំព្យូទ័រ<br>ដុល្លារអាមេរិក | ការសាងសង់កំពុងដំណើរការ<br>ដុល្លារអាមេរិក | សរុប<br>ដុល្លារអាមេរិក |
|---|---|---|---|---|---|---|---|
| **តម្លៃដុលក្នុងបញ្ជីគណនេយ្យ** | | | | | | | |
| សមតុល្យនាថ្ងៃទី១ ខែមករា ឆ្នាំ២០១៧ | ៣.៨៨០.០០០ | ៧.០៣២.៨៩០ | ៩.៤៥១.៦៩៧ | ៦៨.១០៩ | ៨១២.៣៩៣ | - | ២១.២៤៥.០៨៩ |
| តម្លៃបន្ថែម | - | - | **១.០៩៩.១៨០** | - | **៣០.៦៩២** | - | **១.១២៩.៨៧២** |
| សមតុល្យនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ | **៣.៨៨០.០០០** | **៧.០៣២.៨៩០** | **១០.៥៥០.៨៧៧** | **៦៨.១០៩** | **៨៤៣.០៨៥** | - | **២២.៣៧៤.៩៦១** |
| **រំលស់បង្គរ** | | | | | | | |
| សមតុល្យនាថ្ងៃទី១ ខែមករា ឆ្នាំ២០១៧ | (១៩៤.០០០) | (២.១៣២.៧៥៦) | (៣.៤៤៣.៩៩៦) | (៤៥.៣១៥) | (៥៧៧.៣៦៦) | - | (៦.៣៩៣.៤៣៣) |
| រំលស់ប្រចាំឆ្នាំ | (៣៨.៨០០) | (៤៤៨.៥៦៦) | (១.០៨៦.២០០) | (១០.៦៦១) | (៧៤.៥៩០) | - | (១.៦៥៨.៨១៧) |
| សមតុល្យនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ | **(២៣២.៨០០)** | **(២.៥៨១.៣២២)** | **(៤.៥៣០.១៩៦)** | **(៥៥.៩៧៦)** | **(៦៥១.៩៥៦)** | - | **(៨.០៥២.២៥០)** |
| **តម្លៃក្នុងបញ្ជីគណនេយ្យនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧** | **៣.៦៤៧.២០០** | **៤.៤៥១.៥៦៨** | **៦.០២០.៦៨១** | **១២.១៣៣** | **១៩១.១២៩** | - | **១៤.៣២២.៧១១** |
| **ពាន់រៀល (កំណត់សម្គាល់ ៤)** | **១៤.៧៥២.៩២៤** | **១៨.០០៦.៥៩៣** | **២៤.៣៥៣.៦៥៥** | **៤៩.០៧៨** | **៧៧៣.១១៦** | - | **៥៧.៩៣៥.៣៦៦** |

| | ដីភតិសន្យារយៈពេលវែង<br>ដុល្លារអាមេរិក | សំណង់អាគារ<br>ដុល្លារអាមេរិក | រោងចក្រ និងគ្រឿងយន្ត<br>ដុល្លារអាមេរិក | យានយន្ត<br>ដុល្លារអាមេរិក | បរិក្ខារ និងកុំព្យូទ័រ<br>ដុល្លារអាមេរិក | ការសាងសង់កំពុងដំណើរការ<br>ដុល្លារអាមេរិក | សរុប<br>ដុល្លារអាមេរិក |
|---|---|---|---|---|---|---|---|
| តម្លៃដុលក្នុងបញ្ជីគណនេយ្យ | | | | | | | |
| សមតុល្យថ្ងៃទី១ ខែមករា ឆ្នាំ២០១៦ | ៣.៨៨០.០០០ | ២.៤១១.០៧២ | ៤.៩៥០.២៣៩ | ៦៨.១០៩ | ៦៤២.៨៣៧ | ៤.៤៩២.២៧៣ | ១៦.៤៤៤.៥៣០ |
| ការទិញបន្ថែម | - | ១២៩.៥៤៥ | ៤.៥០១.៤៥៨ | - | ១៦៩.៥៥៦ | - | ៤.៨០០.៥៥៩ |
| បង្វែរ | - | ៤.៤៩២.២៧៣ | - | - | - | (៤.៤៩២.២៧៣) | - |
| សមតុល្យនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ | ៣.៨៨០.០០០ | ៧.០៣២.៨៩០ | ៩.៤៥១.៦៩៧ | ៦៨.១០៩ | ៨១២.៣៩៣ | - | ២១.២៤៥.០៨៩ |
| រំលស់បង្គរ | | | | | | | |
| សមតុល្យថ្ងៃទី១ ខែមករា ឆ្នាំ២០១៦ | (១៥៥.២០០) | (១.៦៨៤.១៩១) | (២.៤៨៤.០៦៥) | (៣៤.៤១០) | (៤៨៨.៣០៧) | - | (៤.៨៤៦.១៧៣) |
| ការទិញបន្ថែម | (៣៨.៨០០) | (៤៤៨.៥៦៥) | (៩៥៩.៩៣១) | (១០.៩០៥) | (៨៩.០៥៩) | - | (១.៥៤៧.២៦០) |
| រំលស់ប្រចាំឆ្នាំ | (១៩៤.០០០) | (២.១៣២.៧៥៦) | (៣.៤៤៣.៩៩៦) | (៤៥.៣១៥) | (៥៧៧.៣៦៦) | - | (៦.៣៩៣.៤៣៣) |
| សមតុល្យនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ | ៣.៦៨៦.០០០ | ៤.៩០០.១៣៤ | ៦.០០៧.៧០១ | ២២.៧៩៤ | ២៣៥.០២៧ | - | ១៤.៨៥១.៦៥៦ |
| ពាន់រៀល (កំណត់សម្គាល់ ៤) | ១៤.៨៨០.៣៨២ | ១៩.៧៨១.៨៤១ | ២៤.២៥៣.០៨៩ | ៩២.០១៩ | ៩៤៨.៨០៤ | - | ៥៩.៩៥៦.១៣៥ |

ការគិតរំលស់បានលៃដូចខាងក្រោម:

| | សម្រាប់ចុងការិយបរិច្ឆេទ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ | | សម្រាប់ចុងការិយបរិច្ឆេទ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ | |
|---|---|---|---|---|
| | **ដុល្លារអាមេរិក** | **គិតជាពាន់រៀល** | ដុល្លារអាមេរិក | គិតជាពាន់រៀល |
| ថ្លៃដើម | **១.៥៥៧.៩១៦** | **៦.៣០១.៧៧០** | ១.៤០៥.១០៤ | ៥.៦៧២.៤០៥ |
| ចំណាយលើរដ្ឋបាល | **១០០.៩០១** | **៤០៨.១៤៥** | ១៤២.១៥៦ | ៥៧៣.៨៨៤ |
| | **១.៦៥៨.៨១៧** | **៦.៧០៩.៩១៥** | ១.៥៤៧.២៦០ | ៦.២៤៦.២៨៩ |

## ៧ ទ្រព្យសកម្មអរូបី

| | ឆ្នាំ២០១៧ | កម្មវិធីកុំព្យូទ័រ ឆ្នាំ២០១៦ |
|---|---|---|
| | **ដុល្លារអាមេរិក** | ដុល្លារអាមេរិក |
| **តម្លៃដុលក្នុងបញ្ជីគណនេយ្យ** | | |
| សមតុល្យថ្ងៃទី ១ ខែមករា | **៦៣.៧៣៧** | ៥៨.៦០៧ |
| ការទិញបន្ថែម | **២៤.១០០** | ៥.១៣០ |
| សមតុល្យថ្ងៃទី ៣១ ខែធ្នូ | **៨៧.៨៣៧** | ៦៣.៧៣៧ |
| **រំលស់បង្គរ** | | |
| សមតុល្យថ្ងៃទី ១ ខែមករា | **(៥៣.៨៩៨)** | (៤៨.៧៥៦) |
| រំលស់ក្នុងគ្រា | **(១៥.០៩១)** | (៥.១៤២) |
| សមតុល្យថ្ងៃទី ៣១ ខែធ្នូ | **(៦៨.៩៨៩)** | (៥៣.៨៩៨) |
| **តម្លៃក្នុងបញ្ជីគណនេយ្យថ្ងៃទី ៣១ ខែធ្នូ** | **១៨.៨៤៨** | ៩.៨៣៩ |
| **តម្លៃក្នុងបញ្ជីគណនេយ្យថ្ងៃទី ៣១ ខែធ្នូ (ពាន់រៀល) (កំណត់សម្គាល់៤)** | **៧៦.២៤០** | ៣៩.៧២០ |

- កម្មវិធីកុំព្យូទ័ររួមមាន កម្មវិធីគណនេយ្យ ហើយត្រូវបានរំលស់ក្នុងរយៈពេលប្រាំឆ្នាំ ដោយប្រើវិធីសាស្ត្ររំលស់ថយចុះជាលំដាប់។
- រំលស់លើទ្រព្យសកម្មអរូបី ត្រូវបានកត់បញ្ចូលក្នុងថ្លៃដើម ព្រោះវាត្រូវបានប្រើប្រាស់ជាចម្បងនៅក្នុងសង្វាក់ផលិតកម្ម។

## ៨ សន្និធិ

| | ៣១ ខែធ្នូ ឆ្នាំ២០១៧ | | ៣១ ខែធ្នូ ឆ្នាំ២០១៦ | |
|---|---|---|---|---|
| | **ដុល្លារអាមេរិក** | **គិតជាពាន់រៀល (កំណត់សម្គាល់៤)** | ដុល្លារអាមេរិក | គិតជាពាន់រៀល (កំណត់សម្គាល់៤) |
| វត្ថុធាតុដើម | **៧.២០៤.២៣៥** | **២៩.១៤១.១៣១** | ៣.០០២.៨៤៩ | ១២.១២២.៥០២ |
| ផលិតផលពាក់កណ្ដាលសំរេច | **២.៨៧៥.៥២៧** | **១១.៦៣១.៥០៧** | ២.៨៣២.៨៧២ | ១១.៤៣៦.៣០៤ |
| ផលិតផលសំរេច | **៣.៨៧១.៥៨៨** | **១៥.៦៦០.៥៧៣** | ២.៩១៥.៦២២ | ១១.៧៧០.៣៦៦ |
| | **១៣.៩៥១.៣៥០** | **៥៦.៤៣៣.២១១** | ៨.៧៥១.៣៤៣ | ៣៥.៣២៩.១៧២ |

## ៩ គណនីអតិថិជន និងគណនីត្រូវទទួលផ្សេងៗ

| | ដុល្លារអាមេរិក | ៣១ ខែធ្នូ ឆ្នាំ២០១៧ គិតជាពាន់រៀល (កំណត់សម្គាល់៤) | ដុល្លារអាមេរិក | ៣១ ខែធ្នូ ឆ្នាំ២០១៦ គិតជាពាន់រៀល (កំណត់សម្គាល់៤) |
|---|---|---|---|---|
| **គណនីពាណិជ្ជ** | | | | |
| គណនីពាណិជ្ជត្រូវទទួលពីក្រុមហ៊ុន | | | | |
| មេសម្ព័ន្ធQMI Industrial Co..Ltd | **៤៧.៦៦៣.៣៣៣** | **១៩២.៧៩៨.១៨២** | ៥៥.៩៩២.៧៤១ | ២២៤.០២៤.១៩៦ |
| **គណនីត្រូវទទួលផ្សេងៗ** | | | | |
| គណនីត្រូវទទួលពីក្រុមហ៊ុនសម្ព័ន្ធញាតិ | | | ៧១.៣៥៩ | ២៨៨.០៧៦ |
| Success Index Group | **៦០៥.៨៥៣** | **២.៤៥០.៦៧៥** | | |
| អាករលើតម្លៃបន្ថែម | **១.៤២៩.២៥៤** | **៥.៧៨១.៣៣២** | ១.១៧៩.០៣១ | ៤.៧៥៩.៧៤៨ |
| ចំណាយបង់មុន (*) | **៤.១៣៨.៧០០** | **១៦.៧៤១.០៤២** | ៩២១.១៦១ | ៣.៧១៨.७២७ |
| | **៦.១៧៣.៨០៧** | **២៤.៩៧៣.០៤៩** | ២.១៧១.៥៥១ | ៨.៧៦៦.៥៥១ |
| | **៥៣.៨៣៧.១៤០** | **២១៧.៧៧១.២៣១** | ៥៧.៦៦៤.២៩២ | ២៣២.៧៩០.៧៤៧ |

ក	គណនីពាណិជ្ជត្រូវទទួល គឺជាគណនីមិនមានការប្រាក់ ហើយរយៈកំណត់សងគឺ ៣ខែ (២០១៦: បីខែ) ដែលត្រូវបានទទួលស្គាល់តាមតម្លៃវិក័យប័ត្រ ដែលអាចបញ្ជាក់ពីតម្លៃទីផ្សារ នៅពេលដែលទទួលស្គាល់ដំបូង។

ខ	គណនីត្រូវទទួលពីក្រុមហ៊ុនសម្ព័ន្ធញាតិ គឺទាក់ទងទៅនឹង ការផ្តល់សេវាកម្ម និងការបង់ប្រាក់ជំនួស ហើយវាមិនតំរូវអោយមានវត្ថុធានា គ្មានការប្រាក់ទេ ហើយត្រូវសងតាមតម្រូវការជាសាច់ប្រាក់ ឬសាច់ប្រាក់សមមូល។

(*)	ចំនួននេះ រួមបញ្ចូលទាំងចំណាយបង់មុនទៅក្រុមហ៊ុនសម្ព័ន្ធញាតិ Success Index Group (Cambodia) Ltd ចំនួន ១.៥៣៧.៤០៥ ដុល្លារអាមេរិក (កំណត់សម្គាល់ ២៣) សំរាប់សេវា កាត់ ដេរ និងវេចខ្ចប់។

ការវិភាគអាយុកាលនៃគណនីពាណិជ្ជត្រូវទទួលរបស់ក្រុមហ៊ុន មានដូចខាងក្រោម៖

| | ដុល្លារអាមេរិក | ៣១ ខែធ្នូ ឆ្នាំ២០១៧ គិតជាពាន់រៀល (កំណត់សម្គាល់៤) | ដុល្លារអាមេរិក | ៣១ ខែធ្នូ ឆ្នាំ២០១៦ គិតជាពាន់រៀល (កំណត់សម្គាល់៤) |
|---|---|---|---|---|
| មិនហួសរយៈពេលត្រូវសង | | | | |
| និងមិនមានឱនភាព | **៧.៧៤៣.៨៣០** | **៣១.៣២៣.៧៩៣** | ១៨.៨០៧.៨៥០ | ៧៥.៩២៧.២៩០ |
| ហួសរយៈពេលត្រូវសង | | | | |
| ប៉ុន្តែមិនមានឱនភាព | | | | |
| ពី ៩១ ដល់ ១២០ ថ្ងៃ | **១៥.០០២.០២៣** | **៦០.៦៨៣.១៨៣** | ៤.៧២៨.០៦៩ | ១៩.០៨៧.២១៥ |
| ពី ១២១ ដល់ ១៥០ ថ្ងៃ | **១១.៧៦៧.៦២៧** | **៤៧.៦០០.០៥១** | ៨.៦៥១.០៤៨ | ៣៤.៩២៤.២៨១ |
| ពី ១៥១ ដល់ ១៨០ថ្ងៃ | **៧.៦៥៣.៧៨៧** | **៣០.៩៥៩.៥៦៨** | ៨.៥៣៧.០៧៤ | ៣៤.៤៦៤.១៦៨ |
| លើសពី ១៨០ ថ្ងៃ | **៥.៤៩៦.០៦៦** | **២២.២៣១.៥៨៧** | ១៤.៧៦៨.៧០០ | ៥៩.៦២១.២៤២ |
| | **៣៩.៩១៩.៥០៣** | **១៦១.៤៧៤.៣៨៩** | ៣៦.៦៨៤.៨៩១ | ១៤៨.០៩៦.៩០៦ |
| | **៤៧.៦៦៣.៣៣៣** | **១៩២.៧៩៨.១៨២** | ៥៥.៤៩២.៧៤១ | ២២៤.០២៤.១៩៦ |

### ទឹកប្រាក់ត្រូវទទួលដែលមិនហួសរយៈពេលត្រូវសង និងមិនមានឱនភាព

គណនីអតិថិជនពាណិជ្ជកម្មដែលត្រូវទទួល ដែលមិនហួសរយៈពេលត្រូវបង់ និងមិនមានឱនភាព គឺកូនបំណុលដែលអាចទុកចិត្តបាន និងមានកេរ្តិ៍ឈ្មោះ។ កូនបំណុលទាំងនេះបានរក្សានូវទំនាក់ទំនងល្អជាមួយក្រុមហ៊ុន ហើយនៅចុងការិយបរិច្ឆេទ ពុំមានកត្តាសង្ស័យណាមួយ ដែលថាកូនបំណុលទាំងនោះ នឹងមិនបំពេញនូវ កាតព្វកិច្ចសងប្រាក់របស់ខ្លួនទេ។ ក្រុមហ៊ុនពុំមានគណនីអតិថិជនពាណិជ្ជកម្មដែលត្រូវទទួល ដែលមិនហួសរយៈពេលត្រូវសង និងមិនមានឱនភាព ដែលត្រូវបានចរចារឡើងវិញទេ នៅក្នុងការិយបរិច្ឆេទនេះ។

### ទឹកប្រាក់ត្រូវទទួលដែលហួសរយៈពេលត្រូវសង ប៉ុន្តែមិនមានឱនភាព

ឈរលើលក្ខណៈសមតុល្យ ដែលជាចំនួនទឹកប្រាក់ជំពាក់ដោយក្រុមហ៊ុនមេសម្ព័ន្ធ ដែលបានបន្តកិច្ចសន្យាលក់បន្តទៅក្រុមហ៊ុនមានកេរ្តិ៍ឈ្មោះល្អ ដូចជាសម្ព័ន្ធAdidas ក្រុមហ៊ុនReebok ក្រុមហ៊ុនTayloar Made ក្រុមហ៊ុន Salomon ក្រុមហ៊ុន New balance និងក្រុមហ៊ុនមួយចំនួនទៀត ដែលក្រុមហ៊ុនទាំងនោះត្រូវបានវាយតំលៃថាគ្មានវិបត្តិហិរញ្ញវត្ថុជាសារវន្តឡើយ។ ដូច្នេះពុំមានឱនភាពត្រូវបានកើតឡើងដែលទាក់ទិននឹងគណនីពាណិជ្ជត្រូវទទួលដែលហួសរយៈពេលត្រូវសងនោះទេ។ ទឹកប្រាក់ត្រូវទទួលទាំងនេះ គឺពុំមានទ្រព្យធានានោះទេ។

## ១០ សមតុល្យសាច់ប្រាក់ និងធនាគារ

| | ៣១ ខែធ្នូ ឆ្នាំ២០១៧ ដុល្លារអាមេរិក | ៣១ ខែធ្នូ ឆ្នាំ២០១៧ គិតជាពាន់រៀល (កំណត់សម្គាល់ ៤) | ៣១ ខែធ្នូ ឆ្នាំ២០១៦ ដុល្លារអាមេរិក | ៣១ ខែធ្នូ ឆ្នាំ២០១៦ គិតជាពាន់រៀល (កំណត់សម្គាល់ ៤) |
|---|---|---|---|---|
| សាច់ប្រាក់ក្នុងដៃ | **៦៥.៤៩៧** | **២៦៤.៩៣៥** | ៤៧.៨៥៥ | ១៩៣.១៩១ |
| សាច់ប្រាក់នៅធនាគារ | **១៦៣.០៤០** | **៦៥៩.៤៩៧** | ១.២៤៣.៣៥៥ | ៥.០១៩.៤២៤ |
| | **២២៨.៥៣៧** | **៩២៤.៤៣២** | ១.២៩១.២១០ | ៥.២១២.៦១៥ |

ការបង្ហាញពីការប្រឈមនៃរូបិយប័ណ្ណរបស់សាច់ប្រាក់និងសាច់ប្រាក់សមមូលមានដូចខាងក្រោម៖

| | ៣១ ខែធ្នូ ឆ្នាំ២០១៧ ដុល្លារអាមេរិក | ៣១ ខែធ្នូ ឆ្នាំ២០១៧ គិតជាពាន់រៀល (កំណត់សម្គាល់ ៤) | ៣១ ខែធ្នូ ឆ្នាំ២០១៦ ដុល្លារអាមេរិក | ៣១ ខែធ្នូ ឆ្នាំ២០១៦ គិតជាពាន់រៀល (កំណត់សម្គាល់ ៤) |
|---|---|---|---|---|
| ខ្មែររៀល | **១៩.៧៩៥** | **៨០.០៧១** | ៦១៨.៩០៩ | ២.៤៩៨.៥៣៦ |
| ដុល្លារអាមេរិក | **២០៨.៧៤២** | **៨៤៤.៣៦១** | ៦៧២.៣០១ | ២.៧១៤.០៧៩ |
| | **២២៨.៥៣៧** | **៩២៤.៤៣២** | ១.២៩១.២១០ | ៥.២១២.៦១៥ |

## ១១ ដើមទុន

| | ៣១ ខែធ្នូ ឆ្នាំ២០១៧ ចំនួនភាគហ៊ុន | ៣១ ខែធ្នូ ឆ្នាំ២០១៧ ដុល្លារអាមេរិក | ៣១ ខែធ្នូ ឆ្នាំ២០១៦ ចំនួនភាគហ៊ុន | ៣១ ខែធ្នូ ឆ្នាំ២០១៦ ដុល្លារអាមេរិក |
|---|---|---|---|---|
| ភាគហ៊ុនធម្មតា មានតម្លៃ០.២៥ដុល្លារអាមេរិកក្នុងមួយភាគហ៊ុន | | | | |
| ភាគហ៊ុនដែលបានអនុញ្ញាតិអោយបោះផ្សាយ | **២០០.០០០.០០០** | **៥០.០០០.០០០** | ២០០.០០០.០០០ | ៥០.០០០.០០០ |
| បានបោះផ្សាយនិងបង់រួច | **៤០.០០០.០០០** | **១០.០០០.០០០** | ៤០.០០០.០០០ | ១០.០០០.០០០ |
| បានបោះផ្សាយនិងបង់រួច ពាន់រៀល (កំណត់សម្គាល់៤) | | **៤០.៤៥០.០០០** | | ៤០.៣៧០.០០០ |

## ១២ បុព្វលាភភាគហ៊ុន

បុព្វលាភភាគហ៊ុនបង្ហាញពីសាច់ប្រាក់លើស ដែលទទួលបានដោយសារភាពខុសគ្នារវាងតម្លៃចារិករបស់ភាគហ៊ុន និងតម្លៃដាក់លក់របស់ភាគហ៊ុនចំនួន ១.១២៣.៨១០ ភាគហ៊ុនទៅអោយសាធារណៈជនសញ្ជាតិខ្មែរ និង ៦.៨៧៦.១៩០ ភាគហ៊ុនទៅអោយវិនិយោគិនដែលបានជ្រើសរើសដែលមានតម្លៃចារិក០.២៥ ដុល្លារអាមេរិក ក្នុងមួយភាគហ៊ុន ហើយភាគហ៊ុននីមួយៗត្រូវបានលក់ក្នុងតម្លៃ ២.៤១ ដុល្លារអាមេរិក នាថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៤។

## ១៣ គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម និងគណនីត្រូវបង់ផ្សេងៗ

| | | មិនបានធ្វើសវនកម្ម<br>៣១ ធ្នូ ២០១៧<br>ពាន់រៀល<br>(កំណត់សម្គាល់៤) | | បានធ្វើសវនកម្ម<br>៣១ ធ្នូ ២០១៦<br>ពាន់រៀល<br>(កំណត់សម្គាល់៤) |
|---|---|---|---|---|
| | ដុល្លារអាមេរិក | | ដុល្លារអាមេរិក | |
| **រយៈពេលវែង** | | | | |
| គណនីត្រូវបង់ផ្សេងៗ | **២.២៨៩.៤០០** | **៩.២៦០.៦២៣** | ២.២៥០.០០០ | ៩.០៨៣.២៥០ |
| | | | | |
| **រយៈពេលខ្លី** | | | | |
| គណនីត្រូវបង់ទៅក្រុមហ៊ុនមេសម្ព័ន្ធ៖ | | | | |
| QMI Industrial Co.. Ltd. | **១.៥២៨.៧៤៤** | **៦.១៨៣.៧៦៩** | - | - |
| បង្គរ | **១.១៦៤.៦០៣** | **៤.៧១០.៨១៩** | ២.៣៥៩.៣១១ | ៩.៥២៤.៥៣៩ |
| ពន្ធកាត់ទុកត្រូវបង់ | **៣៩៥.៥២៣** | **១.៥៩៩.៨៩១** | ៣៩៥.៥២៣ | ១.៥៩៦.៧២៦ |
| គណនីត្រូវបង់ផ្សេងៗ | **៧១២.៤២០** | **២.៨៨១.៧៣៩** | ៣៨៤.៧៣៥ | ១.៥៥៣.១៧៥ |
| | **៣.៨០១.២៩០** | **១៥.៣៧៦.២១៨** | ៣.១៣៩.៥៦៩ | ១២.៦៧៤.៤៤០ |
| | **៦.០៩០.៦៩០** | **២៤.៦៣៦.៨៤១** | ៥.៣៨៩.៥៦៩ | ២១.៧៥៧.៦៩០ |

ទឹកប្រាក់ដែលជំពាក់ទៅក្រុមហ៊ុនមេសម្ព័ន្ធ គឺជាទឹកប្រាក់បុរេប្រទានដែលបានទទួលក្នុងឆ្នាំសម្រាប់ក្រុមហ៊ុនប្រើប្រាស់នៅក្នុងប្រតិបត្តិការរបស់ខ្លួន។ ចំនួនទឹកប្រាក់នេះ មិនមានវត្ថុធានា មិនមានការប្រាក់ និងបំណុលត្រូវបង់តាមតម្រូវការ។

## ១៤ កម្ចី

| | | ៣១ ខែធ្នូ ឆ្នាំ២០១៧<br>គិតជាពាន់រៀល<br>(កំណត់សម្គាល់៤) | | ៣១ ខែធ្នូ ឆ្នាំ២០១៦<br>គិតជាពាន់រៀល<br>(កំណត់សម្គាល់៤) |
|---|---|---|---|---|
| | ដុល្លារអាមេរិក | | ដុល្លារអាមេរិក | |
| កម្ចីរយៈពេលវែង | | | | |
| ធនាគារតៃវ៉ាន់ខូអបភើរេធីវ (កំណត់សម្គាល់ ១៤.២) | **២.៦០២.២៨៧** | **១០.៥២៦.២៥១** | - | - |
| កម្ចីរយៈពេលខ្លី | | | | |
| ធនាគារពាណិជ្ជទីមួយ (កំណត់សម្គាល់ ១៤.១) | **៤.០០០.០០០** | **១៦.១៨០.០០០** | ៦.៤០០.០០០ | ២៥.៨៣៦.៨០០ |
| ធនាគារតៃវ៉ាន់ខូអបភើរេធីវ(កំណត់សម្គាល់ ១៤.២) | **៣៦៤.៦១៥** | **១.៤៧៤.៨៦៨** | - | - |
| | **៤.៣៦៤.៦១៥** | **១៧.៦៥៤.៨៦៨** | ៦.៤០០.០០០ | ២៥.៨៣៦.៨០០ |
| | **៦.៩៦៦.៩០២** | **២៨.១៨១.១១៩** | ៦.៤០០.០០០ | ២៥.៨៣៦.៨០០ |

### ១៤.១ ប្រាក់កម្ចីជាមួយធនាគារពាណិជ្ជទីមួយ

យោងតាមកិច្ចសន្យាកម្ចីប្រាក់ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៦ ក្រុមហ៊ុនត្រូវបានផ្តល់នូវកម្ចីរយៈពេលខ្លី ដែលមានទឹកប្រាក់ចំនួន៦.៤លានដុល្លារអាមេរិក (បង្វិល) ដោយធនាគារពាណិជ្ជទីមួយសាខាភ្នំពេញ។ រយៈពេលនៃការផ្តល់ប្រាក់កម្ចីមានរយៈពេល មួយឆ្នាំ ហើយកាលបរិច្ឆេទកំណត់ត្រូវបានបញ្ជាក់នៅក្នុងលិខិតធានានីមួយៗ។ អត្រាការប្រាក់ប្រចាំគឺ អត្រាការប្រាក់អថេរសម្រាប់រយៈពេលប្រាំមួយខែរបស់ LIBOR បូក ៤.២% ≥ ៥%។ ការប្រាក់ត្រូវបានគណនាតាមមូលដ្ឋាន ៣៦០ ថ្ងៃក្នុងមួយឆ្នាំនិងត្រូវបង់ប្រចាំខែ។

កម្ចីត្រូវបានបន្តនៅថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៧ សម្រាប់រយៈពេល ១ឆ្នាំ។ ការប្រាក់ប្រចាំឆ្នាំគឺ អត្រាការប្រាក់អថេរសម្រាប់រយៈពេលប្រាំមួយខែរបស់ LIBOR បូក ៣.៨%≥ ៥%។ អត្រាការប្រាក់ត្រូវបានគណនាលើមូលដ្ឋានចំនួន ៣៦០ ថ្ងៃ ក្នុងមួយឆ្នាំ ហើយការប្រាក់នេះត្រូវបង់ប្រចាំខែ។

កម្ចីរយៈពេលខ្លី ត្រូវបានធានាដូចខាងក្រោម៖

ក. លិខិតធានាដោយ លោក យ៉ាង សាវស៊ីន (Yang Shaw Shin) នាយកក្រុមប្រឹក្សាភិបាល
ខ. កម្ចីដំបូងទៅលើដីធ្លី ដែលកាន់កាប់ដោយ លោក យ៉ាង សាវស៊ីន ជាមួយនឹងប័ណ្ណសម្គាល់ដីធ្លីលេខ ១២០៥០៥០១-០១១៩ ធ្វើឡើងថ្ងៃទី៩ ខែមេសា ឆ្នាំ២០១៣ ទីតាំងស្ថិតនៅ ភូមិជម្ពូវ័ន្ត ត្រពាំងពោធិ៍ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា និង
គ. រាល់ទ្រព្យសកម្មបច្ចុប្បន្ន និងអនាគតរបស់ក្រុមហ៊ុន។

នាកាលបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ ប្រាក់កម្ចីដែលមិនទាន់បានទូទាត់ជាមួយធនាគារពាណិជ្ជទីមួយមានចំនួន ៤.០០០.០០០ ដុល្លារអាមេរិក។

### ១៤.២ ប្រាក់កម្ចីជាមួយធនាគារតៃវ៉ាន់ខូអបភើរេធីវ

ក្រុមហ៊ុនបានចុះកិច្ចសន្យាខ្ចីប្រាក់ពីធនាគារតៃវ៉ាន់ខូអបភើរេធីវ នៅថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ២០១៧ ដែលមានទឹកប្រាក់ចំនួន ៣លាន ដុល្លារអាមេរិក សម្រាប់រយៈពេល ៨៤ខែ រាប់គិតចាប់ពីថ្ងៃដកប្រាក់លើកដំបូង។ នៅថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៧ និងថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១៧ ក្រុមហ៊ុនបានដកប្រាក់ចំនួន ២លានដុល្លារអាមេរិក និង ១លាន ដុល្លារអាមេរិក ជាបន្តបន្ទាប់។ គិតត្រឹមដំណាច់ការិយបរិច្ឆេទនេះ ក្រុមហ៊ុនបានបង់ប្រាក់ថ្លៃដើមចំនួន ៣៣.០៩៨ ដុល្លារអាមេរិក។

អត្រាការប្រាក់ប្រចាំឆ្នាំគឺអត្រាការប្រាក់អថេរសម្រាប់រយៈពេលប្រាំមួយខែរបស់ LIBOR + ៣.៥៧៩៥% បច្ចុប្បន្នគឺ ៤.៩៩៩៩%។ អត្រាការប្រាក់ប្រចាំថ្ងៃត្រូវបានគណនានៅលើមូលដ្ឋាននៃការគណនា ៣៦០ ថ្ងៃ នៅក្នុងមួយឆ្នាំហើយត្រូវបានគិតជារៀងរាល់ថ្ងៃ រាប់គិតចាប់ពីថ្ងៃដកប្រាក់លើកដំបូង ហើយនឹងត្រូវគិតការប្រាក់ចំនួន ៣៦៥ ថ្ងៃ នៅក្នុងមួយឆ្នាំ។ ការបង់ប្រាក់ត្រូវបង់ជារៀងរាល់ខែរាប់គិតចាប់ពីថ្ងៃដកប្រាក់លើកដំបូង។

កម្ចីរយៈពេលវែង ត្រូវបានធានាដូចខាងក្រោម៖

ក. លិខិតធានាដោយ លោក យ៉ាង សាវស៊ីន (Yang Shaw Shin) នាយកក្រុមប្រឹក្សាភិបាល
ខ. លំដាប់ទីមួយនៃហ៊ីប៉ូតែកលើអចលនវត្ថុដូចមានរៀបរាប់ខាងក្រោម (រួមមានទាំងដី និងសំណង់) លេខប័ណ្ណសម្គាល់សិទ្ធកាន់កាប់អចលនវត្ថុ តក ០០៥៣១៥ (Ixii ០០១៩/២១០៩០៩០៨-០០០១) ចុះថ្ងៃទី

២៧ ខែកុម្ភៈ ឆ្នាំ២០១៤ មានទំហំដី ២២៦.៦៩៧ម$^{២}$ ដែលមានទីតាំងនៅ ភូមិចមពល ឃុំពពេល ស្រុកត្រាំកក់ ខេត្តតាកែវ ព្រះរាជាណាចក្រកម្ពុជាលេខប័ណ្ណសម្គាល់សិទ្ធកាន់កាប់អចលនវត្ថុ តក ០០៥៣៦៦ (lxii ០០២០/២១០៩០៩០៨-០០០២) ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៤ មានទំហំដី ១៤.៨៧១ម$^{២}$ ដែលមានទីតាំងនៅ ភូមិចមពល ឃុំពពេល ស្រុកត្រាំកក់ ខេត្តតាកែវ ព្រះរាជាណាចក្រកម្ពុជា។

## ១៥ ចំណូល

| | **សម្រាប់ចុងការិយបរិច្ឆេទថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០១៧** | | សម្រាប់ចុងការិយបរិច្ឆេទថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០១៦ | |
|---|---|---|---|---|
| | **ដុល្លារអាមេរិក** | **គិតជាពាន់រៀល (កំណត់សម្គាល់៤)** | ដុល្លារអាមេរិក | គិតជាពាន់រៀល (កំណត់សម្គាល់៤) |
| ការលក់ទំនិញ | **៨៣.៧០៤.៦៣៤** | **៣៣៨.៥៨៥.២៤៥** | ៨១.៧៧០.១៧៣ | ៣៣០.១០៦.១៨៨ |
| កាត់ ដេរ និងវេចខ្ចប់ | **១.៥៣៥.៦២៣** | **៦.២១១.៥៩៥** | ២៦៤.៤៤៩ | ១.០៦៧.៥៨១ |
| ប្រាក់ចំណូលម៉ៅការបន្ត | - | - | ៥៧.៨៤៩ | ២៣៣.៥៣៦ |
| | **៨៥.២៤០.២៥៧** | **៣៤៤.៧៩៦.៨៤០** | ៨២.០៩២.៤៧១ | ៣៣១.៤០៧.៣០៥ |
| អប្បហារលក់ | **(៥.១៤៤.៤៨១)** | **(២០.៨០៩.៤២៦)** | - | - |
| | **៨០.០៩៥.៧៧៦** | **៣២៣.៩៨៧.៤១៤** | ៨២.០៩២.៤៧១ | ៣៣១.៤០៧.៣០៥ |

## ១៦ ថ្លៃដើម

| | **សម្រាប់ចុងការិយបរិច្ឆេទថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០១៧** | | សម្រាប់ចុងការិយបរិច្ឆេទថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០១៦ | |
|---|---|---|---|---|
| | **ដុល្លារអាមេរិក** | **គិតជាពាន់រៀល (កំណត់សម្គាល់៤)** | ដុល្លារអាមេរិក | គិតជាពាន់រៀល (កំណត់សម្គាល់៤) |
| វត្ថុធាតុដើម | **៤៧.៦៥៧.៤៨៧** | **១៩២.៧៧៤.៥៣៥** | ៤៦.៤៣៩.៩២៣ | ១៨៧.៤៧៧.៩៦៩ |
| ពលកម្មផ្ទាល់ | **១២.១៨៥.៧០០** | **៤៩.២៩១.១៥៧** | ១១.៦៩៥.៨២៨ | ៤៧.២១៦.០៥៨ |
| ចំណាយផ្សេងៗ | **១៣.៥៣៩.០៦៤** | **៥៤.៧៦៥.៥១៣** | ១៣.៦៩៨.៩៩១ | ៥៥.៣០២.៨២៦ |
| | **៧៣.៣៨២.២៥១** | **២៩៦.៨៣១.២០៥** | ៧១.៨៣៤.៧៤២ | ២៨៩.៩៩៦.៨៥៣ |

## ១៧ ចំណាយរដ្ឋបាល

| | **សម្រាប់ចុងការិយបរិច្ឆេទថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០១៧** | | សម្រាប់ចុងការិយបរិច្ឆេទថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០១៦ | |
|---|---|---|---|---|
| | **ដុល្លារអាមេរិក** | **គិតជាពាន់រៀល (កំណត់សម្គាល់៤)** | ដុល្លារអាមេរិក | គិតជាពាន់រៀល (កំណត់សម្គាល់៤ ) |
| ចំណាយលើស្រាវជ្រាវ និងអភិវឌ្ឍន៍ | **១.៤០៥.៦៨៩** | **៥.៦៨៦.០១២** | ១.៦៤១.៦៤២ | ៦.៦២៧.៣០៩ |
| ចំណាយបុគ្គលិក | **១.៣៧១.៣៦០** | **៥.៥៤៧.១៥១** | ១.២៤០.៨១៨ | ៥.០០៩.១៨២ |
| ចំណាយលើការរំលស់ | **១០០.៩០១** | **៤០៨.១៤៥** | ១៤២.១៥៦ | ៥៧៣.៨៨៤ |
| ចំណាយលើសម្ភារៈការិយាល័យ | **១០០.៧៥៤** | **៤០៧.៥៥០** | ១១៣.៥១៨ | ៤៥៨.២៧២ |

| | | | | |
|---|---|---|---|---|
| ចំណាយលើសេវាវិជ្ជាជីវៈ | **៩៣.២៦៩** | **៣៧៧.២៧៣** | ១២៤.៨៦១ | ៥០៤.០៦៤ |
| ចំណាយលើការជួសជុល និងថែរក្សា | **៥៨.៣៩៦** | **២៣៦.២១២** | ២៧.០៩១ | ១០៩.៣៦៦ |
| ចំណាយលើពន្ធនិងផ្សេងៗ | **៤២.៥៤៥** | **១៧២.០៩៥** | ៣៨.៥២៦ | ១៥៥.៥២៩ |
| ចំណាយប្រៃសណីយ៍ | **៣៩.១៨៩** | **១៥៨.៥២០** | ៣៩.៤០៧ | ១៥៩.០៨៧ |
| ចំណាយលើការធ្វើដំណើរ | **៣២.៤៥៨** | **១៣១.២៩៣** | ១៤.៧១០ | ៥៩.៣៨៤ |
| ចំណាយលើធានារ៉ាប់រងទ្រព្យសកម្ម | **២៥.៩៨៨** | **១០៥.១២១** | ២៥.៩៥៦ | ១០៤.៧៨៤ |
| ចំណាយលើការជួលបរិក្ខារ | **១៤.៨៩៥** | **៦០.២៥០** | ១២.១៥៦ | ៤៩.០៧៤ |
| ចំណាយលើការកំសាន្ត | **១០.៩១០** | **៤៤.១៣១** | ៣៣.១៦២ | ១៣៣.៨៧៥ |
| ចំណាយលើទឹក និងភ្លើង | **៣.៦០០** | **១៤.៥៦២** | ៣.៦០០ | ១៤.៥៣៣ |
| ចំណាយលើការបរិច្ចាក | **៤៤៦** | **១.៨០៤** | ១.១៩៧ | ៤.៨៣៣ |
| ចំណាយផ្សេងៗ | **៣១៩.៧០០** | **១.២៩៣.១៨៦** | ៣៥៨.១២៥ | ១.៤៤៣.៩៦០ |
| | **៣.៦២០.១០០** | **១៤.៦៤៣.៣០៥** | ៣.៨១៦.៩២៥ | ១៥.៤០៨.៩២៦ |

## ១៨ ចំណាយលើការដឹកជញ្ជូន

| | **ដុល្លារអាមេរិក** | **សម្រាប់ចុងការិយបរិច្ឆេទថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០១៧ គិតជាពាន់រៀល (កំណត់សម្គាល់៤)** | ដុល្លារអាមេរិក | សម្រាប់ចុងការិយបរិច្ឆេទថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០១៦ គិតជាពាន់រៀល (កំណត់សម្គាល់៤) |
|---|---|---|---|---|
| ថ្លៃពន្ធគយ និងឯកសារ | **១.៤៥១.៣៥៤** | **៥.៨៧០.៧២៧** | ១.៤៩៩.៤៣៣ | ៦.០៥៣.២១១ |
| ថ្លៃដឹកជញ្ជូនចេញ | **១៨៨.៩៤៣** | **៧៦៤.២៧៤** | ៩៨៨.៤៧៩ | ៣.៩៩០.៤៩០ |
| | **១.៦៤០.២៩៧** | **៦.៦៣៥.០០១** | ២.៤៨៧.៩១២ | ១០.០៤៣.៧០១ |

## ១៩ ចំណាយហិរញ្ញប្បទាន

ចំនួននេះតំណាងអោយចំណាយការប្រាក់លើកម្ចីដែលនៅសល់។

## ២០ ពន្ធ

### ២០.១ ចំណាយ(អត្ថប្រយោជន៍) ពន្ធលើប្រាក់ចំណូល

ផ្អែកលើច្បាប់ស្តីពីសារពើពន្ធរបស់ព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុនមានកាតព្វកិច្ចក្នុងការបង់ពន្ធលើប្រាក់ចំណូលក្នុងអត្រា ២០% លើប្រាក់ចំណេញជាប់ពន្ធ ឬ ពន្ធអប្បបរមាក្នុងអត្រានៃផលរបបសរុប ចំពោះជម្រើសណាមួយដែលធំជាង។ ក្រុមហ៊ុនបានទទួលការលើកទឹកចិត្តពន្ធលើប្រាក់ចំណេញ ដោយបន្ថយពន្ធនៅត្រឹម ១០% នៃពន្ធលើប្រាក់ចំណេញដែលត្រូវបង់ស្របតាមអគ្គនាយកដ្ឋានពន្ធដារ សម្រាប់រយៈពេលបីឆ្នាំ ចាប់ពី ២០១៤ រហូតដល់ ២០១៦។

ពន្ធអប្បបរមា គឺត្រូវបានគណនាក្នុងអត្រា១%នៃផលរបបសរុបដែលរួមបញ្ចូលពន្ធទាំងអស់។ ពន្ធអប្បបរមាបានពន្យាពេលបណ្តោះអាសន្ន រហូតដល់ចុងឆ្នាំ ២០២២ ដោយយោងតាមប្រកាសលេខ ១១៣០.ក.ស. ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៧ ចេញដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

លិខិតប្រកាសពន្ធរបស់ក្រុមហ៊ុន ត្រូវត្រួតពិនិត្យដោយអាជ្ញាធរពន្ធដារ។ ដោយសារតែការដាក់ពាក្យ និងការតាក់តែងច្បាប់ពន្ធមានច្រើនប្រភេទ ហើយងាយនឹងបកស្រាយខុស ដូច្នេះចំនួនដែលបានកត់ត្រានៅក្នុងរបាយការណ៍ហិរញ្ញវត្ថុអាចនឹងមានការផ្លាស់ប្តូរនាពេលបន្ទាប់ នៅពេលដែលអាជ្ញាធរពន្ធដារបានធ្វើការត្រួតពិនិត្យ។

តួលេខផ្ទៀងផ្ទាត់រវាង ប្រាក់ចំណេញមុនបង់ពន្ធតាមគណនេយ្យ និងប្រាក់ចំណេញជាប់ពន្ធប៉ាន់ស្មានរបស់ក្រុមហ៊ុនសម្រាប់ចុងការិយបរិច្ឆេទ ៣១ ខែធ្នូ ឆ្នាំ២០១៧ និង២០១៦ មានដូចខាងក្រោម៖

| | **សម្រាប់ចុងការិយបរិច្ឆេទថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០១៧** | | សម្រាប់ចុងការិយបរិច្ឆេទថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០១៦ | |
|---|---|---|---|---|
| | **ដុល្លារអាមេរិក** | **គិតជាពាន់រៀល (កំណត់សម្គាល់៤)** | ដុល្លារអាមេរិក | គិតជាពាន់រៀល (កំណត់សម្គាល់៤) |
| ប្រាក់ចំណេញមុនពេលបង់ពន្ធ | **១.១៦៩.២៣២** | **៤.៧២៩.៥៤៤** | ៣.៨៥៣.៣១៤ | ១៥.៥៥៥.៨២៨ |
| ប្រាក់ពន្ធគណនាតាមអត្រាពន្ធស្របច្បាប់ ២០% (២០១៦:២០%) | **២៣៣.៨៤៦** | **៩៤៥.៩០៧** | ៧២៥.២៣៦ | ២.៩២៧.៧៧៨ |
| ផលប៉ះពាល់នៃ ៖ | | | | |
| ចំណាយដែលមិនអាចកាត់កងបាន | **២.៣៩៥** | **៩.៦៨៨** | ២១.១៦៩ | ៨៥.៤៥៩ |
| ពន្ធលើកទឹកចិត្ត | - | - | (៣៨៥.៣៣១) | (១.៥៥៥.៥៨១) |
| សំវិធានធនលើសនៃពន្ធលើប្រាក់ចំណេញក្នុងឆ្នាំមុនៗ | - | - | (១.៧៩៥.៣៦០) | (៧.២៤៧.៨៦៩) |
| ចំណាយប្រាក់ពន្ធក្នុងគ្រា (អត្ថប្រយោជន៍) | **២៣៦.២៤១** | **៩៥៥.៥៩៥** | (១.៤៣៤.២៨៦) | (៥.៧៩០.២១៣) |
| ចំណាយពន្ធពន្យា | **២៧២.៩១៤** | **១.១០៣.៩៣៧** | ៤៥.៤២៧ | ១៨៣.៣៨៩ |
| ចំណាយ(អត្ថប្រយោជន៍)ពន្ធលើប្រាក់ចំណូល | **៥០៩.១៥៥** | **២.០៥៩.៥៣២** | (១.៣៨៨.៨៥៩) | (៥.៦០៦.៨២៤) |

## ២០.២ បំណុលពន្ធលើប្រាក់ចំណេញ

| | | **៣១ ខែធ្នូ ឆ្នាំ២០១៧** | | ៣១ ខែធ្នូ ឆ្នាំ២០១៦ |
|---|---|---|---|---|
| | **ដុល្លារអាមេរិក** | **គិតជាពាន់រៀល (កំណត់សម្គាល់៤)** | ដុល្លារអាមេរិក | គិតជាពាន់រៀល (កំណត់សម្គាល់៤) |
| គណនីដើមគ្រា | **២.៨១២.៤៧៧** | **១១.៣៥៣.៩៧០** | ៤.៣២០.៧៨៤ | ១៧.៤៤៣.០០៥ |
| ចំណាយពន្ធលើប្រាក់ចំណូល | **២៣៦.២៤១** | **៩៥៥.៥៩៥** | ៣៦១.០៧៤ | ១.៤៥៧.៦៥៦ |
| ពន្ធលើប្រាក់ចំណូលបានបង់រួច | **(១.៦៤៧.០០៩)** | **(៦.៦៦២.១៥១)** | (៧៤.០២១) | (២៩៨.៨២៣) |
| សំវិធានធនលើសនៃពន្ធលើប្រាក់ចំណូល ក្នុងឆ្នាំមុនៗ | - | - | (១.៧៩៥.៣៦០) | (៧.២៤៧.៨៦៨) |
| ភាពលម្អៀងពីការប្តូររូបិយប័ណ្ណ | - | **២២.៤៩៩** | - | - |
| | **១.៤០១.៧០៩** | **៥.៦៦៩.៩១៣** | ២.៨១២.៤៧៧ | ១១.៣៥៣.៩៧០ |

## ២០.៣ បំណុលពន្ធពន្យា

បម្រែបម្រួលនៃបំណុលពន្ធពន្យាទៅលើ ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ ព្រមទាំងទ្រព្យសកម្មអរូបី ក្នុងកំឡុងការិយបរិច្ឆេទគណនេយ្យ មានដូចខាងក្រោម៖

| | **៣១ ខែធ្នូ ឆ្នាំ២០១៧** | | ៣១ ខែធ្នូ ឆ្នាំ២០១៦ | |
|---|---|---|---|---|
| | **ដុល្លារអាមេរិក** | **គិតជាពាន់រៀល (កំណត់សម្គាល់៤)** | ដុល្លារអាមេរិក | គិតជាពាន់រៀល (កំណត់សម្គាល់៤) |
| សមតុល្យដើមគ្រា | **៤៥.៦៦៤** | **១៨៤.៣៤៦** | ២៣៧ | ៩៥៧ |
| កត់ត្រាក្នុងគណនីចំណេញ ឬខាត (កំណត់សម្គាល់ ២០.១) | **២៧២.៩១៤** | **១.១០៣.៩៣៧** | ៤៥.៤២៧ | ១៨៣.៣៨៩ |
| ភាពលម្អៀងពីការប្តូររូបិយប័ណ្ណ | - | **៣៦៤** | - | - |
| | **៣១៨.៥៧៨** | **១.២៨៨.៦៤៧** | ៤៥.៦៦៤ | ១៨៤.៣៤៦ |

## ២០.៤ យថាភាពលើពន្ធ

នាកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមហ៊ុនពុំទាន់ទទួលបានលិខិតជូនដំណឹងពីការកំណត់ពន្ធឡើងវិញ សម្រាប់ការិយបរិច្ឆេទគណនេយ្យពីថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ រហូតដល់ឆ្នាំ ២០១៧។

ប្រព័ន្ធពន្ធដារនៅព្រះរាជាណាចក្រកម្ពុជា មានសភាពថ្មីហើយពន្ធត្រូវបានបែងចែកជាច្រើនប្រភេទនិងបទបញ្ញត្តមានការផ្លាស់ប្តូរញឹកញាប់ដែលជាធម្មតាពុំមានភាពច្បាស់លាស់ មានភាពផ្ទុយគ្នា និងពឹងផ្អែកនៃការបកស្រាយ។ ជាញឹកញាប់ការបកស្រាយខុសគ្នាៗជាច្រើនទៅកើតមាននោះឡើងក្នុងចំនោមអាជ្ញាធរពន្ធដារ និងយុត្តាធិការ។ ពន្ធដារគឺជាកម្មវត្ថុនៃការពិនិត្យឡើងវិញ និងការសង្កេតដោយភ្នាក់ងារពន្ធដារផ្សេងៗជាច្រើន ដែលមានសមត្ថកិច្ចក្នុងការផាកពិន័យធ្ងន់ធ្ងរនិងពិន័យលើការប្រាក់។ កត្តាទាំងនេះហើយដែលអាចធ្វើឲ្យមានហានិភ័យពន្ធដារនៅក្នុងព្រះរាជាណាចក្រកម្ពុជាខ្លាំងជាងប្រទេសដទៃទៀត។ ថ្នាក់ដឹកនាំមានការជឿជាក់ថា ខ្លួនបានធ្វើសំវិធានធនបំណុលពន្ធគ្រប់គ្រាន់ដោយផ្អែកលើការបកស្រាយបទបញ្ញត្តិពន្ធរបស់ខ្លួន។ ទោះបីយ៉ាងនេះក្តី សមត្ថកិច្ចពន្ធពាក់ព័ន្ធអាចការបកស្រាយខុសៗគ្នា ហើយអាចធ្វើឲ្យមានផលប៉ះពាល់ជាសារវ័ន្ត។

## ២១ ភាគលាភ

| | **សម្រាប់ចុងការិយបរិច្ឆេទថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០១៧** | | | សម្រាប់ចុងការិយបរិច្ឆេទថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០១៦ | | |
|---|---|---|---|---|---|---|
| | **ភាគលាភក្នុងមួយភាគហ៊ុន** | **ភាគលាភសរុប** | | ភាគលាភក្នុងមួយភាគហ៊ុន | | ភាគលាភសរុប |
| | **រៀល** | **ពាន់រៀល** | **ដុល្លារអាមេរិក** | រៀល | ពាន់រៀល | ដុល្លារអាមេរិក |
| ភាគលាភបានទូទាត់រួច | **១០០** | **៤.០០០.០០០** | **១.០០០.០០០** | ៥៤ | ២.១៦០.០០០ | ៥៤០.០០០ |

នៅថ្ងៃទី២០ ខែមិថុនាឆ្នាំ ២០១៧ ក្រុមប្រឹក្សាភិបាលបានអនុម័តការប្រកាសភាគលាភសម្រាប់ការិយបរិច្ឆេទ ៣១ ធ្នូ ២០១៦ ដែលមានចំនួន ១០០ រៀល ក្នុងមួយហ៊ុន ដែលស្មើនឹងភាគលាភសរុបចំនួន ៤.០០០ លានរៀល។ ភាគលាភត្រូវបានទូទាត់ជាបន្តបន្ទាប់នៅថ្ងៃទី ១៤ ខែកក្កដាឆ្នាំ ២០១៧ ។

## ២២ ចំណេញក្នុងមួយភាគហ៊ុន

| | សម្រាប់ចុងការិយបរិច្ឆេទថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០១៧ | | សម្រាប់ចុងការិយបរិច្ឆេទថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០១៦ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | គិតជាពាន់រៀល (កំណត់សម្គាល់៤) | ដុល្លារអាមេរិក | គិតជាពាន់រៀល (កំណត់សម្គាល់៤) |
| ចំណេញសម្រាប់ផ្តល់ដល់ភាគហ៊ុនិកធម្មតា | ៦៥០.៥១០ | ២.៦៣១.៣១៤ | ៥.២៤២.១៧៣ | ២១.១៦២.៦៥២ |
| ចំនួនភាគហ៊ុនធម្មតាដែលបានដាក់លក់គិតជាមធ្យម | ៤០.០០០.០០០ | ៤០.០០០.០០០ | ៤០.០០០.០០០ | ៤០.០០០.០០០ |
| ចំណេញក្នុងមួយភាគហ៊ុនគោល | ០.០២ | ០.០៧ | ០.១៣ | ០.៥៣ |
| ចំណេញក្នុងមួយភាគហ៊ុនថយចុះ | ០.០២ | ០.០៧ | ០.១៣ | ០.៥៣ |

ចំណេញក្នុងមួយភាគហ៊ុនថយចុះ ត្រូវបានគណនាដោយទូទាត់ចំនួនភាគហ៊ុនធម្មតាដែលមិនទាន់បានដាក់លក់គិតជាមធ្យម ដើម្បីសន្មតការប្រែសម្រួលនៃរាល់ភាគហ៊ុនធម្មតាដែលអាចធ្លាក់តម្លៃ។

ក្រុមហ៊ុនមិនមានភាគហ៊ុនធម្មតាដែលអាចធ្លាក់តម្លៃទេក្នុងការិយបរិច្ឆេទនេះ។ ដូច្នេះ ចំណេញក្នុងមួយភាគហ៊ុនថយចុះ មានតម្លៃស្មើ ចំណេញក្នុងមួយភាគហ៊ុនគោល។

## ២៣ សមតុល្យ និងប្រតិបត្តិការជាមួយសម្ព័ន្ធញាតិ

ក្រុមហ៊ុនមានសមតុល្យជាមួយនឹងសម្ព័ន្ធញាតិដូចខាងក្រោម៖

| | ទំនាក់ទំនង | ៣១ ខែធ្នូ ឆ្នាំ២០១៧ ដុល្លារអាមេរិក | ៣១ ខែធ្នូ ឆ្នាំ២០១៧ ពាន់រៀល (កំណត់សម្គាល់៤) | ៣១ ខែធ្នូ ឆ្នាំ២០១៦ ដុល្លារអាមេរិក | ៣១ ខែធ្នូ ឆ្នាំ២០១៦ ពាន់រៀល (កំណត់សម្គាល់៤) |
|---|---|---|---|---|---|
| **គណនីអតិថិជនពាណិជ្ជកម្ម** | | | | | |
| **សមតុល្យដែលជំពាក់ពីក្រុមហ៊ុន៖** | | | | | |
| QMI Industrial Co. Ltd | ក្រុមហ៊ុនមេសម្ព័ន្ធ | ៤៧.៧៨១.៤៩៧ | ១៩៣.២៧៦.១៥៥ | ៥៥.៤៩២.៧៤១ | ២២៤.០២៤.១៩៥ |
| Success Index Group | ក្រុមហ៊ុនក្រោមការគ្រប់គ្រងតែមួយ | ៦០៥.៨៥៣ | ២.៤៥០.៦៧៥ | ៧១.៣៥៩ | ២៨៨.០៧៦ |
| | | ៤៨.៣៨៧.៣៥០ | ១៩៥.៧២៦.៨៣០ | ៥៥.៥៦៤.១០០ | ២២៤.៣១២.២៧១ |
| **គណនីត្រូវទទួលផ្សេងៗ** | | | | | |
| **ប្រាក់បង់មុន** | | | | | |
| Success Index Group | ក្រុមហ៊ុនក្រោមការគ្រប់គ្រងតែមួយ | ១.៥៣៧.៤០៥ | ៦.២១៨.៨០៣ | - | - |
| **គណនីត្រូវបង់ផ្សេងៗ** | | | | | |
| **បុរេប្រទានពីក្រុមហ៊ុន៖** | | | | | |
| QMI Industrial Co. Ltd. | ក្រុមហ៊ុនមេសម្ព័ន្ធ | ១.៥២៨.៣៤៤ | ៦.១៨៣.៧៦៩ | - | - |

សមតុល្យដែលនៅសល់ គឺមិនទាមទារវត្ថុធានា មិនមានការប្រាក់ និងគ្មានរយៈពេលសងច្បាស់លាស់។

ក្រុមហ៊ុនមានប្រតិបត្តិការជាមួយនឹងក្រុមហ៊ុនសម្ព័ន្ធញាតិក្នុងការិយបរិច្ឆេទនេះដូចខាងក្រោម៖

| | **សម្រាប់ចុងការិយបរិច្ឆេទថ្ងៃទី ៣១ ធ្នូ ២០១៧** | | សម្រាប់ចុងការិយបរិច្ឆេទថ្ងៃទី ៣១ ធ្នូ ២០១៦ | |
|---|---|---|---|---|
| | **ដុល្លារអាមេរិក** | **ពាន់រៀល (កំណត់សម្គាល់៤)** | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់៤) |
| **ក្រុមហ៊ុនមេសម្ព័ន្ធ** | | | | |
| QMI Industrial Co. Ltd. | | | | |
| លក់ | **៨០.០៩៥.៧៧៦** | **៣២៣.៩៨៧.៤១៤** | ៨១.៧៧០.១៧៣ | ៣៣០.១០៦.១៨៨ |
| ទិញ | **៤៨.៩៣៥.៩០៣** | **១៩៧.៩៤៥.៧២៦** | ៤៦.០១៦.៣៣៤ | ១៨៥.៧៦៧.៩៤២ |
| ប្រាក់ប្រមូលបាន | **៣៧.៦៦៧.៩៦០** | **១៥២.៣៦៦.៨៩៨** | ៣០.៣២៩.០០០ | ១២២.៤៣៨.១៧២ |
| ប្រាក់ទូទាត់ | **២១១.២៩១** | **៨៥៤.៦៧៣** | - | - |
| អប្បហារលក់ | **៥.១៤៤.៤៨១** | **២០.៨០៩.៤២៦** | - | - |
| កាត់កងជាមួយគណនីពាណិជ្ជកម្មត្រូវបង់ | **៤៨.៧២៤.៦១១** | **១៩៧.០៩១.០៥៣** | ៤៦.០១៦.៣៣៤ | ១៨៥.៧៦៧.៩៤២ |
| ការបង់ជំនួស | **៦៥៦.៤៦៦** | **២.៦៥៥.៤០៥** | ៩៩៣.២៩៧ | ៤.០០៩.៩៤០ |
| កាត់កងជាមួយគណនីត្រូវបង់ផ្សេងៗ | **៦៦១.១០១** | **២.៦៧៤.១៥២** | ២.១៦៣.១៣០ | ៨.៧៣២.៥៦០ |
| បុរេប្រទានទៅក្រុមហ៊ុន | **៥៨៧.០០០** | **២.៣៧៤.៤១៥** | - | - |
| ទូទាត់សងបុរេប្រទានដោយក្រុមហ៊ុន | **៥៣៧.០០០** | **២.១៧២.១៦៥** | - | - |
| **ក្រុមហ៊ុនក្រោមការគ្រប់គ្រងតែមួយ** | | | | |
| Success Index Group | | | | |
| កម្រៃសេវាកម្ម (កាត់ ដេរ និងវេចខ្ចប់) | **១.៥៣៥.៦២៣** | **៦.២១១.៥៩៤** | ២៦៤.៤៤៩ | ១.០៦៧.៥៨២ |
| ការបង់ជំនួស | - | - | ២២.៨០៧ | ៩២.០៧២ |
| កាត់កងជាមួយគណនីត្រូវបង់ផ្សេងៗ | **១.០០១.១២៩** | **៤.០៤៩.៥៦៦** | - | - |
| បុរេប្រទានដោយក្រុមហ៊ុន | **៤.២៦៩.៩៣១** | **១៧.២៧១.៨៧២** | - | - |
| ការទូទាត់សងបុរេប្រទានដោយក្រុមហ៊ុន | **២.៧៣២.៥២៦** | **១១.០៥៣.០៦៨** | - | - |
| QMI Industrial (Shanghai) Limited | | | | |
| បុរេប្រទានដោយក្រុមហ៊ុន | - | - | ១០៤.៤៧៧ | ៤២១.៧៧៤ |
| ការទូទាត់សងបុរេប្រទានដោយក្រុមហ៊ុន | - | - | ១០៤.៤៧៧ | ៤២១.៧៧៤ |

## ២៤ ប្រតិបត្តិការជាមួយគណៈគ្រប់គ្រងសំខាន់ៗ

គណៈគ្រប់គ្រងសំខាន់ៗ (ដូចជា ប្រធាន នាយកប្រតិបត្តិ នាយកហិរញ្ញវត្ថុ និងអភិបាល) ទទួលបានប្រាក់បំណាច់នាការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ ចំនួន ៨១.២០០ ដុល្លារអាមេរិក (២០១៦៖ ៨១.២០០ ដុល្លារអាមេរិក)។

## ២៥ កិច្ចសន្យាមូលធន

នាចុងការិយបរិច្ឆេទ ក្រុមហ៊ុនមានកិច្ចសន្យាមូលធនសម្រាប់ការសាងសង់អគារការិយាល័យស្រាវជ្រាវថ្មី ជាមួយ ក្រុមហ៊ុន TACC (C.R) Ltd ដែលមានទឹកប្រាក់ចំនួន ៤.៩០៩.៧៨០ដុល្លារអាមេរិក (៣១ ខែធ្នូ ឆ្នាំ២០១៦៖ ៦.៨០៩.៧៨០ ដុល្លារអាមេរិក)។

## ២៦ កម្មវត្ថុ និងគោលការណ៍នៃការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ

កម្មវត្ថុនៃការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុរបស់ក្រុមហ៊ុនគឺ ដើម្បីបង្កើនប្រសិទ្ធភាពតម្លៃសម្រាប់ភាគហ៊ុនិក ហើយទន្ទឹមគ្នានេះក៏ដើម្បីកាត់បន្ថយសក្តានុពលនៃផលប៉ះពាល់មិនល្អ ដែលអាចកើតឡើងដោយសារការប្រែប្រួលនៃទីផ្សារហិរញ្ញវត្ថុ។

ក្រុមប្រឹក្សាភិបាលមានទំនួលខុសត្រូវលើការកំណត់កម្មវត្ថុនេះ និងគោលការណ៍មូលដ្ឋាននៃ ការគ្រប់គ្រងហានិភ័យ ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន។ ក្រុមប្រឹក្សាភិបាល បង្កើតគោលការណ៍លម្អិតដូចជា កម្រិតសិទ្ធិអំណាច ត្រួតពិនិត្យការទទួលខុសត្រូវ ការកំណត់ និងវាស់វែងអត្តសញ្ញាណហានិភ័យ និងកំណត់ផលប៉ះពាល់ ដោយអនុលោមតាមកម្មវត្ថុ និងគោលការណ៍មូលដ្ឋានដែលបានអនុម័តដោយក្រុមប្រឹក្សាភិបាល។

ចំណុចធំៗនៃហានិភ័យហិរញ្ញវត្ថុ ដែលក្រុមហ៊ុនត្រូវប្រឈម និងគោលការណ៍នៃចំណុចសំខាន់ៗ នៃសកម្មភាពចំបងៗ មានចែងដូចខាងក្រោម៖

## ២៦.១ ហានិភ័យឥណទាន

ហានិភ័យឥណទាន គឺជាការខាតបង់ផ្នែកហិរញ្ញវត្ថុរបស់ក្រុមហ៊ុនដោយសមភាគីមិនបានបំពេញកាតព្វកិច្ចដូចមានចែងក្នុងកិច្ចសន្យា។ ក្រុមហ៊ុនប្រឈមនឹងហានិភ័យឥណទានភាគច្រើនពីការលក់ជំពាក់។ វាជាគោលការណ៍របស់ក្រុមហ៊ុន ដែលត្រូវត្រួតពិនិត្យជាប្រចាំទៅលើស្ថានភាពហិរញ្ញវត្ថុរបស់សមភាគី ដើម្បីធានាថា ក្រុមហ៊ុនប្រឈមនឹងហានិភ័យឥណទានតិចបំផុត។

ហានិភ័យឥណទានដែលក្រុមហ៊ុនងាយរងផលប៉ះពាល់ គឺតាមរយៈគណនីពាណិជ្ជត្រូវទទួល។ អាយុកាលឥណទានរបស់ក្រុមហ៊ុនមានរយៈពេល ៣ខែ ហើយក្រុមហ៊ុនព្យាយាមធ្វើការគ្រប់គ្រងយ៉ាងដិតដល់លើគណនីត្រូវទទួលដែលមិនទាន់ប្រមូលដើម្បីកាត់បន្ថយហានិភ័យឥណទានអោយទាបបំផុត។

សមតុល្យដែលហួសកាលកំណត់ត្រូវពិនិត្យឡើងវិញអោយបានទៀងទាត់ដោយគណៈគ្រប់គ្រង។

<u>សាច់ប្រាក់ និងសាច់ប្រាក់សមមូល</u>

ហានិភ័យឥណទានសម្រាប់សាច់ប្រាក់ និងសាច់ប្រាក់សមមូល ត្រូវបានចាត់ទុកថាជាការធ្វេសប្រហែស ពីព្រោះធនាគារក្នុងស្រុកដែលមានកេរ្តិ៍ឈ្មោះ។

## ២៦.២ ហានិភ័យសាច់ប្រាក់ងាយស្រួល និងលំហូរសាច់ប្រាក់

ហានិភ័យសាច់ប្រាក់ងាយស្រួល និងលំហូរសាច់ប្រាក់ កើតឡើងពីការគ្រប់គ្រងរបស់ក្រុមហ៊ុនទៅលើមូលធនបង្វិល។ វាគឺជាហានិភ័យមួយដែលក្រុមហ៊ុននឹងជួបប្រទះផលលំបាកក្នុងការបំពេញនូវកាតព្វកិច្ចហិរញ្ញវត្ថុ នៅពេលដែលដល់កាលកំណត់ត្រូវសង។

ក្រុមហ៊ុនគ្រប់គ្រងយ៉ាងសកម្មលើរយៈកាលកំណត់របស់បំណុលចាស់ៗ លំហូរសាច់ប្រាក់ពីប្រតិបត្តិការ និងភាពមានស្រាប់នៃមូលនិធិ ដើម្បីធានាអោយបាននូវរាល់តម្រូវការប្រតិបត្តិការវិនិយោគនិងហិរញ្ញប្បទាន។ នៅក្នុងយុទ្ធសាស្ត្រ នៃការគ្រប់គ្រងហានិភ័យសាច់ប្រាក់ងាយស្រួល ក្រុមហ៊ុនធ្វើការរក្សានូវកម្រិតសាច់ប្រាក់ និងសាច់ប្រាក់សមមូលអោយបានគ្រប់គ្រាន់សម្រាប់គាំទ្រដល់សកម្មភាពប្រតិបត្តិការរបស់ក្រុមហ៊ុន។

ការវិភាគលើ បំណុលហិរញ្ញវត្ថុ ដែលបង្ហាញពីរយៈពេលកំណត់ត្រូវសងដោយមិនធ្វើអប្បហារ មានដូចខាងក្រោម៖

| | **តាមតម្រូវការ ឬ ក្នុងរយៈពេល ១ឆ្នាំ** | **ពី ១ឆ្នាំទៅ ៥ឆ្នាំ** | **លើសពី ៥ឆ្នាំ** | **សរុប** | |
|---|---|---|---|---|---|
| | **ដុល្លារអាមេរិក** | **ដុល្លារអាមេរិក** | **ដុល្លារអាមេរិក** | **ដុល្លារអាមេរិក** | **ពាន់រៀល** |
| **នាថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០១៧** | | | | | |
| កម្ចី | ៤.៣៦៤.៦១៥ | ២.១៤៨.១១៤ | ៤៥៤.១៧៣ | ៦.៩៦៦.៩០២ | ២៨.១៨១.១១៩ |
| គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម និងគណនីអ្នកផ្គត់ផ្គង់ផ្សេងៗ | ៣.៨០១.២៩០ | ១.៨០០.០០០ | ៤៨៩.៤០០ | ៦.០៩០.៦៩០ | ២៤.៦៣៦.៨៤១ |
| | **៨.១៦៥.៩០៥** | **៣.៩៤៨.១១៤** | **៩៤៣.៥៧៣** | **១៣.០៥៧.៥៩២** | **៥២.៨១៧.៩៦០** |

| | តាមតម្រូវការ ឬ ក្នុងរយៈពេល ១ឆ្នាំ | ពី ១ឆ្នាំទៅ ៥ឆ្នាំ | លើសពី ៥ឆ្នាំ | សរុប | |
|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ពាន់រៀល |
| នាថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០១៦ | | | | | |
| កម្ចី | ៦.៤០០.០០០ | - | - | ៦.៤០០.០០០ | ២៥.៨៣៦.៨០០ |
| គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម និងគណនីអ្នកផ្គត់ផ្គង់ផ្សេងៗ | ៣.១៣៩.៥៦៩ | ១.៨០០.០០០ | ៤៥០.០០០ | ៥.៣៨៩.៥៦៩ | ២១.៧៥៧.៦៩ 0 |
| | ៩.៥៣៩.៥៦៩ | ១.៨០០.០០០ | ៤៥០.០០០ | ១១.៧៨៩.៥៦៩ | ៤៧.៥៩៤.៤៥០ |

## ២៦.៣ ហានិភ័យអត្រាការប្រាក់

ហានិភ័យអត្រាការប្រាក់គឺជាហានិភ័យដែលតម្លៃទីផ្សារ ឬលំហូរសាច់ប្រាក់នាពេលអនាគត នៃឧបករណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនអាចនឹងប្រែប្រួលដោយសារតែការប្រែប្រួលរបស់អត្រាការប្រាក់ទីផ្សារ។

ការប្រឈមមុខរបស់ក្រុមហ៊ុនទៅនឹងហានិភ័យអត្រាការប្រាក់ គឺទាក់ទងនឹងកម្ចី។ ក្រុមហ៊ុនគ្រប់គ្រងហានិភ័យអត្រាការប្រាក់របស់ខ្លួន ដោយត្រួតពិនិត្យយ៉ាងយកចិត្តទុកលើបំណុលទីផ្សារ ហើយសំខាន់ជាងនេះទៀតគឺ រក្សាអោយបានការលាយឡំគ្នារបស់អត្រាថេរ និងអត្រាអថេររបស់កម្ចីដោយប្រុងប្រយ័ត្ន។ ក្រុមហ៊ុនពុំបានប្រើប្រាស់ដេរីវេឧបករណ៍ហិរញ្ញវត្ថុដើម្បីកាត់បន្ថយហានិភ័យរបស់ប្រាក់បំណុលដែលត្រូវសងនោះទេ។

### ការវិភាគលើរំញោចនៃហានិភ័យការប្រាក់

តារាងខាងក្រោមបង្ហាញពី ការវិភាគលើរំញោចនៃអត្រាការប្រាក់របស់ក្រុមហ៊ុន នាចុងការិយបរិច្ឆេទ ដោយឈរលើគោលការណ៍បម្រែបម្រួល 0.១% និងកត្តាអថេរផ្សេងទៀត ដែលមិនមានការប្រែប្រួល៖

| | **សម្រាប់ចុងការិយបរិច្ឆេទថ្ងៃទី ៣១ ធ្នូ ២០១៧** | | សម្រាប់ចុងការិយបរិច្ឆេទថ្ងៃទី ៣១ ធ្នូ ២០១៦ | |
|---|---|---|---|---|
| | **ដុល្លារអាមេរិក** | **គិតជាពាន់រៀល (កំណត់សម្គាល់៤)** | ដុល្លារអាមេរិក | គិតជាពាន់រៀល (កំណត់សម្គាល់៤) |
| **ផលចំណេញបន្ទាប់ពីកាត់ពន្ធ** | | | | |
| - កំណើន 0.១% (២០១៦:0.១%) | **(១៨៧)** | **(៧៥៦)** | (៣.៦៩២) | (១៤.៩០៥) |
| - តំហយ 0.១% (២០១៦:0.១%) | **១៨៧** | **៧៥៦** | ៣.៦៩២ | ១៤.៩០៥ |

### ២៦.៤ ហានិភ័យរូបិយប័ណ្ណបរទេស

ហានិភ័យរូបិយប័ណ្ណបរទេសរបស់ក្រុមហ៊ុនកើតមានឡើងដោយសារប្រតិបត្តិការដែលបានប្រើប្រាស់រូបិយប័ណ្ណបរទេស។

នាការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ ផលប៉ះពាល់របស់ក្រុមហ៊ុនទៅលើហានិភ័យដែលជាធម្មតាកើតឡើងដោយសារអត្រាប្តូរប្រាក់របស់រូបិយប័ណ្ណបរទេសមានតិចតួច ពីព្រោះប្រតិបត្តិការភាគច្រើនប្រើប្រាស់ជា ដុល្លារអាមេរិក។

## ២៧ ការគ្រប់គ្រងមូលធន

កម្មវត្ថុបឋមរបស់ក្រុមហ៊ុនក្នុងការគ្រប់គ្រងមូលធនគឺ ដើម្បីធានាបានថា ក្រុមហ៊ុនអាចបន្តប្រតិបត្តិការរបស់ខ្លួនដោយឈរលើមូលដ្ឋាននិរន្តភាពនៃដំណើរការអាជីវកម្ម ហើយស្របពេលជាមួយគ្នានេះ ធ្វើអោយមានកំណើនផលលាភដល់ភាគហ៊ុនិក តាមរយៈការធ្វើអោយប្រសើរឡើងនូវអនុបាតបំណុល និងមូលធន។ ពុំមានការផ្លាស់ប្តូរយុទ្ធសាស្រ្តទូទៅរបស់ក្រុមហ៊ុនទេ។

ក្រុមហ៊ុនបានរៀបចំហេដ្ឋារចនាសម្ព័ន្ធ និងធ្វើនិយ័តកម្មលើមូលធនរបស់ខ្លួន ដើម្បីឆ្លើយតបទៅនឹងការផ្លាស់ប្តូរនៃលក្ខខណ្ឌសេដ្ឋកិច្ច។ ដើម្បីរក្សា និងធ្វើនិយ័តកម្មហេដ្ឋារចនាសម្ព័ន្ធលើមូលធន ក្រុមហ៊ុនអាចធ្វើនិយ័តកម្មលើការចំណាយភាគលាភទៅលើភាគហ៊ុនិក បង្វិលភាគហ៊ុនអោយទៅភាគហ៊ុនិក ឬបោះផ្សាយភាគហ៊ុនថ្មី។ ពុំមានការប្រែ ប្រួលលើកម្មវត្ថុ គោលនយោបាយ ឬដំណើរការផ្សេងៗទេ នៅក្នុងការិយបរិច្ឆេទគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ និង ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦។

ក្រុមហ៊ុនគ្រប់គ្រង និងថែរក្សាដោយប្រុងប្រយ័ត្ននូវបំណុលសរុប និងធានាអោយបាននូវអនុលោមភាពនៃតម្រូវការមូលធនផ្ទៃក្រៅ។

## ២៨ តម្លៃទីផ្សារសមរម្យ

### ២៨.១ ការវាស់វែងតម្លៃទីផ្សារសមរម្យនៃឧបករណ៍ហិរញ្ញវត្ថុ

ទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុត្រូវបានប៉ាន់ស្មានក្នុងតម្លៃទីផ្សារសមរម្យ នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុដែលនឹងត្រូវបានរួមបញ្ចូលទៅក្នុងវាងក្រុមទាំងបីកម្រិតនៃតម្លៃសមរម្យ។ ឋានានុក្រមទាំងបីកម្រិតទាំងបី ត្រូវបានកំណត់ដោយការអង្កេតលើធាតុចូលសំខាន់ៗដើម្បីវាស់វែង ដូចខាងក្រោម៖

- កម្រិតទី ១ : តម្លៃដកស្រង់ (មិនទាន់ធ្វើនិយ័តកម្ម) ចេញពីទីផ្សារសកម្មសម្រាប់ទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុស្រដៀងគ្នា
- កម្រិតទី ២ : ទិន្នន័យដែលមិនមែនជាតម្លៃដកស្រង់ ដែលមាននៅក្នុងកម្រិតទី១ ដែលអាចធ្វើការអង្កេតសម្រាប់ទ្រព្យសកម្ម ឬបំណុលហិរញ្ញវត្ថុ ទោះបីដោយផ្ទាល់ ឬដោយប្រយោល
- កម្រិតទី ៣ : ទិន្នន័យសម្រាប់ទ្រព្យសកម្ម ឬបំណុលហិរញ្ញវត្ថុ ដែលមិនអាស្រ័យទៅលើទិន្នន័យអង្កេតទីផ្សារ (ធាតុចូលដែលមិនអាចអង្កេតបាន) ។

### ២៨.២ វិធីសាស្រ្ត និងការសន្មត់ប្រើដើម្បីប៉ាន់ស្មានតម្លៃទីផ្សារសមរម្យ

តម្លៃទីផ្សារសមរម្យរបស់ទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុត្រូវបានដូចខាងក្រោម៖

(១) ឧបករណ៍ហិរញ្ញវត្ថុដែលមិនបានគិតតាមតម្លៃទីផ្សារ ហើយតម្លៃពិតគណនេយ្យមានភាពសមរម្យ ឬប្រហាក់ប្រហែលនឹងតម្លៃទីផ្សារ។ តម្លៃយោងពិតគណនេយ្យរបស់ទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុដូចជា គណនីអតិថិជនពាណិជ្ជកម្ម និងគណនីត្រូវទទួលផ្សេងៗ គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម និងគណនីត្រូវបង់ផ្សេងៗ និងប្រាក់កម្ចីប្រហាក់ប្រហែលនឹងតម្លៃទីផ្សារ ដោយសារតែរយៈពេលខ្លី ឬនៅជិតថ្ងៃនៃចុងការិយបរិច្ឆេទ។

(២) គណនីត្រូវបង់រយៈពេលវែង តម្លៃទីផ្សាររបស់ឧបករណ៍ហិរញ្ញវត្ថុទាំងនេះ ត្រូវបានប៉ាន់ស្មានតាមរយៈការធ្វើអប្បហារ លំហូតសាច់ប្រាក់នាពេលអនាគត តាមអត្រាកម្ចីកើនឡើងរបស់ទីផ្សារសម្រាប់ប្រភេទឧបករណ៍ហិរញ្ញវត្ថុស្រដៀងនៅចុងការិយបរិច្ឆេទ។

## ២៩ ព្រឹត្តិការណ៍បន្ទាប់ពីចុងគ្រារាយការណ៍

មិនមានព្រឹត្តិការណ៍កែសម្រួល និងព្រឹត្តិការណ៍មិនកែសម្រួលសំខាន់ៗណាមួយ បានកើតឡើងចន្លោះរវាងថ្ងៃបរិច្ឆេទរបាយការណ៍ ៣១ ខែធ្នូ ឆ្នាំ២០១៧ និងថ្ងៃដែលបានអនុម័តអោយប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុនោះទេ។

## ៣០ ការអនុម័តនៃរបាយការណ៍ហិរញ្ញវត្ថុ

របាយការណ៍ហិរញ្ញវត្ថុសម្រាប់ចុងការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ នេះត្រូវបានអនុម័តដោយក្រុមប្រឹក្សាភិបាលនៅថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៨។

# ៨.ទំនាក់ទំនង និងប្រតិបត្តិការ ជាមួយភាគីពាក់ព័ន្ធ

## ១ -ប្រតិបត្តិការជាមួយភាគហ៊ុនិក ដោយបញ្ជាក់ពីឈ្មោះភាគហ៊ុនិក ប្រភេទប្រតិបត្តិការ និងកាលបរិច្ឆេទ

### ភតិសន្យាជួលអចិន្ត្រៃយ៍ជាមួយលោក យ៉ាង សាវស៊ីន

លោក យ៉ាង សាវស៊ីន ដែលជាភាគហ៊ុនិក និងជាប្រធានក្រុមប្រឹក្សាភិបាលក្រុមហ៊ុន ហ្គ្រេន ធ្វីន សញ្ជាតិខ្មែរ មានអត្តសញ្ញាណប័ណ្ណខ្មែរលេខ០១០០៣៥៨៤៩ ចុះកាលបរិច្ឆេទថ្ងៃទី២៥ ខែកក្កដាឆ្នាំ២០០១ និងលិខិតឆ្លងដែនខ្មែរលេខ N០៥៧៩៦១៦ ចុះកាលបរិច្ឆេទថ្ងៃទី០៦ ខែមីនា ឆ្នាំ២០០៨។ លោកស្នាក់នៅអាសយដ្ឋានផ្ទះលេខ១០២ ផ្លូវលេខ៥៩២ សង្កាត់បឹងកក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

ភតិសន្យានេះ គឺជាកិច្ចព្រមព្រៀងជួលដីអចិន្ត្រៃយ៍ដែលរោងចក្រផលិតកម្មស្ថិតនៅ។ ភតិសន្យានេះបានចុះកាលបរិច្ឆេទថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១២ រវាងប្រធានក្រុមប្រឹក្សាភិបាលក្រុមហ៊ុន ហ្គ្រេន ធ្វីន លោក យ៉ាង សាវស៊ីន ដែលកាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ០១០០៣៥៨៤៩ ជាភតិបតី និងក្រុមហ៊ុនជា ភតិកៈ។

យោងទៅតាមកិច្ចព្រមព្រៀង ទ្រព្យភតិសន្យា គឺជាចំណែកនៃដីដែលមានទំហំប្រមាណ ៣២.២៤១ (បីម៉ឺនពីរពាន់ពីររយសែសិបមួយ) ម៉ែត្រការ៉េ មានអាសយដ្ឋានស្ថិតនៅភូមិត្រពាំងពោធិ៍ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ សម្គាល់ដោយវិញ្ញាបនប័ត្រកាន់កាប់អចលនវត្ថុលេខភព០០០៧៧ ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ១៩៩៧ និង ភព០០៥២៥ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ១៩៩៧ បានចុះនៅក្រោមឈ្មោះលោក យ៉ាង សាវស៊ីន។

ភតិសន្យានេះមានថេរវេលា ៥០ (ហាសិប) ឆ្នាំ អាចត្រូវបានពន្យាពេលបន្តដោយស្វ័យប្រវត្តិចំនួន ៥០ (ហាសិប) ឆ្នាំបន្ថែមទៀត ដោយចាប់ផ្តើមពីថ្ងៃ៣១ ខែមីនា ឆ្នាំ២០១២ រហូតដល់ ថ្ងៃ៣០ ខែមីនា ឆ្នាំ២០៦២ ។ ថ្លៃឈ្នួលសរុបនៃដីភតិសន្យារយៈពេលវែង គឺចំនួន ១៥.៥២០ លាន រៀល (៣.៨៨ លាន ដុល្លារអាមេរិក)។ បន្ទាប់ពីការចុះហត្ថលេខាលើភតិសន្យានេះភតិបតីនឹងយកតម្លៃជួលដីមកដាក់ចូលជាដើមទុនសម្រាប់ការបង្កើនដើមទុនរបស់ភតិកៈ។

យោងតាមភតិសន្យានេះ ភតិកៈមានសិទ្ធិកាន់កាប់ ប្រើប្រាស់ ផ្ទេរ ជួលបន្តផ្នែកទាំងអស់ឬផ្នែកណាមួយនៃដី។ យោងតាមប្រការ៩ នៃភតិសន្យានេះ ជាថ្នូរនឹងការផ្តល់ថ្លៃឈ្នួល ភតិបតីបានផ្តល់សិទ្ធអោយភតិកៈជម្រើសក្នុងការទិញដីក្នុងតម្លៃមួយដុល្លារអាមេរិក។ ជម្រើសក្នុងការទិញអាចត្រូវបានអនុវត្តដោយភតិកៈនៅពេលណាក៏បានក្នុងអំឡុងថេរវេលា ឬថេរវេលាពន្យានៃភតិសន្យា ដោយអនុលោមទៅតាមច្បាប់ដែលពាក់ព័ន្ធ។

## ២ - ប្រតិបត្តិការសំខាន់ៗជាមួយអភិបាល ឬបុគ្គលិកជាន់ខ្ពស់ ឬប្រតិបត្តិការសំខាន់ៗជាមួយបុគ្គលដែលអភិបាល ឬបុគ្គលិកជាន់ខ្ពស់មានផលប្រយោជន៍

ដោយឡែក សម្រាប់ឆ្នាំ២០១៧ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ ប្រតិបត្តិការសំខាន់ៗ របស់ក្រុមហ៊ុន ហ្គ្រេន ធ្វីន ជាមួយអភិបាល ឬបុគ្គលិកជាន់ខ្ពស់ ឬបុគ្គលដែលអភិបាល ឬបុគ្គលិកជាន់ខ្ពស់មានផលប្រយោជន៍ជាមួយ រួមមាន៖

### ការធានាផ្ទាល់ខ្លួនរបស់ប្រធានក្រុមប្រឹក្សាភិបាល លោក យ៉ាង សាវស៊ីន

លោក យ៉ាង សាវស៊ីន ដែលជាភាគហ៊ុនិក និងជាប្រធានក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន ហ្គ្រេន ធ្វីន បានផ្តល់ការធានាផ្ទាល់ខ្លួនរួមគ្នាសម្រាប់កិច្ចសន្យាខ្ចីប្រាក់ពីធនាគារ៖

| ល.រ | ធនាគារ/ ហរិញ្ញករ | ប្រភេទនៃកម្ចី | ចំនួន (គិតជាដុល្លារអាមេរិក | អ្នកធានា | វត្ថុបញ្ចាំ |
|---|---|---|---|---|---|
| ១ | ធនាគារពាណិជ្ជកម្មទីមួយ សាខាភ្នំពេញ | កម្ចីរយៈពេលខ្លីមួយឆ្នាំ(បង្វិល) ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៦ | ៦.៤០០.០០០ | លោក យ៉ាង សាវស៊ីន | វិញ្ញាបនប័ត្រកាន់កាប់អចលនវត្ថុ ១២០៥៥០១០១១៩ |
| ២ | ធនាគារ តៃវ៉ាន់ខូអបភើរេធី | កម្ចីរយៈពេលវែង សម្រាប់រយៈពេល ៨៤ ខែ ថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១៧ | ៣.០០០.០០០ | លោក យ៉ាង សាវស៊ីន | វិញ្ញាបនប័ត្រកាន់កាប់អចលនវត្ថុ ០០៥៣១៥ (lxii ០០១៩/២១០៩០៩០៨-០០០១) និង តក ០០៥៣៦៦ (lxii ០០២០/២១០៩០៩០៨-០០០២ |

លោក យ៉ាង សាវស៊ីន បានចេញលិខិតធានា សម្រាប់កិច្ចសន្យាកម្ចីប្រាក់ចុះកាលបរិច្ឆេទថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៦ (លិខិតធានា) ក្នុងការផ្តល់ការធានាផ្ទាល់ខ្លួន ដើម្បីទទួលបានកម្ចីរយៈពេលខ្លីរយៈពេល ០១ (មួយ) ឆ្នាំ ដែល មានទឹកប្រាក់ ៦,៤ លាន ដុល្លារអាមេរិក (បង្វិល) ជូនក្រុមហ៊ុន ហ្គ្រេន ធ្វីន ពីធនាគារពាណិជ្ជកម្មទីមួយ (ធនាគារ) សាខា ភ្នំពេញ កិច្ចសន្យាខ្ចីបានចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៥ (កិច្ចសន្យាខ្ចីប្រាក់)។ កម្ចីត្រូវបានបន្តនៅថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៧ សម្រាប់រយៈពេល ១ឆ្នាំ។ នាកាលបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ ប្រាក់កម្ចីដែលមិនទាន់បានទូទាត់ជាមួយធនាគារពាណិជ្ជទីមួយ មានចំនួន ៤ លាន ដុល្លារអាមេរិក។

លោកក៏បានចេញធានាលើកិច្ចសន្យាកម្ចីប្រាក់ចុះកាលបរិច្ឆេទថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១៧ ផងដែរ ក្នុងការផ្តល់ការធានា ផ្ទាល់ខ្លួនដើម្បីទទួលបានកម្ចីរយៈពេលវែង ៨៤ ខែ ដែលមានទឹកប្រាក់ចំនួន ៣ លាន ដុល្លារអាមេរិក (បង្វិល) ជូនក្រុមហ៊ុន ពីធនាគារ តៃវ៉ាន់ ខូអបភើរេធីវ កិច្ចសន្យាខ្ចីបានចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១៧ (កិច្ចសន្យាខ្ចីប្រាក់)។

យោងតាមលិខិតធានា លោក យ៉ាង សាវស៊ីន បានធានាថានឹង ទូទាត់ប្រាក់គ្រប់ចំនួន និងទាន់ពេលវេលា តាមចំនួនទឹកប្រាក់ដែលត្រូវសងដោយក្រុមហ៊ុន ហ្គ្រេន ធ្វីន ក្រោមកិច្ចព្រមព្រៀងខ្ចីប្រាក់ ចំពោះប្រាក់ជំពាក់ទាំងឡាយ កាតព្វកិច្ច និងបំណុលទាំងអស់របស់ក្រុមហ៊ុន ហ្គ្រេន ធ្វីន ព្រមទាំងធ្វើការទូទាត់សង ចំនួនប្រាក់ដើមដែលនៅជំពាក់បូករួមជាមួយនិងការប្រាក់ត្រូត ព្រមទាំងសោហ៊ុយចំណាយ និងកម្រៃផ្សេងៗក្រោមកិច្ចព្រមព្រៀងខ្ចីប្រាក់ក្នុងកំឡុងពេល ៦ (ប្រាំមួយ) ខែ ក្រោយមានការទាមទារពីធនាគារជាលាយលក្ខណ៏អក្សរ។

## ៣ - ប្រតិបត្តិការសំខាន់ៗជាមួយសមាជិកគ្រួសារផ្ទាល់របស់អភិបាល និងបុគ្គលិកជាន់ខ្ពស់

សមាជិកគ្រួសារផ្ទាល់ រួមមាន ប្តី ប្រពន្ធ កូន ឪពុកម្តាយ បងប្អូនប្រុស ឬបងប្អូនស្រីរបស់អភិបាល បុគ្គលិកជាន់ខ្ពស់ ឬភាគហ៊ុនិកដែលមានភាគហ៊ុនចាប់ពី ៥% ឡើងទៅ នៃមូលបត្រកម្មសិទ្ធិ ។

សម្រាប់ការិយបរិច្ឆេទឆ្នាំ២០១៧ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ ក្រុមហ៊ុន ហ្គ្រេន ធ្វីន ពុំមានប្រតិបត្តិការ ណាមួយជាមួយសមាជិកគ្រួសារផ្ទាល់របស់អភិបាល បុគ្គលិកជាន់ខ្ពស់ និងបុគ្គលដែលមានភាគហ៊ុនចាប់ពី ០៥ (ប្រាំ) ភាគរយឡើងទៅទេ។

**៤ - ប្រតិបត្តិការសំខាន់ៗជាមួយបុគ្គលដែលមានទំនាក់ទំនងជាមួយអភិបាលរបស់បុគ្គលបោះផ្សាយ ក្រុមហ៊ុនបុត្រសម្ព័ន្ធ ឬ ក្រុមហ៊ុនហូលឌីងរបស់បុគ្គលបោះផ្សាយ ដែលទំនាក់ទំនងរបស់បុគ្គលទាំងនោះកើតមាននៅក្នុងប្រតិបត្តិការ ឬការចាត់ចែង ណាមួយដែលធ្វើឡើងដោយបុគ្គលបោះផ្សាយ**

ប្រតិបត្តិការសំខាន់ៗជាមួយបុគ្គល ដែលមានទំនាក់ទំនងជាមួយអភិបាលរបស់ក្រុមហ៊ុនបោះផ្សាយ ក្រុមហ៊ុនបុត្រសម្ព័ន្ធ ឬក្រុមហ៊ុនហូលឌីងរបស់ក្រុមហ៊ុនបោះផ្សាយ ដែលមានទំនាក់ទំនងរបស់បុគ្គលទាំងនេះកើតមាននៅក្នុងប្រតិបត្តិ ការ ឬការចាត់ចែងណាមួយ ដែលបានធ្វើឡើងដោយក្រុមហ៊ុនបោះផ្សាយ រួមមាន៖

**ប្រតិបត្តិការជាមួយក្រុមហ៊ុន QMI Industrial Co., Ltd (Taiwan)**

សម្រាប់ការិយបរិច្ឆេទឆ្នាំ២០១៧ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ ការបញ្ជាទិញរបស់អតិថិជនរបស់ក្រុមហ៊ុន ហ្គ្រេន ធ្វីន ត្រូវបានដាក់តាមរយៈក្រុមហ៊ុន QMI Industrial Co., Ltd (Taiwan) (សម្រាប់ព័ត៌មានលម្អិត សូមពិនិត្យក្នុងរបាយការណ៍ហិរញ្ញវត្ថុ របស់សវនករឯករាជ្យក្នុងផ្នែកទី ៧) ។

**៥ - ប្រតិបត្តិការសំខាន់ៗជាមួយបុគ្គលធ្លាប់ជាអភិបាល ឬបុគ្គលជាប់ពាក់ព័ន្ធជាមួយបុគ្គលធ្លាប់ជាអភិបាលក្នុងរយៈពេល ០២ (ពីរ) ឆ្នាំចុងក្រោយ**

សម្រាប់ការិយបរិច្ឆេទឆ្នាំ២០១៧ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ ក្រុមហ៊ុន ហ្គ្រេន ធ្វីន ពុំមានប្រតិបត្តិការណាមួយជាមួយបុគ្គលធ្លាប់ជាអភិបាល ឬបុគ្គលជាប់ពាក់ព័ន្ធជាមួយបុគ្គលធ្លាប់ជាអភិបាលទេ។

**៦ - ប្រតិបត្តិការសំខាន់ៗជាមួយអភិបាលដែលទទួលបានផលប្រយោជន៍ ឬកម្រៃវិជ្ជាជីវៈ សម្រាប់សេវាដែលខ្លួនបានផ្តល់តាមរយៈក្រុមហ៊ុនណាមួយ ដល់ក្រុមហ៊ុន**

សម្រាប់ការិយបរិច្ឆេទឆ្នាំ២០១៧ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ ក្រុមហ៊ុន ហ្គ្រេន ធ្វីន ពុំមានប្រតិបត្តិការណាមួយជាមួយអភិបាលដែលកាន់កាប់មុខតំណែងណាមួយ នៅក្នុងសមាគម ឬអង្គការមិនស្វែងរកប្រាក់ចំណេញ ឬនៅក្នុងក្រុមហ៊ុនណាមួយផ្សេងទៀតទេ។

**៧ - ប្រតិបត្តិការសំខាន់ៗជាមួយភាគីជាប់ពាក់ព័ន្ធផ្សេងទៀត**

សម្រាប់ការិយបរិច្ឆេទឆ្នាំ២០១៧ ឆ្នាំ២០១៦ និង ឆ្នាំ២០១៥ គិតត្រឹម ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ ក្រុមហ៊ុនមានប្រតិបត្តិការជាមួយភាគីពាក់ព័ន្ធដូចខាងក្រោម៖

| បរិយាយ | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ | |
|---|---|---|---|---|---|---|
| | រៀល "០០០" | ដុល្លារអាមេរិក | រៀល "០០០" | ដុល្លារអាមេរិក | រៀល "០០០" | ដុល្លារអាមេរិក |
| QMI Industrial Co., Ltd (Taiwan) | | | | | | |
| ការលក់ទំនិញ | ៣២៣.៩៨៧.៤១៤ | ៨០.០៩៥.៧៧៦ | ៣៣០.១០៦.១៨៨ | ៨១.៧៧០.១៧៣ | ២២១.៨៩៥.៨៩១ | ៥៤.៧៨៩.១០៩ |
| Succes Index Group | | | | | | |
| កាត់ ដេរ វេចខ្ចប់ | ៦.២១១.៥៩៤ | ១.៥៣៥.៦២៣ | ១.០៦៧.៥៨២ | ២៦៤.៤៤៩ | ៤.៩០៧.៦៩៨ | ១.២១១.៧៧៧ |

# ៩.ការពិភាក្សា និងការវិភាគ របស់គណៈគ្រប់គ្រងរបស់ ក្រុមហ៊ុន ហ្គ្រន ធ្វីន

## ១. ទិដ្ឋភាពទូទៅនៃប្រតិបត្តិការរបស់ក្រុមហ៊ុន ហ្គ្រេន ធ្វីន

របាយការណ៍ហិរញ្ញវត្ថុសម្រាប់ការិយបរិច្ឆេទឆ្នាំ២០១៧ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ បានរៀបចំឡើងអនុលោមទៅតាមស្តង់ដារគណនេយ្យកម្ពុជា "ស.គ.ក" ។ គោលការណ៍គណនេយ្យដែលបានប្រើប្រាស់ អាចនឹងខុសពីគោលការណ៍គណនេយ្យទូទៅដែលប្រើប្រាស់ក្នុងប្រទេសដទៃ ឬយុត្តាធិការផ្សេងៗទៀត។ ដូច្នេះរបាយការណ៍ហិរញ្ញវត្ថុដែលភ្ជាប់មកជាមួយនេះ មិនមានបំណងបង្ហាញពីស្ថានភាពហិរញ្ញវត្ថុ និងលទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់អនុលោមទៅយុត្តាធិការណាក្រៅពីព្រះរាជាណាចក្រកម្ពុជានោះទេ។

### ក. ការវិភាគចំណូល

ចំណូលរបស់ក្រុមហ៊ុន ហ្គ្រេន ធ្វីន គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ មានចំនួន ៣២៣.៩៨៧ លាន រៀល (៨០,០៩៦ លាន ដុល្លារអាមេរិក) បន្ទាប់ពីដកចេញអប្បហារលក់ចំនួន ២០.៨០៩ លាន រៀល (៥,១៤៤ លាន ដុល្លារអាមេរិក) ចំណូលបានថយចុះចំនួន ៧.៤២០ លាន រៀល (១,៩៩៧ លាន ដុល្លារអាមេរិក) បើធៀបនឹងចំណូលសរុបចំនួន ៣៣១.៤០៧ លាន រៀល (៨២,០៩២ លាន ដុល្លារអាមេរិក) គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ ដែលអត្រាធ្លាក់ចុះស្មើនឹង ២,២៤%។ ដោយឡែក ចំណូលរបស់ក្រុមហ៊ុន ហ្គ្រេន ធ្វីន គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ មានចំនួន ៣៣១.៤០៧ លាន រៀល (៨២,០៩២ លាន ដុល្លារអាមេរិក) ចំណូលបានកើនឡើងចំនួន ១០១.៤៦៨ លាន រៀល (២៥,៣១៧ ដុល្លារអាមេរិក) បើធៀបនឹងចំណូលសរុបចំនួន ២២៩.៩៣៩ លាន រៀល (៥៦,៧៧៥ លាន ដុល្លារអាមេរិក) គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ ដែលអត្រាធ្លាក់ចុះស្មើនឹង ៤៤,១៣%។

យោងតាមរបាយការណ៍របស់ធនាគារពិភពលោក GDP ពិភពលោក គិតជាភាគរយមានចំនួន ២,៤១% នៅឆ្នាំ២០១៤ និងព្យាករណ៍ថា កើនឡើងរហូតដល់ ២,៧១% នៅឆ្នាំ២០១៥ និង ២,៨៥% នៅឆ្នាំ២០១៦ (World Bank Global Economic Prospects 2015)។ ដោយឡែក GDP របស់សហគមន៍អឺរ៉ុបនៅឆ្នាំ២០១៥ បានរំពឹងទុកថា មានចំនួន ៣,១% GDP របស់សហរដ្ឋអាមេរិកនៅឆ្នាំ២០១៥ មានចំនួន ២,៨% ដែលកំណើននេះ មានការកើនឡើងតិចតួច បើធៀបនឹងបណ្តាឆ្នាំកន្លងទៅ។ តំបន់ទាំងពីរដែលបានរៀបរាប់ខាងលើនេះ គឺជាតំបន់លក់ចម្បងបំផុតរបស់ក្រុមហ៊ុន ហ្គ្រេន ធ្វីន ជាពិសេសឥទ្ធិពលពីកំណើនភាគរយ GDP ទាបនៅអឺរ៉ុប ក៏បានជះឥទ្ធិពលដល់ក្រុមហ៊ុន ហ្គ្រេន ធ្វីន នៅក្នុងឆ្នាំ២០១៥ ផងដែរ។

ម្យ៉ាងវិញទៀត នៅដើមឆ្នាំ២០១៤ ស្ថានភាពនយោបាយនៅព្រះរាជាណាចក្រកម្ពុជា ពិសេស គឺការបោះឆ្នោតជាសាកលនៅចុងឆ្នាំ២០១៣ និងកូដកម្មពីសំណាក់សហជីពកម្មករ ក្នុងការទាមទារតម្លើងប្រាក់បៀវត្សរ៍ជាមធ្យមរបស់ពលកររោងចក្រកាត់ដេរ ដែលជាកត្តាចម្បងដែលបានប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សេដ្ឋកិច្ចជាតិ ជាពិសេសវិស័យកាត់ដេរ និងបានប៉ះពាល់ដល់ចំណូលរបស់ក្រុមហ៊ុន ហ្គ្រេន ធ្វីន។ ស្ថានការណ៍នេះ បណ្តាលឲ្យខ្សែសង្វាក់ផលិតកម្មត្រូវបានផ្អាកមួយរយៈពេល កំឡុងពេលដែលមានកូដកម្មតាមបណ្តារោងចក្រនៅទូទាំងប្រទេស ដែលជាហេតុនាំឲ្យចំណាយមានការកើនឡើង ផលិតកម្មរបស់ក្រុមហ៊ុន បានថយចុះដែលធ្វើឲ្យមានការកាត់បន្ថយថ្លៃលក់ និងការថយចុះនៃចំណូលសរុប។

យោងតាមរបាយការណ៍របស់សមាគមរោងចក្រកាត់ដេរ GMAC នៅចុងឆ្នាំ២០១៤ ចំនួនកូដកម្ម និងចំនួនថ្ងៃផ្អាកការធ្វើការនៅក្នុងវិស័យឧស្សាហកម្មកាត់ដេរមានការកើនឡើងគួរឲ្យកត់សម្គាល់ និងបានធ្វើឲ្យខាត់បង់ទឹកប្រាក់ប្រមាណ ៥.៥០០ លានដុល្លារអាមេរិក បានធ្លាក់ចុះយ៉ាងខ្លាំង បើធៀបនឹងឆ្នាំមុន។ យោងតាមរបាយការណ៍ចុងក្រោយរបស់ GMAC

ចំនួនកូដកម្មដែលបានធ្លាក់ប្រមាណ ២៥ % ពី ចំនួន ១៤៧ ក្នុងឆ្នាំ ២០១៣ មកនៅត្រឹម ១០៨ ក្នុងឆ្នាំ២០១៤ និងចំនួនអ្នកបាត់បង់ការងារធ្វើបានធ្លាក់ចុះ ពីចំនួន ៨៨៩.០០០ នាក់ មកនៅត្រឹម ៥១៣.០០០ ពោលគឺ ថយចុះប្រមាណ ៤០ ភាគរយ។ ប្រាក់ឈ្នួលគោលថ្មី ចំនួន ១៧៣ ដុល្លារអាមេរិក ត្រូវបានអនុវត្តចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨ កន្លងទៅនេះ (*ប្រភព៖* https://www.cambodiad aily.com/news/garment-factories-report-major-drop-in-strikes-75823/) ។

ចំណូលសរុបនៅឆ្នាំ២០១៧ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ នេះ ក្រុមហ៊ុន ហ្គ្រេន ធ្វីន ទទួលបានចំណូលសរុបចំនួន ៣៤៤.៧៩៧ លាន រៀល (៨៥,២៤០ លាន ដុល្លារអាមេរិក) ពុំទាន់ដកចេញអប្បហារលក់ ដែលក្នុងនោះ ចំណូលបានពីការលក់ទំនិញ មានចំនួន ៣៣៨.៥៨៥ លាន រៀល (៨៣,៧០៥ លាន ដុល្លារអាមេរិក) និង ចំណូលទទួលបានកាត់ ដេរ និងវេចខ្ចប់ ចំនួន ៦.២១២ លាន រៀល (១,៥៣៦ ដុល្លារអាមេរិក)។ ដោយឡែក ក្រុមហ៊ុន ហ្គ្រេន ធ្វីន ពុំមានចំណូលពីការម៉ៅការឡើយនៅឆ្នាំ២០១៧ នេះ។

ចំណូលចម្បងរបស់ក្រុមហ៊ុន ហ្គ្រេន ធ្វីន គឺបានមកពីការផលិត និងលក់សំលៀកបំពាក់។ ផលិតផលបានលក់ចេញមិនអាចផ្លាស់ប្តូរវិញបានឡើយ លើកលែងតែមានបញ្ហាគុណភាព។ ក្នុងករណីផលិតផល មានបញ្ហាគុណភាព អតិថិជនអាចបញ្ជូនផលិតផលមកក្រុមហ៊ុន ហ្គ្រេន ធ្វីន វិញដើម្បីកែច្នៃ ឬជំនួស។ ការបញ្ជាទិញមិនអាចលុបចោល លុះត្រាមានការយល់ព្រមពីភាគីសងខាង។ ប៉ុន្តែអតិថិជនអាចពន្យា ឬកំណត់ពេលឡើងវិញ។ ក្រុមហ៊ុន ហ្គ្រេន ធ្វីន មិនដែលធ្លាប់មានបញ្ហាគុណភាពវត្ថុធាតុដើម ឬការលុបចោលការបញ្ជាទិញពីសំណាក់អតិថិជននោះឡើយ។

ជាធម្មតា ក្រុមហ៊ុន ហ្គ្រេន ធ្វីន មិនមានកិច្ចសន្យាបញ្ជាទិញរយៈពេលវែងពីអតិថិជន។ ប៉ុន្តែក្រុមហ៊ុន ហ្គ្រេន ធ្វីន ទទួលកិច្ចព្រមព្រៀងបញ្ជាទិញ (framework agreement) ជាមួយអតិថិជន។ កិច្ចព្រមព្រៀងជាទូទៅមានរយៈពេល ៣ខែ។ កិច្ចព្រមព្រៀងមានចែងពីបរិមាណលក់អប្បបរមា ការជ្រើសរើសម៉ូដសំលៀកបំពាក់និងថ្លៃលក់។ អតិថិជនធ្វើការបញ្ជាទិញទៅតាមតម្រូវការ។ ការបញ្ជាទិញតែងតែមានបញ្ជាក់យ៉ាងលម្អិតពីការជ្រើសរើសម៉ូដសំលៀកបំពាក់ បរិមាណ ពណ៌ ទំហំ និងថ្ងៃដឹកជញ្ជូនជាមួយនឹងថ្លៃដែលមាននៅក្នុងកិច្ចព្រមព្រៀងបញ្ជាទិញ។

ចំណូលត្រូវបានវាស់វែងតាមតម្លៃទីផ្សារនៃតម្លៃតបស្នងដែលបានទទួល ឬតម្លៃដែលនឹងត្រូវទទួលក្រោយពីដាត់ទាត់ការបញ្ចុះថ្លៃ និងការបង្វិលសងវិញ។ ចំណូលត្រូវបានទទួលស្គាល់តែនៅពេលដែលមានភវនីយភាពផលប្រយោជន៍សេដ្ឋកិច្ចទាក់ទងនឹងប្រតិបត្តិការនឹងហូរចូលមកក្នុងក្រុមហ៊ុន ហើយចំណូល និងថ្លៃដើមដែលបានកើតឡើង ឬនឹងកើតឡើងទាក់ទងទៅនឹងប្រតិបត្តិការនេះ អាចត្រូវបានវាស់វែងគួរឲ្យទុកចិត្តបាន និងអាចគោរពបានលក្ខខណ្ឌទទួលស្គាល់ជាក់លាក់សម្រាប់សកម្មភាពនីមួយៗ ដូចខាងក្រោម៖

**(ក) ការលក់ទំនិញ**

ចំណូលពីការលក់ទំនិញ ត្រូវបានទទួលស្គាល់នៅពេលដែលហានិភ័យជាសារវ័ន្ត និងភាពជាម្ចាស់កម្មសិទ្ធិលើទំនិញបានផ្ទេរទៅឲ្យអ្នកទិញហើយនៅពេលដែលក្រុមហ៊ុន ហ្គ្រេន ធ្វីន មិនធ្វើការគ្រប់គ្រងទៅលើទំនិញដែលបានលក់។ ជាទូទៅ ស្របពេលជាមួយគ្នានៃការដឹកជញ្ជូនទំនិញទៅឲ្យ និងការទទួលទំនិញដោយអតិថិជន។

**(ខ) ការផ្តល់សេវាកម្ម**

ចំណូលពីសេវាកម្ម ត្រូវបានទទួលស្គាល់នៅពេលដែលសេវាកម្មនោះត្រូវបានធ្វើឡើង។ ចំណូលពី សេវាកម្ម រួមមាន កាត់ ដេរ និងវេចខ្ចប់ "CMP" ត្រូវបានទទួលស្គាល់នៅពេលដែលសេវាកម្មបានបញ្ចប់ និងត្រូវបានផ្ទេរ និងទទួលយកដោយអតិថិជន។

## ខ. ការវិភាគចំណូលតាមផ្នែក

ចំណូលតាមផ្នែករបស់ក្រុមហ៊ុន ហ្រ្គេន ធ្វីន សម្រាប់រយៈពេល ៣ឆ្នាំ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ ថ្ងៃទី៣១ ខែធ្នូឆ្នាំ ២០១៦ និងថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ មានបង្ហាញក្នុងតារាងខាងក្រោម៖

| បរិយាយ | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ | |
|---|---|---|---|---|---|---|
| | រៀល"000" | ដុល្លារអាមេរិក | រៀល"000" | ដុល្លារអាមេរិក | រៀល"000" | ដុល្លារអាមេរិក |
| ចំណូលពីការលក់ទំនិញ | ៣៣៨.៥៨៥.២៤៥ | ៨៣.៧០៤.៦៣៤ | ៣៣០.១០៦.១៨៨ | ៨១.៧៧០.១៧៣ | ២២០.៥៤៦.៨៣៦ | ៥៤.៤៥៦.០០៩ |
| ចំណូលពីការម៉ៅការ | ៦.២១១.៥៩៥ | ១.៥៣៥.៦២៣ | ២៣៣.៥៣៦ | ៥៧.៨៤៩ | ៤.៤៦៨.៨៤៣ | ១.១០៣.៤១៨ |
| ចំណូលពីកាត់ ដេរ និងវេចខ្ចប់ | - | - | ១.០៦៧.៥៨១ | ២៦៤.៤៤៩ | ៤.៩២៣.៣៨៧ | ១.២១៥.៦៥១ |
| **ចំណូលសរុប** | **៣៤៤.៧៩៦.៨៤០** | **៨៥.២៤០.២៥៧** | **៣៣១.៤០៧.៣០៥** | **៨២.០៩២.៤៧១** | **២២៩.៩៣៩.៩៦៦** | **៥៦.៧៧៥.០៧៨** |

ចំណូលរបស់ក្រុមហ៊ុន ហ្រ្គេន ធ្វីន រួមមាន ចំណូលពីការលក់ទំនិញ ចំណូលពីការម៉ៅការ និងចំណូលពីកាត់ ដេរនិងវេចខ្ចប់ ។ ក្នុងរយៈពេល ៣ឆ្នាំ ចុងក្រោយនេះ ចំណូលពីការលក់ទំនិញ មានចំនួនមិនតិចជាង ៩៩% នៃចំណូលសរុប។ ចំណូលពីការម៉ៅការ និងចំណូលពី កាត់ ដេរ និងវេចខ្ចប់ មានចំនួនតិចតួចបើប្រៀបធៀបនឹងចំណូលសរុប។ ហេតុដូច្នេះ រាល់ការប្រែប្រួលជាចំបងនៃការលក់ និងចំណូលសរុប គឺបណ្តាលមកពីការប្រែប្រួលចំណូលពីការលក់ទំនិញ។ ចំណូលពីការលក់ទំនិញ ពឹងផ្អែកទៅលើចំនួនសំលៀកបំពាក់ដែលក្រុមហ៊ុនផលិត និងលក់ហើយត្រូវបានពិភាក្សាយ៉ាងលម្អិតខាងក្រោម។

### (ក) ចំណូលលើការលក់ទំនិញ

ចំណូលលើការលក់ទំនិញកើនឡើងពីចំនួន ៣៣០.៤០៧ លាន រៀល (៨១,៧៧០ លាន ដុល្លារអាមេរិក) តំណាងឲ្យ ៩៩,៦១% នៃចំណូលសរុបគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ រហូតដល់ចំនួន ៣៣៨.៥៨៥ លាន រៀល (៨៣,៧០៥ លាន ដុល្លារអាមេរិក) តំណាងឲ្យ ៩៨,២០% នៃចំណូលសរុប ពុំទាន់ដកចេញអប្បហារលក់ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ ដែលការកើនឡើង សរុបមានចំនួន ៨.៤៧៩ លាន រៀល (១,៩៣៤ លាន ដុល្លារអាមេរិក) ឬស្មើនឹង ២,៥៧%។ ចំណូលលើការលក់ទំនិញកើនឡើងពីចំនួន ២២០.៥៤៧ លាន រៀល (៥៤,៤៥៦ លាន ដុល្លារអាមេរិក) តំណាងឲ្យ ៩៥,៩២% នៃចំណូលសរុបគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ រហូតដល់ចំនួន ៣៣០.៤០៧ លាន រៀល (៨១,៧៧០ លាន ដុល្លារអាមេរិក) តំណាងឲ្យ ៩៩,៦១% នៃចំណូលសរុបគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ ដែលការកើនឡើងសរុបមានចំនួន ១០៩.៥៥៩ លាន រៀល (២៧,៣១៤ លាន ដុល្លារអាមេរិក) ឬស្មើនឹង ៤៩,៦៨%។ ការកើនឡើងនេះគឺ បណ្តាលមកពីការកើនឡើងនៃការទទួលបញ្ជាទិញពីអតិថិជន។

(ខ) ចំណូលពីការម៉ៅការ

ចំណូលពីការម៉ៅការ រួមមាន ចំណូលបានមកពីសេវាកម្មកាត់ និងដេរ ដល់រោងចក្រផ្សេងៗ ដែលលើសពីសមត្ថភាពផលិត។ ចំណូលពីការម៉ៅការ មានចំនួន ២៣៤ លាន រៀល (៥៧.៨៤៩ ដុល្លារអាមេរិក) ឬ ០,០៧% នៃចំណូលសរុបសម្រាប់រយៈពេល ១ឆ្នាំ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ គឺមានការថយចុះចំនួន ៤.២៣៥ លាន រៀល (១,០៤៦ លាន ដុល្លារអាមេរិក) ឬ ៩៤,៧៧% លើសពីចំណូលពីការម៉ៅការចំនួន ៤.៤៦៩ លាន រៀល (១,១០៣ លាន ដុល្លារអាមេរិក) ឬ ១,៩៤% នៃចំណូលសរុបសម្រាប់រយៈពេល ១ឆ្នាំ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។ ដោយឡែក ក្រុមហ៊ុន មិនមានចំណូលពីការម៉ៅការ នៅឆ្នាំ ២០១៧ ឡើយ។

(គ) ចំណូលពីការកាត់ ដេរ និងវេចខ្ចប់

ចំណូលពីការកាត់ ដេរ និងវេចខ្ចប់បានមកពីសេវាកម្មកាត់ ដេរ និងវេចខ្ចប់ដល់រោងចក្រផ្សេងៗ ក្នុងព្រះរាជាណាចក្រកម្ពុជា។ ចំណូលពីការ កាត់ ដេរ និងវេចខ្ចប់ មានចំនួន ៦.២១២ លាន រៀល (១,៥៣៦ លាន ដុល្លារអាមេរិក) ឬ ១,៨០% នៃចំណូលសរុបសម្រាប់រយៈពេល ១ឆ្នាំ គិតត្រឹមថ្ងៃទី៣១ ខែធ្នូឆ្នាំ២០១៧ បានកើនឡើងចំនួន ៥.១៤៤ លាន រៀល (១,២៧១ លាន ដុល្លារអាមេរិក) ឬស្មើនឹង ៤៨១,៨៤% បើធៀបនឹង ចំណូលទទួលបានកាត់ ដេរ និងវេចខ្ចប់ ចំនួន ១.០៦៨ លាន រៀល (២៦៤.៤៤៩ ដុល្លារអាមេរិក) ឬ ០,៣២% នៃចំណូលសរុបសម្រាប់រយៈពេល ១ឆ្នាំ គិតត្រឹមថ្ងៃទី៣១ ខែធ្នូឆ្នាំ២០១៦។ ដោយឡែក ចំណូលពីការ កាត់ ដេរ និងវេចខ្ចប់ មានចំនួន ១.០៦៨ លាន រៀល (២៦៤.៤៤៩ ដុល្លារអាមេរិក) ឬ ០,៣២% នៃចំណូលសរុបសម្រាប់រយៈពេល ១ឆ្នាំ គិតត្រឹមថ្ងៃទី៣១ ខែធ្នូឆ្នាំ២០១៦ បានថយចុះចំនួន ៣.៨៥៦ លាន រៀល (៩៥១.២០២ ដុល្លារអាមេរិក) ឬស្មើនឹង ៧៨,៣២% បើធៀបនឹង ចំណូលទទួលបានពីការកាត់ ដេរ និងវេចខ្ចប់ ចំនួន ៤.៩២៣ លាន រៀល (១,២១៦ លាន ដុល្លារអាមេរិក) ឬ ២,១៤% នៃចំណូលសរុបសម្រាប់ រយៈពេល ១ឆ្នាំ គិតត្រឹមថ្ងៃទី៣១ ខែធ្នូឆ្នាំ២០១៥។

គ. ការវិភាគគំលាតចំណេញដុល

ចំណេញដុលបានមកពីចំណូលពីការលក់ដកថ្លៃដើម។ គំលាតចំណេញដុលស្មើនឹងចំណេញដុលចែកនឹងចំណូលពីការលក់។ ចំណេញដុលមានចំនួន ២៧.១៥៦ លាន រៀល (៦,៧១៤ លាន ដុល្លារអាមេរិក) គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០១៧ បានថយចុះចំនួន ១៤.២៥៤ លាន រៀល (៣,៥៤៤ លាន ដុល្លារអាមេរិក) ឬ ស្មើនឹង ៣៤,៤២% បើធៀបនឹង ចំណេញដុលមានចំនួន ៤១.៤១០ លាន រៀល (១០,២៥៨ លាន ដុល្លារអាមេរិក) គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦។ ដោយឡែក ចំណេញដុលមានចំនួន ៤១.៤១០ លាន រៀល (១០,២៥៨ លាន ដុល្លារអាមេរិក) គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០១៦ មានការកើនឡើងចំនួន ១៥.១៨១ លាន រៀល (៣,៧៨១ លាន ដុល្លារអាមេរិក) ឬ ស្មើនឹង ៥៧,៨៨% បើធៀបនឹងចំណេញដុលមានចំនួន ២៦.២២៩ លាន រៀល (៦,៤៧៦ លាន ដុល្លារអាមេរិក) គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។ ដូចដែលមានលម្អិតនៅក្នុងវាក្យខណ្ឌខាងលើ ក្រុមហ៊ុន ហ្គ្រេន ធ្វីន បានបង្កើនចំណូលពីការកាត់ ដេរ និងវេចខ្ចប់ ជំនួសពីចំណូលដែល ធ្លាក់ចុះពី ការលក់ទំនិញ ដើម្បីរក្សាប្រាក់ចំណេញដុល។

(ក) ចំណូល

ចំណូលរបស់ក្រុមហ៊ុន ហ្គ្រេន ធ្វីន គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ មានចំនួន ៣២៣.៩៨៧ លាន រៀល (៨០,០៩៦ លាន ដុល្លារអាមេរិក) បន្ទាប់ពីដកចេញអប្បហារលក់ចំនួន ២០.៨០៩ លាន រៀល (៥,១៤៤ លាន ដុល្លារអាមេរិក) ចំណូលបានថយចុះចំនួន ៧.៤២០ លាន រៀល (១,៩៩៧ លាន ដុល្លារអាមេរិក) បើធៀបនឹងចំណូលសរុបចំនួន ៣៣១.៤០៧ លាន រៀល (៨២,០៩២ លាន ដុល្លារអាមេរិក) គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ ដែលអត្រាធ្លាក់ចុះ

ស្មើនឹង ២,២៤%។ ដោយឡែក ចំណូលរបស់ក្រុមហ៊ុន ហ្គ្រេន ធ្វីន។ ដោយឡែក ចំណូលរបស់ក្រុមហ៊ុន ហ្គ្រេន ធ្វីន គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ មានចំនួន ៣៣១.៤០៧ លាន រៀល (៨២,០៩២ លាន ដុល្លារអាមេរិក)។ ចំណូលបានកើនឡើងចំនួន ១០១.៤៦៨ លាន រៀល (២៥,៣១៧ លាន ដុល្លារអាមេរិក) បើធៀបនឹងចំណូលសរុបចំនួន មានចំនួន ២២៩.៩៣៩ លាន រៀល (៥៦,៧៧៥ លាន ដុល្លារអាមេរិក) គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ ដែលអត្រាកើនឡើង ស្មើនឹង ៤៤,១៣%។

### (ខ) ថ្លៃដើម

ថ្លៃដើមរបស់ក្រុមហ៊ុន ហ្គ្រេន ធ្វីន សម្រាប់រយៈពេល ១ឆ្នាំ ឆ្នាំ២០១៧ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ ឆ្នាំ២០១៦ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ និងឆ្នាំ២០១៥ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ ត្រូវបានបង្ហាញក្នុងតារាងខាងក្រោម៖

| បរិយាយ | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ | |
|---|---|---|---|---|---|---|
| | រៀល"000" | ដុល្លារអាមេរិក | រៀល"000" | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក |
| ចំណាយវត្ថុធាតុដើម | ១៩២.៧៧៤.៥៣៥ | ៤៧.៦៥៧.៤៨៧ | ១៨៧.៤៧៧.៩៦៩ | ៤៦.៤៣៩.៩២៣ | ១៣០.៥២៥.៣៥៦ | ៣២.២២៨.៤៨៣ |
| ចំណាយពលកម្មផ្ទាល់ | ៤៩.២៩១.១៥៧ | ១២.១៨៥.៧០០ | ៤៧.២១៦.០៥៨ | ១១.៦៩៥.៨២៨ | ៣៨.០៥៥.៤៧៧ | ៩.៣៩៦.៤១៤ |
| ចំណាយផ្សេងៗ | ៥៤.៧៦៥.៥១៣ | ១៣.៥៣៩.០៦៤ | ៥៥.៣០២.៨២៦ | ១៣.៦៩៨.៩៩១ | ៣៥.១២៩.១០៩ | ៨.៦៧៣.៨៥៤ |
| **សរុប** | **២៩៦.៨៣១.២០៥** | **៧៣.៣៨២.២៥១** | **២៨៩.៩៩៦.៨៥៣** | **៧១.៨៣៤.៧៤២** | **២០៣.៧០៩.៩៤២** | **៥០.២៩៨.៧៥១** |

ថ្លៃដើមរបស់ក្រុមហ៊ុន ហ្គ្រេន ធ្វីន រួមមាន វត្ថុធាតុដើមពលកម្មផ្ទាល់ និងចំណាយផ្សេងៗ។ ចំណាយវត្ថុធាតុដើម រួមមាន ការចំណាយលើក្រណាត់ ដែលជាផ្នែកនៃផលិតផលសម្រេច។ ចំណាយពលកម្មផ្ទាល់ រួមមាន ការចំណាយទៅលើនិយោជិតដែលចូលរួមដោយផ្ទាល់ក្នុងផលិតកម្ម។ ចំណាយផ្សេងៗផ្ទាល់ រួមមាន ការចំណាយដែលពាក់ព័ន្ធ ទៅនឹងផលិតកម្ម និងលក់ទំនិញ។ ចំណាយផ្សេងៗមិនផ្ទាល់ រួមមាន ចំណាយពាក់ព័ន្ធនឹងអគ្គិសនី អ្នកបោសសំអាត សេវាកម្មសំអាត និងសេវាកម្មសន្តិសុខ។

ថ្លៃដើមរបស់ក្រុមហ៊ុន ហ្គ្រេន ធ្វីន រួមមាន វត្ថុធាតុដើមពលកម្មផ្ទាល់ និងចំណាយផ្សេងៗ។ ចំណាយវត្ថុធាតុដើម រួមមាន ការចំណាយលើក្រណាត់ ដែលជាផ្នែកនៃផលិតផលសម្រេច។ ចំណាយពលកម្មផ្ទាល់ រួមមាន ការចំណាយទៅលើនិយោជិតដែលចូលរួមដោយផ្ទាល់ក្នុងផលិតកម្ម។ ចំណាយផ្សេងៗផ្ទាល់ រួមមាន ការចំណាយដែលពាក់ព័ន្ធទៅនឹងផលិតកម្ម និងលក់ទំនិញ។ ចំណាយផ្សេងៗមិនផ្ទាល់ រួមមាន ចំណាយពាក់ព័ន្ធនឹងអគ្គិសនី អ្នកបោសសំអាត សេវាកម្មសំអាត និងសេវាកម្មសន្តិសុខ។

ថ្លៃដើមមានចំនួន ២៩៦.៨៣១ លាន រៀល (៧៣,៣៨២ លាន ដុល្លារអាមេរិក) សម្រាប់ឆ្នាំ២០១៧ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ ថ្លៃដើមបានកើនឡើង ចំនួន ៦.៨៣៤ លាន រៀល (១,៥៤៨ លាន ដុល្លារអាមេរិក) ឬ ស្មើ ២,៣៦% បើប្រៀបធៀបនឹងថ្លៃដើមសរុបចំនួន ២៨៩.៩៩៧ លាន រៀល (៧១,៨៣៥ លាន ដុល្លារអាមេរិក) សម្រាប់ឆ្នាំ ២០១៦ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦។ ការកើនឡើងនេះ ដោយសារតែការកើនឡើងតម្លៃវត្ថុធាតុដើមផ្ទាល់ ចំណាយពលកម្មផ្ទាល់ក្នុងអំឡុងពេលផលិតកម្ម។ ដោយឡែក ថ្លៃដើមមានចំនួន ២៨៩.៩៩៧ លាន រៀល (៧១,៨៣៥ លាន ដុល្លារអាមេរិក) សម្រាប់ឆ្នាំ២០១៦ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ ថ្លៃដើមបានកើនឡើង ចំនួន ៨៦.២៨៧ លាន រៀល (២១,៥៣៦ លាន ដុល្លារអាមេរិក) ឬ ស្មើ ៤២,៣៦% បើប្រៀបធៀបនឹងថ្លៃដើមសរុបចំនួន ២០៣.៧១០ លាន រៀល (៥០,២៩៩ លាន ដុល្លារអាមេរិក) សម្រាប់ឆ្នាំ២០១៥ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។ ការ កើនឡើងនេះ ដោយសារតែការកើនឡើងតម្លៃវត្ថុធាតុដើមផ្ទាល់ និងចំណាយផ្សេងៗ ក្នុងអំឡុងពេលផលិតកម្ម ជាជាងការកើនឡើងតម្លៃលើកម្លាំងពលកម្ម។

ចំណាយវត្ថុធាតុដើមបានកើនឡើងចំនួន ៥.២៩៧ លាន រៀល (១,២១៨ លាន ដុល្លារអាមេរិក) ឬ ២,៨៣% ពី ១៨៧.៤៧៨ លាន រៀល (៤៦,៤៤០ លាន ដុល្លារអាមេរិក) សម្រាប់ឆ្នាំ២០១៦ រហូតដល់ ១៩២.៧៧៥ លាន រៀល (៤៧,៦៥៧ លាន ដុល្លារអាមេរិក) សម្រាប់ឆ្នាំ២០១៧។ ដោយឡែក ចំណាយវត្ថុធាតុដើមបានកើនឡើងចំនួន ៥៦.៩៥៣ លាន រៀល (១៤,២១១ លាន ដុល្លារអាមេរិក) ឬ ៤៣,៦៣% ពី ១៣០.៥២៥ លាន រៀល (៣២,២២៨ លាន ដុល្លារអាមេរិក) សម្រាប់ឆ្នាំ២០១៥ រហូតដល់ ១៨៧.៤៧៨ លាន រៀល (៤៦,៤៤០ លាន ដុល្លារអាមេរិក) សម្រាប់ឆ្នាំ២០១៦។ ការកើនឡើងនេះ ស្របតាមការកើនឡើងថ្លៃវត្ថុធាតុដើម សម្រាប់ផលិតសំលៀកបំពាក់។

ចំណាយពលកម្មផ្ទាល់បានកើនឡើងចំនួន ២.០៧៥ លាន រៀល (៤៨៩.៨៧២ ដុល្លារអាមេរិក) ឬ ៤,៣៩% ពីចំនួន ៤៧.២១៦ លាន រៀល (១១,៦៩៦ លាន ដុល្លារអាមេរិក) ក្នុងឆ្នាំ២០១៦ រហូតដល់ ចំនួន ៤៩,២៩១ លាន រៀល (១២,១៨៦ លាន ដុល្លារអាមេរិក) ក្នុងឆ្នាំ២០១៧។ ដោយឡែក ចំណាយពលកម្មផ្ទាល់បានកើនឡើងចំនួន ៩,១៦១ លាន រៀល (២,២៩៩ លាន ដុល្លារអាមេរិក) ឬ ២៤,០៧% ពី ៣៨.០៥៥ លាន រៀល (៩,៣៩៦ លាន ដុល្លារអាមេរិក) ក្នុងឆ្នាំ២០១៥ រហូតដល់ ចំនួន ៤៧.២១៦ លាន រៀល (១១,៦៩៦ លាន ដុល្លារអាមេរិក) ក្នុងឆ្នាំ២០១៦។ ការកើនឡើងនេះ ស្របតាមការកើនឡើងនៃចំណាយពលកម្មផ្ទាល់។

ចំណាយផ្សេងៗ បានថយចុះចំនួន ៥៣៧ លាន រៀល (១៥៩.៩២៧ ដុល្លារអាមេរិក) ឬ ០,៩៧% ពី ៥៥.៣០៣ លាន រៀល (១៣,៦៩៩ លាន ដុល្លារអាមេរិក) ក្នុងឆ្នាំ២០១៦ មកនៅត្រឹមចំនួន ៥៤.៧៦៦ លាន រៀល (១៣,៥៣៩ លាន ដុល្លារអាមេរិក) ក្នុងឆ្នាំ២០១៧។ ដោយឡែកចំណាយផ្សេងៗ បានកើនឡើងចំនួន ២០.១៧៤ លាន រៀល (៥,០២៥ លាន ដុល្លារអាមេរិក) ឬ ៥៧,៤៣% ពី ៣៥.១២៩ លាន រៀល (៨,៦៧៤ លាន ដុល្លារអាមេរិក) សម្រាប់ឆ្នាំ២០១៥ រហូតដល់ចំនួន ៥៥.៣០៣ លាន រៀល (១៣,៦៩៩ លាន ដុល្លារអាមេរិក) ក្នុងឆ្នាំ២០១៦។

### ឃ- ការវិភាគចំណេញមុនបង់ពន្ធ

ចំណេញមុនបង់ពន្ធ គឺជាគំលាតចំណេញដុល បូកបន្ថែមចំណូលផ្សេងៗ ដកចំណាយលើការដឹកជញ្ជូនចំណាយរដ្ឋបាល ចំណាយផ្សេងៗ និងចំណាយការប្រាក់។

សម្រាប់រយៈពេល ១ឆ្នាំ ឆ្នាំ២០១៧ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ ចំណេញមុនបង់ពន្ធមានចំនួន ៤.៧៣០ លាន រៀល (១,១៦៩ លាន ដុល្លារអាមេរិក) បានថយចុះចំនួន ១០.៨២៦ លាន រៀល (២,៦៨៤ លាន ដុល្លារអាមេរិក) ឬស្មើនឹង ៦៩,៦០% បើប្រៀបធៀបនឹងចំណេញមុនបង់ពន្ធចំនួន ១៥.៥៥៦ លាន រៀល (៣,៨៥៣ លាន ដុល្លារអាមេរិក)

នៅឆ្នាំ២០១៦។ ការថយចុះចំណេញមុនបង់ពន្ធនេះ បណ្តាលមកពីអប្បហារលក់ចំនួន ២០.៨០៩ លាន រៀល (៥,១៤៤ លាន ដុល្លារអាមេរិក)។ ដោយឡែក សម្រាប់រយៈពេល ១ឆ្នាំ ឆ្នាំ២០១៦ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ ចំណេញមុនបង់ពន្ធមាន ចំនួន ១៥.៥៥៦ លាន រៀល (៣,៨៥៣ លាន ដុល្លារអាមេរិក) បានកើនឡើង ចំនួន ១២.៣៧១ លាន រៀល (៣,០៦៧ លាន ដុល្លារអាមេរិក) ឬ ស្មើនឹង ៣៨៨,៣៨% បើប្រៀបធៀបនឹងចំណេញមុនបង់ពន្ធចំនួន ៣.១៨៥ លាន រៀល (៧៨៦.៤៦៦ ដុល្លារអាមេរិក) នៅឆ្នាំ២០១៥។ ការកើនឡើងចំណេញមុនបង់ពន្ធនេះ បណ្តាលមកពីការកើនឡើងបរិមាណបញ្ជាទិញ ទោះបីជាថ្លៃដើមមាន ការកើនឡើងក្តី ដែលធ្វើអោយគំលាត(ខាត)/ចំណេញដុលក្នុងថ្លៃលក់មធ្យមនៅរក្សាបានការកើនឡើង។

**(ក) ធាតុចំណេញមុនបង់ពន្ធ**

គំលាតចំណេញមុនបង់ពន្ធរបស់ក្រុមហ៊ុន ហ្គ្រេន ធ្វីន សម្រាប់ការិយបរិច្ឆេទឆ្នាំ២០១៧ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ ការិយបរិច្ឆេទឆ្នាំ២០១៦ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ និងការិយបរិច្ឆេទឆ្នាំ២០១៥ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ បានពិភាក្សាលម្អិតក្នុងផ្នែកខាងលើ។

**(ខ) ចំណូលផ្សេងៗ**

ចំណូលផ្សេងៗ រួមមាន ចំណូលពីការប្រាក់គណនីសន្សំ ការលក់កាកសំណល់ ចំណូលពីការលក់ទ្រព្យសកម្មរយៈពេលវែង និងចំណូលមិនមែនប្រតិបត្តិការដទៃទៀត។ ចំណូលផ្សេងៗមានចំនួន ៣០៣ លាន រៀល (៧៤.៨៧៨ ដុល្លារអាមេរិក) សម្រាប់រយៈពេល ១ឆ្នាំ ឆ្នាំ២០១៧ ចំនួន ២៤៣ លាន រៀល (៦០.១១៥ ដុល្លារអាមេរិក) សម្រាប់រយៈពេល ១ឆ្នាំ ឆ្នាំ២០១៦ និងចំនួន ៨០៧ លាន រៀល (១៩៩.២៤៣ ដុល្លារអាមេរិក) សម្រាប់រយៈពេល ១ឆ្នាំ ឆ្នាំ២០១៥។

**(គ) ការចំណាយលើការដឹកជញ្ជូន**

ចំណាយលើការដឹកជញ្ជូនរួមមាន ចំណាយលើការដឹកជញ្ជូនផលិតផលសម្រេចទៅអោយអតិថិជន។ ចំណាយលើការដឹកជញ្ជូនសម្រាប់ការិយបរិច្ឆេទឆ្នាំ២០១៧ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ មានចំនួន ៦.៦៣៥ លាន រៀល (១,៦៤០ លាន ដុល្លារអាមេរិក) ចំណាយលើការដឹកជញ្ជូនបានថយចុះចំនួន ៣.៤០៩ លាន រៀល (៨៤៧.៦១៥ ដុល្លារអាមេរិក) ឬ ស្មើនឹង ៣៣,៩៤% បើប្រៀបធៀបនឹងចំណាយលើការដឹកជញ្ជូនមានចំនួន ១០.០៤៤ លាន រៀល (២,៤៨៨ លាន ដុល្លារអាមេរិក) នៅឆ្នាំ២០១៦ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦។ ការកើនឡើងនៃការចំណាយលើការដឹកជញ្ជូនក្នុងឆ្នាំ២០១៦ ស្របពេលការកើនឡើងបញ្ជាទិញដែលបណ្តាលឲ្យមានការកើនឡើងនៃចំណាយលើការដឹកជញ្ជូន។ ដោយឡែក ចំណាយលើការដឹកជញ្ជូនសម្រាប់ការិយបរិច្ឆេទឆ្នាំ២០១៦ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ មានចំនួន ១០.០៤៤ លាន រៀល (២,៤៨៨ លាន ដុល្លារអាមេរិក) ចំណាយលើការដឹកជញ្ជូនបានកើនឡើង ចំនួន ៤.៩៤៦ លាន រៀល (១,២២៩ លាន ដុល្លារអាមេរិក) ឬ ស្មើនឹង ៩៧,០១% បើប្រៀបធៀបនឹងចំណាយលើការដឹកជញ្ជូនមានចំនួន ៥.០៩៨ លាន រៀល (១,២៥៩ លានដុល្លារអាមេរិក) នៅឆ្នាំ២០១៥ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។ ការកើនឡើងនៃការចំណាយលើការដឹកជញ្ជូនក្នុងឆ្នាំ២០១៦ ស្របពេលការកើនឡើងបញ្ជាទិញដែលបណ្តាលឲ្យមានការកើនឡើងនៃចំណាយលើការដឹកជញ្ជូន។

**(ឃ) ចំណាយរដ្ឋបាល**

ចំណាយរដ្ឋបាលបានរៀបរាប់នៅក្នុងតារាងខាងក្រោមនេះរួមមាន ចំណាយលើបុគ្គលិក ចំណាយលើការស្រាវជ្រាវ និងអភិវឌ្ឍន៍ចំណាយផ្សេងៗ និងចំណាយលើការរំលស់។ ចំណាយលើការស្រាវជ្រាវ និងអភិវឌ្ឍន៍ រួមមានចំណាយលើបុគ្គលិក និងសម្ភារៈបរិក្ខារ។

សម្រាប់ការិយបរិច្ឆេទឆ្នាំ២០១៧ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ ចំណាយរដ្ឋបាលមានចំនួន ១៤.៦៤៣ លាន រៀល (៣,៦២០ លាន ដុល្លារអាមេរិក) ចំណាយរដ្ឋបាលបានថយចុះចំនួន ៧៦៥ លាន រៀល (១៩៦.៨២៥ ដុល្លារអាមេរិក) ឬ ស្មើនឹង ៤,៩៧% បើធៀបនឹងចំណាយរដ្ឋបាលចំនួន ១៥.៤០៩ លាន រៀល (៣,៨១៧ លាន ដុល្លារអាមេរិក) ឆ្នាំ២០១៦ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦។ សម្រាប់ការិយបរិច្ឆេទឆ្នាំ២០១៦ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ ចំណាយរដ្ឋបាលមានចំនួន ១៥.៤០៩ លាន រៀល (៣,៨១៧ លាន ដុល្លារអាមេរិក) ចំណាយរដ្ឋបាលបានថយចុះចំនួន ២.៦៤៩ លាន រៀល (៦៤១.៩២៥ ដុល្លារអាមេរិក) ឬ ស្មើនឹង ១៤,៦៧% ប្រៀបធៀបនឹងចំណាយរដ្ឋបាល មានចំនួន ១៨.០៥៨ លាន រៀល (៤,៤៥៩ លាន ដុល្លារអាមេរិក) ឆ្នាំ២០១៥ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។ ការថយចុះនៃចំណាយរដ្ឋបាល បណ្តាលមកពីចំណាយសម្រាប់អ្នកអាជីពថយចុះបន្ទាប់ពីក្រុមហ៊ុនចុះបញ្ជីលក់មូលបត្រ និងចំណាយសម្រាប់អ្នកផ្តល់សេវាប្រឹក្សាយោបល់។ ក្រុមហ៊ុន ហ្គ្រេន ធ្វីន នៅតែបន្តវិនិយោគលើសមត្ថភាពផលិតរបស់ក្រុមហ៊ុនដើម្បីផលិតនូវអាវរងា ក្រុមហ៊ុនត្រូវការចំណាយសម្រាប់អ្នកអាជីព និងលើការបណ្តុះបណ្តាលបន្ថែម។ លើសពីនេះទៅទៀត ចំណាយលើបុគ្គលិកកើនឡើងដោយសារក្រុមហ៊ុន ហ្គ្រេន ធ្វីន បានជួលបុគ្គលិកបន្ថែម ដើម្បីឆ្លើយតបនឹងការបញ្ជាទិញ ព្រមទាំងបានបង្កើន ប្រាក់បៀវត្សរ៍សម្រាប់បុគ្គលិកចាស់។ ក្រុមហ៊ុន បានវិនិយោគលើសមត្ថភាពផលិតរបស់ក្រុមហ៊ុនដើម្បីផលិតអាវរងា និងចំណាយលើការបណ្តុះបណ្តាល។

| បរិយាយ | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ | |
|---|---|---|---|---|---|---|
| | រៀល"000" | ដុល្លារអាមេរិក | រៀល"000" | ដុល្លារអាមេរិក | រៀល"000" | ដុល្លារអាមេរិក |
| ចំណាយលើការរំលស់ | ៤០៨.១៤៥ | ១០០.៩០១ | ៥៧៣.៨៨៤ | ១៤២.១៥៦ | ៤៨៨.៤៥៨ | ១២០.៦០៧ |
| ចំណាយលើការបរិច្ចាក | ១.៨០៤ | ៤៤៦ | ៤.៨៣៣ | ១.១៩៧ | - | - |
| ចំណាយលើការកំសាន្ត | ៤៤.១៣១ | ១០.៩១០ | ១៣៣.៨៧៥ | ៣៣.១៦២ | ៧២.៧០២ | ១៧.៩៥១ |
| ចំណាយលើការជួលបរិក្ខា | ៦០.២៥០ | ១៤.៨៩៥ | ៤៩.០៧៤ | ១២.១៥៦ | ៣៨.០៣០ | ៩.៣៩០ |
| ចំណាយលើបុគ្គលិក | ៥.៥៤៧.១៥១ | ១.៣៧១.៣៦០ | ៥.០០៩.១៨២ | ១.២៤០.៨១៨ | ៤.០៨២.៤៥៣ | ១.០០៨.០១៣ |
| ចំណាយលើប្រៃសណីយ៍ | ១៥៨.៥២០ | ៣៩.១៨៩ | ១៥៩.០៨៧ | ៣៩.៤០៧ | ១៥៧.១៨៩ | ៣៨.៨១២ |
| ចំណាយលើអ្នកអាជីព | ៣៧៧.២៧៣ | ៩៣.២៦៩ | ៥០៤.០៦៤ | ១២៤.៨៦១ | ១.៨៣០.១២៦ | ៤៥១.៨៨៣ |
| ចំណាយលើធានារ៉ាប់រងលើទ្រព្យ | ១០៥.១២១ | ២៥.៩៨៨ | ១០៤.៧៨៤ | ២៥.៩៥៦ | ១០១.៥៧៨ | ២៥.០៨១ |
| ចំណាយលើពន្ធនិងផ្សេងៗ | ១៧២.០៩៥ | ៤២.៥៤៥ | ១៥៥.៥២៩ | ៣៨.៥២៦ | - | - |
| ចំណាយលើការជួសជុលនិងថែរក្សា | ២៣៦.២១២ | ៥៨.៣៩៦ | ១០៩.៣៦៦ | ២៧.០៩១ | ១២២.៨០៤ | ៣០.៣២២ |
| ចំណាយលើការស្រាវជ្រាវនិងអភិវឌ្ឍន៍ | ៥.៦៨៦.០១២ | ១.៤០៥.៦៨៩ | ៦.៦២៧.៣០៩ | ១.៦៤១.៦៤២ | ៧.០២២.៨៧៨ | ១.៧៣៤.០៤៤ |

| | | | | | | |
|---|---|---|---|---|---|---|
| ចំណាយលើសំភារៈការិយាល័យ | ៤០៧.៥៥០ | ១០០.៧៥៤ | ៤៥៨.២៧២ | ១១៣.៥១៨ | ៤៤៥.៦៩៤ | ១១០.០៤៨ |
| ចំណាយលើការធ្វើដំណើរ | ១៣១.២៩៣ | ៣២.៤៥៨ | ៥៩.៣៨៤ | ១៤.៧១០ | ៥១.៧៣១ | ១២.៧៧៣ |
| ចំណាយលើទឹក និងភ្លើង | ១៤.៥៦២ | ៣.៦០០ | ១៤.៥៣៣ | ៣.៦០០ | - | - |
| ចំណាយផ្សេងៗ | ១.២៩៣.១៨៦ | ៣១៩.៧០០ | ១.៦០១.២៧៩ | ៣៩៦.៦៥១ | ៣.៦៤៤.៧០០ | ៨៩៩.៩២៦ |
| **សរុប** | **១៤.៦៤៣.៣០៥** | **៣.៦២០.១០០** | **១៥.៤០៨.៩២៦** | **៣.៨១៦.៩២៥** | **១៨.០៥៨.៣៤៣** | **៤.៤៥៨.៨៥០** |

**(ង) ចំណាយផ្សេងៗ**

ចំណាយផ្សេងៗតំណាងឲ្យការខាតបង់កើតឡើងពីការកាត់បន្ថយថ្លៃលក់ផលិតផល ខុសទាំងពណ៌ និងខ្វាត។ ចំណាយផ្សេងៗមានចំនួន ៦៩៥ លាន រៀល (១៧១.៨៨១ ដុល្លារអាមេរិក) សម្រាប់ការិយបរិច្ឆេទឆ្នាំ២០១៧ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ ចំណាយផ្សេងៗបានកើនឡើងចំនួន ៤៩ លាន រៀល (១២.៤៥៤ ដុល្លារអាមេរិក) ឬ ស្មើនឹង ២១,៥៨% ប្រៀបធៀបនឹងចំណាយផ្សេងៗ ចំនួន ១.៦០១ លាន រៀល (៣៩៦.៦៥១ ដុល្លារអាមេរិក) សម្រាប់ការិយបរិច្ឆេទឆ្នាំ២០១៦ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦។ ចំណាយផ្សេងៗមានចំនួន ១.៦០១ លាន រៀល (៣៩៦.៦៥១ ដុល្លារអាមេរិក) សម្រាប់ការិយបរិច្ឆេទឆ្នាំ២០១៦ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ ចំណាយផ្សេងៗបានកើនឡើងចំនួន ៤៩ លាន រៀល (១២.៤៥៤ ដុល្លារអាមេរិក) ឬ ស្មើនឹង ២១,៥៨% ប្រៀបធៀបនឹងចំណាយផ្សេងៗ ចំនួន ២៧៦ លាន រៀល (៦៨.២១៩ ដុល្លារអាមេរិក) សម្រាប់ការិយបរិច្ឆេទឆ្នាំ២០១៥ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។ ដូច្នេះចំណាយផ្សេងៗ មិនមែនជាចំណាយធំដុំតំណាងឲ្យចំណាយប្រតិបត្តិការសម្រាប់ក្រុមហ៊ុនទេ។

**(ច) ចំណាយការប្រាក់**

ចំណាយការប្រាក់ រួមមាន ចំណាយការប្រាក់បំណុលដែលនៅជំពាក់។ ចំណាយការប្រាក់មានចំនួន ៨៣៧ លាន រៀល (២០៦.៩៩៨ ដុល្លារអាមេរិក) សម្រាប់រយៈពេល ១ឆ្នាំ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ ចំនួន ៥៥៩ លាន រៀល (១៣៨.៣៩៦ ដុល្លារអាមេរិក) សម្រាប់រយៈពេល ១ឆ្នាំ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ និងចំនួន ៤១៨ លាន រៀល (១០៣.២៦៦ ដុល្លារអាមេរិក) សម្រាប់រយៈពេល ១ឆ្នាំ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។

**ង. ការវិភាគចំណេញក្រោយការបង់ពន្ធ**

ចំណេញក្រោយបង់ពន្ធ គឺបានមកចំណេញមុនបង់ពន្ធ ដកចំណាយបង់ពន្ធ។ សម្រាប់រយៈពេល ១ឆ្នាំ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ ចំណេញមុនបង់ពន្ធមានចំនួន ៤.៧៣០ លាន រៀល (១,១៦៩ ដុល្លារអាមេរិក) និងចំណាយបង់ពន្ធ -២.០៦០ លាន រៀល (-៥០៩.១៥៥ ដុល្លារអាមេរិក) និងចំណេញក្រោយបង់ពន្ធ មានចំនួន ២.៦៧០ លាន រៀល (៦៦០.០៧៧ លាន ដុល្លារអាមេរិក)។

សម្រាប់រយៈពេល ១ឆ្នាំ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ ចំណេញមុនបង់ពន្ធមានចំនួន ១៥.៥៥៦ លាន រៀល (៣,៨៥៣ ដុល្លារអាមេរិក) និងចំណាយបង់ពន្ធ ៥.៦០៧ លាន រៀល (១,៣៨៩ លាន ដុល្លារអាមេរិក) និងចំណេញក្រោយបង់ពន្ធមានចំនួន ២១.១៦៣ លាន រៀល (៥,២៤២ លាន ដុល្លារអាមេរិក)។ សម្រាប់រយៈពេល ១ឆ្នាំ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ ចំណេញមុនបង់ពន្ធមានចំនួន ៣.១៨៥ លាន រៀល (៧៨៦.៤៦៦ ដុល្លារអាមេរិក រៀល (៥,២៤២ លាន ដុល្លារអាមេរិក)។ ក្រុមហ៊ុន ហ្គ្រេន ធ្វីន ទទួលបានការលើកលែងពន្ធលើប្រាក់ចំណេញសម្រាប់ឆ្នាំ២០១៤ ឆ្នាំ២០១៥ និង ឆ្នាំ២០១៦ ដូចបានពិពណ៌នាក្នុងផ្នែក "ការវិភាគពីពន្ធ"។

**ច. ការវិភាគពីកត្តា និងនិន្នាការដែលប៉ះពាល់ដល់ស្ថានភាព និងលទ្ធផលហិរញ្ញវត្ថុ**

**(ក) ចំណូល**

ចំណូលរបស់ក្រុមហ៊ុន ហ្គ្រេន ធ្វីន បានមកពីនាំចេញទំនិញទៅគ្រប់តំបន់ជុំវិញពិភពលោក។ ចំណូលពីការលក់ទំនិញទៅសហរដ្ឋអាមេរិក មានចំនួន ២១% នៃចំណូលសរុបក្នុងឆ្នាំ២០១៧ ទៅសហគមន៍អឺរ៉ុបចំនួន ៥០% បណ្តាប្រទេសអាស៊ី ចំនួន ២៧% និង ២% បណ្តាប្រទេសផ្សេងៗទៀត។

ដោយឡែក ក្នុងរយៈពេល ៣ឆ្នាំ ចុងក្រោយចំណូលរបស់ក្រុមហ៊ុន ហ្គ្រេន ធ្វីន បានថយចុះប្រមាណ ២,២៤% ពីចំនួន ៣៣១.៤០៧ លាន រៀល (៨២,០៩២ លាន ដុល្លារអាមេរិក) នៅឆ្នាំ២០១៦ មកនៅត្រឹមចំនួន ៣២៣.៩៨៧ លាន រៀល (៨០,០៩៦ លាន ដុល្លារអាមេរិក) នៅឆ្នាំ២០១៧ បន្ទាប់ពីដកចេញអប្បហារលក់ចំនួន ២០.៨០៩ លាន រៀល (៥,១៤៤ លាន ដុល្លារ អាមេរិក)។ ដោយឡែក ចំណូលរបស់ក្រុមហ៊ុន ហ្គ្រេន ធ្វីន បាន៤៤,១៣% ពីចំនួន ២២៩.៩៣៩ លាន រៀល (៥៦,៧៧៥ លានដុល្លារអាមេរិក) នៅឆ្នាំ២០១៥ កើនឡើងរហូតដល់ចំនួន ៣៣១.៤០៧ លាន រៀល (៨២,០៩២ លាន ដុល្លារអាមេរិក) នៅឆ្នាំ២០១៦។ ក្នុងរយៈពេល ៣ឆ្នាំ ក្រោយការចុះបញ្ជីលក់មូលបត្រ ចំណូលរបស់ក្រុមហ៊ុន ហ្គ្រេន ធ្វីន បានកើនឡើងដែលកំណើនចំណូល រួមមាន ៤ ប្រភព សំខាន់ៗ៖

**កត្តាទី ១៖** អតិថិជនក្នុងវិស័យសំលៀកបំពាក់នៅបរទេស បានបង្វែរការបញ្ជាទិញពីសាធារណរដ្ឋប្រជាមានិតចិន មកព្រះរាជាណាចក្រកម្ពុជាវិញ នេះជាការឆ្លើយតបទៅនឹងការកើនឡើងប្រាក់បៀវត្សរ៍ក្នុងសាធារណៈរដ្ឋប្រជាមានិតចិន។ ឧទាហរណ៍ក្នុងសាធារណរដ្ឋប្រជាមានិតចិន ប្រាក់បៀវត្សជាមធ្យមរបស់ពលករោងចក្រកាត់ដេរ គឺ ៥៥០ ដុល្លារអាមេរិក ដោយឡែកប្រាក់បៀវត្សរ៍ជាមធ្យមរបស់ពលកររោងចក្រកាត់ដេរក្នុងព្រះរាជាណាចក្រកម្ពុជាគឺ ១៥៣ ដុល្លារអាមេរិក (បូករួមទាំងលាភការ ចំនួន ១០៥ ដុល្លារអាមេរិក) គិតត្រឹមឆ្នាំ២០១៧។

**កត្តាទី២៖** ក្នុងឆ្នាំ២០១០ ក្រុមហ៊ុន ហ្គ្រេន ធ្វីន ចាប់ផ្តើមផលិតនិងលក់ផលិតផលខោអាវរងា។ផលិតផលនេះមិនត្រឹមតែផ្តល់ឲ្យក្រុមហ៊ុន ហ្គ្រេន ធ្វីន នូវគំលាតផលចំណេញខ្ពស់ប៉ុណ្ណោះទេ ថែមទាំងធ្វើឲ្យក្រុមហ៊ុនអាចទាក់ទាញបានការបញ្ជាទិញបន្ថែមទៀត ពីអតិថិជនបរទេស។

**កត្តាទី៣៖** ដោយមានការអនុគ្រោះពន្ធពីទីផ្សារសហគមន៍អឺរ៉ុប ដល់ព្រះរាជាណាចក្រកម្ពុជា ដែលទាក់ទាញការបញ្ជាទិញពីអតិថិជនសហគមន៍អឺរ៉ុប។

**កត្តាទី៤៖** Adidas ជាអតិថិជនធំជាងគេរបស់ក្រុមហ៊ុន ហ្គ្រេន ធ្វីន ដែលបានបញ្ជាទិញដ៏ច្រើនពីក្រុមហ៊ុនក្នុងឆ្នាំថ្មីៗនេះ។ ចំណូលនៃការលក់ឲ្យ Adidas មានប្រមាណ ៩០% នៃចំណូលសរុបរបស់ក្រុមហ៊ុន ហ្គ្រេន ធ្វីន ។

ដោយឡែក សម្រាប់ ២ ឆ្នាំ ចុងក្រោយនេះ ពោលគឺ ឆ្នាំ២០១៦ និង២០១៧ នេះ ចំណូលរបស់ក្រុមហ៊ុន ហ្វ្រេន ធ្វីន បានកើនឡើង ទន្ទឹមនឹងចំណាយមានការកើនឡើងខ្លាំងផងដែរ បើធៀបនឹងបណ្តាឆ្នាំកន្លងទៅ។ ការកើនឡើងនៃចំណាយ រួមមាន ៖

**កត្តាទី ១៖** អតិថិជនក្នុងវិស័យសំលៀកបំពាក់នៅបរទេស បានបង្វែរការបញ្ជាទិញពីព្រះរាជាណាចក្រកម្ពុជា ទៅប្រទេសជិតខាងវិញ រួមមាន ប្រទេសវៀតណាម បង់ក្លាដេស ជាដើម ដោយសារការកើនឡើងប្រាក់បៀវត្សរ៍នៅព្រះរាជាណាចក្រកម្ពុជាក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ។ ឧទាហរណ៍ ប្រាក់បៀវត្សរ៍ជាមធ្យមរបស់ពលករោងចក្រកាត់ដេរក្នុងព្រះរាជាណាចក្រកម្ពុជាគឺ ៦១ ដុល្លារអាមេរិក ប្រាក់បៀវត្សរ៍ជាមធ្យមបានកើនឡើងដល់ចំនួន ១០០ ដុល្លារអាមេរិក។ នៅឆ្នាំ២០១៥ នេះ ប្រាក់បៀវត្សរ៍ជាមធ្យមកើនឡើង ចំនួន ២៨% ពោលគឺ ពី ១០០ ដុល្លារអាមេរិក រហូតដល់ ១២៨ ដុល្លារអាមេរិក។ ជាក់ស្តែង ចំណាយពលកម្មផ្ទាល់បានកើនឡើងប្រមាណ ៥,៣២៣ លាន ដុល្លាអាមេរិក នៅឆ្នាំ២០១៥។ ការកើនឡើងនៃប្រាក់បៀវត្សរ៍ជាមធ្យម នៅតែបន្តនៅឆ្នាំ២០១៦ ប្រាក់បៀវត្សរ៍ជាមធ្យមបានកើនឡើងរហូតដល់ ១៤០ ដុល្លារអាមេរិក និង ១៥៣ ដុល្លារអាមេរិក នៅឆ្នាំ២០១៧។

**កត្តាទី២៖** តម្លៃនៃផលិតផលជាមធ្យម បានថយចុះ ចំនួន ០,៤៥ ដុល្លារអាមេរិក ក្នុងមួយឈុត ដែលបណ្តាលអោយ តម្លៃនៃផលិតផលជាមធ្យម បានថយចុះពីចំនួន ៨,៧៩ លាន ដុល្លារអាមេរិក នៅឆ្នាំ២០១៤ មកនៅត្រឹម ៨,៣៤ លាន ដុល្លារអាមេរិក នៅឆ្នាំ២០១៥។ ការកើនឡើងតម្លៃសម្រាប់ការបោះពុម្ព និងប៉ាក់ ក៏ជាកត្តាចម្បងមួយ ដែលប៉ះពាល់ដល់ចំណូលរបស់ក្រុមហ៊ុន ផងដែរ។

**កត្តាទី៣៖** ការធ្វើកូដកម្មតាមបណ្តារោងចក្រទូទាំងប្រទេសនៅឆ្នាំ២០១៤ ពីសំណាក់សហជីពកម្មករទាមទារតម្លើងប្រាក់បៀវត្សរ៍ជាមធ្យម បានធ្វើឲ្យខ្សែសង្វាក់ផលិតកម្មរបស់ក្រុមហ៊ុន ត្រូវបានផ្អាកមួយរយៈពេល ក្នុងកំឡុងពេលកូដកម្ម។ ខ្សែសង្វាក់ផលិតកម្ម មានភាពយឺតយ៉ាវ ដូចជា ការយឺតយ៉ាវក្នុងការរៀបចំវត្ថុធាតុដើមសម្រាប់ផលិត ការរៀបចំវេចខ្ចប់ និងបញ្ជូនទំនិញទៅអតិថិជន ដោយមិនអាចឆ្លើយតបនឹងតម្រូវការអតិថិជនឲ្យបានទាន់ពេលវេលា។

### (ខ) ថ្លៃលក់សំលៀកបំពាក់

ថ្លៃលក់សំលៀកបំពាក់របស់ក្រុមហ៊ុន ហ្វ្រេន ធ្វីន ផ្អែកលើចំណាយប្រតិបត្តិការសរុប បូកបន្ថែមគំលាតចំណេញ គំលាតចំណេញ ត្រូវបានកំណត់ដោយអតិថិជន។ ថ្លៃលក់សំលៀកបំពាក់វាយរបស់អតិថិជនផ្អែកលើតម្រូវការទីផ្សារ និងស្ថានភាពផ្គត់ផ្គង់ជាពិសេសការទទួលស្គាល់ពីគុណភាព និងម៉ាកសញ្ញានៃផលិតផលរបស់អតិថិជន។

ក្រុមហ៊ុន ហ្វ្រេន ធ្វីន ផលិតសំលៀកបំពាក់ប្រមាណ ៣.០០០ ម៉ូដ ក្នុងឆ្នាំ២០១៧។ សម្រាប់អាវធំក្រុមហ៊ុន ហ្វ្រេន ធ្វីន លក់ក្នុងថ្លៃប្រមាណ ៥០ ដុល្លារអាមេរិក ក្នុងមួយឯកតា ក្នុងឆ្នាំ២០១៧។ សម្រាប់ខោអាវកីឡាប្រមាណ ២០ ទៅ ៣០ដុល្លារអាមេរិក ក្នុងមួយឈុតក្នុងឆ្នាំ២០១៤ សម្រាប់សំលៀកបំពាក់កីឡា និងប្រមាណ ៥ ទៅ ១០ ដុល្លារអាមេរិក ក្នុងឆ្នាំ២០១៤។ សម្រាប់ឆ្នាំ២០១៧ ថ្លៃលក់សំលៀកបំពាក់របស់ក្រុមហ៊ុន ហ្វ្រេន ធ្វីន មិនមានការប្រែប្រួលខ្លាំងទេ។

ព័ត៌មានលម្អិតនៃកត្តាហានិភ័យដែលមានផលប៉ះពាល់ទៅលើសកម្មភាពធុរកិច្ចរបស់ក្រុមហ៊ុន ហ្វ្រេន ធ្វីន បានរៀបរាប់នៅក្នុងផ្នែកខាងលើនៃរបាយការណ៍ប្រចាំឆ្នាំនេះ។ កត្តាដែលមានផលប៉ះពាល់ទៅលើចំណូលរបស់ក្រុមហ៊ុន ហ្វ្រេន ធ្វីន រួមមាន ដូចខាងក្រោម៖

ក. សមត្ថភាពនៃការប្រកួតប្រជែងរបស់ក្រុមហ៊ុន ប្រេ្គន ធ្វីន ជាមួយនឹងគូប្រកួតប្រជែងដែលមានស្រាប់ ឬគូប្រកួតប្រជែងថ្មីនៅក្នុងវិស័យកាត់ដេរ។ វិស័យកាត់ដេរជាវិស័យដែលមានការប្រកួតប្រជែងខ្លាំង និងគ្មានរនាំងការពារ ការហូរចូលសម្រាប់គូប្រកួតប្រជែងថ្មីក្នុងទីផ្សារ។

ខ.សមត្ថភាពក្នុងការរចនាម៉ូដសំលៀកបំពាក់ថ្មីៗដើម្បីឆ្លើយតបបាននូវការផ្លាស់ប្តូរម៉ូដ និន្នាការទីផ្សារ និងម៉ូដលក់សំលៀកបំពាក់។

គ.ការពឹងផ្អែកទៅលើក្រុមហ៊ុន Adidas និងReebok ការប៉ះពាល់លើជាអវិជ្ជមានលើកេរ្តិ៍ឈ្មោះនៃម៉ាកណាមួយនឹងមានផលប៉ះពាល់ជាអវិជ្ជមានដល់ក្រុមហ៊ុន ប្រេ្គន ធ្វីន ទាំងផ្នែកស្ថានភាពហិរញ្ញវត្ថុ និងលទ្ធផលប្រតិបត្តិការ។

ឃ.លទ្ធភាពការដាក់កម្រិតនៃការនាំចូលរបស់ប្រទេសណាមួយដែលក្រុមហ៊ុន ប្រេ្គន ធ្វីន នាំចេញផលិតផលទៅលក់អាចមានផលប៉ះពាល់ជាអវិជ្ជមានដល់ចំណូលក្រុមហ៊ុន ប្រេ្គន ធ្វីន ។

## ២. កត្តាសំខាន់ៗដែលប៉ះពាល់លើផលចំណេញរបស់ក្រុមហ៊ុន

### ក. ការវិភាគលើលក្ខខណ្ឌតម្រូវការ និងការផ្គត់ផ្គង់

ចំណូលក្រុមហ៊ុន ប្រេ្គន ធ្វីន មានលក្ខណៈល្អប្រសើរនៅឆ្នាំ២០១៧ ពោលគឺ មានការថយចុះតិចតួចប្រមាណ ២,២៤% ក្នុងឆ្នាំ២០១៧ ធៀបនឹងចំណូលសរុបទទួលបាននៅឆ្នាំ២០១៦ បណ្តាលមកពីការលក់បញ្ចុះតម្លៃទំនិញជូនអតិថិជន ប្រមាណ ២០.៨០៩ លាន រៀល (៥,១៤៤ លាន ដុល្លារអាមេរិក) ដោយសារកង្វះខាតសមត្ថភាពក្នុងការប្រើប្រាស់ម៉ាស៊ីនទំនើបថ្មីរបស់និយោជិក។ ក្នុងឆ្នាំ២០១៧ ទោះបីជាមានការលក់បញ្ចុះតម្លៃទំនិញជូនអតិថិជនក្តី ក៏ក្រុមហ៊ុននៅតែអាចរក្សាបាននូវភាពចំណេញ។ ក្រុមហ៊ុន ប្រេ្គន ធ្វីន មិនមានចំណូលទទួលបានពីការ ម៉ៅការ តែក្រុមហ៊ុនបានបង្កើនចំណូលពីការកាត់ ដេរ និងវេចខ្ចប់ បន្ថែមលើចំណូលពីការលក់ទំនិញ ដែលជាលទ្ធផល កំណើនប្រាក់ចំណេញដុលមានចំនួន ២៧.១៥៦ លាន រៀល (៦,៧១៤ លាន ដុល្លាអាមេរិក) គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ គឺថយចុះចំនួន ១៤.២៥៤ លាន រៀល (៣,៥៤៤ លាន ដុល្លាអាមេរិក) ឬស្មើ ៣៤,៤២% បើធៀបនឹងចំណេញដុល ចំនួន ៤១.៤១០ លាន រៀល (១០,២៥៨ លាន ដុល្លាអាមេរិក) គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦។ ដោយឡែក ប្រាក់ចំណេញដុលមានចំនួន ៤១.៤១០ លាន រៀល (១០,២៥៨ លាន ដុល្លាអាមេរិក) គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ គឺកើនឡើងចំនួន ១៥.១៨១ លាន រៀល (៣,៧៨១ លាន ដុល្លាអាមេរិក) ឬស្មើ ៥៧,៨៨% បើធៀបនឹងចំណេញដុលចំនួន ២៦.២២៩ លាន រៀល (៦,៤៧៦ លាន ដុល្លាអាមេរិក) គិត ត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។

ក្រុមហ៊ុន ប្រេ្គន ធ្វីន មិនដែលជួបប្រទះបញ្ហាចម្បងក្នុងការស្វែងរកការផ្គត់ផ្គង់វត្ថុធាតុដើម ដែលមានតម្លៃសមរម្យ ហើយក្រុមហ៊ុន ប្រេ្គន ធ្វីន រំពឹងថា មានលទ្ធភាពក្នុងការបំពេញតម្រូវការកើនឡើងរបស់អតិថិជនបន្តទៀត។

### ខ. ការវិភាគលើការប្រែប្រួលថ្លៃវត្ថុធាតុដើម

ក្នុងរយៈពេល ៣ ឆ្នាំ ចុងក្រោយ ថ្លៃវត្ថុធាតុដើម មានការប្រែប្រួល ប៉ុន្តែមិនមានការប៉ះពាល់ខ្លាំងលើលទ្ធផលហិរញ្ញវត្ថុរបស់ក្រុមហ៊ុនឡើយ។ ក្រុមហ៊ុន ប្រេ្គន ធ្វីន រំពឹងទុកថានឹងមិនមានការប្រែប្រួលថ្លៃវត្ថុធាតុដើមច្រើនក្នុងពេលអនាគតហើយក្រុមហ៊ុន ប្រេ្គន ធ្វីន ក៏រំពឹងថាការប្រែប្រួលថ្លៃនឹងមិនមានការប៉ះពាល់លើលទ្ធផលហិរញ្ញវត្ថុរបស់ក្រុមហ៊ុនឡើយ។

### គ. ការវិភាគលើពន្ធ

ពន្ធលើប្រាក់ចំណេញ រួមមាន ពន្ធលើប្រាក់ចំណេញជាប់ពន្ធទាំងអស់។ ការវិនិច្ឆ័យសំខាន់ៗត្រូវបានប្រើក្នុងការកំណត់នូវសំវិធានធនពន្ធរបស់ក្រុមហ៊ុន។ ក្រុមហ៊ុន ហ្រ្គេន ធ្វីន ទទួលស្គាល់បំណុលសម្រាប់រាល់ចំណាយលើការបង់ពន្ធដែលរំពឹងទុកផ្អែកទៅលើការប៉ាន់ប្រមាណតាមរយៈការបកស្រាយច្បាប់សារពើពន្ធដែលត្រូវបង់។ នៅពេលដែលចំណាយលើការបង់ពន្ធចុងក្រោយខុសពីតម្លៃប៉ាន់ស្មានដែលត្រូវបានទទួលស្គាល់ពីមុនភាពខុសគ្នាទាំងនេះនឹងមានផលប៉ះពាល់ដល់សំវិធានធនពន្ធក្នុងឆ្នាំហិរញ្ញវត្ថុនោះ។ ពន្ធដែលមាននៅក្នុងរបាយការណ៍លទ្ធផល រួមមាន ពន្ធក្នុងគ្រា និងពន្ធពន្យា។

**(ក) ពន្ធក្នុងគ្រា**

ពន្ធក្នុងគ្រា ជាពន្ធលើប្រាក់ចំណេញដែលត្រូវបង់ ឬទទួលបានគិតលើប្រាក់ចំណេញជាប់ពន្ធ ឬខាតក្នុងគ្រា។

ពន្ធក្នុងគ្រាសម្រាប់គ្រាបច្ចុប្បន្ន និងគ្រាមុនត្រូវវាស់វែងនៅតម្លៃដែលរំពឹងថា ត្រូវទទួល ឬបង់ជូនអជ្ញាធរពន្ធដារ។ អត្រាពន្ធ និងច្បាប់សារពើពន្ធដែលបានប្រើប្រាស់ដើម្បីគណនាចំណាយពន្ធដែលជាច្បាប់សារពើពន្ធទាំងឡាយណាដែលបានចូលជាធរមាន ឬនឹងចូលជាធរមាននៅចុងគ្រារាយការណ៍។

**(ខ) ពន្ធពន្យា**

ពន្ធពន្យាត្រូវបានទទួលស្គាល់ទាំងស្រុង ដោយប្រើវិធានបំណុលលើភាពខុសគ្នាបណ្តោះអាសន្នដែលកើតឡើងពីភាពខុសគ្នារវាងតម្លៃពិតគណនេយ្យនៃទ្រព្យសកម្ម ឬបំណុលនៅក្នុងតារាងតុល្យការ និងមូលដ្ឋានពន្ធ។ ពន្ធពន្យា ត្រូវបានទទួលស្គាល់សម្រាប់រាល់ភាពខុសគ្នាបណ្តោះអាសន្ន លើកលែងតែ ពន្ធពន្យាដែលកើតចេញពីការទទួលស្គាល់បឋមនូវទ្រព្យសកម្ម ឬបំណុលក្នុងប្រតិបត្តិការដែលមិនមែនជាការទិញបង្រួមអាជីវកម្មហើយនៅពេលដែលប្រតិបត្តិការនោះកើតឡើង មិនមានផលប៉ះពាល់ណាមួយចំពោះប្រាក់ចំណេញតាមវិធីសាស្រ្តគណនេយ្យ ឬប្រាក់ចំណេញតាមវិធីសាស្រ្តពន្ធដារឡើយ។

ពន្ធពន្យាទ្រព្យសកម្ម ត្រូវបានទទួលស្គាល់នៅពេលដែលមានភវនីយភាពប្រាក់ចំណេញជាប់ពន្ធអាចកើតមានឡើង ដែលនឹងអាចទូទាត់ជាមួយនឹងភាពខុសគ្នាបណ្តោះអាសន្ន។ តម្លៃក្នុងបញ្ជីនៃពន្ធពន្យានៃទ្រព្យសកម្មត្រូវពិនិត្យឡើងវិញនៅចុងការិយបរិច្ឆេទនៃតារាងតុល្យការនីមួយៗ។ តម្លៃពិតគណនេយ្យនៃទ្រព្យសកម្មពន្ធពន្យាត្រូវបានកាត់បន្ថយនៅពេលដែលដឹងថាប្រាក់ចំណេញជាប់ពន្ធនាពេលអនាគតមិនមានគ្រប់គ្រាន់ដើម្បីប្រើប្រាស់មួយផ្នែក ឬទាំងស្រុងនៃទ្រព្យសកម្មពន្ធពន្យានោះ។ ការកាត់បន្ថយបែបនេះត្រូវបានកត់ត្រាលប់មកវិញនៅពេលដែលប្រាក់ចំណេញជាប់ពន្ធអាចនឹងមានគ្រប់គ្រាន់។

ពន្ធពន្យាទ្រព្យសកម្ម និងបំណុលពន្ធពន្យាអាចកាត់កងគ្នានៅពេលដែលមានសិទ្ធិស្របច្បាប់ដើម្បីធ្វើការទូទាត់ពន្ធក្នុងគ្រាត្រូវទទួលទៅនឹងពន្ធក្នុងគ្រាត្រូវសងហើយនៅពេលចំណូលពន្ធពន្យាទាក់ទងទៅនឹងអជ្ញាធរពន្ធដារដូចគ្នាលើ៖

(១) គ្រឹះស្ថានជាប់ពន្ធដូចគ្នាឬ

(២) គ្រឹះស្ថានជាប់ពន្ធផ្សេងគ្នាដែលមានបំណងនឹងទូទាត់ពន្ធក្នុងគ្រាត្រូវបង់ និងត្រូវទទួលសរុប ឬទទួលស្គាល់ពន្ធត្រូវទទួលហើយទូទាត់ពន្ធត្រូវបង់បន្តបន្ទាប់គ្នានៅក្នុងការិយច្ឆេទនីមួយៗ នាពេលអនាគតដែលពន្ធពន្យាត្រូវបង់ និងត្រូវទទួលរំពឹងថា នឹងធ្វើការទូទាត់ ឬទទួលបានមកវិញ។

ពន្ធពន្យានឹងត្រូវទទួលស្គាល់ជាចំណូល ឬចំណាយហើយត្រូវដាក់នៅក្នុងរបាយការណ៍លទ្ធផល ឬខាត លើកលែងតែក្នុងករណីពន្ធនោះទទួលស្គាល់ដោយផ្ទាល់ជាចំណាយ ឬចំណូលនៅក្នុងដើមទុននៅក្នុងការិយ បរិច្ឆេទដូចគ្នា ឬខុសគ្នាក្នុងស្ថានភាពបែបនេះ ពន្ធពន្យានឹងត្រូវបានទទួលស្គាល់ដោយផ្ទាល់នៅក្នុងដើមទុន។

ពន្ធពន្យាទ្រព្យសកម្ម និងបំណុលត្រូវបានគណនាតាមអត្រាពន្ធដែលរំពឹងទុកថា នឹងប្រើប្រាស់នៅក្នុងគ្រានៅពេល ដែលទ្រព្យសកម្មត្រូវបានទទួលស្គាល់ និងបំណុលដែលត្រូវបានសងផ្អែកទៅលើអត្រា និងបទប្បញ្ញត្តិពន្ធទាំងឡាយណា ដែលបានចូលជាធរមាននៅថ្ងៃចុងការិយបរិច្ឆេទរបាយការណ៍ហិរញ្ញវត្ថុនីមួយៗ។

ដោយក្រុមហ៊ុន ហ្គ្រេន ធ្វីន មានចំណេញនៅចុងការិយបរិច្ឆេទឆ្នាំ២០០៨ រយៈពេលគន្លឹះត្រូវបានបញ្ចប់ភ្លាមហើយ ក្រុមហ៊ុនបានមានរយៈពេល ៤ឆ្នាំ សម្រាប់ការលើកលែងពន្ធលើប្រាក់ចំណេញគិតចាប់ពីឆ្នាំ២០០៨ ដល់ឆ្នាំ២០១១។ ជាលទ្ធផលក្រុមហ៊ុន ហ្គ្រេន ធ្វីន នឹងត្រូវបង់ពន្ធលើប្រាក់ចំណេញចំនួន ២០% ចាប់ពីឆ្នាំ ២០១២។

ក្រុមហ៊ុន ហ្គ្រេន ធ្វីន បានបោះផ្សាយលក់មូលបត្រកម្មសិទ្ធិលើកដំបូងជាសាធារណៈ និងចុះបញ្ជីលក់មូលបត្រ ជាផ្លូវការក្នុងខែមិថុនា ឆ្នាំ២០១៤ ក្រុមហ៊ុនអាចទទួលបានការលើកទឹកចិត្តពន្ធលើប្រាក់ចំណេញ ដោយទទួលបានការកាត់ បន្ថយពន្ធលើប្រាក់ចំណេញ ៥០% នៃចំនួនទឹកប្រាក់ដែលត្រូវបង់ពន្ធ សម្រាប់ឆ្នាំ២០១៤ ដល់ ឆ្នាំ២០១៦។ ដូច្នេះ ក្រុមហ៊ុនត្រូវបង់ពន្ធលើប្រាក់ចំណេញចំនួន ៥០% តែប៉ុណ្ណោះ នៃពន្ធលើប្រាក់ចំណេញដែលត្រូវបង់។ សម្រាប់ឆ្នាំ២០១៤ ដល់ ឆ្នាំ២០១៦ ក្រុមហ៊ុន ហ្គ្រេន ធ្វីន បានទទួលការបន្ថយពន្ធលើប្រាក់ចំណេញ ៥០% នៃចំនួនទឹក ប្រាក់ដែលត្រូវបង់ពន្ធ សម្រាប់ ៣ឆ្នាំ កន្លងទៅ។ ដោយឡែកសម្រាប់ឆ្នាំ២០១៧ ក្រុមហ៊ុន ហ្គ្រេន ធ្វីន រពឹងពុំបានទទួលការបន្ថយពន្ធលើប្រាក់ ចំណេញ ៥០% នៃចំនួនទឹកប្រាក់ដែលត្រូវបង់ទៀតឡើយ។ ព័ត៌មានលម្អិតសូមអានចំនុចទី ២០-២ ក្នុងផ្នែកទី ៧ " *របាយការណ៍ហិរញ្ញវត្ថុ ដែលធ្វើសវនកម្មរួចដោយសវនករឯករាជ្យ* " នៃរបាយការណ៍ប្រចាំឆ្នាំនេះ។

**ឃ. ការវិភាគធាតុដែលខុសពីធម្មតា និងធាតុវិសាមញ្ញ**

ក្រុមហ៊ុន មិនមានធាតុដែលខុសពីធម្មតា និងធាតុវិសាមញ្ញ ដែលប៉ះពាល់ដល់ទ្រព្យសកម្ម បំណុល ដើមទុន ប្រាក់ចំណេញសុទ្ធ ឬលំហូរសាច់ប្រាក់ គិតត្រឹមឆ្នាំ២០១៧ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ នោះឡើយ។

**៣. ការប្រែប្រួលសំខាន់ៗលើការលក់ និងចំណូលរបស់ក្រុមហ៊ុន**

ចំណូលរបស់ក្រុមហ៊ុន ហ្គ្រេន ធ្វីន បានធ្លាក់ចុះប្រមាណ ២,២៤% ពីចំនួន ៣៣១.៤០៧ លាន រៀល (៨២,០៩២ លាន ដុល្លារអាមេរិក) នៅឆ្នាំ២០១៦ មកនៅត្រឹមចំនួន ៣២៣.៩៨៧ លាន រៀល (៨០,០៩៦ លាន ដុល្លារអាមេរិក) នៅឆ្នាំ២០១៧។ ដោយឡែក ចំណូលរបស់ក្រុមហ៊ុន ហ្គ្រេន ធ្វីន បានកើនឡើងប្រមាណ ៤៤,១៣% ពីចំនួន ២២៩.៩៣៩ លាន រៀល (៥៦,៧៧៥ លានដុល្លារអាមេរិក) នៅឆ្នាំ២០១៥ កើនឡើងរហូតដល់ចំនួន ៣៣១.៤០៧ លាន រៀល (៨២,០៩២ លាន ដុល្លារអាមេរិក) នៅឆ្នាំ២០១៦។

ចំណូលរបស់ក្រុមហ៊ុន ហ្គ្រេន ធ្វីន រួមមាន ចំណូលពីការលក់ទំនិញ ចំណូលពីការម៉ៅការ និងចំណូលពីការកាត់ ដេរ និងវេចខ្ចប់។ ចំពោះឆ្នាំ២០១៧ នេះ ក្រុមហ៊ុន ហ្គ្រេន ធ្វីន ទទួលបានចំណូលសរុបចំនួន ៣២៣.៩៨៧ លាន រៀល (៨០,០៩៦ លាន ដុល្លារអាមេរិក) ដែលក្នុងនោះ ចំណូលបានពីការលក់ទំនិញ ទទួលបានចំនួន ៣៣៨.៥៨៥ លាន រៀល (៨៣,៧០៥ លាន ដុល្លារអាមេរិក) និងចំណូលបានពីការកាត់ ដេរ និងវេចខ្ចប់ ទទួលបានចំនួន ៦.២១២ លាន រៀល (១,៥៣៦ លាន ដុល្លារអាមេរិក)។ ដោយឡែក ក្រុមហ៊ុន ហ្គ្រេន ធ្វីន មិនមានចំណូលបានពីការម៉ៅការទេ នៅឆ្នាំ២០១៧។ ចំណូលពីលក់ទំនិញមានចំនួនមិនតិចជាង ៩៨% នៃចំណូលសរុប ជាក់ស្តែងចំណូលពីលក់ទំនិញ របស់ក្រុមហ៊ុនទទួល បានចំនួន ៣៣៨.៥៨៥ លាន រៀល (៨៣,៧០៥ លាន ដុល្លារអាមេរិក) ស្មើនឹង ៩៨,២០% នៃចំណូលសរុប ឆ្នាំ២០១៧។

ចំណូលលើការម៉ៅការ និងការកាត់ ដេរ និងវេចខ្ចប់ មានចំនួនតិចតួច បើប្រៀបធៀបនឹងចំណូលសរុប។ ហេតុ ដូច្នេះរាល់ការប្រែប្រួលជាចម្បងនៃចំណូលសរុបគឺបណ្តាលមកពីការប្រែប្រួលចំណូលពីការលក់ទំនិញ។ ចំណូលពីការលក់

ទំនិញ ពឹងផ្អែកទៅលើបរិមាណសំលៀកបំពាក់ដែលក្រុមហ៊ុន ហ្វ្រេន ធ្វីន ផលិត និងលក់ និងថ្លៃលក់ នឹងពិភាក្សាលម្អិតក្នុងផ្នែក *"(ខ) ថ្លៃលក់សំលៀកបំពាក់"* ។

## ៤. ផលប៉ះពាល់នៃអត្រារូបិយវត្ថុ អត្រាការប្រាក់ និងថ្លៃខុម៉ូឌីធី

### ផលប៉ះពាល់នៃអត្រារូបិយវត្ថុ

ក្រុមហ៊ុន ហ្វ្រេន ធ្វីន រកបានចំណូលចម្បងជា ប្រាក់ដុល្លារអាមេរិក។ ការចំណាយចម្បងជា ប្រាក់ដុល្លារអាមេរិក និងប្រាក់រៀល។ ក្រុមហ៊ុន ហ្វ្រេន ធ្វីន មិនមានប្រតិបត្តិការទប់ស្កាត់នឹងហានិភ័យអត្រាប្តូរប្រាក់ឡើយ ដោយក្រុមហ៊ុន ហ្វ្រេន ធ្វីន ជឿជាក់ថា ការចំណាយទៅលើការទប់ស្កាត់ហានិភ័យ មិនមានលក្ខណៈសមស្របទៅនឹងការប៉ះពាល់ជាអវិជ្ជមាននិងការប្រែប្រួលអត្រាប្តូរប្រាក់។

### ផលប៉ះពាល់អត្រាការប្រាក់

ការប្រឈមរបស់ក្រុមហ៊ុនទៅនឹងហានិភ័យអត្រាការប្រាក់ គឺទាក់ទងទៅ នឹងកម្ចី។ ក្រុមហ៊ុនគ្រប់គ្រងហានិភ័យអត្រាការប្រាក់របស់ខ្លួន ដោយត្រួតពិនិត្យយ៉ាងយកចិត្តទុកលើបំណុលទីផ្សារ ហើយសំខាន់ជាងនេះទៀត គឺរក្សាអោយបានការលាយឡំគ្នារបស់អត្រាថេរ និងអត្រាអថេររបស់កម្ចីដោយប្រុងប្រយ័ត្ន។ ក្រុមហ៊ុន ហ្វ្រេន ធ្វីន ពុំបានប្រើប្រាស់ដេរីវេឧបករណ៍ហិរញ្ញវត្ថុ ដើម្បីកាត់បន្ថយហានិភ័យរបស់ប្រាក់បំណុលដែលត្រូវសងនោះទេ។

*<u>ការវិភាគលើភាពងាយរងផលប៉ះពាល់នៃអត្រាការប្រាក់</u>*

តារាងខាងក្រោម បង្ហាញពីការវិភាគលើភាពងាយរងផលប៉ះពាល់នៃអត្រាការប្រាក់របស់ក្រុមហ៊ុន ហ្វ្រេន ធ្វីន នៅចុងការិយបរិច្ឆេទ ដោយឈរលើគោលការណ៍បម្រែបម្រួល 0.១% និងកត្តាអថេរផ្សេងទៀត មិនមានការប្រែប្រួលៈ

| បរិយាយ | សម្រាប់ចុងការិយបរិច្ឆេទថ្ងៃទី ថ្ងៃទី៣១ ខែធ្នូ ២០១៧ | | សម្រាប់ចុងការិយបរិច្ឆេទថ្ងៃទី ថ្ងៃទី៣១ ខែធ្នូ ២០១៦ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | គិតជាពាន់រៀល | ដុល្លារអាមេរិក | គិតជាពាន់រៀល |
| ផលចំណេញបន្ទាប់ពីកាត់ពន្ធ | | | | |
| - កំណើន 0.១% (២០១៦:0.១%) | (១៨៧) | (៧៥៦) | (៣.៦៩២) | (១៤.៩០៥) |
| - តំហយ 0.១% (២០១៦:0.១%) | ១៨៧ | ៧៥៦ | ៣.៦៩២ | ១៤.៩០៥ |

### ផលប៉ះពាល់ថ្លៃខុម៉ូឌីធី

កិច្ចព្រមព្រៀងរវាងក្រុមហ៊ុន ហ្វ្រេន ធ្វីន និងអតិថិជនរបស់ក្រុមហ៊ុន បានផ្តល់នូវគំលាតចំណេញដុលដែលមានសង្គតភាព។ ដូច្នេះ ការផ្លាស់ប្តូរថ្លៃខុម៉ូឌីធី មានផលប៉ះពាល់តិចតួចលើស្ថានភាពហិរញ្ញវត្ថុ ឬលទ្ធផលប្រតិបត្តិការរបស់ក្រុមហ៊ុន ហ្វ្រេន ធ្វីន។

## ៥. ផលប៉ះពាល់អតិផរណា

ការកើនឡើងនៃអត្រាអតិផរណាអាចប៉ះពាល់អវិជ្ជមានថ្លៃប្រេងឥន្ធនៈកើនឡើង និងកើនឡើងលើចំណាយលើការដឹកជញ្ជូន។ ជាងនេះទៅទៀត ការកើនឡើងនៃអត្រាអតិផរណាអាចបន្ថយអំណាចទិញនៃប្រាក់បៀវត្សរ៍របស់ពលករដែលអាចនាំឲ្យមានការកើនឡើងនូវវិវាទការងារចំពោះក្រុមហ៊ុន និងការទាមទារការតម្លើងប្រាក់បៀវត្សរ៍ កូដកម្ម និងការរាំងស្ទះការងារផ្សេងៗ។ ការកើនឡើងនៃការចំណាយលើការដឹកជញ្ជូន ឬវិវាទការងារចំពោះក្រុមហ៊ុន អាចមានផលប៉ះពាល់អវិជ្ជមានលើស្ថានភាពហិរញ្ញវត្ថុ និងលទ្ធផលប្រតិបត្តិការរបស់ក្រុមហ៊ុន។

## ៦. គោលនយោបាយរដ្ឋាភិបាល សេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុ

### គោលនយោបាយរដ្ឋាភិបាល

បទប្បញ្ញត្តិរបស់រាជរដ្ឋាភិបាលកម្ពុជា ដូចជា ការលើកលែងពន្ធ និងការចរចាលក្ខខណ្ឌសម្រាប់នាំចេញជាមួយប្រទេសដទៃទៀត បានផ្តល់អត្ថប្រយោជន៍វិជ្ជមានមកលើធុរកិច្ចរបស់ក្រុមហ៊ុន ហ្គ្រេន ធ្វីន។ ចាប់តាំងពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១១ នៅក្រោមភាពផ្តួចផ្តើម **"អ្វីៗគ្រប់យ៉ាងលើកលែងសព្វាវុធ"** របស់សហភាពអឺរ៉ុប ប្រទេសកំពុងអភិវឌ្ឍន៍ ដូចជាព្រះរាជាណាចក្រកម្ពុជា បានទទួលការអនុគ្រោះក្នុងការនាំចេញដោយគ្មានការបង់ពន្ធទៅសហភាពអឺរ៉ុប និងគ្មានកូតា បើសិនជា ប្រទេសនោះផលិតបាន ៤0% នៃតម្លៃផលិតផលសរុប។ ការកម្រិតថ្មីនេះ ត្រូវបានថយចុះដែលកាលពីមុនស្មើនឹង ៧0% នៃតម្លៃផលិតផលសរុប។

### សេដ្ឋកិច្ច

សេដ្ឋកិច្ចរបស់ព្រះរាជាណាចក្រកម្ពុជា បន្តការរីកចម្រើនខ្លាំងដែល ផ.ស.ស កើនឡើងចំនួន ៧,១% ក្នុងឆ្នាំ ២០១៧ និងរំពឹងថា ៧,១% ក្នុងឆ្នាំ២០១៨ នេះ យោងតាមទិន្នន័យរបស់ធនាគារអភិវឌ្ឍន៍អាស៊ាន (ADB) ។ កំណើនខ្ពស់នេះកើតឡើងដោយសារតែមានលំហូរខ្លាំងនូវវិនិយោគផ្ទាល់ពីក្រៅប្រទេស បូករួម ចំណាយប្រើប្រាស់ក្នុង ស្រុកមានកំណើន។ ព្រះរាជាណាចក្រកម្ពុជា ជាប្រទេសមួយដែលមានសេដ្ឋកិច្ចរីកចម្រើនលឿនក្នុងរយៈពេល ១0ឆ្នាំ ចុងក្រោយនេះ កំណើនប្រចាំឆ្នាំជាមធ្យម ៨% ចាប់តាំងពីឆ្នាំ២000។ ការធ្លាក់ចុះនៃសេដ្ឋកិច្ចរបស់សហរដ្ឋអាមេរិក និង សហភាពអឺរ៉ុប ដែលជាគោលដៅពីរធំបំផុតនៃការនាំចេញការកាត់ដេរ និងវាយនភណ្ឌរបស់ព្រះរាជាណាចក្រកម្ពុជា ពុំទាន់មានឥទ្ធិពលអវិជ្ជមានជាចម្បងដល់ការនាំចេញរបស់កម្ពុជាទេ។

### គោលនយោបាយសារពើពន្ធ

គោលនយោបាយសារពើពន្ធរបស់ប្រទេសថ្មីៗនេះ បង្ហាញសញ្ញាវិជ្ជមានក្នុងនោះការធ្លាក់ចុះនៃឱនភាពថវិកា។ រាជរដ្ឋាភិបាលកំពុងពង្រឹងលើការអនុវត្តច្បាប់សារពើពន្ធ។

### ពន្ធយថាហេតុ

ប្រព័ន្ធពន្ធដារនៅព្រះរាជាណាចក្រកម្ពុជាមានសភាពថ្មី ហើយពន្ធត្រូវបានបែងចែកជាច្រើនប្រភេទ និងបទប្បញ្ញត្តិមានការផ្លាស់ប្តូរញឹកញាប់ ដែលជាធម្មតាពុំមានភាពច្បាស់លាស់មានភាពផ្ទុយគ្នា និងជាកម្មវត្ថុនៃការបកស្រាយ។ ជាញឹកញាប់ ការបកស្រាយខុសគ្នាៗជាច្រើនទៅកើតមាននោះឡើងក្នុងចំនោមអជ្ញាធរពន្ធដារ និងយុត្តាធិការ។ ពន្ធដារ គឺជាកម្មវត្ថុនៃការពិនិត្យឡើងវិញ និងការសង្កេតដោយភ្នាក់ងារពន្ធដារផ្សេងៗជាច្រើន ដែលមានសមត្ថកិច្ចក្នុងការដាក់ពិន័យធ្ងន់ធ្ងរ និងពិន័យលើការប្រាក់។ កត្តាទាំងនេះហើយ ដែលអាចធ្វើអោយមានហានិភ័យពន្ធដារនៅក្នុងព្រះរាជាណាចក្រ

កម្ពុជាខ្លាំងជាងប្រទេសដទៃទៀត។ ថ្នាក់ដឹកនាំមានការជឿជាក់ថា ខ្លួនបានធ្វើសំវិធានធនបំណុលពន្ធគ្រប់គ្រាន់ ដោយផ្អែកលើការបកស្រាយបទបញ្ញត្តិពន្ធរបស់ខ្លួន។ ទោះបីយ៉ាងនេះក្តី សមត្ថកិច្ចពន្ធពាក់ព័ន្ធអាចមានការបកស្រាយខុសៗគ្នា ហើយអាចធ្វើអោយមានផលប៉ះពាល់ជាសារវន្ត។

### គោលនយោបាយរូបិយវត្ថុ

ព្រះរាជាណាចក្រកម្ពុជា គឺជាសេដ្ឋកិច្ចដុល្លាររូបនីយកម្ម ដែលធ្វើឲ្យរូបិយវត្ថុរបស់ប្រទេស ប្រាក់រៀល ងាយនឹងប្រឈមមុខនឹងការធ្លាក់ចុះនៃតម្លៃប្រាក់ដុល្លារអាមេរិក។ សម្រាប់ទីផ្សារមូលបត្រកម្ពុជា ច្បាប់ និងបទប្បញ្ញត្តិដែលពាក់ព័ន្ធតម្រូវឲ្យប្រើប្រាស់ប្រាក់រៀល ដើម្បីចុះបញ្ជីដែលការអនុវត្តនេះបានបង្ហាញនូវឆន្ទៈរបស់រាជ រដ្ឋាភិបាលក្នុងការពង្រឹងនូវការប្រើប្រាស់ប្រាក់រៀល។

គោលនយោបាយរដ្ឋាភិបាល សេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុ មិនមានផលប៉ះពាល់អវិជ្ជមានដល់លទ្ធភាពចំណេញសម្រាប់ការិយបរិច្ឆេទឆ្នាំ២០១៧ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ របស់ក្រុមហ៊ុនឡើយ។

# ១០. ព័ត៌មានចាំបាច់ផ្សេងទៀត សម្រាប់ការពារវិនិយោគិន

គិតត្រឹមកាលបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ នេះ  ពុំមានព័ត៌មានផ្សេងទៀត ក្រៅពីព័ត៌មានដែលបានបង្ហាញក្នុងរបាយការណ៍ប្រចាំឆ្នាំ ២០១៧ នោះទេ។

កាលបរិច្ឆេទៈ ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៨

បានអាន និងឯកភាព

លោក **យ៉ាង សាវស៊ីន**
ប្រធានក្រុមប្រឹក្សាភិបាល

កាលបរិច្ឆេទៈ ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៨
បានអាន និងឯកភាព

លោក Liao Chung-Te
អភិបាលប្រតិបត្តិ និងនាយកប្រតិបត្តិ

កាលបរិច្ឆេទៈ ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៨
បានអាន និងឯកភាព

ឧកញ៉ា **លី យុនថៃ**
អភិបាលឯករាជ្យ

កាលបរិច្ឆេទៈ ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៨
បានអាន និងឯកភាព

លោក Chen Tsung-Chi
អភិបាលមិនប្រតិបត្តិ

កាលបរិច្ឆេទៈថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៨
បានអាន និងឯកភាព

លោកស្រី Wang Yi Ting
អភិបាលមិនប្រតិបត្តិ

**ក្រុមហ៊ុន ហ្គ្រេន ធ្វីន អ៊ិនធើណេសិនណល ធីអិលស៊ី**

អាសយដ្ឋាន: ភូមិត្រពាំងពោធិ៍ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ  រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

Address: Phum Trapaing Poe, Sangkat Chom Chao, Khan Porsenchey, Phnom Penh, Cambodia

លេខទូរស័ព្ទ : (៨៥៥)២៣ ៨៩០ ៣២៥ / លេខទូរសារ : (៨៥៥)២៣ ៨៩០ ៣២៦

Phone number: ( 855 ) 23 890 325/Fax number: ( 855 ) 23 890 326

គេហទំព័រ : www.Grandtwins.com.kh/ អ៊ីម៉ែល : vuthy.phuong@qmico.com

Website: www.Grandtwins.com.kh/E-mail: vuthy.phuong@qmico.com